របាយការណ៍ពិនិត្យតាមដានជាសកល
លើការអប់រំសម្រាប់ទាំងអស់គ្នា

២០១៣/៤

ការអប់រំសម្រាប់ទាំងអស់គ្នា

# ការបង្រៀន និងរៀន៖ សម្រេចឱ្យបាននូវគុណភាព សម្រាប់ទាំងអស់គ្នា

## សេចក្តីសង្ខេប



ED.2013/WS/29
Phnom Penh, March 2014
Original: English

United Nations
Educational, Scientific and
Cultural Organization

# ការបង្រៀន និងរៀន ៖ សម្រេចឱ្យបាននូវគុណភាព សម្រាប់ទាំងអស់គ្នា

## សេចក្តីសង្ខេប

UNESCO Publishing

United Nations
Educational, Scientific and
Cultural Organization

របាយការណ៍នេះ គឺជាការបោះពុម្ពផ្សាយឯករាជ្យ រៀបចំឡើងដោយយូណេស្កូ តាងនាមតំណាងឱ្យសហគមន៍ អន្តរជាតិទាំងមូល។ របាយការណ៍នេះ គឺជាសមិទ្ធផលនៃការសហការរួមគ្នានៃសមាជិករបស់ក្រុមការងារតាក់តែង របាយការណ៍ ក៏ដូចជាបុគ្គលផ្សេងទៀត ទីភ្នាក់ងារ ស្ថាប័ន និងរដ្ឋាភិបាលនានាផងដែរ។

ឈ្មោះ និងការបង្ហាញព័ត៌មាននានា នៅក្នុងឯកសារបោះពុម្ពផ្សាយនេះ ពុំមែនជាការបង្ហាញពីការយល់ឃើញអ្វីមួយរបស់យូណេស្កូ ពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយ ឬអាជ្ញាធររបស់ប្រទេស ដែនដី ទីក្រុង ឬតំបន់នោះ ឬពាក់ព័ន្ធទៅនឹងការកំណត់ព្រំប្រទល់របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់នោះឡើយ។

ក្រុមការងារតាក់តែងរបាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា ជាអ្នកទទួលខុសត្រូវ លើការជ្រើសរើស និងបង្ហាញព័ត៌មាននានា នៅក្នុងសៀវភៅនេះ ក៏ដូចជាការយល់ឃើញដែលមាន ដែលមិនមែនជាការ យល់ឃើញរបស់យូណេស្កូ ហើយក៏មិនមែនជាការសន្យាអ្វីមួយរបស់អង្គការនេះដែរ។ គំនិត និង ការយល់ឃើញ ដែលមាន នៅក្នុងរបាយការណ៍នេះ គឺការទទួលខុសត្រូវរួមរបស់ប្រធានក្រុមការងារនេះ។

ក្រុមការងារតាក់តែងរបាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា
ប្រធានក្រុមការងារ ៖ Pauline Rose

Kwame Akyeampong, Manos Antoninis, Madeleine Barry, Nicole Bella, Erin Chemery, Marcos Delprato, Nihan Köseleci Blanchy, Joanna Härmä, Catherine Jere, Andrew Johnston, François Leclercq, Alasdair McWilliam, Claudine Mukizwa, Judith Randrianatoavina, Kate Redman, Maria Rojnov-Petit, Martina Simeti, Emily Subden and Asma Zubairi.

*របាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នានេះ គឺជាការបោះពុម្ពផ្សាយប្រចាំឆ្នាំ ដោយឯករាជ្យ។ ការរៀបចំឯកសារបោះពុម្ពផ្សាយនេះ ធ្វើឡើងដោយមានការសម្របសម្រួល និងការគាំទ្រពីយូណេស្កូ។*

សម្រាប់ព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ សូមទាក់ទង ៖
ក្រុមការងារតាក់តែងរបាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា
អាសយដ្ឋាន c/o UNESCO, 7, place de Fontenoy
75352 Paris 07 SP, France
Email: efareport@unesco.org
Tel.: +33 1 45 68 07 41
www.efareport.unesco.org

របាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា ដែលចេញផ្សាយកន្លងមក

២០១២. យុវជន និងជំនាញ ៖ ប្រែក្លាយការអប់រំឱ្យក្លាយទៅជាការងារ
២០១១. វិបត្តិលាក់កំបាំង ៖ ជម្លោះប្រដាប់អាវុធ និងការអប់រំ
២០១០. ការឈានទៅគ្របដណ្តប់ដល់អ្នកដែលគ្មានឱកាស
២០០៩. ការជំនះវិសមភាព ៖ ហេតុអ្វីបានជាអភិបាលកិច្ចមានសារៈសំខាន់?
២០០៨. ការអប់រំសម្រាប់ទាំងអស់គ្នា ត្រឹមឆ្នាំ ២០១៥ - តើយើងនឹងអាចសម្រេចគោលដៅនេះដែរឬទេ?
២០០៧. មូលដ្ឋានគ្រឹះរឹងមាំ - ការគាំពារ និងការអប់រំកុមារតូច
២០០៦. អក្ខរកម្មសម្រាប់ជីវិត
២០០៥. ការអប់រំសម្រាប់ទាំងអស់គ្នា - លក្ខខណ្ឌតម្រូវផ្នែកគុណភាព
២០០៣/៤. យេនឌ័រ និងការអប់រំសម្រាប់ទាំងអស់គ្នា - ការបោះជំហានទៅរកសមភាព
២០០២. ការអប់រំសម្រាប់ទាំងអស់គ្នា - តើពិភពលោកកំពុងដើរតាមផ្លូវត្រូវដែរឬទេ?

កំហុសណាមួយ ឬការខកខានមិនបានបង្ហាញព័ត៌មានអ្វីមួយ ដែលរកឃើញក្រោយការបោះពុម្ព នឹងត្រូវកែតម្រូវ
នៅក្នុងសំណៅអនឡាញ ដែលអាចរកបានតាមរយៈគេហទំព័រ www.efareport.unesco.org

© យូណេស្កូ ២០១៤
រក្សាសិទ្ធិគ្រប់បែបយ៉ាង
កំណែទីមួយ
បោះពុម្ពផ្សាយនៅក្នុងឆ្នាំ ២០១៤ ដោយអង្គការអប់រំ វិទ្យាសាស្រ្ត និងវប្បធម៌ នៃសហប្រជាជាតិ
អាសយដ្ឋាន 7, Place de Fontenoy, 75352 Paris 07 SP, France

រូបថតគ្របមុខដោយ Nick Sells/UNICEF
រចនាក្រាហ្វិចដោយ FHI 360
រៀបចំទម្រង់ទូទៅដោយ FHI 360

លេខកាតាឡុកក្នុងទិន្នន័យអំពីឯកសារបោះពុម្ពផ្សាយរបស់បណ្ណាល័យសភាខុនហ្គ្រេស
មានទិន្នន័យ
វាយអត្ថបទដោយយូណេស្កូ


ED.2013/WS/29

# អារម្ភកថា

របាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា ទី១១ នេះ ផ្តល់បច្ចុប្បន្នភាពទាន់ពេលវេលាស្តីពីវឌ្ឍនភាព ដែលប្រទេសនានាកំពុងសម្រេចបាន ក្នុងការឈានទៅសម្រេចគោលដៅអប់រំជាសកល ដែលទទួលបានការឯកភាព នៅក្នុងឆ្នាំ ២០០០។ របាយការណ៍នេះក៏ជាករណីសិក្សាប្រកបដោយអានុភាពមួយ ដើម្បីជម្រុញឱ្យមាន ការចាត់ទុកការអប់រំ ជាអាទិភាពស្នូលមួយនៃរបៀបវារៈអភិវឌ្ឍន៍ជាសកល ក្រោយឆ្នាំ ២០១៥ ផងដែរ។ នៅក្នុងឆ្នាំ ២០០៨ របាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា បានសួរនូវសំណួរមួយថា - តើយើងនឹងអាចសម្រេចបានដែរឬទេ? នៅសល់មិនដល់ ២ ឆ្នាំទៀង នៅពេលដែលឆ្នាំ ២០១៥ មកដល់ ហើយរបាយការណ៍នេះបានបញ្ជាក់យ៉ាងច្បាស់លាស់ថា យើងមិនអាចសម្រេចគោលដៅ ដែលយើងបានគ្រោងទុកឡើយ។

កុមារចំនួន ៥៧ លាននាក់ នៅតែខកខានមិនមានឱកាសរៀនសូត្រ មិនមែនត្រឹមតែដោយសារតែពួកគេមិនបានចូលសាលារៀននោះទេ។ ការចូលរៀន មិនមែនជាវិបត្តិតែមួយគត់នោះឡើយ - គុណភាពទាបនៃការអប់រំ កំពុងធ្វើឱ្យការរៀនសូត្រដើរថយក្រោយមកវិញ សូម្បីតែសម្រាប់អ្នកដែលមានឱកាសទៅរៀនក្នុងសាលារៀន។ កុមារក្នុងវ័យសិក្សា នៅសាលាបឋមសិក្សាចំនួនមួយភាគបី មិនបានរៀនចំណេះដឹងជាមូលដ្ឋានឡើយ មិនថាកុមារទាំងនេះកំពុងរៀនសូត្រក្នុង សាលារៀន ឬអត់នោះទេ។ ដើម្បីសម្រេចគោលដៅរបស់យើងទាំងអស់គ្នា របាយការណ៍នេះអំពាវនាវឱ្យរដ្ឋាភិបាលបង្កើន កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនឱ្យបានទ្វេដងថែមទៀត សំដៅផ្តល់ការរៀនសូត្រដល់កុមារគ្រប់រូប ដែលជួបប្រទះការលំបាក មិនថាដោយសារតែភាពក្រីក្រ យេនឌ័រ កន្លែងដែលពួកគេរស់នៅ ឬកត្តាផ្សេងទៀតនោះទេ។

ប្រព័ន្ធអប់រំមួយ អាចល្អបានត្រឹមតែកម្រិតរបស់គ្រូបង្រៀនក្នុងប្រព័ន្ធអប់រំនោះតែប៉ុណ្ណោះ។ ការផ្តល់លទ្ធភាពឱ្យពួកគេអាចបញ្ចេញសក្តានុពលរបស់ខ្លួន មានសារៈសំខាន់យ៉ាងខ្លាំងចំពោះការលើកកម្ពស់គុណភាពនៃការរៀនសូត្រ។ ភស្តុតាងនានាបង្ហាញថា គុណភាពនៃការអប់រំមានការកើនឡើង នៅពេលដែលគ្រូទទួលបានការគាំទ្រ។ គុណភាពនៃការអប់រំមានការថយចុះ ប្រសិនបើពួកគេមិនបានទទួលការគាំទ្រ ដែលនេះជាដើមចម ដែលរួមចំណែកធ្វើឱ្យអត្រាអនក្ខរកម្ម របស់យុវវ័យកើនឡើងដល់កម្រិតគួរឱ្យព្រួយបារម្ភខ្លាំង ដូចបង្ហាញក្នុងរបាយការណ៍នេះ។

រដ្ឋាភិបាលត្រូវតែពន្លឿនកិច្ចខិតខំប្រឹងប្រែង ដើម្បីជ្រើសរើសគ្រូបង្រៀន ១ លាន ៦ សែននាក់ បន្ថែមទៀត ដើម្បីសម្រេចនូវសកលកម្មនៃការអប់រំកម្រិតបឋមសិក្សា ឱ្យបានត្រឹមឆ្នាំ ២០១៥។ របាយការណ៍នេះលើកឡើងពីយុទ្ធសាស្ត្រ ចំនួន ៤ ដើម្បីផ្តល់គ្រូដែលល្អបំផុត ក្នុងគោលបំណងឱ្យកុមារគ្រប់រូបទទួលបាននូវការអប់រំប្រកបដោយគុណភាព។ ទីមួយ ត្រូវតែមានការជ្រើសរើសគ្រូប្រកបដោយលក្ខណៈសម្បត្តិសមស្របទៅតាមភាពចម្រុះរបស់កុមារ ដែលពួកគេនឹងបង្រៀន។ ទីពីរ គ្រូត្រូវទទួលបានការបណ្តុះបណ្តាលអំពីរបៀបផ្តល់ការគាំទ្រដល់សិស្សដែលរៀនខ្សោយជាងគេ ចាប់ផ្តើម ពីថ្នាក់ដំបូងៗទៅ។ យុទ្ធសាស្ត្រទីបី មានគោលបំណងជំនះបញ្ហាវិសមភាព នៅក្នុងការរៀនសូត្រ តាមរយៈការពង្រាយគ្រូ ដែលល្អបំផុត ទៅតាមតំបន់ដែលជួបប្រទះការលំបាកបំផុត នៅក្នុងប្រទេស។ ចុងក្រោយ រដ្ឋាភិបាលត្រូវផ្តល់ឱ្យគ្រូនូវការ លើកទឹកចិត្តគ្រប់ផ្នែកឱ្យបានសមស្រប ដើម្បីលើកទឹកចិត្តពួកគេឱ្យបន្តបម្រើការងារនេះ និងធានាថាកុមារគ្រប់រូបពិតជា អាចរៀនសូត្របានដមែន មិនថាពួកគេស្ថិតក្នុងកាលៈទេសៈណានោះទេ។

ប៉ុន្តែ គ្រូមិនអាចរ៉ាប់រងការទទួលខុសត្រូវនេះតែឯងនោះទេ។ របាយការណ៍នេះបង្ហាញផងដែរថា គ្រូអាចរីកចម្រើនទៅបាន តែនៅក្នុងបរិបទសមស្របប៉ុណ្ណោះ ពោលគឺត្រូវមានកម្មវិធីសិក្សាដែលរៀបចំបានល្អ និងមានយុទ្ធសាស្ត្រ វាយតម្លៃ ដើម្បីលើកកម្ពស់ការបង្រៀន និងរៀន។

ការផ្លាស់ប្តូរគោលនយោបាយទាំងនេះ ត្រូវមានចំណាយ។ នេះជាមូលហេតុ ដែលយើងចាំបាច់ត្រូវតែធ្វើការផ្លាស់ប្តូរឱ្យបានឆាប់រហ័សនូវអាទិភាពនៃការផ្តល់ថវិកា។ បច្ចុប្បន្ននេះ ការអប់រំកម្រិតមូលដ្ឋាននៅខ្វះថវិកា ២៦ ពាន់លានដុល្លារ ក្នុងមួយឆ្នាំ ស្របពេលដែលហិរញ្ញប្បទានសហប្រតិបត្តិការបន្តមានការថយចុះ។ នៅដំណាក់កាលនេះ រដ្ឋាភិបាល មិនអាចកាត់បន្ថយការវិនិយោគលើវិស័យអប់រំនោះទេ ហើយអ្នកផ្តល់ជំនួយក៏មិនគួរដកថយពីការសន្យាផ្តល់ថវិការបស់ខ្លួននោះដែរ។ របាយការណ៍នេះអំពាវនាវឱ្យមានការរិះរកវិធីថ្មីៗ ដើម្បីផ្តល់ថវិកាដល់តម្រូវការបន្ទាន់ទាំងនេះ។

យើងត្រូវរៀនសូត្រពីភស្តុតាងនានា ខណៈពេលដែលយើងកំពុងរៀបចំរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពថ្មី សម្រាប់សកលលោកទាំងមូល ក្រោយឆ្នាំ ២០១៥។ ដូចដែលបង្ហាញក្នុងរបាយការណ៍នេះ សមភាពក្នុងការទទួលបានការអប់រំ និងការរៀនសូត្រ ត្រូវតែជាស្នូលនៃគោលដៅនៃការអប់រំនាពេលអនាគត។ យើងត្រូវធានាថា កុមារ និងយុវវ័យគ្រប់ រូបកំពុងរៀនសូត្រចំណេះដឹងជាមូលដ្ឋាន ហើយពួកគេមានឱកាសទទួលបានជំនាញដែលអាចផ្ទេរបាន ដែលចាំបាច់ដើម្បី ឱ្យពួកគេក្លាយជាប្រជាពលរដ្ឋរបស់សកលលោក។ យើងក៏ត្រូវតែដាក់ចេញនូវគោលដៅនានា ដែលមានភាពច្បាស់លាស់ និងអាចវាស់វែងបានផងដែរ ដើម្បីផ្តល់លទ្ធភាពឱ្យមានការពិនិត្យ និងតាមដាន ដែលនេះជាអ្វីដែលមានសារៈសំខាន់យ៉ាងខ្លាំង ចំពោះរដ្ឋាភិបាល ក៏ដូចជាអ្នកផ្តល់ជំនួយ និងភ្នាប់គម្លាតនានាដែលនៅសល់។

ស្របពេលដែលយើងបោះជំហានទៅរកឆ្នាំ ២០១៥ និងកំណត់របៀបវារៈថ្មី ដើម្បីអនុវត្តតាម រដ្ឋាភិបាលទាំងអស់ ត្រូវតែវិនិយោគលើការអប់រំ ដោយចាត់ទុកវិស័យនេះថាជាកតាលីករសម្រាប់ពន្លឿនការអភិវឌ្ឍសម្រាប់ទាំងអស់គ្នា។ ភស្តុតាង ដែលមាននៅក្នុងរបាយការណ៍នេះ បង្ហាញយ៉ាងច្បាស់លាស់ថា ការអប់រំផ្តល់នូវនិរន្តរភាពដល់វឌ្ឍនភាព ដែលសម្រេចបានលើគ្រប់គោលដៅអភិវឌ្ឍន៍ទាំងអស់។ នៅពេលដែលអ្នកអប់រំម្តាយ មានន័យថា អ្នកផ្តល់ភាពអង់អាចដល់ស្ត្រី និងជួយសង្គ្រោះជីវិតរបស់កុមារ។ នៅពេលដែលអ្នកអប់រំសហគមន៍ មានន័យថា អ្នកធ្វើឱ្យមានការផ្លាស់ប្តូរក្នុងសង្គម និងធ្វើឱ្យសេដ្ឋកិច្ចមានការរីកចម្រើន។ នេះគឺជាសារសំខាន់នៃ របាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នានេះ។



Irina Bokova

អគ្គនាយកយូណេស្កូ

# សេចក្ដីផ្ដើម

ជាមួយនឹងកាលបរិច្ឆេទកំណត់សម្រាប់គោលដៅអប់រំសម្រាប់ទាំងអស់គ្នានឹងខិតមកដល់ ក្នុងរយៈពេលមិនដល់ ២ ឆ្នាំទៀតផង មានការបង្ហាញយ៉ាងច្បាស់ថា បើទោះបីជាមានការសម្រេចបាននូវវឌ្ឍនភាពជាច្រើន នៅក្នុងទសវត្សរ៍ចុងក្រោយនេះ ពុំមានគោលដៅណាមួយនឹងអាចសម្រេចបានត្រឹមឆ្នាំ ២០១៥ នៅទូទាំងសកលលោកទាំងមូលនោះឡើយ។ របាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា ដែលចេញផ្សាយនៅឆ្នាំនេះ គូសបញ្ជាក់ថា ប្រជាពលរដ្ឋ ដែលស្ថិតក្នុងក្រុមជួបប្រទះការលំបាកជាងគេ នៅតែបន្តមិនបានទទួលឱកាសអប់រំ នៅក្នុងទសវត្សរ៍កន្លងទៅនេះ។ ប៉ុន្តែ វាមិនទាន់យឺតពេលពេកនោះទេ ក្នុងការពន្លឿនវឌ្ឍនភាពទាំងនេះ នៅដំណាក់កាលចុងក្រោយនេះ។ ហើយ ការបង្កើតក្របខ័ណ្ឌអប់រំជាសកលក្រោយឆ្នាំ ២០១៥ ដែលមានភាពរឹងមាំ សម្រាប់អនុវត្ត គឺជាការងារដ៏សំខាន់មួយ ដើម្បី បំពេញការងារដែលនៅសេសសល់ ហើយក្នុងពេលជាមួយគ្នា អាចដោះស្រាយបញ្ហាប្រឈមមួយចំនួន ដែលកើតមានឡើងថ្មីៗ។ គោលដៅអប់រំក្រោយឆ្នាំ ២០១៥ នឹងអាចសម្រេចបាន ប្រសិនបើគោលដៅទាំងនេះមានអមមកជាមួយនឹង ចំណុចដៅច្បាស់លាស់ អាចវាស់វែងបាន ដោយមានសូចនាករសម្រាប់ធ្វើការតាមដានឱ្យដឹងថាពិតជាពុំមានអ្នកណាម្នាក់ត្រូវបានផាត់ចេញនោះឡើយ និងឱ្យដឹងថាតើមានការកំណត់ចំណុចដៅជាក់លាក់ផ្នែកការផ្ដល់ហិរញ្ញប្បទានដល់វិស័យអប់រំ ដោយសំណាក់រដ្ឋាភិបាល និងអ្នកផ្ដល់ជំនួយដែរឬទេ។

*របាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ ២០១៣-២០១៤ នេះ ចែកចេញជា ៣ ផ្នែក។ ផ្នែកទី ១ បង្ហាញពីបច្ចុប្បន្នភាពអំពីវឌ្ឍនភាព ក្នុងការឈានទៅសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នាទាំង ៦។ ផ្នែកទី ២ បង្ហាញពីភស្ដុតាងច្បាស់លាស់ថា វឌ្ឍនភាពក្នុងវិស័យអប់រំ មានសារៈសំខាន់យ៉ាងខ្លាំងដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ ក្រោយឆ្នាំ ២០១៥។ ផ្នែកទី ៣ គូសបញ្ជាក់ពីសារៈសំខាន់នៃការអនុវត្តគោលនយោបាយដែលមាន ភាពរឹងមាំ ដើម្បីបង្កលក្ខណៈឱ្យគ្រូអាចសម្រេចសក្ដានុពលរបស់ខ្លួនឱ្យបានពេញលេញ និងដើម្បីផ្ដល់ការគាំទ្រដល់ពួកគេ នៅក្នុងការដោះវិបត្តិពាក់ព័ន្ធជាមួយនឹងការរៀនសូត្រជាសកល។*

## ព័ត៌មានសំខាន់ៗ

- *គោលដៅទី ១ ៖ បើទោះបីជាមានការរីកចម្រើនខ្លះក៏ដោយ មានកុមារជាច្រើនអនេក ដែលនៅមិនទាន់ទទួលបាន សេវាគាំពារ និងអប់រំកុមារតូច។ នៅក្នុងឆ្នាំ ២០១២ កុមារអាយុក្រោម ៥ ឆ្នាំ ចំនួន ២៥% ជួបប្រទះនឹងបញ្ហាក្រិន។ នៅក្នុងឆ្នាំ ២០១១ មានកុមារតូចប្រហែលជាពាក់កណ្ដាល បានទទួលការអប់រំកម្រិតមត្តេយ្យសិក្សា ហើយនៅក្នុងតំបន់អាហ្វ្រិចសាប់សាហារ៉ា ភាគរយនេះមានត្រឹមតែ ១៨% ប៉ុណ្ណោះ។*

- *គោលដៅទី ២ ៖ សកលកម្មនៃការអប់រំបឋមសិក្សា ទំនងជានឹងមិនអាចសម្រេចបាន ក្នុងកម្រិតមួយដ៏ធំ។ កុមារក្រៅសាលា មានចំនួន ៥៧ លាននាក់ នៅក្នុងឆ្នាំ ២០១១ ដែលពាក់កណ្ដាលនៃចំនួននេះ គឺជាកុមារដែលរស់នៅក្នុងប្រទេស រងផលប៉ះពាល់ ដោយសារជម្លោះ។ នៅតំបន់អាហ្វ្រិចសាបសាហារ៉ា មានក្មេងស្រី មកពីគ្រួសារក្រីក្រក្នុងតំបន់ជនបទតែ ២៣% ប៉ុណ្ណោះ ដែលរៀនចប់កម្រិតបឋមសិក្សា ត្រឹមចុងទសវត្សរ៍នេះ។ ប្រសិនបើនិន្នាការបច្ចុប្បន្ន នៅក្នុងតំបន់នេះ នៅតែបន្តមានទៅមុខទៀត ក្មេងប្រុសមកពីគ្រួសារដែលមានជីវភាពធូរជាជាងគេ នឹងអាចរៀនចប់បឋម សិក្សាជាសកល នៅក្នុងឆ្នាំ ២០២១ ប៉ុន្តែ ក្មេងស្រី មកពីគ្រួសារដែលក្រខ្សត់ជាងគេ នឹងមិនអាចតាមទាន់ក្មេងប្រុសទាំងនេះឡើយ រហូតដល់ឆ្នាំ ២០៨៦។*

- *គោលដៅទី ៣ ៖ ក្មេងជំទង់ជាច្រើននាក់ នៅខ្វះជំនាញជាមូលដ្ឋាន ដែលពួកគេគួរទទួលបាន តាមរយៈការអប់រំកម្រិត មធ្យមសិក្សាបឋមភូមិ។ នៅក្នុងឆ្នាំ ២០១១ មានក្មេងជំទង់ ៦៩ លាននាក់ នៅក្រៅសាលា ដោយចំនួននេះមានការ កើនឡើងតិចតួចតែប៉ុណ្ណោះ ចាប់តាំងពីឆ្នាំ ២០០៤ មក។ នៅតាមបណ្ដាប្រទេសដែលមានចំណូលទាប មានក្មេងជំទង់ ត្រឹមតែ ៣៧% ប៉ុណ្ណោះ ដែលបានរៀបចប់កម្រិតមធ្យមសិក្សាបឋមភូមិ ហើយអត្រានេះមានកម្រិតទាបរហូតដល់ ១៤% សម្រាប់ក្មេងជំទង់មកពីគ្រួសារក្រខ្សត់ជាងគេ។ បើតាមនិន្នាការបច្ចុប្បន្ននេះ ក្មេងស្រីមកពីគ្រួសារក្រខ្សត់ជាងគេ នៅតំបន់អាហ្វ្រិចសាប់សាហារ៉ា អាចរៀនចប់មធ្យមសិក្សាបឋមភូមិបាន ទាល់តែដល់ឆ្នាំ ២១១១ ឯណោះ។*

- *គោលដៅទី ៤ ៖ អត្រាអក្ខរកម្មរបស់មនុស្សពេញវ័យ មានការកើនឡើងតិចតួច។ នៅក្នុងឆ្នាំ ២០១១ មនុស្សពេញ វ័យមិនចេះអក្សរមានចំនួន ៧៧៤ លាននាក់ ដែលមានការថយចុះត្រឹមតែ ១% ប៉ុណ្ណោះ ចាប់តាំងពីឆ្នាំ ២០០០ មក។ ចំនួននេះ ត្រូវបានគេព្យាករថានឹងថយចុះតិចតួចប៉ុណ្ណោះមកនៅត្រឹម ៧៤៣ លាននាក់ ត្រឹមឆ្នាំ ២០១៥។ មនុស្ស ពេញវ័យមិនចេះអក្សរជិតពីរភាគបី គឺជាស្ត្រី។ ស្ត្រីវ័យក្មេង មកពីគ្រួសារក្រខ្សត់ជាងគេ នៅតាមប្រទេសកំពុងអភិវឌ្ឍ អាចមិនទទួលបានសេវាអក្ខរកម្មជាសកលឡើយ រហូតដល់ឆ្នាំ ២០៧២។*

- *គោលដៅទី ៥ ៖ គម្លាតយេនឌ័រ នៅតែមាន នៅតាមប្រទេសជាច្រើន។ បើទោះបីជាយុត្តិភាពយេនឌ័រត្រូវសម្រេចឱ្យ បានតាំងពីឆ្នាំ ២០០៥ មកម្ល៉េះក៏ដោយ នៅក្នុងឆ្នាំ ២០១១ មានប្រទេសត្រឹមតែ ៦០% ប៉ុណ្ណោះ ដែលបានសម្រេច គោលដៅនេះ នៅកម្រិតបឋមសិក្សា និងមានប្រទេស ៣៨% បានសម្រេចគោលដៅនេះ នៅកម្រិតមធ្យមសិក្សាបឋមភូមិ។*

- *គោលដៅទី ៦ ៖ ការអប់រំដែលមានគុណភាពទាប មានន័យថា មានកុមាររាប់លាននាក់មិនបានរៀនសូត្រចំណេះដឹង ជាមូលដ្ឋាន ដែលពួកគេគួររៀន។ មានកុមារប្រមាណជា ២៥០ លាននាក់ ដែលមិនបានរៀនជំនាញជាមូលដ្ឋាន បើទោះបីជាពួកគេពាក់កណ្ដាល បានចំណាយពេលតិចបំផុត ៤ ឆ្នាំ នៅក្នុងសាលារៀនក៏ដោយ។ ការខាតបង់ប្រចាំឆ្នាំ ដោយសារបញ្ហានេះ មានប្រមាណជា ១២៩ ពាន់លានដុល្លារ។ ការវិនិយោគលើគ្រូបង្រៀន គឺជាគន្លឹះសំខាន់ ៖ នៅក្នុង ប្រទេសប្រមាណជាមួយភាគបី មានគ្រូបឋមសិក្សាតិចជាង ៧៥% ដែលទទួលបានការបណ្ដុះបណ្ដាល ទៅតាម ស្ដង់ដាជាតិ។ នៅក្នុងប្រទេសមួយភាគបី បញ្ហាលំបាកក្នុងការផ្ដល់ការបណ្ដុះបណ្ដាលដល់គ្រូដែលកំពុងបំពេញការងារ មានកម្រិតធ្ងន់ធ្ងរជាងការជ្រើសរើស និងការបណ្ដុះបណ្ដាលគ្រូថ្មីៗ។*

# ផ្នែកទី ១ ៖ ការពិនិត្យតាមដាន គោលដៅអប់រំសម្រាប់ទាំងអស់គ្នា

ចាប់តាំងពីពេលដែលក្របខ័ណ្ឌអប់រំសម្រាប់ទាំងអស់គ្នា ត្រូវបានដាក់ចេញ នៅក្នុងឆ្នាំ ២០០០ មក ប្រទេសទាំងឡាយបានសម្រេចនូវវឌ្ឍនភាព ក្នុងការឈានទៅបំពេញគោលដៅទាំងនេះ។ ប៉ុន្តែ ប្រទេសជាច្រើនអនេក ដែលនៅឆ្ងាយ ពីការសម្រេចចំណុចដៅ នៅក្នុងឆ្នាំ ២០១៥ (រូបភាពទី ១)។

**រូបភាពទី ១ ៖ ត្រឹមឆ្នាំ ២០១៥ ប្រទេសជាច្រើន នៅមិនទាន់អាចសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នាឡើយ**

ភាគរយរបស់ប្រទេស ដែលត្រូវបានគេព្យាករថានឹងអាចសម្រេចទៅតាមចំណុចដៅនៃគោលដៅអប់រំសម្រាប់ទាំងអស់គ្នាទាំង ៥ ត្រឹមឆ្នាំ ២០១៥




*សម្គាល់ ៖ ប្រទេសទាំងនេះត្រូវបានធ្វើការវាយតម្លៃ ថាតើបានសម្រេចចំណុចដៅនេះដែរឬទេ ប្រសិនបើពួកគេបានសម្រេចអត្រារួមនៃ ការសិក្សានៅកម្រិតមត្តេយ្យសិក្សា ៨០% (គោលដៅទី ១), អត្រាពិតនៃការសិក្សានៅកម្រិតបឋមសិក្សា ៩៧% (គោលដៅទី ២), អត្រាពិតនៃការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ ៩៧% (គោលដៅទី ៣), អត្រាអក្ខរកម្មមនុស្សពេញវ័យ ៩៧% (គោលដៅទី ៤), សន្ទស្សន៍យុគភាពយេនឌ័រចន្លោះពី ០,៩៧ ដល់ ១,០៣ នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ (គោលដៅទី ៥)។ ការ វិភាគនេះត្រូវបានធ្វើឡើង លើអនុក្រុមប្រទេស ដែលគេអាចធ្វើការព្យាករបាន ដូច្នេះ ការវិភាគនេះគ្របដណ្តប់លើប្រទេសក្នុងចំនួនតិច ជាងប្រទេសដែលមានព័ត៌មាន អាចនៅក្នុងឆ្នាំ ១៩៩៩ ឬ ២០១១។*

*ប្រភព ៖ Bruneforth (2013)*

## គោលដៅទី ១ ៖ ការគាំពារ និងអប់រំកុមារតូច

មូលដ្ឋានគ្រឹះ ដែលបង្កើតបាន នៅក្នុងរយៈពេលមួយពាន់ថ្ងៃដំបូងនៃជីវិតរបស់កុមារ ចាប់ពីពេលបង្កកំណើត រហូតដល់អាយុបានពីរឆ្នាំ មានសារៈសំខាន់យ៉ាងខ្លាំង សម្រាប់សុខុមាលភាពនាពេលអនាគត។ ដូច្នេះ វាគឺជាការសំខាន់ ដែលគ្រួសារត្រូវមានលទ្ធភាពទទួលបានការថែទាំសុខភាពឱ្យបានគ្រប់គ្រាន់ រួមជាមួយនឹងការគាំទ្រនានា ដើម្បីឱ្យមានការ សម្រេចចិត្តឱ្យបានត្រឹមត្រូវ សម្រាប់ម្តាយ និងកូន។ លើសពីនេះ ការទទួលបានអាហារូបត្ថម្ភបានល្អ គឺជាកូនសោរ សម្រាប់អភិវឌ្ឍប្រព័ន្ធភាពស៊ាំរបស់កុមារ ក៏ដូចជាសមត្ថភាពស្រូបយកចំណេះដឹងដែលពួកគេត្រូវការ ដើម្បីធ្វើការរៀនសូត្រ។

បើទោះបីជាមានការកែលំអយ៉ាងណាក៏ដោយ នៅមានកុមារក្នុងចំនួនខ្ពស់ដល់មិនអាចទទួលយកបាន ដែលជួប ប្រទះនឹងបញ្ហាសុខភាព ៖ មរណភាពកុមារអាយុក្រោម ៥ ឆ្នាំ មានការថយចុះ ៤៨% ពីឆ្នាំ ១៩៩០ ដល់ ២០១២ ប៉ុន្តែនៅ តែមានកុមារ ៦,៦ លាននាក់ស្លាប់ មុនពេលដល់អាយុបាន ៥ ឆ្នាំ នៅក្នុងឆ្នាំ ២០១២។

វឌ្ឍនភាព ដែលសម្រេចបានកន្លងមក មានភាពយឺតយ៉ាវ។ នៅក្នុងប្រទេសចំនួន ៤៣ មានកុមារច្រើនជាង ១ នាក់ ក្នុងចំណោម ១០ នាក់ ដែលបាត់បង់ជីវិតមុនអាយុ ៥ ឆ្នាំ នៅក្នុងឆ្នាំ ២០០០។ ប្រសិនបើគេព្យាករសម្រាប់ឆ្នាំ ២០១៥ ផ្អែកទៅតាមអត្រាប្រចាំឆ្នាំនៃការកាត់បន្ថយមរណភាពកុមារ នៅក្នុងប្រទេសទាំង ៤៣ ចន្លោះពីឆ្នាំ ២០០០ និង ២០១១ មានប្រទេសតែ ៨ ប៉ុណ្ណោះ ដែលនឹងសម្រេចបាននូវចំណុចដៅនៃការកាត់បន្ថយមរណភាពកុមារបានពីរភាគបី ធៀបនឹងកម្រិតនៃអត្រានេះ នៅឆ្នាំ ១៩៩០ នៅក្នុងប្រទេសទាំងនេះ។ ប្រទេសក្រីក្រមួយចំនួន ដែលបានវិនិយោគលើអន្តរាគមន៍កុមារតូច ដូចជា ប្រទេសបង់ក្លាដេស និងទីម័រខាងកើតជាដើម បានកាត់បន្ថយមរណភាពកុមារតិចបំផុតត្រឹម ២ ភាគ ៣ មុនកាលបរិច្ឆេទកំណត់ទៅទៀត។

វឌ្ឍនភាព នៅក្នុងការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភរបស់កុមារ មានក្នុងកម្រិតមួយខ្ពស់គួរសម។ ប៉ុន្តែ គិតត្រឹមឆ្នាំ ២០១២ មានកុមារអាយុក្រោម ៥ ឆ្នាំ ប្រមាណជា ១៦២ លាននាក់ នៅមានបញ្ហាកង្វះអាហារូបត្ថម្ភ។ កុមារ ៣ ភាគ ៤ ក្នុងចំណោមកុមារទាំងនេះ រស់នៅតំបន់អាហ្វ្រិចសាប់សាហារ៉ា អាស៊ីខាងត្បូង និង

អាស៊ីខាងលិច។ ខណៈពេល ដែលភាគរយកុមារអាយុក្រោម ៥ ឆ្នាំ ដែលមានបញ្ហាក្រិន ដែលជាសូចនាករសំខាន់មួយបង្ហាញពីបញ្ហាកង្វះអាហារូបត្ថម្ភ ក្នុងរយៈពេលវែង មាន ២៥% ថយចុះពី ៤០% នៅក្នុងឆ្នាំ ១៩៩០ អត្រាប្រចាំឆ្នាំនៃការថយចុះនេះ ត្រូវតែបង្កើតជិតទ្វេដង ប្រសិនបើគេចង់សម្រេចចំណុចដៅជាសកល នៅត្រឹមឆ្នាំ ២០២៥។

ការគាំពារកុមារតូច និងការអប់រំ មានទំនាក់ទំនងស្អិតរមួតជាមួយគ្នា និងជួយពង្រឹងគ្នាទៅវិញទៅមក។ សេវាគាំពារ និងអប់រំកុមារតូច ជួយកសាងជំនាញ នៅពេលដែលខួរក្បាលរបស់កុមារកំពុងមានការអភិវឌ្ឍ ដែលជាការផ្តល់ប្រយោជន៍រយៈពេលវែងដល់កុមារ ដែលមានប្រវត្តិជួបប្រទះការលំបាក។ ឧទាហរណ៍ នៅក្នុងប្រទេសចាម៉ៃកា ទារក ដែលមានបញ្ហាក្រិន និងមកពីគ្រួសារជួបប្រទះការលំបាក ហើយបានទទួលការភ្ញោចផ្នែកចិត្តសង្គមរៀងរាល់សប្តាហ៍ អាចរកចំណូលច្រើនជាងទារកផ្សេងទៀត ដែលមិនបានទទួលសេវានេះ ចំនួន ៤២% នៅពេលដែលពួកគេឈានដល់វ័យ ២០ ឆ្នាំ តិចតួច។

ចាប់តាំងពីឆ្នាំ ២០០០ មក ការអប់រំកម្រិតមត្តេយ្យសិក្សា មានការពង្រីកបានច្រើន គួរឱ្យកត់សម្គាល់។ អត្រារួម នៃការសិក្សានៅកម្រិតមត្តេយ្យសិក្សា មានការកើនឡើងពី ៣៣% នៅក្នុងឆ្នាំ ១៩៩៩ ដល់ ៥០% នៅក្នុងឆ្នាំ ២០១១ បើទោះបីជាអត្រានេះមានត្រឹមតែ ១៨% នៅអាហ្វ្រិចសាប់សាហារ៉ាក៏ដោយ។ ចំនួនកុមារ ដែលបានចុះឈ្មោះចូលរៀន នៅសាលាមត្តេយ្យ មានការកើនឡើងជិត ៦០ លាននាក់ នៅក្នុងរយៈពេលនេះ។

តែទោះជាយ៉ាងនេះក្តី នៅតាមប្រទេសជាច្រើនក្នុងពិភពលោក គម្លាតនៃការសិក្សារវាងអ្នកមានបំផុត និងអ្នកក្រ បំផុត នៅតែធំ (រូបភាពទី ២)។ មូលហេតុមួយផ្នែក គឺដោយសារតែរដ្ឋាភិបាលមិនទាន់បានទទួលយកការទទួលខុសត្រូវឱ្យ បានគ្រប់គ្រាន់លើការអប់រំកម្រិតមត្តេយ្យសិក្សា ៖ គិតត្រឹមឆ្នាំ ២០១១ អ្នកផ្តល់សេវាមត្តេយ្យសិក្សាឯកជនស្រូបយក ៣៣% នៃកុមារដែលចុះឈ្មោះចូលរៀនសរុប ដែលភាគរយនេះកើនឡើងដល់ ៧១% នៅបណ្តារដ្ឋអារ៉ាប់។ ការចំណាយ លើសេវាឯកជន គឺជាកត្តាមួយ ដែលរួមចំណែកធ្វើឱ្យមានសមធម៌នៃការទទួលបានការអប់រំ នៅកម្រិតនេះ។

ពុំមានចំណុចដៅណាមួយ ត្រូវបានដាក់ចេញ នៅទីក្រុងដាកា ក្នុងឆ្នាំ ២០០០ ដើម្បីផ្តល់ជាការណែនាំលើការវាយតម្លៃជោគជ័យនៃការអប់រំកុមារតូចឡើយ។ ដើម្បីវាស់វែងភាពជឿនលឿននេះ របាយការណ៍នេះបានកំណត់អត្រារួមនៃការសិក្សានៅកម្រិតមត្តេយ្យសិក្សា ៨០% សម្រាប់ជាចំណុចដៅបណ្តោះអាសន្ន សម្រាប់ឆ្នាំ ២០១៥។ ក្នុងចំណោមប្រទេស ១៤១ ដែលមានទិន្នន័យ មាន ២១% បានសម្រេចចំណុចដៅនេះ នៅក្នុងឆ្នាំ ១៩៩៩។ គិតត្រឹមឆ្នាំ ២០១១ តួលេខនេះបានកើនឡើងដល់ ៣៧%។ សម្លឹងទៅមុខដល់ឆ្នាំ ២០១៥ គេព្យាករថា ប្រទេសចំនួន ៤៨% នឹងអាចសម្រេចចំណុចដៅនេះ។

ចំណុចដៅ ៨០% គឺជាតួលេខមួយទាប ដែលនាំឱ្យមានកុមារតូចជាច្រើននាក់ ដែលជាកុមារងាយរងគ្រោះបំផុត នៅក្រៅសាលាមត្តេយ្យ។ គោលដៅក្រោយឆ្នាំ ២០១៥ ត្រូវតែដាក់ចេញនូវចំណុចដៅឱ្យបានច្បាស់លាស់ ដើម្បីធានាយ៉ាងណាឱ្យកុមារតូចទាំងអស់អាចទទួលបានការអប់រំកម្រិតមត្តេយ្យសិក្សា និងត្រូវកំណត់ពីវិធី សម្រាប់ធ្វើការតាមដាន វឌ្ឍនភាពរបស់ក្រុមជួបប្រទះការលំបាក សំដៅធានាយ៉ាងណាកុំឱ្យពួកគេខកខានមិនបានទទួលសេវានេះ។

**រូបភាពទី ២ ៖ មានកុមារអាយុ ៤ ឆ្នាំ មកពីគ្រួសារក្រីក្រក្នុងចំនួនតិចតួចប៉ុណ្ណោះ ដែលទទួលបានការអប់រំមត្តេយ្យសិក្សា**

ភាគរយកុមារអាយុ ៣៦ ដល់ ៥៩ ខែ ដែលចូលរួមក្នុងកម្មវិធីអប់រំកុមារតូចដែលរៀបចំឡើងក្នុងរូបភាពមួយចំនួន បែងចែកតាមទ្រព្យសម្បត្តិ ក្នុងប្រទេសមួយចំនួន ២០០៥-២០១២




*ប្រភព ៖ មូលដ្ឋានទិន្នន័យពិភពលោកស្តីពីវិសមភាពក្នុងវិស័យអប់រំ www.education-inequalities.org*

## គោលដៅទី ២ ៖ សកលកម្មនៃការអប់រំបឋមសិក្សា

នៅប្រហែលជាពីរឆ្នាំទៀតប៉ុណ្ណោះ ដែលកាលបរិច្ឆេទឆ្នាំ ២០១៥ សម្រាប់គោលដៅអប់រំសម្រាប់ទាំងអស់គ្នា នឹងមកដល់ ហើយគោលដៅសកលកម្មនៃការអប់រំកម្រិតបឋមសិក្សា ទំនងជាមិនអាចសម្រេចបាន ដោយគម្លាតរវាងអ្វីដែលសម្រេចបានជាក់ស្តែង និងគោលដៅ មានកម្រិតមួយយ៉ាងធំ។ គិតត្រឹមឆ្នាំ ២០១១ មានកុមារ ៥៧ លាននាក់ ដែលបន្តនៅក្រៅសាលា។

**នៅក្នុងឆ្នាំ ២០១១ មានប្រទេសចំនួន ១៤ ដែលមានកុមារក្រៅសាលាជាង ១ លាននាក់។**

មានព័ត៌មានល្អៗមួយចំនួនផងដែរ ៖ ចន្លោះពីឆ្នាំ ១៩៩៩ ដល់ ២០១១ ចំនួនកុមារក្រៅសាលា មានការថយចុះជិតពាក់កណ្តាល។ ក្រោយរយៈពេលដែលចំនួននេះនៅទ្រឹង មានការរីកចម្រើនតិចតួចប៉ុណ្ណោះ ចន្លោះពីឆ្នាំ ២០១០ ដល់ ២០១១។ ប៉ុន្តែការថយចុះចំនួន ១,៩ លាននាក់ គឺច្រើនជាងមួយភាគបួនបន្តិចនៃការថយចុះគិតជាមធ្យមចន្លោះពីឆ្នាំ ១៩៩៩ និង ២០០៤ ប៉ុណ្ណោះ។ ប្រសិនបើកអត្រានៃការថយចុះនេះ ចន្លោះពីឆ្នាំ ១៩៩៩ និង ២០០៨ នៅអាចរក្សាបាន នោះគេស្ទើរតែអាចសម្រេចគោលដៅសកលកម្មការអប់រំបឋមសិក្សា ត្រឹមឆ្នាំ ២០១៥ (រូបភាពទី ៣)។

តំបន់អាហ្វ្រិចសាប់សាហារ៉ា គឺជាតំបន់ ដែលមានភាពយឺតយ៉ាវជាងគេ ដោយកុមារដល់អាយុចូលរៀនបឋមសិក្សាក្នុងតំបន់នេះចំនួន ២២% នៅក្រៅសាលានៅឡើយនៅក្នុងឆ្នាំ ២០១១។ ផ្ទុយទៅវិញ អាស៊ីខាងត្បូង និងអាស៊ីខាងលិច មានការថយចុះលឿនជាងគេ ដែលនាំឱ្យមានការថយចុះចំនួនកុមារក្រៅសាលាសរុបជាងពាក់កណ្តាល។

**រូបភាពទី ៣ ៖ កុមាររាប់លាននាក់ដែលនៅក្រៅសាលា នៅក្នុងឆ្នាំ ២០១១**

ចំនួនកុមារអាយុចូលរៀនបឋមសិក្សា ដែលនៅក្រៅសាលា បែងចែកតាមតំបន់ ១៩៩៩-២០១១




*សម្គាល់ ៖ បន្ទាត់ដាច់ៗពីឆ្នាំ ២០០៨ ដល់ ២០១៥ គឺផ្អែកទៅតាមការថយចុះគត់ប្រចាំឆ្នាំនូវចំនួនកុមារក្រៅសាលា ពីឆ្នាំ ១៩៩៩ ដល់ ២០០៨*

*ប្រភព ៖ មូលដ្ឋានទិន្នន័យ UIS, ការគណនារបស់ក្រុមតាក់តែងរបាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា (២០១៣)*

ក្មេងស្រីមាន ៥៤% នៃចំនួនកុមារក្រៅសាលាសរុប នៅក្នុងសកលលោកទាំងមូល។ នៅតាមបណ្តារដ្ឋអារ៉ាប់ ភាគរយនេះ មានដល់ ៦០% ដែលមិនមានការប្រែប្រួលសោះ ចាប់តាំងពីឆ្នាំ ២០០០ មក។ ផ្ទុយទៅវិញ នៅអាស៊ីខាងត្បូង និងអាស៊ីខាងលិច ភាគរយក្មេងស្រី នៅក្នុងក្រុមកុមារក្រៅសាលា មានការថយចុះជាបន្តបន្ទាប់ ពោលគឺពី ៦៤% នៅក្នុងឆ្នាំ ១៩៩៩ មកនៅ ៥៧% នៅ ក្នុងឆ្នាំ ២០១១។ គេរំពឹងថា កុមារក្រៅសាលាជិតពាក់កណ្តាល នឹងមិនមានឱកាសបានទៅរៀនឡើយ ដូចគ្នានឹងក្មេងស្រីជិតពីរភាគបី នៅតាមបណ្តារដ្ឋអារ៉ាប់ និងតំបន់អាហ្វ្រិចសាប់សាហារ៉ា។

ប្រទេស ដែលបំពេញការងារបានល្អជាងគេ នៅក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ រួមមាន សាធារណរដ្ឋ ប្រជាមានិតប្រជាធិបតេយ្យឡាវ រវ៉ាន់ដា និងវៀតណាម ដែលបានកាត់បន្ថយចំនួនកុមារក្រៅសាលានៅក្នុងប្រទេសរបស់ ខ្លួនបានយ៉ាងហោចណាស់ ៨៥%។ មានការប្រែប្រួលតិចតួចប៉ុណ្ណោះ នៅក្នុងបញ្ជីប្រទេស ដែលមានចំនួនកុមារក្រៅសាលាខ្ពស់ជាងគេ។ ប្រទេសនៅលើគេទាំង ១០ មិនបានប្រែប្រួលឡើយ នៅក្នុងរយៈពេលនេះ លើកលែងតែប្រទេសហ្គាណា ដែលត្រូវបានជំនួសដោយប្រទេសយេម៉ែន។

ប្រទេសមួយចំនួន ដែលគួរតែមានឈ្មោះនៅក្នុងបញ្ជីប្រទេសដែលមានកុមារក្រៅសាលាច្រើនជាងគេដែរ ប៉ុន្តែមិនមានឈ្មោះទៅវិញ គឺដោយសារតែប្រទេសទាំងនោះមិនមានទិន្នន័យគួរឱ្យជឿទុកចិត្តថ្មីៗតែប៉ុណ្ណោះ។ ដោយប្រើប្រាស់ការ អង្កេតតាមគ្រួសារ របាយការណ៍នេះប៉ាន់ប្រមាណថា មានប្រទេសចំនួន ១៤ ដែលមានកុមារក្រៅសាលាជាង ១ លាននាក់ នៅក្នុងឆ្នាំ ២០១១ រាប់បញ្ចូលទាំងប្រទេសអាហ្វហ្គានីស្ថាន ចិន សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ សូម៉ាលី ស៊ូដង់ (មុនពេលមានការបែងចែកប្រទេសនេះជាពីរ) និងសាធារណៈរដ្ឋតង់ហ្សានៀ។

កុមារក្រៅសាលាក្នុងពិភពលោកប្រមាណជាពាក់កណ្តាល រស់នៅតាមប្រទេស ដែលទទួលរងផលប៉ះពាល់ ដោយសារជម្លោះ កើនឡើងពី ៤២% នៅក្នុងឆ្នាំ ២០០៨។ ក្នុងចំណោមកុមារក្រៅសាលា ដែលដល់អាយុចូលរៀននៅ បឋមសិក្សា ២៨,៥ លាននាក់ នៅតាមប្រទេសដែលរងផលប៉ះពាល់ដោយសារជម្លោះ មាន ៩៥% រស់នៅក្នុងប្រទេស ដែលមានចំណូលទាប និងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ ក្មេងស្រី ដែលមាន ៥៥% នៃចំនួនសរុប គឺជាអ្នក ដែលទទួលរងផលប៉ះពាល់ជាងគេ។

ជារឿយៗ កុមារមិនអាចមករៀនបាន ដោយសារតែការលំបាក ដែលពួកគេមានពីកំណើតមក។ ការលំបាកមួយ ក្នុងចំណោមការលំបាក ដែលគេមិនយកចិត្តទុកដាក់ជាងគេ គឺពិការភាព។ ការវិភាគថ្មីៗ ធ្វើឡើងនៅក្នុងប្រទេសចំនួន ៤ បង្ហាញថា កុមារដែលប្រឈមមុខខ្ពស់នឹងពិការភាព ច្រើនតែពុំទទួលបានឱកាសទៅសាលារៀន ដោយភាពខុសប្លែកគ្នាក្នុង ចំណោមពួកគេ មានច្រើន អាស្រ័យទៅតាមប្រភេទពិការភាព។ ឧទាហរណ៍ នៅក្នុងប្រទេសអ៊ីរ៉ាក់ កុមារអាយុពី ៦ ដល់ ៩ ឆ្នាំ ដែលពុំមានពិការភាព ១០% មិនបានទៅរៀនឡើយ នៅក្នុងឆ្នាំ ២០០៦ ប៉ុន្តែកុមារដែលមានកម្សោយផ្នែកការស្តាប់ ចំនួន ១៩% និងកុមារដែលមានពិការភាពផ្នែកបញ្ញាក្នុងកម្រិតធ្ងន់ធ្ងរចំនួន ៥១% មិនដែលបានទៅសាលារៀនឡើយ។

កុមារច្រើនតែអាចរៀនចប់បឋមសិក្សា ប្រសិនបើពួកគេចូលរៀនត្រូវអាយុ។ ប៉ុន្តែ អត្រាពិតនៃការចូលរៀនថ្មី សម្រាប់ឆ្នាំទី ១ នៅបឋមសិក្សា មានការកើនឡើងតិចតួចប៉ុណ្ណោះ ចន្លោះពីឆ្នាំ ១៩៩៩ និង ២០១១ ពោលគឺពី ៨១% ទៅ ៨៦% និងកើនឡើងតិចជាង ១ ភាគរយចំណុច ប៉ុណ្ណោះ នៅក្នុងរយៈពេល ៤ ឆ្នាំចុងក្រោយនេះ។ ប៉ុន្តែប្រទេសមួយចំនួន សម្រេចបាននូវវឌ្ឍនភាពធំធេង ក្នុងការប្រមូលកុមារឱ្យចូលរៀនទាន់ពេលវេលា ដូចជា ប្រទេសអេត្យូពី ជាដើម ដែលបានបង្កើនអត្រានេះពី ២៣% នៅក្នុងឆ្នាំ ១៩៩៩ ដល់ ៩៤% នៅក្នុងឆ្នាំ ២០១១។

ការបោះបង់ចោលការសិក្សា មុនពេលបញ្ចប់ការអប់រំកម្រិតបឋមសិក្សាឱ្យបានពេញលេញ ស្ទើរតែពុំមានការប្រែប្រួល ចាប់តាំងពីឆ្នាំ ១៩៩៩ មក។ នៅក្នុងឆ្នាំ ២០១០ មានកុមារ ដែលបានចាប់ផ្តើមរៀននៅបឋមសិក្សាប្រមាណជា ៧៥% បានរៀនដល់ថ្នាក់ចុងក្រោយ។ នៅអាហ្វ្រិចសាប់សាហារ៉ា ភាគរយរបស់កុមារ ចាប់ផ្តើមចូលរៀន និងអាចរៀន រហូតដល់ថ្នាក់ចុងក្រោយ មានការថយចុះពី ៥៨% នៅក្នុងឆ្នាំ ១៩៩៩ មកនៅ ៥៦% នៅក្នុងឆ្នាំ ២០១០។ ផ្ទុយទៅវិញ នៅក្នុងបណ្តារដ្ឋអារ៉ាប់ ភាគរយនេះមានការកើនឡើងពី ៧៩% នៅក្នុងឆ្នាំ ១៩៩៩ ដល់ ៨៧% នៅក្នុងឆ្នាំ ២០១០។

ការចូលរៀនជាសកល នៅសាលាបឋមសិក្សា ទំនងជានៅមិនអាចសម្រេចបានឡើយ នៅតាមប្រទេសជាច្រើន ត្រឹមឆ្នាំ ២០១៥។ ក្នុងចំណោមប្រទេសចំនួន ១២២ ភាគរយកុមារនៃការចូលរៀនជាសកលនៅបឋមសិក្សា មានការកើនឡើងពី ៣០% នៅក្នុងឆ្នាំ ១៩៩៩ ដល់ ៥០% នៅក្នុងឆ្នាំ ២០១១។ សម្លឹងមើលទៅមុខដល់ឆ្នាំ ២០១៥ គេព្យាករថា ប្រទេសចំនួន ៥៦% នឹងសម្រេចបានដល់ចំណុចដៅនេះ។ នៅក្នុងឆ្នាំ ២០១៥ ប្រទេស ១២% នៅមានកុមារតិចជាង ៨ នាក់ ក្នុងចំណោម ១០ នាក់ ដែលបានចូលរៀននៅកម្រិតនោះ ក្នុងនោះប្រទេស ២ ភាគ ៣ ស្ថិតនៅក្នុងតំបន់អាហ្វ្រិចសាប់សាហារ៉ា។

ការវិនិច្ឆ័យថាតើសកលកម្មនៃការអប់រំបឋមសិក្សា អាចសម្រេចទៅបានឬអត់ គួរវិនិច្ឆ័យ មិនត្រឹមតែដោយសារ ការចូលរៀនតែឯងនោះទេ ប៉ុន្តែត្រូវមើលថាតើកុមារបានរៀនចប់សាលាបឋមសិក្សាដែរឬអត់។ នៅក្នុងចំណោមប្រទេស ទាំង ៩០ ដែលមានទិន្នន័យនេះ គេរំពឹងថា មានកុមារយ៉ាងហោចណាស់ ៩៧% នឹងរៀនដល់ថ្នាក់ចុងក្រោយនៅបឋមសិក្សា មុនឆ្នាំ ២០១៥ ត្រឹមតែនៅក្នុងប្រទេសចំនួន ១៣ ប៉ុណ្ណោះ ដែលក្នុងនោះមានប្រទេសចំនួន ១០ ជាប្រទេសសមាជិក OECD ឬជារដ្ឋសមាជិករបស់សហភាពអឺរ៉ុប។

## គោលដៅទី ៣ ៖ ជំនាញរបស់យុវជន និងមនុស្សពេញវ័យ

គោលដៅអប់រំសម្រាប់ទាំងអស់គ្នាទី ៣ គឺជាគោលដៅ ដែលគេមិនយកចិត្តទុកដាក់ជាងគេ មួយផ្នែក ដោយសារ តែពុំមានការកំណត់ពីចំណុចដៅ ឬសូចនាករសម្រាប់ពិនិត្យតាមដានវឌ្ឍនភាពរបស់វា។ របាយការណ៍ឆ្នាំ ២០១២ បានស្នើឱ្យមានការបង្កើតនូវក្របខ័ណ្ឌមួយ ដែលបង្ហាញពីមាគ៌ាចម្រុះ សម្រាប់ទទួលបានជំនាញដូចជា ជំនាញជាមូលដ្ឋាន ជំនាញ ដែលអាចផ្ទេរបាន និងជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដែលនេះជាបែបផែនមួយ សម្រាប់លើកកម្ពស់ការងារពិនិត្យតាម ដាន ប៉ុន្តែសហគមន៍អន្តរជាតិ នៅមិនទាន់អាចវាស់វែងការទទួលបានជំនាញទាំងនេះ ក្នុងលក្ខណៈជាប្រព័ន្ធនៅឡើយ។

មាគ៌ា ដែលមានប្រសិទ្ធភាពជាងគេ ដើម្បីទទួលបានជំនាញជាមូលដ្ឋាន គឺតាមរយៈការចូលរៀននៅសាលាមធ្យម សិក្សាបឋមភូមិ។ អត្រារួមនៃការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ មានការកើនឡើងពី ៧២% ដល់ ៨២% ពីឆ្នាំ ១៩៩៩ ដល់ ២០១១។ ការកើនឡើងលឿនជាងគេ គឺនៅតំបន់អាហ្វ្រិចសាប់សាហារ៉ា នៅការចូលរៀនមានការកើនឡើងទ្វេដង រហូតដល់ ៤៩% នៅក្នុងឆ្នាំ ២០១១ ពីភាគរយគោល ដែលមានកម្រិតទាប។

កុមារចាំបាច់ត្រូវរៀនឱ្យចប់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ ទើបអាចទទួលបានជំនាញជាមូលដ្ឋានបាន។ ការវិភាគ ដោយប្រើប្រាស់ការអង្កេតគ្រួសារ បង្ហាញថា អត្រាបញ្ចប់ការសិក្សាកើនឡើងដល់ត្រឹមតែ ៣៧% ប៉ុណ្ណោះ នៅតាមបណ្តាប្រទេសដែលមានចំណូលទាប ត្រឹមឆ្នាំ ២០១០។ ការបញ្ចប់ការសិក្សានេះនៅមានវិសមភាពខ្ពស់ ជាមួយនឹង អត្រា ៦១% សម្រាប់គ្រួសារដែលមានជីវភាពធូរធាជាងគេ ប៉ុន្តែត្រឹមតែ ១៤% សម្រាប់អ្នកដែលក្រខ្សត់ជាងគេ។

ចាប់តាំងពីឆ្នាំ ១៩៩៩ មក ចំនួនក្មេងជំទង់ក្រៅសាលា មានការថយចុះ ៣១% មកនៅ ៦៩ លាននាក់។ ប៉ុន្តែ ចំនួននេះនៅទ្រឹង ចាប់តាំងពីឆ្នាំ ២០០៧ មក ដែលធ្វើឱ្យយុវជនជាច្រើននាក់ ចាំបាច់ត្រូវទទួលបានកម្មវិធីផ្តល់ឱកាសទីពីរ ដល់ពួកគេទើបអាចទទួលបានជំនាញជាមូលដ្ឋាន។ វឌ្ឍនភាពយឺតយ៉ាវ ក្នុងការឈានទៅកាត់បន្ថយចំនួនក្មេងជំទង់ក្រៅសាលា នៅអាស៊ីខាងត្បូង និងអាស៊ីខាងលិច នាំឱ្យភាគរយក្មេងជំទង់ក្រៅសាលារបស់តំបន់នេះ ធៀបជាមួយនឹងចំនួនសរុប មានការកើនឡើងពី ៣៩% នៅក្នុងឆ្នាំ ១៩៩៩ ដល់ ៤៥% នៅក្នុងឆ្នាំ ២០១១។ នៅតំបន់អាហ្វ្រិចសាប់សាហារ៉ា ចំនួនក្មេងជំទង់ក្រៅសាលា នៅមាន ២២ លាននាក់ ចន្លោះពីឆ្នាំ ១៩៩៩ ដល់ ២០១១ ដោយសារតែកំណើនចំនួនប្រជាជន មានលើសពីកំណើនចំនួនសិស្សចូលរៀន (រូបភាពទី ៤)។

ដោយសារតែគេរំពឹងថា សកលកម្មនៃការអប់រំមធ្យមសិក្សាបឋមភូមិ នឹងក្លាយជាគោលដៅជាក់លាក់មួយ ក្រោយឆ្នាំ ២០១៥ វាជាការសំខាន់ ដែលគេត្រូវធ្វើការវាយតម្លៃ ថាតើពិភពលោកទាំងមូលទំនងជានឹងស្ថិតនៅក្នុង ស្ថានភាពបែបណា នៅក្នុងឆ្នាំ ២០១៥។ ការវាយតម្លៃលើវឌ្ឍនភាពនានា ដែលសម្រេចបាននៅក្នុងប្រទេសចំនួន ៨២ រកឃើញថា មានប្រទេសប្រហែលជា ២៦% ប៉ុណ្ណោះ ដែលសម្រេចបាននូវសកលកម្មនៃការអប់រំមធ្យមសិក្សាបឋមភូមិ នៅក្នុងឆ្នាំ ១៩៩៩។ គិតត្រឹមឆ្នាំ ២០១១ ប្រទេសចំនួន ៣២% បានឈានដល់កម្រិតនោះ។ ត្រឹមឆ្នាំ ២០១៥ ភាគរយនៃ ប្រទេសដែលឈានដល់កម្រិតនេះ នឹងមានការកើនឡើងដល់ ៤៦%។

**រូបភាពទី ៤ ៖ ចំនួនក្មេងជំទង់ក្រៅសាលារៀន មានការថយចុះតិចតួចបំផុត ចាប់តាំងពីឆ្នាំ ២០០៧ មក**

ចំនួនក្មេងជំទង់ក្រៅសាលារៀន បែងចែកតាមតំបន់ ពីឆ្នាំ ១៩៩៩ ដល់ ២០១១




*ប្រភព* ៖ មូលដ្ឋានទិន្នន័យ UIS

**នៅក្នុងប្រទេសដែលមានចំណូលទាប មានកុមារក្រខ្សត់ជាងគេ ត្រឹមតែ ១៤% ប៉ុណ្ណោះ ដែលរៀនចប់សាលាមធ្យមសិក្សាបឋមភូមិ។**

ការវាយតម្លៃលើ ធ្វើឡើងផ្អែកទៅតាមព័ត៌មាន តែពីប្រទេសចំនួន ៤០% ក្នុងចំណោមប្រទេសទាំងអស់តែ ប៉ុណ្ណោះ។ ការវាយតម្លៃនេះ ដាក់បញ្ចូលប្រទេស ២ ភាគ ៣ នៅអាមេរិចខាងជើង និងអឺរ៉ុបខាងលិច ប៉ុន្តែមានប្រទេសនៅ អាហ្វ្រិចសាប់សាហារ៉ាត្រឹមតែ ១ ភាគ ៤ ប៉ុណ្ណោះ ដូច្នេះ ការវាយតម្លៃនេះ មិនមែនជាការវាយតម្លៃតំណាងឡើយ។ បើគិតទាំងប្រទេស ដែលមិនទាន់សម្រេចបាននូវសកលកម្មការអប់រំបឋមសិក្សា ភាគរយរបស់ប្រទេស ដែលអាចសម្រេចបាននូវសកលកម្មការអប់រំមធ្យមសិក្សាបឋមភូមិ ត្រឹមឆ្នាំ ២០១៥ អាចមានកម្រិតទាបជាងនេះច្រើន។

## គោលដៅទី ៤ ៖ អក្ខរកម្មមនុស្សពេញវ័យ

សកលកម្មអក្ខរកម្ម គឺជាមូលដ្ឋានគ្រឹះ ដើម្បីសម្រេចឱ្យបាននូវភាពរីកចម្រើនក្នុងសង្គម និងសេដ្ឋកិច្ច។ ជំនាញអក្ខរកម្ម អាចអភិវឌ្ឍបានល្អបំផុត នៅវ័យកុមារ តាមរយៈការអប់រំប្រកបដោយគុណភាព។ ប្រទេសមួយចំនួនតូច ផ្តល់ឱកាសទីពីរពិតប្រាកដ ដល់មនុស្សពេញវ័យមិនចេះអក្សរ។ ដូច្នេះ ប្រទេស ដែលធ្លាប់តែមានអត្រាចូលរៀនទាប មិនអាចលុបបំបាត់បញ្ហាមិនចេះអក្សរបស់មនុស្សពេញវ័យបានឡើយ។

**ចំនួនមនុស្សពេញវ័យមិនចេះអក្សរថយចុះបានតែ ១% ប៉ុណ្ណោះតាំងពីឆ្នាំ ២000 មក**

ចំនួនមនុស្សពេញវ័យមិនចេះអក្សរ នៅតែមានកម្រិតខ្ពស់ដដែល ពោលគឺ ៧៧៤ លាននាក់ ហើយមានការថយចុះ ត្រឹមតែ ១២% ប៉ុណ្ណោះ ចាប់តាំងពីឆ្នាំ ១៩៩០ មក ប៉ុន្តែត្រឹមតែ ១% ប៉ុណ្ណោះ ចាប់តាំងពីឆ្នាំ ២០០០។ គេព្យាករថា តួលេខនេះនឹងថយមកនៅត្រឹមតែ ៧៤៣ លាននាក់ប៉ុណ្ណោះ នៅឆ្នាំ ២០១៥។ ប្រទេសចំនួន ១០ ជាប្រទេស ដែលស្រូប យកជិត ៣ ភាគ ៤ នៃចំនួនអនក្ខរជនជាមនុស្សពេញវ័យ ក្នុងពិភពលោក (រូបភាពទី ៥)។ ស្រ្តីមានជិត ២ ភាគ ៣ នៃចំនួនសរុបនេះ ហើយកន្លងមក ពុំមានវឌ្ឍនភាព ក្នុងការកាត់បន្ថយភាគរយនេះឡើយ ចាប់តាំងពីឆ្នាំ ១៩៩០ មក។ ក្នុងចំណោមប្រទេសចំនួន ៦១ ដែលមានទិន្នន័យ មានប្រទេសប្រហែលជាពាក់កណ្តាល ដែលគេរំពឹងថា នឹងសម្រេចបាននូវយុគភាពយេនឌ័រ ក្នុងអក្ខរកម្មរបស់មនុស្សពេញវ័យ គិតត្រឹមឆ្នាំ ២០១៥ និងមានប្រទេសចំនួន ១០ ដែលទៅកៀកនឹងយុគភាពយេនឌ័រនេះ។

ចាប់តាំងពីឆ្នាំ ១៩៩០ មក អត្រាអក្ខរកម្មមនុស្សពេញវ័យ មានការកើនឡើងលឿនជាងគេ នៅតាមបណ្តារដ្ឋអារ៉ាប់។ តែទោះជាយ៉ាងណាក៏ដោយ បើគិតទាំងការកើនឡើងនូវចំនួនប្រជាជនផងនោះ ចំនួនមនុស្សពេញវ័យមិនចេះអក្សរ ថយចុះត្រឹមតែពី ៥២ លាននាក់ មក ៤៨ លាននាក់ប៉ុណ្ណោះ។ ស្រដៀងគ្នានេះដែរ តំបន់ ដែលមានការកើនឡើងនូវ អត្រាអក្ខរកម្មមនុស្សពេញវ័យលឿនជាងគេទី ២ គឺអាស៊ីខាងត្បូង និងខាងលិច នៅមានចំនួនមនុស្សពេញវ័យមិនចេះអក្សរ ក្នុងកម្រិតមួយថេរ ពោលគឺជាង ៤០០ លាននាក់។ នៅតំបន់អាហ្វ្រិចសាប់សាហារ៉ា ចំនួនមនុស្សពេញវ័យមិនចេះអក្សរ មានការកើនឡើង ៣៧% ចាប់តាំងពីឆ្នាំ ១៩៩០ មក ភាគច្រើន ដោយសារតែកំណើនចំនួនប្រជាជន ដល់ ១៨២ លាននាក់ នៅក្នុងឆ្នាំ ២០១១។ ត្រឹមឆ្នាំ ២០១៥ គេព្យាករថា មានមនុស្សពេញវ័យមិនចេះអក្សរ ២៦% នឹងរស់នៅក្នុងតំបន់អាហ្វ្រិចសាប់សាហារ៉ា ពោលគឺកើនពី ១៥% នៅក្នុងឆ្នាំ ១៩៩០។

វឌ្ឍនភាពយឺតយ៉ាវ មានន័យថា មានការប្រែប្រួលតិចតួចប៉ុណ្ណោះ នូវចំនួនប្រទេស ដែលសម្រេចបានសកលកម្មអក្ខរកម្មមនុស្សពេញវ័យ។ ក្នុងចំណោមប្រទេសចំនួន ៨៧ មាន ២១% ដែលសម្រេចបានសកលកម្មអក្ខរកម្មមនុស្សពេញវ័យ នៅក្នុងឆ្នាំ ២០០០។ ចន្លោះពីឆ្នាំ ២០០០ ដល់ ២០១១ ចំនួនប្រទេស ដែលឈានដល់កម្រិតនេះ បានកើនឡើងដល់ ២៦%។ ផ្ទុយទៅវិញ ប្រទេស ២៦% នៅឃ្លាតឆ្ងាយពីកម្រិតនេះ នៅក្នុងឆ្នាំ ២០១១។ នៅក្នុងឆ្នាំ ២០១៥ គេរំពឹងថា ប្រទេស ២៩% នឹងសម្រេចបាននូវសកលកម្មអក្ខរកម្មមនុស្សពេញវ័យ ស្របពេលដែល ៣៧% នៅឃ្លាតឆ្ងាយពីកម្រិតនេះនៅឡើយ។

ប្រទេសចំនួន ១៥ នៅអាហ្វ្រិចខាងលិច ស្ថិតនៅក្នុងចំណោមប្រទេសដែលមានអត្រាអក្ខរកម្មមនុស្សពេញវ័យ ទាបជាងគេ នៅលើសកលលោក ហើយមានប្រទេសចំនួន ៥ ដែលមានអត្រាអក្ខរកម្មទាបជាងគេក្នុងលោក ពោលគឺទាបជាង ៣៥%។ ប្រទេសទាំង ៥ នេះ ក៏មានអត្រាអក្ខរកម្មរបស់ស្រ្តី ក្រោម ២៥% ផងដែរ បើធៀបជាមួយនឹងអត្រាមធ្យម ៥០% នៅក្នុងតំបន់អាហ្វ្រិចសាប់សាហារ៉ានេះ។ និន្នាការទាំងនេះ ទំនងជានឹងមានការរីកចម្រើន ក្នុងពេលឆាប់ៗនេះ ឡើយ។ នៅក្នុងប្រទេសចំនួន ១២ ក្នុងចំណោមប្រទេសចំនួន ១៥ មានស្រ្តីវ័យក្មេងតិចជាងពាក់កណ្តាលដែលចេះអក្សរ។

## គោលដៅទី ៥ ៖ យុគភាព និងសមភាពយេនឌ័រ

យុគភាពយេនឌ័រ - ការធានាឱ្យអត្រាចូលរៀនរបស់ក្មេងស្រី និងក្មេងប្រុស មានស្មើគ្នា គឺជាជំហានទីមួយ ដើម្បី ឈានទៅសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នាទី ៥។ គោលដៅពេញលេញ ពោលគឺសមភាពយេនឌ័រ ក៏ទាមទារឱ្យមានបរិយាកាសសមស្របក្នុងសាលារៀន ការរៀនសូត្រដោយពុំមានការរើសអើង និងឱកាសស្មើភាពគ្នារវាងក្មេងប្រុស និងក្មេងស្រីផងដែរ ដើម្បីឱ្យពួកគេអាចសម្រេចនូវសក្តានុពលរបស់ពួកគេ។

និន្នាការគម្លាតយេនឌ័រ មានការប្រែប្រួលរវាងប្រទេសមួយ និងប្រទេសមួយទៀត ទៅតាមក្រុមចំណូលផ្សេងៗ។ ក្នុងចំណោមប្រទេសដែលមានចំណូល

**រូបភាពទី ៥ ៖ ប្រទេសចំនួន ១០ ដែលស្រូបយកមនុស្សពេញវ័យមិនចេះអក្សរ ៧២% ក្នុងចំណោមចំនួនមនុស្សពេញវ័យ មិនចេះអក្សរសរុបក្នុងពិភពលោក**

ចំនួនមនុស្សពេញវ័យមិនចេះអក្សរ ប្រទេសចំនួន ១០ ដែលមានមនុស្សពេញវ័យមិនចេះអក្សរច្រើនជាងគេ ១៩៨៥-១៩៩៤ និង ២០០៥-២០១១




*មិនមានទិន្នន័យ

*ប្រភព ៖ ឧបសម្ព័ន្ធ តារាងស្ថិតិទី ២*

ទាប គម្លាតច្រើនតែមាននៅខាងក្មេងស្រី ៖ ប្រទេស ២០% សម្រេចបាននូវយុគភាពយេនឌ័រ នៅកម្រិតអប់រំបឋមសិក្សា ១០% នៅកម្រិតអប់រំមធ្យមសិក្សាបឋមភូមិ និង ៨% នៅកម្រិតអប់រំមធ្យមសិក្សាទុតិយភូមិ។ ក្នុងចំណោមប្រទេសចំណូលមធ្យម និងខ្ពស់ ដែលមានប្រទេសជាច្រើនបានសម្រេចនូវយុគភាព នៅគ្រប់កម្រិត គម្លាតយេនឌ័រច្រើនតែលំអៀងទៅរកក្មេងប្រុសវិញ នៅពេលដែលកុមារបន្តទៅរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ។ ឧទាហរណ៍ ប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ២% មានគម្លាតនៅខាងក្មេងប្រុស នៅក្នុងសាលាបឋមសិក្សា ២៣% នៅក្នុងសាលាមធ្យមសិក្សាបឋមភូមិ និង ៦២% នៅក្នុងសាលាមធ្យមសិក្សាទុតិយភូមិ (រូបភាពទី ៦)។

ការសម្រេចឱ្យបាននូវយុគភាព នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ត្រូវបានកំណត់ថាត្រូវសម្រេចឱ្យបាន នៅមុនឆ្នាំ ២០០៥ ពោលគឺឆាប់ជាងគោលដៅដទៃទៀត។ ប៉ុន្តែ សូម្បីតែមកដល់ឆ្នាំ ២០១១ មានប្រទេសជាច្រើន ដែលនៅមិនទាន់សម្រេចគោលដៅនេះនៅឡើយ។ នៅកម្រិតបឋមសិក្សា ក្នុងចំណោមប្រទេសចំនួន ១៦១ មាន ៥៧% ដែលបានសម្រេចយុគភាពយេនឌ័រ នៅក្នុងឆ្នាំ ១៩៩៩។ ចន្លោះពីឆ្នាំ ១៩៩៩ ដល់ ២០១១ ភាគរយនៃប្រទេស ដែលបានសម្រេចចំណុចដៅនេះ បានកើនឡើងដល់ ៦៣%។ ចំនួនប្រទេស ដែលឆ្ងាយជាងគេពីចំណុចដៅនេះ ពោលគឺប្រទេស ដែលមានក្មេងស្រីតិចជាង ៩០ នាក់ រៀងរាល់ក្មេងប្រុស ១០០ នាក់ បានចូលរៀន បានថយចុះពី ១៩% នៅក្នុងឆ្នាំ ១៩៩៩ មកនៅ ៩% នៅក្នុងឆ្នាំ ២០១១។

សម្លឹងមើលទៅថ្ងៃអនាគត គេព្យាករថា ត្រឹមឆ្នាំ ២០១៥ ប្រទេសចំនួន ៧០% នឹងសម្រេចគោលដៅនេះ ហើយ មានប្រទេស ៩% ដែលនឹងទៅកៀកនឹងសម្រេចគោលដៅនេះ។ ផ្ទុយទៅវិញ ប្រទេស ១៤% នៅឆ្ងាយពីចំណុចដៅនេះ និង ៧% នៅឆ្ងាយខ្លាំង ក្នុងនោះប្រទេសចំនួន ៣ ភាគ ៤ ស្ថិតនៅតំបន់អាហ្វ្រិចសាប់សាហារ៉ា។

ការបោះជំហានទៅសម្រេចយុគភាពយេនឌ័រ មិនមែនជានិច្ចកាល មានន័យថា ត្រូវមានកុមារឱ្យបានច្រើននាក់ រៀនក្នុងសាលានោះទេ។ ឧទាហរណ៍ គេព្យាករថា ប្រទេសប៊ើគីណាហ្វាសូ នឹងសម្រេចយុគភាពនៅសាលាបឋមសិក្សា នៅឆ្នាំ ២០១៥ ប៉ុន្តែប្រទេសនេះនៅមានអត្រារួមនៅនៃការសិក្សាទាបជាងគេទី ៧ នៅក្នុងពិភពលោក។ លើសពីនេះ នៅក្នុងប្រទេសសេណេហ្គាល់ ដែលមានការសម្រេចបាននូវវឌ្ឍនភាពក្នុងការកាត់បន្ថយគម្លាតយេនឌ័រ ការសម្រេចបានបែបនេះ គឺដោយសារតែអត្រានៃការសិក្សារបស់សិស្សស្រីមានការកើនឡើង ខណៈពេលដែលអត្រានៃការសិក្សារបស់សិស្ស ប្រុសមិនមានការកើនឡើងសោះ ចាប់តាំងពីឆ្នាំ ២០០៤ មក។

នៅកម្រិតអប់រំមធ្យមសិក្សាបឋមភូមិ ក្នុងចំណោម ១៥០ ប្រទេសមាន ៤៣% ដែលបានសម្រេចយុគភាព យេនឌ័រ នៅក្នុងឆ្នាំ ១៩៩៩។ គេព្យាករថា នៅត្រឹមឆ្នាំ ២០១៥ មានប្រទេស ៥៦% នឹងសម្រេចនូវចំណុចដៅនេះ។ នៅចុងម្ខាងទៀត ប្រទេស ៣៣% នៅឆ្ងាយពីចំណុចដៅនេះ នៅក្នុងឆ្នាំ ១៩៩៩ ដែលក្នុងនោះមានប្រទេស ៣ ភាគ ៤ មាន គម្លាត ទៅខាងក្មេងស្រី។ គេរំពឹងថា ត្រឹមឆ្នាំ ២០១៥ ប្រទេស ២១% នៅតែមានបញ្ហាគម្លាតយេនឌ័រ នៅសាលាមធ្យមសិក្សាបឋមភូមិ ក្នុងនោះមាន ៧០% នឹងមានគម្លាតយេនឌ័រនេះ លំអៀងទៅរកក្មេងស្រី។

ការសម្រេចឱ្យបាននូវវឌ្ឍនភាពឆាប់រហ័ស គឺអាចធ្វើទៅបាន ដូចដែលបង្ហាញនៅក្នុងឧទាហរណ៍របស់ប្រទេសតួគី ៖ ប្រទេសនេះស្ទើរតែសម្រេចបាននូវយុគភាពយេនឌ័រ នៅកម្រិតមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ បើទោះបីជាសន្ទស្សន៍យុគភាពយេនឌ័រ នៅក្នុងឆ្នាំ ១៩៩៩ មាន ០,៧៤ នៅកម្រិតមធ្យមសិក្សាបឋមភូមិ និង ០,៦២ នៅកម្រិត មធ្យមសិក្សាទុតិយភូមិក៏ដោយ។ ប៉ុន្តែ គេមិនអាចបង្អែបង្អន់បានទេ។ ការយល់ឃើញជាប្រពៃណីអំពីតួនាទីយេនឌ័រ ដែលសាយភាយក្នុងសង្គមទាំងមូល ក៏ជ្រាបចូលទៅដល់សាលារៀនផងដែរ។

**ត្រឹមឆ្នាំ ២០១៥ ប្រទេស ៧០% ត្រូវបានគេរំពឹងថា នឹងសម្រេចបាននូវយុគភាពយេនឌ័រ នៅក្នុងការអប់រំកម្រិតបឋមសិក្សា**

**រូបភាពទី ៦ ៖ មានប្រទេសចំណូលទាបមួយចំនួនតូច ដែលសម្រេចបានយុគភាពយេនឌ័រ នៅគ្រប់កម្រិតអប់រំទាំងអស់**
ប្រទេសដែលមានយុគភាពយេនឌ័រ នៅក្នុងអត្រាសិក្សា បែងចែកតាមក្រុមចំណូលរបស់ប្រទេស ២០១១




*ប្រភព ៖ មូលដ្ឋានទិន្នន័យ UIS*

## គោលដៅទី ៦ ៖ គុណភាពនៃការអប់រំ

ការបង្កើនគុណភាពនៃការរៀនសូត្រ ទំនងជានឹងកាន់តែមានសារៈសំខាន់ ចំពោះក្របខ័ណ្ឌអភិវឌ្ឍន៍ជាសកល ក្រោយឆ្នាំ ២០១៥។ ការផ្លាស់ប្តូរនេះ បែបនេះ មានសារៈសំខាន់ ដើម្បីបង្កើនឱកាសអប់រំដល់កុមារ ២៥០ លាននាក់ ដែល មិនចេះអាន សរសេរ ឬគណនាប្រមាណវិធីងាយៗ ក្នុងនោះមាន ១៣០ លាននាក់ កំពុងរៀនសូត្រតាមសាលារៀន។

**ក្នុងប្រទេស ១ ភាគ ៣ មានគ្រូតិចជាង ៧៥% បានទទួលការបណ្តុះបណ្តាល**

ផលធៀបសិស្ស-គ្រូ គឺជារង្វាស់មួយ សម្រាប់ធ្វើការវាយតម្លៃវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅទី ៦។ នៅទូទាំងសកលលោកទាំងមូល ផលធៀបសិស្ស-គ្រូជាមធ្យម ស្ទើរតែពុំមានការប្រែប្រួល នៅកម្រិតមត្តេយ្យ បឋម និងមធ្យមសិក្សា។ នៅតំបន់អាហ្វ្រិចសាប់សាហា៉រា ដែលការជ្រើសរើសគ្រូ មានភាពយឺតយ៉ាវជាងកំណើនចំនួនសិស្សចូលរៀន ផលធៀបនេះនៅទ្រឹង ហើយឥឡូវនេះ ជាផលធៀបដែលខ្ពស់ជាងគេ នៅក្នុងពិភពលោក សម្រាប់កម្រិតមត្តេយ្យ និងបឋមសិក្សា។ ក្នុងចំណោមប្រទេសទាំង ១៦២ ដែលមានទិន្នន័យ នៅក្នុងឆ្នាំ ២០១១ ប្រទេសចំនួន ២៦ មានផលធៀប សិស្ស-គ្រូ នៅបឋមសិក្សា លើសពី ៤០ ៖ ១ ដែលក្នុងនោះមាន ២៣ ប្រទេស ស្ថិតនៅក្នុងតំបន់អាហ្វ្រិចសាប់សាហា៉រា។

ចន្លោះពីឆ្នាំ ១៩៩៩ ដល់ ២០១១ ផលធៀបសិស្ស-គ្រូ នៅបឋមសិក្សា បានកើនឡើងយ៉ាងហោចណាស់ ២០% នៅក្នុងប្រទេសចំនួន ៩។ ផ្ទុយទៅវិញ ផលធៀបនេះមានការថយចុះជិត ២០% នៅក្នុងប្រទេសចំនួន ៦០។ ប្រទេស កុងហ្គោ អេត្យូពី និងម៉ាលើ មានការកើនឡើងនូវចំនួនសិស្សចុះឈ្មោះចូលរៀនក្នុងសាលាបឋមសិក្សាពីរដង ប៉ុន្តែ ផលធៀបសិស្ស-គ្រូ មានការថយចុះជាង សិស្ស ១០ នាក់ ក្នុងគ្រូម្នាក់។

ប៉ុន្តែ ប្រទេសជាច្រើនបានបង្កើនចំនួនគ្រូយ៉ាងឆាប់រហ័ស ដោយបានជួលគេឱ្យបង្រៀន ដោយមិនបានផ្តល់ការ បណ្តុះបណ្តាល។ នេះអាចឱ្យមានកុមារកាន់តែច្រើននាក់បានចូលរៀន ប៉ុន្តែអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពនៃការអប់រំ។ នៅក្នុងប្រទេស ១ ភាគ ៣ ដែលមានទិន្នន័យ មានគ្រូតិចជាង ៧៥% ទទួលបានការបណ្តុះបណ្តាល ទៅតាមស្តង់ដាជាតិ។ ផលធៀបសិស្ស-គ្រូដែលបានទទួលការបណ្តុះបណ្តាល មានលើសពីផលធៀបសិស្ស-គ្រូ ក្នុងចំនួនសិស្ស ១០ នាក់ នៅក្នុងប្រទេសចំនួន ២៩ ក្នុងចំណោមប្រទេសចំនួន ៩៨ ដែលក្នុងនោះមានប្រទេស ២ ភាគ ៣ ស្ថិតនៅក្នុងតំបន់អាហ្វ្រិចសាប់សាហា៉រា (រូបភាពទី ៧)។

នៅកម្រិតមធ្យមសិក្សា ក្នុងប្រទេសចំនួន ១៤ ក្នុងចំណោមប្រទេស ១៣០ ដែលមានទិន្នន័យ ផលធៀបសិស្ស-គ្រូ មានលើសពី ៣០ ៖ ១។ បើទោះបីជាប្រទេសភាគច្រើនលើសលុប ដែលប្រឈមនឹងបញ្ហាធំៗជាងគេ គឺជាប្រទេសនៅ អាហ្វ្រិចសាប់សាហា៉រាយ៉ាងណាក៏ដោយ តំបន់នេះបានបង្កើនចំនួនគ្រូមធ្យមសិក្សាទ្វេដង ចន្លោះពីឆ្នាំ ១៩៩៩ ដល់ ២០១១។ ក្នុងចំណោមប្រទេសចំនួន ៦០ ដែលមានទិន្នន័យអំពីភាគរយនៃគ្រូមធ្យមសិក្សា ដែលទទួលបានការបណ្តុះបណ្តាល មានប្រទេសពាក់កណ្តាល ដែលមានបុគ្គលិកសិក្សាតិចជាង ៧៥% បានទទួលការបណ្តុះបណ្តាលតាមស្តង់ដាជាតិ ក្នុងនោះមានប្រទេសចំនួន ១១ ដែលមានបុគ្គលិកសិក្សាតិចជាង ៥០% បានទទួលការបណ្តុះបណ្តាល។

ភាគរយគ្រូ ដែលបានទទួលការបណ្តុះបណ្តាលទៅតាមស្តង់ដាជាតិ មានកម្រិតទាប ជាពិសេស នៅកម្រិតមត្តេយ្យសិក្សា។ បើទោះបីជាចំនួនគ្រូ នៅកម្រិតនេះ មានការកើនឡើង ៥៣% ចាប់តាំងពីឆ្នាំ ២០០០ មកក៏ដោយ ក្នុងប្រទេស ៤០ ក្នុងចំណោម ៧៥ ដែលមានទិន្នន័យ មានគ្រូតិចជាង ៧៥% ដែលបានទទួលការបណ្តុះបណ្តាល ទៅតាមស្តង់ដាជាតិ។

នៅក្នុងបរិបទមួយចំនួន វត្តមានរបស់គ្រូស្រី មានសារៈសំខាន់ សម្រាប់ទាក់ទាញក្មេងស្រីឱ្យមកសាលារៀន និងលើកកម្ពស់លទ្ធផលរៀនសូត្ររបស់ពួកគេ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ចំនួនគ្រូស្រី នៅមានការខ្វះខាត នៅតាមប្រទេសមួយចំនួន ដែលគម្លាតយេនឌ័រមានកម្រិតខ្ពស់ នៅក្នុងការចូលរៀនរបស់សិស្ស ដូចជា នៅក្នុងប្រទេស Djibouti និង Eritrea ជាដើម។

គ្រូត្រូវការឯកសាររៀនសូត្រប្រកបដោយគុណភាព ដើម្បីឱ្យការបង្រៀនរបស់ពួកគេអាចមានប្រសិទ្ធភាព ប៉ុន្តែ ពួកគេជាច្រើននាក់ពុំមានសៀវភៅសិក្សាសម្រាប់ប្រើប្រាស់ឡើយ។ នៅក្នុងសាធារណរដ្ឋតង់ហ្សានៀ មានសិស្សថ្នាក់ទី ៦ តែ ៣,៥% ប៉ុណ្ណោះ ដែលមានសៀវភៅសម្រាប់អានម្នាក់មួយក្បាល។ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គឺជាបញ្ហាមួយទៀត សម្រាប់សិស្ស នៅតាមបណ្តាប្រទេសក្រីក្រជាច្រើន។ ជារឿយៗ កុមារត្រូវប្រជ្រៀតគ្នារៀនក្នុងថ្នាក់រៀន ដែលមានសិស្ស ច្រើនជាពិសេស កុមាររៀនថ្នាក់ដំបូងៗ និងកុមារដែលជួបប្រទះការលំបាក។ នៅក្នុងប្រទេសម៉ាឡាវី ជាមធ្យម មានកុមារ ១៣០ នាក់ នៅក្នុងថ្នាក់ទី ១ បើធៀបជាមួយនឹង ៦៤ នាក់ នៅថ្នាក់ចុងក្រោយ។ នៅក្នុងប្រទេសឆាដ ក្នុងចំណោម សាលារៀន ៤ កន្លែង មានសាលារៀនតែមួយកន្លែងប៉ុណ្ណោះ ដែលមានបង្គន់ប្រើប្រាស់ ហើយក្នុងចំណោមបង្គន់ចំនួន ៣ មានបង្គន់តែ ១ ប៉ុណ្ណោះ សម្រាប់ឱ្យក្មេងស្រីប្រើប្រាស់។

**រូបភាពទី ៧ ៖ នៅក្នុងប្រទេសចំនួន ២៩ មានគម្លាតមួយដ៏ធំរវាងចំនួនសិស្សក្នុងគ្រូម្នាក់ និងចំនួនសិស្សក្នុងគ្រូម្នាក់ ដែលបាន ទទួលការបណ្តុះបណ្តាល**

ផលធៀបសិស្ស-គ្រូ និងផលធៀបសិស្ស-គ្រូដែលទទួលបានការបណ្តុះបណ្តាល នៅកម្រិតបឋមសិក្សា ប្រទេសដែលផលធៀបសិស្ស-គ្រូដែលទទួលបានការបណ្តុះបណ្តាលលើសពីផលធៀបសិស្ស-គ្រូ យ៉ាងហោចណាស់ ១០ ៖ ១ ឆ្នាំ ២០១១




*ប្រភព ៖ ឧបសម្ព័ន្ធ តារាងស្ថិតិទី ៨*

ដោយមានកុមារចំនួន ២៥០ លាននាក់ មិនបានរៀនសូត្រចំណេះដឹងជាមូលដ្ឋាន ជាការសំខាន់ណាស់ ដែល គោលដៅសកលក្រោយឆ្នាំ ២០១៥ ត្រូវបង្កើតឡើង ដើម្បីធ្វើការពិនិត្យតាមដាន ថាតើ នៅត្រឹមឆ្នាំ ២០៣០ គ្រប់កុមារ និងយុវជនទាំងអស់ មិនថាពួកគេស្ថិតក្នុងកាលៈទេសៈបែបណានោះទេ បានទទួលជំនាញជាមូលដ្ឋានផ្នែកអាន សរសេរ និងគណិតវិទ្យាដែរឬទេ។ ការបំពេញតម្រូវការនេះ ទាមទារឱ្យប្រទេសទាំងឡាយធ្វើការពង្រឹងប្រព័ន្ធវាយតម្លៃថ្នាក់ជាតិរបស់ខ្លួន និងធានាយ៉ាងណាឱ្យមានការប្រើប្រាស់ការវាយតម្លៃទាំងនេះជាព័ត៌មានសម្រាប់តាក់តែងគោលនយោបាយ។ នៅក្នុងន័យនេះ ប្រព័ន្ធវាយតម្លៃថ្នាក់ជាតិ នៅមានការខ្វះខាតច្រើននៅឡើយ។ ជារឿយៗ រដ្ឋាភិបាលនានាចាត់ទុកប្រព័ន្ធប្រឡងសាធារណៈ ថាសមមូលទៅនឹងប្រព័ន្ធវាយតម្លៃថ្នាក់ជាតិ បើទោះបីជាប្រព័ន្ធនេះប្រើប្រាស់សំខាន់បំផុត ដើម្បីឱ្យសិស្សឡើងថ្នាក់ពីកម្រិតអប់រំមួយ ទៅកម្រិតអប់រំមួយទៀតក៏ដោយ។ ការវាយតម្លៃថ្នាក់ជាតិ គួរតែជាឧបករណ៍វិភាគ ដែលអាចធ្វើការកំណត់ថាតើសិស្សអាចសម្រេចទៅតាមស្តង់ដានៃការរៀនសូត្រ ដែលគេរំពឹងថានឹងមាននៅអាយុ ឬថ្នាក់អ្វីមួយដែរឬទេ និងថាតើការសម្រេចទៅតាមស្តង់ដានេះមានការប្រែប្រួល សម្រាប់ក្រុមសិស្សតូចៗទៀតដែរឬទេ។

ការវាយតម្លៃថ្នាក់តំបន់ និងអន្តរជាតិ មានសារៈសំខាន់ សម្រាប់ពិនិត្យតាមដានគោលដៅរៀនសូត្រជាសកល ក្រោយឆ្នាំ ២០១៥។ ដូចគ្នានឹងការដែលការពិនិត្យតាមដានជាសកលដែលប្រសើរជាងមុនលើការទទួលបានការអប់រំ បាន ជួយរក្សាសម្ពាធលើរដ្ឋាភិបាល ដើម្បីធានាយ៉ាងណាឱ្យកុមារគ្រប់រូបអាចរៀនចប់សាលាបឋមសិក្សាដូច្នោះដែរ ការពិនិត្យតាមដានឱ្យបានកាន់តែប្រសើរលើការរៀនសូត្រ អាចជម្រុញឱ្យរដ្ឋាភិបាល ធានាឱ្យប្រាកដថា កុមារគ្រប់រូបមិនត្រឹមតែ បានទៅរៀនក្នុងសាលាប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ទទួលបានចំណេះដឹងជាមូលដ្ឋានផងដែរ។

ដើម្បីឱ្យការវាយតម្លៃទាំងនេះ អាចសម្រួលដល់ការពិនិត្យតាមដានគោលដៅនៃការរៀនសូត្រជាសកល ក្រោយ ឆ្នាំ ២០១៥ មានគោលការណ៍សំខាន់ៗចំនួន ៣ ដែលគេត្រូវអនុវត្តតាម។ ទីមួយ ត្រូវមានការពិចារណាលើកុមារ និងយុវជនទាំងអស់ នៅពេលដែលមានការបកស្រាយលទ្ធផល ពោលគឺមិនត្រឹមតែពិចារណាតែពីអ្នកដែលបានរៀនសូត្រក្នុង សាលារៀន និងបានចូលរួម នៅក្នុងការវាយតម្លៃនោះទេ។ កុមារជួបប្រទះការលំបាក ប្រហែលជាស្ថិតនៅខាងក្រៅប្រព័ន្ធ សាលារៀនរួចទៅហើយ ដូច្នេះ ពួកគេមិនទំនងជាសម្រេចបាននូវស្តង់ដានៃការរៀនសូត្រកម្រិតអប្បបរមានោះទេ នៅពេលដែលធ្វើការវាយតម្លៃនោះ។ ការមិនរាប់បញ្ចូលពួកគេ មានន័យថា គេមិនបានដឹងពីវិសាលភាពរបស់បញ្ហាឱ្យបាន ទាំងស្រុងឡើយ។ ទីពីរ ព័ត៌មានកាន់តែប្រសើរអំពីប្រវត្តិ និងចរិតរបស់សិស្ស គឺជាព័ត៌មាន ដែលចាំបាច់ត្រូវមាន ដើម្បី កំណត់ឱ្យដឹងថាតើកុមារក្នុងក្រុមណាខ្លះ ដែលរៀនមិនចេះ។ ទីបី ព័ត៌មានអំពីគុណភាពនៃប្រព័ន្ធអប់រំ ក៏គួរតែដាក់បញ្ចូល ទៅក្នុងការវាយតម្លៃទាំងនេះផងដែរ។

## មិនទុកអ្នកណាម្នាក់ចោលឡើយ - តើវាត្រូវការពេលយូរប៉ុណ្ណា?

ក្រោយឆ្នាំ ២០១៥ ការងារដែលមិនទាន់ធ្វើចប់សព្វគ្រប់ នឹងបន្តមាន សម្រាប់គោលដៅអប់រំសម្រាប់ទាំងអស់គ្នា ទាំង ៦ ខណៈពេលដែលទំនងជានឹងមានការកំណត់អាទិភាពថ្មីៗបន្ថែមទៀត។ ការវិភាគលើរយៈពេល ដែលត្រូវការ ដើម្បីសម្រេចឱ្យបាននូវសកលកម្មនៃការបញ្ចប់ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ និងអក្ខរកម្មរបស់យុវជន នាំឱ្យគេមានការព្រួយបារម្ភ។

ខណៈពេលដែលគេរំពឹងថា ក្មេងប្រុសមកពីគ្រួសារមានជីវភាពធូរធា នឹងឈានទៅសម្រេចសកលកម្មនៃការបញ្ចប់ការអប់រំកម្រិតបឋមសិក្សា ត្រឹមឆ្នាំ ២០៣០ នៅក្នុងប្រទេសដែលមានចំណូលទាប និងមធ្យម ៥៦ ក្នុងចំណោម ៧៤ ក្មេងស្រីមកពីគ្រួសារក្រីក្រ នឹងអាចសម្រេចគោលដៅនេះបាន គិតត្រឹមឆ្នាំខាងលើនេះ តែនៅក្នុងប្រទេសចំនួន ៧ ប៉ុណ្ណោះ ដែលក្នុងនោះមានប្រទេសតែមួយប៉ុណ្ណោះ ដែលជាប្រទេសមានចំណូលទាប។ សូម្បីតែត្រឹមឆ្នាំ ២០៦០ ក្មេងស្រីមកពីគ្រួសារក្រីក្រ នៅក្នុងប្រទេសចំណូលទាបចំនួន ២៤ ក្នុងចំណោម ២៨ ក្នុងសំណាកគំរូនេះ នឹងមិនអាចសម្រេចគោលដៅនេះបានឡើយ។ នៅអាហ្វ្រិចសាប់សាហារ៉ា ប្រសិនបើនិន្នាការបច្ចុប្បន្ននេះនៅតែបន្តមានទៀត ក្មេងប្រុសមកពីគ្រួសារមានជីវភាពធូរធាបំផុត នឹងអាចសម្រេចសកលកម្មនៃការបញ្ចប់ការអប់រំកម្រិតបឋមសិក្សា នៅក្នុងឆ្នាំ ២០២១ ប៉ុន្តែក្មេងស្រីមកពីគ្រួសារក្រីក្រជាងគេ នឹងមិនអាចសម្រេចគោលដៅនេះឡើយ រហូតដល់ឆ្នាំ ២០៨៦ (រូបភាពទី ៨)។

**នៅអាហ្វ្រិចសាប់សាហារ៉ា ក្មេងស្រី មកពីគ្រួសារក្រីក្រជាងគេ នឹងមិនអាចសម្រេចបាននូវសកលកម្មនៃការបញ្ចប់ការអប់រំកម្រិតបឋមសិក្សាឡើយ រហូតដល់ឆ្នាំ ២០៨៦**

ការចំណាយពេលរៀននៅសាលាបឋមសិក្សា មិនអាចធានាបានថា កុមារម្នាក់នឹងរៀនចេះអាន និងសរសេរនោះ ឡើយ។ ក្នុងចំណោមប្រទេសចំនួន ៦៨ ដែលមានទិន្នន័យ គេព្យាករថា ស្ត្រីវ័យក្មេង ដែលមានជីវភាពក្រីក្រជាងគេ នឹង អាចសម្រេចបាននូវសកលកម្មអក្ខរកម្ម តែក្នុងឆ្នាំ ២០៧២ តែប៉ុណ្ណោះ។

ស្ថានភាពនេះរឹតតែធ្ងន់ធ្ងរទៅទៀត សម្រាប់ការបញ្ចប់ការអប់រំនៅកម្រិតមធ្យមសិក្សាបឋមភូមិ។ នៅក្នុងប្រទេសចំនួន ៤៤ ក្នុងចំណោម ៧៤ ប្រទេស ដែល

**រូបភាពទី ៨ ៖ ការសម្រេចនូវសកលកម្មនៃការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ អាស្រ័យលើអនាគត របស់តំបន់អាហ្វ្រិចសាប់សាហារ៉ា**

ឆ្នាំ ដែលត្រូវបានគេព្យាករ សម្រាប់សម្រេចនូវការបញ្ចប់ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ លើសពី ៩៧% បែងចែកតាមក្រុមសិស្ស នៅអាហ្វ្រិចសាប់សាហារ៉ា




*ប្រភព ៖ ការគណនារបស់ក្រុមតាក់តែងរបាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា (២០១៣) ផ្អែកតាម Lange (2013)*

ត្រូវបានគេយកមកធ្វើការវិភាគ មានគម្លាតយ៉ាងហោចណាស់ ៥០ ឆ្នាំ រវាងពេលដែលក្មេងប្រុសមកពីគ្រួសារធូរជាជាងគេទាំងអស់ អាចបញ្ចប់ការអប់រំនៅកម្រិតមធ្យមសិក្សាបឋមភូមិ និង ពេលដែលក្មេងស្រីក្រីក្រជាងគេទាំងអស់ នឹងបញ្ចប់ការអប់រំកម្រិតនេះដែរ។ ហើយប្រសិនបើ និន្នាការថ្មីៗនេះនៅតែបន្ត ទៀត ក្មេងស្រីមកពីគ្រួសារក្រីក្រជាងនៅអាហ្វ្រិចសាប់សាហារ៉ា នឹងអាចសម្រេចគោលដៅនេះបាន នៅក្នុងឆ្នាំ ២០១១ ឯណោះ ពោលគឺ ៦៤ ឆ្នាំ យឺតជាក្មេងប្រុសមកពីគ្រួសារ ដែលមានជីវភាពធូរជាជាងគេ។

ខណៈពេលដែលការព្យាករទាំងនេះបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំង ការព្យាករទាំងនេះធ្វើឡើង ដោយផ្អែកទៅ តាមនិន្នាការថ្មីៗ ដែលអាចមានការផ្លាស់ប្តូរ ប្រសិនបើរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងសហគមន៍អប់រំអន្តរជាតិ ខិតខំប្រឹងប្រែងរួមគ្នា ដើម្បីឱ្យមានការផ្តល់សេវាអប់រំសម្រាប់ទាំងអស់គ្នា រាប់បញ្ចូលទាំងអ្នកបាត់បង់ឱកាសផងដែរ។ ការព្យាករទាំងនេះក៏បង្ហាញផងដែរពីសារៈសំខាន់នៃការតាមដានវឌ្ឍនភាពឈានទៅសម្រេចគោលដៅអប់រំ សម្រាប់ក្រុមជួបប្រទះ នឹងការលំបាកជាងគេបំផុត ក្រោយឆ្នាំ ២០១៥ និងដើម្បីដាក់ឱ្យអនុវត្តនូវគោលនយោបាយនានាដែលរក្សាបាន និងពន្លឿនវឌ្ឍនភាពនានា តាមរយៈការដោះស្រាយបញ្ហាអតុល្យភាពទាំងនេះ។

## ការពិនិត្យតាមដានចំណុចដៅអប់រំជាសកល ក្រោយឆ្នាំ ២០១៥

ចាប់តាំងពីពេលដែលគោលដៅអប់រំសម្រាប់ទាំងអស់គ្នាទាំង ៦ ត្រូវបានអនុម័ត នៅទីក្រុងដាកា ប្រទេស សេណេហ្គាល់ នៅក្នុងឆ្នាំ ២០០៦ មក ការមិនមានចំណុចដៅ និងសូចនាករឱ្យបានជាក់លាក់ បានបន្ទុចបង្អាក់មិនឱ្យ អាទិភាពអប់រំមួយចំនួន មិនឱ្យទទួលបានការយកចិត្តទុកដាក់ ដែលអាទិភាពទាំងនេះសមនឹងទទួលបាន។

**ត្រឹមឆ្នាំ ២០១០ ស្ត្រីវ័យក្មេង រស់នៅ តាមជនបទ ដែល មានជីវភាព ក្រីក្រជាងគេ បាន ចំណាយពេល តិចជាង ៣ ឆ្នាំ ក្នុងសាលារៀន**

ការកំណត់គោលដៅថ្មីៗ ក្រោយឆ្នាំ ២០១៥ គួរអនុវត្តទៅតាមគោលការណ៍ ដែលចាត់ទុកការអប់រំជាសិទ្ធិមួយ ដោយធានាយ៉ាងណាឱ្យកុមារគ្រប់រូបមានឱកាសស្មើភាពគ្នា ដើម្បីទទួលបានការអប់រំ និងទទួលស្គាល់ពីដំណាក់កាលរៀនសូត្រនៅដំណាក់កាលនីមួយៗនៃជីវិតរបស់មនុស្សម្នាក់ៗ។ គួរតែមានគោលដៅស្នូលមួយក្រុម ដែលតម្រឹមស្របទៅតាម របៀបវារៈអភិវឌ្ឍន៍ជាសកល អមដោយសូចនាករកាន់តែលំអិត ដែលជាសមាសភាគមួយនៃក្របខ័ណ្ឌអប់រំសម្រាប់ទាំងអស់គ្នា ក្រោយឆ្នាំ ២០១៥។ គោលដៅនីមួយៗ ត្រូវតែមានភាពច្បាស់លាស់ និងអាចវាស់វែងបាន ក្នុងគោលបំណងធានា យ៉ាងណាមិនឱ្យមានការទុកអ្នកណាម្នាក់ចោលឡើយ។ ដើម្បីសម្រេចគោលដៅនេះបាន គួរមានការតាមដានវឌ្ឍនភាព ទៅតាមលទ្ធផល ដែលសម្រេចបានដោយក្រុមដែលបំពេញការងារក្នុងកម្រិតទាបជាងគេ ដោយធានាយ៉ាងណាឱ្យមានការកាត់បន្ថយគម្លាតរវាងពួកគេ និងអ្នកដែលសម្រេចលទ្ធផលបានល្អប្រសើរជាងពួកគេ។

ចំនួនឆ្នាំ ដែលយុវជនចំណាយក្នុងសាលារៀន គឺជារង្វាស់មួយ ដើម្បីឱ្យដឹងពីវឌ្ឍនភាពជារួមនៃការទទួលបានការអប់រំ។ ដើម្បីសម្រេចគោលដៅសកលកម្មនៃការបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ ត្រឹមឆ្នាំ ២០៣០ យុវជន ចាំបាច់ត្រូវចំណាយពេលប្រហែលជា ៩ ឆ្នាំ ក្នុងសាលារៀន។ គិតត្រឹមឆ្នាំ ២០១០ យុវជននៅទីប្រជុំជនមកពីគ្រួសារធូរជាជាងគេ បានចំណាយពេលលើសពី ៩ ឆ្នាំកន្លះ ជាមធ្យម នៅក្នុងសាលារៀន នៅក្នុងប្រទេសដែលមានចំណូលទាប និងជាង ១២ ឆ្នាំ នៅតាមបណ្តាប្រទេសចំណូលមធ្យមកម្រិតទាប។ ប៉ុន្តែ យុវតីមកពីគ្រួសារក្រីក្រជាងគេ នៅតំបន់ជនបទវិញ ចំណាយពេលក្នុងសាលារៀន តិចជាង ៣ ឆ្នាំ ទាំងក្នុង

**រូបភាពទី ៩ ៖ វិសមភាពនៃការទទួលបានការអប់រំ នៅតែមិនមានការផ្លាស់ប្តូរ នៅក្នុងទសវត្សរ៍ចុងក្រោយនេះ**

ចំនួនឆ្នាំទទួលបានការអប់រំ ២០-២៤ ឆ្នាំ រវាងឆ្នាំ ២០០០ និង ២០១០




*ប្រភព ៖ ការវិភាគរបស់ក្រុមតាក់តែងរបាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា (២០១៣) ផ្អែកតាមការអង្កេតប្រជាសាស្ត្រ និងសុខភាព និងការអង្កេតលើសំណុំសូចនាករចម្រុះ*

ប្រទេសដែលមានចំណូលទាប និងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ដែលធ្វើឱ្យពួកគេស្ថិតនៅក្រោមចំណុចដៅ ៦ ឆ្នាំ ដែលពាក់ព័ន្ធជាមួយនឹងសកលកម្មនៃការបញ្ចប់ការអប់រំ កម្រិតបឋមសិក្សា ដែលត្រូវសម្រេចឱ្យបាននៅត្រឹមឆ្នាំ ២០១៥ (រូបភាពទី ៩)។ នៅអាហ្វ្រិចសាប់សាហារ៉ា គម្លាតរវាង រយៈពេលដែលស្ត្រីជនបទក្រីក្រជាងគេ និងបុរសរស់នៅទីប្រជុំជនមានជីវភាពធូរជាជាងគេ ចំណាយក្នុងសាលារៀន តាមពិតទៅមានការកើនឡើងពី ៦,៩ ឆ្នាំ នៅក្នុងឆ្នាំ ២០០០ ដល់ ៨,៣ ឆ្នាំ នៅក្នុងឆ្នាំ ២០១០។

នៅក្នុងទសវត្សរ៍ចុងក្រោយនេះ មានការសម្រេចបានវឌ្ឍនភាព ក្នុងការប្រមូលកុមារចូលរៀននៅសាលាបឋមសិក្សា បានច្រើនជាងការធានាឱ្យកុមាររៀនចប់កម្រិតបឋមសិក្សា ឬមធ្យមសិក្សាបឋមភូមិ។ លើសពីនេះ វិសមភាពធ្ងន់ ធ្ងរ នៅតែមានហើយនៅក្នុងករណីមួយចំនួនមានកាន់តែធំជាងមុនទៅទៀត។ ឧទាហរណ៍ នៅអាហ្វ្រិចសាប់សាហារ៉ា ក្មេងប្រុសមកពីគ្រួសារដែលមានជីវភាពធូរជា នៅតំបន់ប្រជុំជនទាំងអស់ បានចូលសាលារៀន នៅក្នុងឆ្នាំ ២០០០។ នៅមុនចុងទសវត្សរ៍នេះ អត្រាបញ្ចប់ការអប់រំកម្រិតបឋមសិក្សារបស់ពួកគេបានឈានដល់ ៨៧% ហើយការបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិរបស់ពួកគេ បានឡើងដល់ ៧០%។ ផ្ទុយទៅវិញ ក្នុងចំណោមក្មេងស្រីមកពីគ្រួសារក្រីក្រជាងគេ នៅតំបន់ជនបទ មានតែ ៤៩% ប៉ុណ្ណោះ ដែលបានចូលសាលា នៅដើមទសវត្សរ៍នេះ និង ៦១% នៅមុនចុងទសវត្សរ៍នេះ។ ពួកគេត្រឹមតែ ២៥% ប៉ុណ្ណោះ ដែលរៀនចប់បឋមសិក្សា និង ១១% បានចប់មធ្យមសិក្សាបឋមភូមិ នៅក្នុងឆ្នាំ ២០០០។ លើសពីនេះ អត្រាទាំងនេះមានការថយចុះ នៅចុងទសវត្សរ៍នេះ មកនៅត្រឹម ២៣% និង ៩% ប៉ុណ្ណោះ។ វិសមភាព នៅអាស៊ីខាងត្បូង និងខាងលិច ក៏មានកម្រិតធំផងដែរ ហើយមិនមានការប្រែប្រួលឡើយ ៖ គិតត្រឹមចុងទសវត្សរ៍នេះ ខណៈពេលដែលមានក្មេងប្រុសមកពីគ្រួសារមានជីវភាពធូរជាជាងគេនៅតំបន់ប្រជុំជន ៨៩% បានបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ មានក្មេងស្រីជនបទមកពីគ្រួសារក្រីក្រជាងគេត្រឹមតែ ១៣% ប៉ុណ្ណោះ ដែលបានបញ្ចប់ការសិក្សាកម្រិតនេះ។

គោលដៅ ដែលពាក់ព័ន្ធជាមួយនឹងការរៀនសូត្រ គឺជាផ្នែកចាំបាច់មួយរបស់ក្របខ័ណ្ឌពិនិត្យតាមដានការអប់រំជាសកល ប៉ុន្តែការផ្តោតតែលើការវាយតម្លៃការរៀនសូត្រ អាចនាំឱ្យមានការភ័ន្តច្រឡំ ប្រសិនបើមានកុមារច្រើននាក់ ដែលមិនបានរៀនដល់កម្រិតថ្នាក់ ដែលមានការធ្វើតេស្តជំនាញ។ ឧទាហរណ៍ នៅសាធារណរដ្ឋតង់ហ្សានៀ ភាគរយកុមាររៀន ថ្នាក់ទី ៦ ដែលបានសម្រេចនូវស្តង់ដាអប្បបរមាផ្នែកការអាន នៅក្នុងឆ្នាំ ២០០៧ មានចាប់ពី ៨០% នៃក្មេងស្រីជនបទមកពីគ្រួសារក្រីក្រជាងគេ ដល់ ៩៧% នៃក្មេងប្រុសប្រជុំជនមកពីគ្រួសារធូរជាជាងគេ។ ប៉ុន្តែ ខណៈពេលដែល ក្មេងប្រុសប្រជុំជនមកពីគ្រួសារធូរជាជាងគេ ៩២% ដែលដល់អាយុរៀនថ្នាក់ទី ៦ បានរៀនដល់កម្រិតថ្នាក់នេះជាក់ស្តែង មានក្មេង ស្រីជនបទមកពីគ្រួសារក្រីក្រជាងគេត្រឹមតែ ៤០% ប៉ុណ្ណោះ ដែលអាចរៀនបែបនេះបាន។ ប្រសិនបើគេសន្មត់ថា កុមារ ដែលមិនបានរៀនដល់ថ្នាក់ទី ៦ មិនអាចសម្រេចទៅតាមស្តង់ដាអប្បបរមានោះ នោះភាគរយរបស់ក្រុមការងារ ដែលរៀនចេះចំណេះដឹងជាមូលដ្ឋានមាន ៩០% សម្រាប់ក្មេងប្រុសប្រជុំជនមកពីគ្រួសារធូរជាជាងគេ និង ៣២% សម្រាប់ក្មេងស្រីជនបទមកពីគ្រួសារក្រីក្រជាងគេ។

ដើម្បីឱ្យមានការជំនះបញ្ហាវិសមភាព នៅឆ្នាំ ២០៣០ ផែនការរបស់ប្រទេសនានា ចាំបាច់ត្រូវដាក់បញ្ចូលនូវចំណុចដៅជាក់លាក់ ដើម្បីឱ្យគេអាចពិនិត្យតាមដានការចូលរួមក្នុងការអប់រំ និងការរៀនសូត្ររបស់ក្រុមជាក់លាក់។ មានផែនការតិចតួចប៉ុណ្ណោះ ដែលមានដាក់បញ្ចូលនូវចំណុចដៅបែបនេះ។ យេនឌ័រ គឺជាបញ្ហា ដែលត្រូវបានគេលើកយកមក និយាយញឹកញាប់ជាងគេ នៅក្នុងផែនការអប់រំនានា ប៉ុន្តែមានផែនការប្រទេសត្រឹមតែ ២៤ លើ ៥៣ ដែលត្រូវបានយកមកពិនិត្យ សម្រាប់របាយការណ៍នេះ ប៉ុណ្ណោះ ដែលមានដាក់បញ្ចូលចំណុចដៅសមភាពយេនឌ័រ នៅក្នុងការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។

ផែនការចំនួន ៤ បានដាក់បញ្ចូលនូវសូចនាករអំពីការចូលរួមរបស់ជនជាតិភាគតិចមួយចំនួន។ មានផែនការតែ ៣ ប៉ុណ្ណោះ ដែលផ្តោតជាក់លាក់លើគម្លាតនៃការទទួលបានការអប់រំបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ រវាងតំបន់ជនបទ និងតំបន់ប្រជុំជន។ លើសពីនេះ មានផែនការតែ ៣ ប៉ុណ្ណោះ ដែលមានសូចនាករអំពីការចូលរៀន ដែលធ្វើការបែងចែក រវាងកុមារមកពីគ្រួសារក្រីក្រ និងកុមារមកពីគ្រួសារមានជីវភាពធូរជា។ ផែនការរបស់ប្រទេសបង់ក្លាដេស មានដាក់បញ្ចូលនូវក្របខ័ណ្ឌពិនិត្យតាមដានមួយ សម្រាប់ធ្វើការតាមដានវឌ្ឍនភាពនៃអត្រាសិក្សា ទៅតាមបញ្ចភាគទ្រព្យសម្បត្តិ ហើយផែនការរបស់ប្រទេសណាំមីបៀ មានដាក់បញ្ចូលចំណុចដៅ ធ្វើយ៉ាងណាឱ្យកុមារកំព្រា និងកុមារងាយរងគ្រោះដទៃទៀតចំនួន ៨០% នៅតាមតំបន់នីមួយៗ បានចុះឈ្មោះចូលរៀន នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ត្រឹមឆ្នាំចុងក្រោយរបស់ផែនការនេះ។

មានប្រទេសរឹតតែតិចតួចទៅទៀត ដែលមានផែនការពិនិត្យតាមដានវិសមភាព នៅក្នុងលទ្ធផលនៃការរៀនសូត្រ។ មានប្រទេសត្រឹមតែ ៨ ក្នុងចំណោម ៥៣ ប៉ុណ្ណោះ ដែលមានផែនការបែបនេះ នៅកម្រិតបឋមសិក្សា ហើយមានប្រទេសចំនួន ៨ ដែលមានផែនការនេះនៅកម្រិតមធ្យមសិក្សាបឋមភូមិ ហើយនៅក្នុងករណីភាគច្រើន ការពិនិត្យតាមដាន ត្រូវបានកំហិតត្រឹមតែវិសមភាពយេនឌ័រប៉ុណ្ណោះ។ ប្រទេសស្រីលង្កា គឺជាករណីលើកលែងមួយ ដោយសារតែប្រទេសនេះ មានកំណត់ចំណុចដៅ សម្រាប់ពិន្ទុគណិតវិទ្យា និងភាសាជាតិ សម្រាប់តំបន់ ដែលមានលទ្ធផលទាបជាងគេ។

**មានប្រទេសត្រឹមតែ ៨ ក្នុងចំណោម ៥៣ ប៉ុណ្ណោះ ដែលមានផែនការពិនិត្យតាមដានវិសមភាព ក្នុងការរៀនសូត្រ**

ការខកខាន នៅក្នុងទសវត្សរ៍ចុងក្រោយនេះ ដើម្បីធ្វើការវាយតម្លៃវឌ្ឍនភាពនៃការសម្រេចគោលដៅអប់រំ ទៅតាមអនុក្រុមប្រជាជន បានលាក់កំបាំងមិនឱ្យគេមើលឃើញវិសមភាពដ៏ធំ។ ការមិនឃើញបែបនេះ ត្រូវបានឆ្លុះបញ្ចាំង បន្ថែមទៀត តាមរយៈការមិនបានកំណត់ចំណុចដៅនៅថ្នាក់ជាតិ នៅក្នុងផែនការរបស់ប្រទេស សម្រាប់ធ្វើការវាយតម្លៃ វឌ្ឍនភាពនៃការកាត់បន្ថយគម្លាតក្នុងការទទួលបានការអប់រំ ឬការរៀនសូត្រ។ គោលដៅក្រោយឆ្នាំ ២០១៥ ចាំបាច់ត្រូវ តែដាក់បញ្ចូលការប្តេជ្ញាចិត្តដើម្បីធានាយ៉ាងណាឱ្យក្រុមដែលជួបប្រទះការលំបាកជាងគេ អាចសម្រេចទៅតាមចំណុចដៅ ដែលកំណត់សម្រាប់គោលដៅនានា។ ការខកខានមិនបានធ្វើបែបនេះ អាចមានន័យថា ការវាស់វែងវឌ្ឍនភាពនានានៅតែ បន្តលាក់កំបាំងការពិតដែលថា អ្នកដែលមានឱកាសច្រើនជាងគេ គឺជាអ្នកដែលទទួលបានប្រយោជន៍ជាងគេ។

# ការពិនិត្យតាមដានវឌ្ឍនភាពពាក់ព័ន្ធ នឹងការផ្តល់ហិរញ្ញប្បទានដល់ការអប់រំសម្រាប់ ទាំងអស់គ្នា

ការផ្តល់ថវិកាមិនបានគ្រប់គ្រាន់ គឺជាឧបសគ្គមួយ ក្នុងចំណោមឧបសគ្គចម្បងនានា ដែលធ្វើឱ្យរាំងស្ទះដល់ការ សម្រេចការអប់រំសម្រាប់ទាំងអស់គ្នា។ គម្លាតនៃការផ្តល់ថវិកា ដើម្បីសម្រេចការអប់រំសម្រាប់ទាំងអស់គ្នាប្រកបដោយ គុណភាព នៅត្រឹមឆ្នាំ ២០១៥ បានកើនឡើងដល់ ២៦ ពាន់លានដុល្លារ ដែលនាំឱ្យគោលដៅផ្តល់ការអប់រំក្នុងសាលារៀន ដល់កុមារគ្រប់រូប នៅឆ្ងាយពីការសម្រេចបាន។ អ្វីដែលគួរឱ្យសោកស្តាយ អ្នកផ្តល់ជំនួយទំនងជានឹងកាត់បន្ថយជំនួយរបស់ពួកគេ ជាជាងបង្កើន នៅក្នុងបណ្តាឆ្នាំខាងមុខនេះ។ ប្រសិនបើមិនមានការចាត់វិធានការបន្ទាន់ ដើម្បីធ្វើការផ្លាស់ប្តូរនិន្នាការនៃការផ្តល់ជំនួយនេះទេ នោះគោលដៅនៃការធានាឱ្យកុមារគ្រប់រូបបានចូលសាលារៀន និងទទួលបានការរៀនសូត្រ ត្រឹមឆ្នាំ ២០១៥ នឹងទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាមិនខាន។

> **ក្នុងចំណោម ១៥០ ប្រទេស មានប្រទេសត្រឹមតែ ៤១ ប៉ុណ្ណោះ ដែលបានចំណាយថវិកាចាប់ពី ៦% ឡើងទៅ នៃ ផលិតផលជាតិសរុប លើវិស័យអប់រំ នៅក្នុងឆ្នាំ ២០១១**

ជាមួយនឹងការសល់ពេលវេលាតិចតួចមុនឆ្នាំ ២០១៥ ការបិទគម្លាតថវិកានេះ ហាក់បីដូចជាមិនអាចធ្វើទៅបានឡើយ។ ប៉ុន្តែ ការវិភាគនៅក្នុងរបាយការណ៍នេះបង្ហាញថា គេអាចបំពេញគម្លាតនេះបាន តាមរយៈការបង្កើនចំណូលក្នុង ស្រុកឱ្យបានច្រើនជាងមុន និងបែងចែកធនធានរបស់រដ្ឋាភិបាលដែលមានស្រាប់ និងដែលបានព្យាករទុកឱ្យបានគ្រប់គ្រាន់ ដល់វិស័យអប់រំ និងសម្រួចគោលដៅរបស់ជំនួយ ដែលទទួលបានពីខាងក្រៅ។

ប្រសិនបើគោលដៅអប់រំថ្មី ក្រោយឆ្នាំ ២០១៥ គ្របដណ្តប់លើការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ ដូចការរំពឹង ទុកមែននោះ គម្លាតថវិកានេះនឹងកើនឡើងដល់ ៣៨ ពាន់លានដុល្លារ។ ក្របខ័ណ្ឌក្រោយឆ្នាំ ២០១៥ នេះ ត្រូវតែដាក់បញ្ចូលចំណុចដៅពាក់ព័ន្ធជាមួយនឹងការផ្តល់ហិរញ្ញប្បទានឱ្យបានច្បាស់លាស់ ដែលទាមទារឱ្យមានតម្លាភាពពេញលេញ ដើម្បីឱ្យគ្រប់អ្នកផ្តល់ជំនួយទាំងអស់មានគណនេយ្យភាពចំពោះការសន្យារបស់ពួកគេ ហើយគម្លាតថវិកានឹងមិនធ្វើឱ្យ ប៉ះពាល់ដល់ការសន្យា ដែលយើងមានចំពោះកុមារឡើយ។

## ប្រទេសជាច្រើន នៅមានលទ្ធភាពទាបឆ្ងាយជាងលទ្ធភាពចំណាយថវិកាបន្ថែមទៀតលើវិស័យអប់រំ ដើម្បីសម្រេចនូវ ការអប់រំសម្រាប់ទាំងអស់គ្នា

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការចំណាយក្នុងប្រទេសលើវិស័យអប់រំ មានការកើនឡើង ជាពិសេស នៅតាមប្រទេសដែលមានចំណូលទាប និងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប មួយផ្នែកដោយសារតែមានការ កើនឡើងនូវកំណើនសេដ្ឋកិច្ច។ ការចំណាយរបស់រដ្ឋាភិបាលលើវិស័យអប់រំ មានការកើនឡើងជាមធ្យមពី ៤,៦% ដល់ ៥,១% នៃផលិតផលជាតិសរុប (GNP) ចន្លោះពីឆ្នាំ ១៩៩៩ ដល់ ២០១១។ នៅតាមប្រទេសចំណូលទាប និងប្រទេស ចំណូលមធ្យម ចំណាយនេះមានការកើនឡើងលឿនជាងនេះ ៖ ប្រទេសចំនួន ៣០ ក្នុងចំណោមប្រទេសទាំងនេះ បានបង្កើន ចំណាយរបស់ពួកគេលើវិស័យអប់រំ ចាប់ពីមួយភាគរយចំណុចឡើងទៅ នៃ GNP ចន្លោះពីឆ្នាំ ១៩៩៩ និង ២០១១។

ក្របខ័ណ្ឌសកម្មភាពទីក្រុងដាកា មិនបានកំណត់ថាតើប្រទេសនានាគួរផ្តល់ថវិកាប៉ុន្មានដល់វិស័យអប់រំឡើយ។ ការខកខានមិនបានកំណត់ចំណុចដៅនៃការផ្តល់ហិរញ្ញប្បទានជារួម សម្រាប់គោលដៅអប់រំសម្រាប់ទាំងអស់គ្នា គួរយកមកគិតគូរពិចារណាក្រោយឆ្នាំ ២០១៥ ដោយមានការដាក់ចេញនូវគោលដៅជាក់លាក់ ពោលគឺប្រទេសនានាគួរបែងចែកឱ្យបានយ៉ាងហោចណាស់ ៦% នៃ GNP សម្រាប់វិស័យអប់រំ។ ក្នុងចំណោមប្រទេសទាំង ១៥០ ដែលមានទិន្នន័យ មានតែ ៤១ ប្រទេសប៉ុណ្ណោះ ដែលបានចំណាយចាប់ពី ៦% នៃ GNP លើវិស័យអប់រំ នៅក្នុងឆ្នាំ ២០១១ ហើយមានប្រទេសចំនួន ២៥ ដែលចំណាយថវិកាតិចជាង ៣%។

មានការទទួលស្គាល់ជាទូទៅថា ប្រទេសនានាគួរបែងចែកថវិកាឱ្យបានយ៉ាងហោចណាស់ ២០% នៃថវិការបស់ខ្លួន សម្រាប់វិស័យអប់រំ។ ប៉ុន្តែ ការវិភាជន៍ថវិកាគិតជាមធ្យមក្នុងសកលលោកទាំងមូល សម្រាប់វិស័យនេះ នៅក្នុងឆ្នាំ ២០១១ មានត្រឹមតែ ១៥% ប៉ុណ្ណោះ ដែលភាគរយនេះស្ទើរតែពុំមានការផ្លាស់ប្តូរ ចាប់តាំងពីឆ្នាំ ១៩៩៩ មក។ ក្នុងចំណោមប្រទេស ចំនួន ១៣៨ ដែលមានទិន្នន័យ មានតែ ២៥ ប៉ុណ្ណោះ ដែលចំណាយលើសពី ២០% នៅក្នុងឆ្នាំ ២០១១ ហើយក្នុងពេលជាមួយគ្នាមានប្រទេសចំណូលទាប និងចំណូលមធ្យមយ៉ាងហោចណាស់ ៦ បានកាត់បន្ថយចំណាយអប់រំរបស់ពួកគេ ចាប់ពី ៥ ភាគរយចំណុចឡើងទៅ ធៀបជាមួយនឹងចំណាយសរុបរបស់រដ្ឋាភិបាល ចន្លោះពីឆ្នាំ ១៩៩៩ ដល់ ២០១១។

គេមិនរំពឹងថា ស្ថានភាពនេះនឹងមានភាពល្អប្រសើរជាងមុន នៅក្នុងរយៈពេលប៉ុន្មានឆ្នាំទៀតខាងមុខនេះឡើយ។ ក្នុងចំណោម ៤៩ ប្រទេស ដែលមានទិន្នន័យ នៅក្នុងឆ្នាំ ២០១២ មានប្រទេសចំនួន ២៥ ដែលមានផែនការកាត់បន្ថយថវិកា អប់រំរបស់ខ្លួន ពីឆ្នាំ ២០១១ ដល់ ២០១២។ ក្នុងចំណោមប្រទេសទាំងនេះ មានប្រទេសចំនួន ១៦ ស្ថិតនៅក្នុងតំបន់ អាហ្វ្រិចសាប់សាហារ៉ា។ ប៉ុន្តែ ប្រទេសមួយចំនួន ក្នុងនោះមានប្រទេសអាហ្វហ្គានីស្ថាន បេនីន និងអេត្យូពីផង កំពុងប្រឆាំងតបតជាមួយនឹងនិន្នាការជាអវិជ្ជមាននេះ ហើយនឹងបង្កើនថវិកាអប់រំរបស់ខ្លួន។

ដើម្បីទាញប្រយោជន៍ពីសក្តានុពលកំណើនសេដ្ឋកិច្ច នៅក្នុងប្រទេសក្រីក្របំផុតជាច្រើន ក្នុងពិភពលោក រដ្ឋាភិបាល ទាំងឡាយចាំបាច់ត្រូវតែពង្រីកមូលដ្ឋានពន្ធរបស់ខ្លួន និងបែងចែកថវិកាចំនួន ១ ភាគ ៥ សម្រាប់វិស័យអប់រំ។ ប្រសិនបើរដ្ឋាភិបាលនៅក្នុងប្រទេសចំណូលទាប និងមធ្យមចំនួន ៦៧ ធ្វើដូចអ្វីដែលលើកឡើងខាងលើ ពួកគេអាចប្រមូលថវិកាបាន ១៥៣ ពាន់លានដុល្លារបន្ថែមទៀត សម្រាប់វិស័យអប់រំ នៅក្នុងឆ្នាំ ២០១៥។ នេះនឹងបង្កើនភាគរយនៃ GDP ជាមធ្យម ដែលចំណាយលើវិស័យអប់រំ ពី ៣% ដល់ ៦% នៅមុនឆ្នាំ ២០១៥។

ប្រទេសក្រីក្រមួយចំនួនតូច បានបង្កើនការប្រមូលពន្ធដល់ ២០% នៃ GDP ដែលជាការចាំបាច់ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ មានប្រទេសតែ ៧ ក្នុងចំណោម ៦៧ ប្រទេស ដែលមានទិន្នន័យប៉ុណ្ណោះ ដែលអាច ប្រមូលពន្ធបាន ២០% នៃ GDP ផង និងធ្វើការបែងចែកចំណូលចំនួន ២០% សម្រាប់វិស័យអប់រំ ដូចដែលផ្តល់ក្នុងអនុសាសន៍ខាងលើ។ នៅក្នុងប្រទេសប៉ាគីស្ថាន ចំណូលពន្ធមានត្រឹមតែ ១០% នៃ GDP ប៉ុណ្ណោះ ហើយវិស័យអប់រំទទួល បានត្រឹមតែ ១០% នៃចំណាយសរុបរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ។ ប្រសិនបើរដ្ឋាភិបាលបង្កើនចំណូលពន្ធរបស់ខ្លួនដល់ ១៤% នៃ GDP ត្រឹមឆ្នាំ ២០១៥ និងវិភាជន៍ ១ ភាគ ៥ នៃចំណូលនេះសម្រាប់វិស័យអប់រំ នោះរដ្ឋាភិបាលនេះនឹងអាច មានថវិកាគ្រប់គ្រាន់ ដើម្បីឱ្យកុមារ និងក្មេងជំទង់ទាំងអស់ក្នុងប្រទេសប៉ាគីស្ថាន ទទួលបានការអប់រំតាមសាលារៀនបាន។

ប្រទេសអេត្យូពី គឺជាប្រទេសមួយ ក្នុងចំណោម ១១ ប្រទេសលើ ៦៧ ប្រទេស ដែលទទួលបានជោគជ័យលើការចាត់ទុកវិស័យអប់រំ ជាវិស័យអាទិភាព នៅក្នុងថវិការបស់រដ្ឋាភិបាល ប៉ុន្តែអាចធ្វើការងារបន្ថែមទៀត ដើម្បីបង្កើនចំណូល ពីពន្ធដារដល់កម្រិតអតិបរមា។ នៅក្នុងឆ្នាំ ២០១១ រដ្ឋាភិបាលបានទទួលថវិកា ជាមធ្យម ១២% នៃ GDP ពីប្រភពពន្ធ។ ប្រសិនបើភាគរយនេះនឹងកើនឡើងដល់ ១៥% ត្រឹមឆ្នាំ ២០១៥ វិស័យនេះនឹងទទួលបានធនធាន ១៨% បន្ថែមទៀត ដែលអាចឱ្យគេចំណាយថវិកា ១៩ ដុល្លារបន្ថែមទៀត ដល់កុមារម្នាក់ ដែលដល់អាយុចូលរៀននៅសាលាបឋមសិក្សា។

ប៉ុន្តែ ចំណូលពន្ធ គិតជាភាគរយនៃ GDP មានការកើនឡើងយឺតយ៉ាវ មែនទែន នៅតាមប្រទេសក្រីក្រ។ នៅត្រឹមអត្រាបច្ចុប្បន្ននេះ មានប្រទេសតែ ៤ ក្នុងចំណោម ៤៨ ប្រទេស ដែលបច្ចុប្បន្ននេះប្រមូលពន្ធបានតិចជាង ២០% នៃ GDP នឹងអាចសម្រេចដល់កម្រិត ២០% នេះ នៅត្រឹមឆ្នាំ ២០១៥។

ប្រព័ន្ធប្រមូលពន្ធ ដែលដំណើរការបានល្អ ផ្តល់លទ្ធភាពឱ្យរដ្ឋាភិបាលនានាអាចផ្តល់ការគាំទ្រដល់ប្រព័ន្ធអប់រំរបស់ខ្លួន ដោយប្រើប្រាស់ប្រភពថវិកាក្នុងស្រុក។ ប្រទេសចំណូលមធ្យមមួយចំនួន ដូចជា អេហ្ស៊ីប ឥណ្ឌា និងហ្វីលីពីន ជាដើម មានសក្តានុពលធំធេង ក្នុងការកៀងគរធនធានក្នុងស្រុក សម្រាប់វិស័យអប់រំតាមរយៈការបង្កើនចំណូលពន្ធ។ ចំណូលពន្ធខ្ពស់ជាងមុន នៅក្នុងប្រទេសប្រេស៊ីល ជួយពន្យល់ពីមូលហេតុ ដែលប្រទេសនេះអាចចំណាយថវិកាដល់ទៅ ១០ ដង ច្រើនជាងប្រទេសឥណ្ឌា សម្រាប់កុមារម្នាក់ ដែលរៀននៅសាលាបឋមសិក្សា។

ប្រទេសមួយចំនួន នៅអាស៊ីខាងត្បូង ផ្តល់ការលើកលែងពន្ធយ៉ាងច្រើន ដល់ក្រុមក្នុងស្រុកមួយចំនួន ដែលមានឥទ្ធិពលខ្លាំង ដែលនេះនាំឱ្យប្រទេសទាំងនោះមានផលធៀបពន្ធលើ GDP ទាបជាងគេ នៅក្នុងពិភពលោក។ នៅក្នុងប្រទេសប៉ាគីស្ថាន ផលធៀបពន្ធលើ GDP ១០% អាចពន្យល់មួយផ្នែក ដោយសារតែឥទ្ធិពលនយោបាយរបស់អ្នកដែល បញ្ចុះបញ្ចូលរដ្ឋាភិបាល ដើម្បីប្រយោជន៍របស់ក្រុមហ៊ុនកសិកម្ម។ ខណៈពេលដែលវិស័យកសិកម្មមានប្រមាណជា ២២,៥% នៃ GDP របស់ប្រទេសប៉ាគីស្ថាន ភាគរយចំណូលពន្ធរបស់វិស័យនេះ មានត្រឹមតែ ១,២%ប៉ុណ្ណោះ។ នៅក្នុងប្រទេសឥណ្ឌា ចំណូលពន្ធភាគច្រើនដែលបាត់បង់ គឺដោយសារតែការលើកលែងមិនឱ្យមានការបង់ពន្ធនាំចូល និងអាករផ្សេងៗ។ ចំណូលដែលបាត់បង់ ដោយសារការលើកលែងពន្ធ ស្មើនឹង ៥,៧% នៃ GDP នៅក្នុងឆ្នាំ ២០១២-២០១៣។ ប្រសិនបើ ២០% នៃចំណូលនេះត្រូវបានបែងចែកសម្រាប់វិស័យអប់រំ នោះវិស័យនេះនឹងទទួលបានថវិកា ២២,៥ ពាន់លានដុល្លារបន្ថែមទៀត នៅក្នុងឆ្នាំ ២០១៣ ដែលនាំឱ្យមានការបង្កើនថវិកាបានដល់ជិត ៤០% បើធៀបជាមួយនឹងថវិកាសម្រាប់វិស័យអប់រំបច្ចុប្បន្ន។

រដ្ឋាភិបាលមួយចំនួន លក់សម្បទានទាញប្រយោជន៍ពីធនធានធម្មជាតិ តិចជាងតម្លៃពិតប្រាកដរបស់ធនធានទាំង នោះ។ សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ខាតបង់ថវិកា ១,៣៦ ពាន់លានដុល្លារ ដោយសារការផ្តល់សម្បទានដល់ ក្រុមហ៊ុនរុករករ៉ែ ក្នុងរយៈពេល ៣ ឆ្នាំ ពីឆ្នាំ ២០១០ ដល់ ២០១២ ស្មើនឹងចំនួនថវិកាវិភាជន៍សម្រាប់វិស័យអប់រំ ក្នុងរយៈពេល ២ ឆ្នាំ ក្នុងឆ្នាំ ២០១០ និង ២០១១។

សម្រាប់ប្រទេសក្រីក្រជាងគេជាច្រើនក្នុងពិភពលោក ការគេចវេសមិនបង់ពន្ធ នាំឱ្យជនមានអំណាចអាចបង្កើនទ្រព្យធនសម្រាប់ខ្លួនឯង ជាជាងធ្វើឱ្យប្រព័ន្ធអប់រំមានភាពរឹងមាំ សម្រាប់ប្រជាជនភាគច្រើន។ ប្រសិនបើថវិការាប់រយពាន់លានដុល្លារ ដែលគេប៉ាន់ប្រមាណថាខាតបង់ ដោយសារការគេចមិនបង់ពន្ធត្រូវបានគេប្រមូលបានវិញនោះ ហើយ ២០% នៃចំណូលដែលប្រមូលបាននេះ ត្រូវបានគេយកមកបែងចែកសម្រាប់វិស័យអប់រំ នោះគេនឹងអាចបន្ថែមថវិកាចន្លោះពី ៣៨ ពាន់លានដុល្លារ ដល់ ៥៦ ពាន់លានដុល្លារ សម្រាប់វិស័យនេះ។

` ការគេចពន្ធខុសច្បាប់ ធ្វើឱ្យរដ្ឋាភិបាលនៅអាហ្វ្រិចខាតបង់ថវិកាប្រមាណជា ៦៣ ពាន់លានដុល្លារ ក្នុងមួយឆ្នាំ។ ប្រសិនបើគេអាចបញ្ឈប់ទង្វើទាំងនេះបាន ហើយយក ២០% នៃចំណូលដែលប្រមូលបានវិញនេះ មកចំណាយលើវិស័យអប់រំ គេអាចប្រមូលថវិកាបាន ១៣ ពាន់លានដុល្លារបន្ថែមទៀត សម្រាប់វិស័យនេះជារៀងរាល់ឆ្នាំ។

ខណៈពេលដែលរដ្ឋាភិបាលត្រូវតែដឹកនាំការងារកំណែទម្រង់ពន្ធដារ អ្នកផ្តល់ជំនួយអាចបំពេញតួនាទីបំពេញបន្ថែមដ៏សំខាន់។ ឧទាហរណ៍ ការចំណាយថវិកាត្រឹមតែ ១ ដុល្លារ ពីជំនួយរបស់អ្នកផ្តល់ជំនួយ ដើម្បីពង្រឹងរបបពន្ធ អាចបង្កើនចំណូលពន្ធរហូតដល់ ៣៥០ ដុល្លារ។ តែទោះជាយ៉ាងណាក៏ដោយ មានថវិកាតិចជាង ០,១% នៃជំនួយសរុបប៉ុណ្ណោះ ដែលត្រូវបានចំណាយ សម្រាប់គាំទ្រដល់កម្មវិធីពន្ធដារ ចន្លោះពីឆ្នាំ ២០០២ ដល់ ២០១១។ លើសពីនេះ រដ្ឋាភិបាលរបស់ប្រទេសផ្តល់ជំនួយគួរទាមទារនូវតម្លាភាពពីក្រុមហ៊ុននានា ដែលបានចុះបញ្ជិកា នៅតាមប្រទេសរបស់ពួកគេ។

**ប្រទេសចំនួន ៦៧ អាចបង្កើនធនធានអប់រំរបស់ខ្លួនបាន ១៥៣ ពាន់លានដុល្លារ តាមរយៈការធ្វើកំណែទម្រង់ ដើម្បីពង្រីកមូលដ្ឋានពន្ធ**

ការបង្កើនចំណូលពន្ធ និងការបែងចែកចំណែកឱ្យបានគ្រប់គ្រាន់ដល់វិស័យអប់រំ អាចបង្កើនធនធានបន្ថែមយ៉ាងច្រើន សម្រាប់វិស័យនេះ នៅក្នុងរយៈពេលខ្លី។ ក្រុមតាក់តែងរបាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា ប៉ាន់ប្រមាណថា មានប្រទេសចំណូលទាប និងមធ្យម ៦៧ អាចបង្កើនធនធានសម្រាប់វិស័យអប់រំបាន ១៥៣ ពាន់លានដុល្លារ ឬ ៧២% នៅត្រឹមឆ្នាំ ២០១៥ តាមរយៈកំណែទម្រង់ ដើម្បីបង្កើនផលធៀបពន្ធ លើ GDP និងចំណាយសាធារណៈលើវិស័យអប់រំ។



ជាមធ្យម ក្នុងចំណោមប្រទេសទាំង ៦៧ ការចំណាយលើកុមារដល់អាយុចូលរៀននៅបឋមសិក្សាម្នាក់ នឹងកើនឡើងពី ២០៩ ដុល្លារ ដល់ ៤៦៦ ដុល្លារ នៅក្នុងឆ្នាំ ២០១៥។ នៅក្នុងប្រទេសចំណូលទាប ក្នុងចំណោមប្រទេសទាំង ៦៧ នេះ ថវិកាជាមធ្យម ដែលចំណាយលើកុមារអាយុចូលរៀននៅបឋមសិក្សាម្នាក់ នឹងកើនឡើងពី ១០២ ដុល្លារ ដល់ ១៥៨ ដុល្លារ។

ប្រទេសចំនួន ១៤ ក្នុងចំណោមប្រទេសទាំង ៦៧ បានសម្រេចនូវចំណុចដៅ ដែលស្នើឡើង ឱ្យមានការចំណាយ យ៉ាងហោចណាស់នូវថវិកា ៦% នៃ GDP លើវិស័យអប់រំ។ ក្នុងចំណោមប្រទេស ដែលមិនទាន់បានសម្រេចចំណុចដៅនេះ នៅឡើយ មានប្រទេសចំនួន ១៩ អាចសម្រេចចំណុចដៅនេះបាន ប្រសិនបើប្រទេសទាំងនោះពង្រីក និងធ្វើពិសោធកម្ម មូលដ្ឋានពន្ធ និងចាត់ទុកចំណាយលើវិស័យអប់រំ ថាជាចំណាយអាទិភាព នៅមុនឆ្នាំ ២០១៥ (រូបភាពទី ១០)។

**កំណែទម្រង់ដើម្បីពង្រីកធនធានក្នុងស្រុក អាចបំពេញបាននូវគម្លាតថវិកាប្រចាំឆ្នាំចំនួន ៥៦% សម្រាប់វិស័យអប់រំជាមូលដ្ឋាន**

ធនធានបន្ថែមពីលើធនធានក្នុងស្រុកទាំងនេះ អាចបំពេញបាន ៥៦% នៃគម្លាតថវិកាប្រចាំឆ្នាំជាមធ្យម ២៦ ពាន់ លានដុល្លារ សម្រាប់ការអប់រំថ្នាក់មូលដ្ឋានសម្រាប់ប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមកម្រិតទាបចំនួន ៤៦ ឬ ៥៤% នៃគម្លាតថវិកា ៣៨ ពាន់លានដុល្លារ សម្រាប់ការអប់រំថ្នាក់មូលដ្ឋាន និងការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ។

កំណែទម្រង់ទាំងនេះ មិនមែនមិនធ្លាប់មាននោះទេ។ ប្រទេសអេក្វាឌ័របានធ្វើការចរចាកិច្ចសន្យាសារជាថ្មី ជាមួយ នឹងក្រុមហ៊ុនប្រេង ដែលនាំឱ្យមានការពង្រីកមូលដ្ឋានពន្ធរបស់ខ្លួន និងផ្តល់អាទិភាពកាន់តែខ្ពស់ដល់វិស័យអប់រំ ដោយបានបង្កើនចំណាយសម្រាប់វិស័យអប់រំចំនួន ៣ ដង ពីឆ្នាំ ២០០៣ ដល់ ២០១០។

ដើម្បីសម្រេចឱ្យបាននូវការអប់រំសម្រាប់ទាំងអស់គ្នា គេចាំបាច់មិនត្រឹមតែបង្កើនធនធានក្នុងស្រុក សម្រាប់វិស័យអប់រំប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវធ្វើការបែងចែកធនធានទាំងនេះសារជាថ្មីផងដែរ ដើម្បីឱ្យចំណែកស្មើភាពអាចបានដល់ អ្នកដែលមានតម្រូវការជាងគេ។ ប៉ុន្តែ ជារឿយៗ ធនធានច្រើនតែតម្រង់ទៅរកអ្នកដែលមានបុព្វសិទ្ធិខ្ពស់។ ដើម្បីផ្លាស់ប្តូរ ចំណាយសម្រាប់វិស័យអប់រំឱ្យលំអៀងមករកអ្នកដែលបាត់បង់ឱកាស រដ្ឋាភិបាលជាច្រើនបានដាក់ឱ្យអនុវត្តនូវយន្តការផ្តល់ថវិកា ដែលវិភាជន៍ធនធានច្រើនជាងមុនដល់តំបន់នានាក្នុងប្រទេស ឬក្រុមសាលារៀន ដែលត្រូវការការគាំទ្រច្រើនជាងមុន ដើម្បីជំនះបញ្ហាមិនបានទទួលការអប់រំ និងវិសមភាពក្នុងការរៀនសូត្រ។ ប្រទេសនានាមានវិធីសាស្រ្តផ្សេងៗគ្នា សម្រាប់ធ្វើការបែងចែកធនធានសារជាថ្មី។ ឧទាហរណ៍ ប្រទេសប្រេស៊ីល ធានាឱ្យមានការចំណាយអប្បបរមាក្នុងកម្រិតមួយ សម្រាប់កុមារម្នាក់ ដោយផ្តល់អាទិភាពដល់សាលារៀន នៅតាមតំបន់ជនបទ និងផ្តោតការយកចិត្តទុកដាក់ខ្លាំងដល់ ក្រុមជនជាតិដើមភាគតិច ដែលបាត់បង់ឱកាសក្នុងកម្រិតខ្ពស់។ កំណែទម្រង់ទាំងនេះបាននាំឱ្យមានការកើនឡើងនូវការចូលរៀន និងការរៀនសូត្ររបស់កុមារជួបប្រទះការលំបាក នៅភាគខាងជើងរបស់ប្រទេស។

ប៉ុន្តែ កម្មវិធីបែងចែកធនធានសារជាថ្មីដទៃទៀត មិនសូវជាបានជោគជ័យឡើយ។ មូលហេតុមួយ គឺដោយសារតែ ការបែងចែកធនធានសម្រាប់កុមារម្នាក់ នៅមិនទាន់បានឆ្លុះបញ្ចាំងឱ្យបានគ្រប់គ្រាន់ពីចំណាយ សម្រាប់ផ្តល់ការអប់រំប្រកបដោយគុណភាពដល់កុមារដែលបាត់បង់ឱកាស។ នៅក្នុងរដ្ឋកេរ៉ាឡា ដែលជារដ្ឋសម្បូរធនធានមួយរបស់ប្រទេសឥណ្ឌា ការចំណាយលើការអប់រំកុមារម្នាក់ មានប្រហែលជា ៦៨៥ ដុល្លារ។ ផ្ទុយទៅវិញ នៅក្នុងរដ្ឋប៊ីហា ដែលជារដ្ឋក្រីក្រ ការចំណាយនេះមានត្រឹមតែ ១០០ ដុល្លារតែប៉ុណ្ណោះ។

ប្រទេសក្រីក្រ អាចជួបប្រទះនឹងការលំបាក ក្នុងការកំណត់ និងផ្តោតគោលដៅលើក្រុម ដែលមានការខ្វះខាតជាង គេ។ ដូច្នេះ ប្រទេសជាច្រើនធ្វើការបែងចែកធនធាន ទៅតាមតួលេខនៃការចុះឈ្មោះចូលរៀន ដែលនាំឱ្យខូចប្រយោជន៍ ដល់តំបន់ ដែលមានកុមារក្រៅសាលាច្រើននាក់។ ឧទាហរណ៍ នៅក្នុងប្រទេសកេនយ៉ា ការបែងចែកធនធានជំនួយធ្វើឡើង ទៅតាមចំនួនសិស្ស ដែលបានចុះឈ្មោះចូលរៀន ដែលនាំឱ្យខាតប្រយោជន៍ដល់ខោនធីចំនួន ១២ ដែលជាតំបន់ដីគ្មានជីជាតិ និងមិនសូវមានជីជាតិ ដែលមានអ្នកបោះបង់ចោលការសិក្សាចំនួន ៤៦%។

ដើម្បីសម្រេចនូវសក្តានុពលពេញលេញនៃវិធានការបែងចែកធនធានសារជាថ្មី រដ្ឋាភិបាលចាំបាច់ត្រូវតែធានាយ៉ាង ណាឱ្យធនធានទាំងនេះអាចរ៉ាប់រងលើចំណាយទាំងស្រុងលើការផ្តល់ការអប់រំប្រកបដោយគុណភាព ដល់អ្នកដែលងាយរងគ្រោះបំផុត និងធានថា កំណែទម្រង់ទូលំទូលាយបែបនេះអាចពង្រឹងសមត្ថភាពរបស់ប្រព័ន្ធអប់រំ ក្នុងការអនុវត្តវិធានការ ទាំងនេះបាន។

**រូបភាពទី ១០ ៖ ការបង្កើនកិច្ចខិតខំប្រឹងប្រែងប្រមូលពន្ធ ទោះតិចតួចក្តី និងការផ្តល់អាទិភាពលើចំណាយសម្រាប់ការអប់រំ អាចនាំឱ្យមានការបង្កើនធនធានបានយ៉ាងច្រើន**

ចំណាយលើវិស័យអប់រំ គិតជាភាគរយនៃ GDP នៅក្នុងឆ្នាំ ២០១៥ ប្រសិនបើផលធៀបពន្ធលើ GDP មានការកើនឡើង ហើយភាគរយថវិកាសម្រាប់វិស័យអប់រំមានការកើនឡើង




*ប្រភព ៖ ការគណនារបស់ក្រុមតាក់តែងរបាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា (២០១៣) ផ្អែកតាម មូលដ្ឋានទិន្នន័យរបស់ UIS, អង្គការហិរញ្ញវត្ថុអតិវឌ្ឍន៍អន្តរជាតិ និងអក់ហ្វាម (២០១៣), IMF (២០១២, ២០១៣*

## និន្នាការហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់វិស័យអប់រំ

ជាមួយនឹងភាពល្អប្រសើរនៃចំនួនកុមារក្រៅសាលាបន្តនៅទ្រឹង ចាំបាច់ត្រូវមានការជម្រុញចុងក្រោយ ដើម្បីធានា យ៉ាងណាឱ្យកុមារទាំងអស់អាចចូលរៀនបាន នៅត្រឹមឆ្នាំ ២០១៥។ សូម្បីតែមុនពេលមានឱនភាពសេដ្ឋកិច្ចក៏ដោយ អ្នកផ្ដល់ជំនួយមិនបានធ្វើទៅតាមការសន្យារបស់ពួកគេ ក្នុងការផ្ដល់ថវិកាដល់វិស័យអប់រំនោះឡើយ។ ការថយចុះកាលពីពេល ថ្មីៗនេះនូវជំនួយ សម្រាប់ការអប់រំថ្នាក់មូលដ្ឋាន នាំឱ្យការងារនេះរឹតតែលំបាកមួយកម្រិតទៀត។

ក្រោយឆ្នាំ ២០០២ ជំនួយសម្រាប់វិស័យអប់រំមានការកើនឡើងបន្តិចម្ដងៗ រហូតដល់កម្រិតកំពូល នៅក្នុងឆ្នាំ ២០១០ ហើយឥឡូវនេះ បានថមថយមកវិញ ៖ ជំនួយសរុបសម្រាប់ការអប់រំគ្រប់កម្រិត មានការថយចុះ ៧% ពីឆ្នាំ ២០១០ ដល់ ២០១១ (រូបភាពទី ១១)។ ជំនួយសម្រាប់ការអប់រំថ្នាក់មូលដ្ឋានមានការថយចុះជាលើកទីមួយ ចាប់តាំងពី ឆ្នាំ ២០០២ មក ចំនួន ៦% ពោលគឺពី ៦,២ ពាន់លានដុល្លារ នៅក្នុងឆ្នាំ ២០១០ មកនៅ ៥,៨ ពាន់លានដុល្លារ នៅក្នុងឆ្នាំ ២០១១។ ជំនួយសម្រាប់ការអប់រំមធ្យមសិក្សា បានថយចុះ ១១% ពីឆ្នាំ ២០១០ ដល់ ២០១១ ពីកម្រិតដែលទាបរួចទៅហើយ។ នេះនាំឱ្យមានហានិភ័យដល់ឱកាសអាចសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា និងក្ដីសង្ឃឹមទាំងឡាយ ដែលចង់មានគោលដៅប្រកបដោយមហិច្ឆតាជាងនេះ ដូចជាដាក់បញ្ចូលគោលដៅសកលកម្មការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ ក្រោយឆ្នាំ ២០១៥ ជាដើម។

ប្រទេសមានចំណូលទាប ដែលទទួលបានថវិកាប្រមាណជា ១ ភាគ ៣ នៃជំនួយសរុប សម្រាប់ការអប់រំថ្នាក់មូលដ្ឋាន ទទួលបានជំនួយសម្រាប់ការអប់រំថ្នាក់មូលដ្ឋានថយចុះច្រើនជាងប្រទេសចំណូលមធ្យមទៅទៀត។ នៅតាមប្រទេសដែលមានចំណូលទាប ជំនួយមានការថយចុះ ៩% ពីឆ្នាំ ២០១០ ដល់ ២០១១ ពោលគឺពី ២,០៥ ពាន់លានដុល្លារ មកនៅ ១,៨៦ ពាន់លានដុល្លារ។ ដូច្នេះ ធនធាន ដែលមានសម្រាប់កុមារម្នាក់មានការថយចុះពី ១៨ ដុល្លារ នៅក្នុងឆ្នាំ ២០១០ មក ១៦ ដុល្លារ នៅក្នុងឆ្នាំ ២០១១។

នៅតំបន់អាហ្វ្រិចសាប់សាហារ៉ា ដែលមានអ្នកបោះបង់ចោលការសិក្សាជាងពាក់កណ្ដាល នៃចំនួនអ្នកបោះបង់ ចោលការសិក្សាសរុប នៅក្នុងពិភពលោក ជំនួយសម្រាប់ការអប់រំថ្នាក់មូលដ្ឋាន មានការថយចុះ ៧% ពីឆ្នាំ ២០១០ ដល់ ២០១១។ ការកាត់បន្ថយថវិកា ១៣៤ លានដុល្លារ នៃជំនួយសម្រាប់ការអប់រំថ្នាក់មូលដ្ឋាន សម្រាប់តំបន់នេះ គឺជាចំនួនគ្រប់គ្រាន់ សម្រាប់ផ្ដល់ថវិកា ដើម្បីបង្កើតឱ្យមានសាលារៀនប្រកបដោយគុណភាព សម្រាប់កុមារជាង ១ លាននាក់។

នៅក្នុងប្រទេសមួយចំនួន ជំនួយបាន និងកំពុងថយចុះជាងមួយឆ្នាំទៅហើយ។ ជំនួយបំពេញតួនាទីយ៉ាងសំខាន់ ក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដើម្បីឱ្យបានកុមារកាន់តែច្រើននាក់ចូលរៀនតាមសាលា នៅក្នុងសាធារណរដ្ឋតង់ហ្សានៀ ប៉ុន្តែវាមានការថយចុះ ១២% ចន្លោះពីឆ្នាំ ២០០៩ ដល់ ២០១០ និងថយចុះ ៥៧% បន្ថែមទៀត នៅក្នុងឆ្នាំ ២០១១។

កុមារ ដែលមានជីវភាពក្រីក្រជាងគេ ហើយដែលទំនងជាអ្នកដែលក្រៅសាលាជាងគេ កំពុងរស់នៅមិនត្រឹមតែក្នុង ប្រទេសដែលមានចំណូលទាបប៉ុណ្ណោះទេ ប៉ុន្តែក៏នៅក្នុងប្រទេសចំណូលមធ្យមកម្រិតទាបមួយចំនួនផងដែរ។ ចាប់តាំងពីឆ្នាំ ២០០០ មក មានប្រទេសចំនួន ២៥ ដែលបានចាកចេញពីក្រុមប្រទេសនេះ ដែលឥឡូវនេះមាន ៥៤ ប្រទេស ខណៈពេលមានប្រទេសចំនួន ៣៦ ត្រូវបានចាត់ទុកថាជាប្រទេសមានចំណូលទាប។ នៅក្នុងឆ្នាំ ១៩៩៩ កុមារក្រៅសាលា ៨៤% ក្នុងចំណោមកុមារក្រៅសាលាសរុបក្នុងពិភពលោក រស់នៅក្នុងប្រទេសដែលមានចំណូលទាប ហើយ ១២% រស់នៅក្នុងប្រទេស ដែលមានចំណូលមធ្យមកម្រិតទាប។ គិតត្រឹមឆ្នាំ ២០១១ ៣៧% រស់នៅក្នុងប្រទេសចំណូលទាប និង ៤៩% នៅក្នុងប្រទេសចំណូលមធ្យមកម្រិតទាប។ ការផ្លាស់ប្ដូរនេះ មួយភាគធំ កើតឡើងដោយសារការក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប របស់ប្រទេសដែលមានប្រជាជនច្រើនមួយចំនួន ដូចជា ប្រទេសឥណ្ឌា នេហ្សេរីយ៉ា និងប៉ាគីស្ថាន ជាដើម។ ខណៈពេលដែលប្រទេសទាំងនេះអាចធ្វើការងារបន្ថែមទៀត ដើម្បីបង្កើនធនធានរបស់ខ្លួនសម្រាប់វិស័យអប់រំ និងធ្វើការបែងចែកធនធានទាំងនេះដល់អ្នកដែលមានតម្រូវការច្រើនបំផុត កំណែទម្រង់ទាំងនេះត្រូវការពេលវេលា។ ក្នុងពេលជាមួយគ្នា អ្នកផ្ដល់ជំនួយនានាគួរផ្ដោតទិសដៅជំនួយទៅកាន់តំបន់ នៅក្នុងប្រទេសចំណូលមធ្យមកម្រិតទាប ដែលសម្បូរដោយប្រជាជនក្រីក្រ ដើម្បីធានាថាកុមារមួយជំនាន់ទៀតនៅក្នុងប្រទេសទាំងនេះ មិនត្រូវបានគេបដិសេធសិទ្ធិ ទទួលបានការអប់រំរបស់ពួកគេឡើយ។

ជំនួយដោយផ្ទាល់សម្រាប់វិស័យអប់រំ មានការថយចុះបន្តិចបន្តួច ជាងជំនួយជារួមសម្រាប់វិស័យដទៃទៀត ចន្លោះពីឆ្នាំ ២០១០ ដល់ ២០១១ ដូច្នេះ ភាគរយនៃជំនួយសម្រាប់វិស័យអប់រំ មានការថយចុះពី ១២% ដល់ ១១%។ ការថយចុះនូវជំនួយសម្រាប់វិស័យអប់រំនេះ ឆ្លុះបញ្ចាំងពីការផ្លាស់ប្ដូរនិន្នាការចំណាយរបស់ប្រទេសផ្ដល់ជំនួយធំៗ។ ប្រទេសកាណាដា បារាំង ហុល្លង់ និងសហរដ្ឋអាមេរិច បានកាត់ចំណាយលើវិស័យអប់រំ ច្រើនជាងការកាត់បន្ថយជំនួយជារួមរបស់ពួកគេ។ ចន្លោះពីឆ្នាំ ២០១០ ដល់ ២០១១ អ្នកផ្ដល់ជំនួយទ្វេភាគី និងពហុភាគីចំនួន ២១ បានកាត់បន្ថយជំនួយរបស់ខ្លួន សម្រាប់ការអប់រំថ្នាក់មូលដ្ឋាន។ ការថយចុះច្រើនជាងគេ គិតជាចំនួនទឹកប្រាក់ រួមមាន ដោយប្រទេសកាណាដា សហភាពអឺរ៉ុប បារាំង ជប៉ុន ហុល្លង់ អេស្ប៉ាញ និងសហរដ្ឋអាមេរិច ដែលរួមគ្នាស្រូបយក ៩០% នៃការកាត់បន្ថយជំនួយសម្រាប់ការអប់រំថ្នាក់មូលដ្ឋាន។

**នៅក្នុងឆ្នាំ ២០១១ ជំនួយសម្រាប់ការអប់រំថ្នាក់មូលដ្ឋានមានការថយចុះជាលើកដំបូងចាប់តាំងពីឆ្នាំ ២០០២ មក**

**រូបភាពទី ១១ ៖ ជំនួយដល់វិស័យអប់រំថយចុះចំនួន ១ ពាន់លានដុល្លារ ពីឆ្នាំ ២០១០ ដល់ ២០១១**

ជំនួយសរុបដែលផ្ដល់ដល់វិស័យអប់រំ ២០០២-២០១១




*ប្រភព ៖ OECD-DAC (2013)*

## វិស័យអប់រំទទួលបានត្រឹមតែ ១,៤%នៃជំនួយមនុស្សធម៌តែប៉ុណ្ណោះ

សហរដ្ឋអាមេរិចបានផ្លាស់ពីអ្នកផ្តល់ជំនួយទ្វេភាគីធំជាងគេដល់ការអប់រំថ្នាក់មូលដ្ឋាន នៅក្នុងឆ្នាំ ២០១០ មកជា អ្នកផ្តល់ជំនួយធំជាងទី ២ នៅក្នុងឆ្នាំ ២០១១។ ឥឡូវនេះ ចក្រភពអង់គ្លេស គឺជាអ្នកផ្តល់ជំនួយធំជាងគេសម្រាប់វិស័យអប់រំ។ ជំនួយរបស់ប្រទេសហុល្លង់សម្រាប់ការអប់រំថ្នាក់មូលដ្ឋាន មានការថយចុះជាង ១ ភាគ ៣ ចន្លោះពីឆ្នាំ ២០១០ ដល់ ២០១១។ ប្រទេសនេះធ្លាប់ជាអ្នកផ្តល់ជំនួយធំជាងគេដល់ការអប់រំថ្នាក់មូលដ្ឋាន នៅក្នុងឆ្នាំ ២០០៧ ប៉ុន្តែគិតត្រឹមឆ្នាំ ២០១១ ប្រទេសនេះបានធ្លាក់មកនៅជាប្រទេសទី ១១។

ប្រទេសអូស្ត្រាលី មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក បានបង្កើនជំនួយជារួមរបស់ខ្លួនសម្រាប់ការ អប់រំថ្នាក់មូលដ្ឋាន ចន្លោះពីឆ្នាំ ២០១០ ដល់ ២០១១ ប៉ុន្តែបានកាត់បន្ថយចំណាយរបស់ខ្លួន នៅតាមបណ្តាប្រទេសដែលមានចំណូលទាប។ ជំនួយរបស់ធនាគារពិភពលោក ដល់ការអប់រំថ្នាក់មូលដ្ឋាន បានកើនឡើងជារួមចំនួន ១៣% ប៉ុន្តែថយចុះ ២៣% នៅតាមប្រទេសចំណូលទាប។ សាធារណរដ្ឋតង់ហ្សានៀ ទទួលបានជំនួយពីធនាគារពិភពលោក ថយចុះពី ៨៨ លានដុល្លារ នៅក្នុងឆ្នាំ ២០០២ មកនៅតិចជាង ០,៣ លានដុល្លារ នៅក្នុងឆ្នាំ ២០១១។

ភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE) គឺជាប្រភពដ៏សំខាន់សម្រាប់ហិរញ្ញប្បទានដល់ប្រទេសដែលមាន ចំណូលទាបមួយចំនួន។ នៅក្នុងឆ្នាំ ២០១១ GPE បានផ្តល់ថវិកា ៣៨៥ លានដុល្លារ ដែលជាចំនួនថវិកាខ្ពស់បំផុតមិនធ្លាប់មាន ដល់ការអប់រំថ្នាក់មូលដ្ឋាន ដែលធ្វើឱ្យកម្មវិធីនេះក្លាយទៅជាអ្នកផ្តល់ជំនួយធំជាងគេទី ៤ ដល់ប្រទេសចំណូលទាប និងប្រទេសចំណូលមធ្យមកម្រិតទាប នៅក្នុងឆ្នាំនោះ។ សម្រាប់ប្រទេសទាំង ៣១ ដែលទទួលបានជំនួយសម្រាប់អនុវត្តកម្មវិធី នៅក្នុងឆ្នាំ ២០១១ ជំនួយសម្រាប់ការអប់រំថ្នាក់មូលដ្ឋានចំនួន ២៤% ត្រូវបានផ្តល់ដោយ GPE។ ប៉ុន្តែ ជំនួយនេះ មិនទំនងជាអាចទូទាត់ជាមួយនឹងការកាត់បន្ថយចំណាយរបស់ធនាគារពិភពលោកឡើយ។ សាធារណរដ្ឋតង់ហ្សានៀបានក្លាយជាដៃគូរបស់ GPE នៅក្នុងឆ្នាំ ២០១៣ ដោយបានទទួលជំនួយ ៥,២ លានដុល្លារ សម្រាប់ផែនការអប់រំរបស់ខ្លួន។ ប៉ុន្តែ ចំនួននេះត្រូវបានបែងចែកទៅឱ្យ Zanzibar ហើយចំនួននេះគឺជាចំនួនតិចតួច បើធៀបជាមួយនឹងអ្វីដែលប្រទេសនេះ បានទទួលពីធនាគារពិភពលោក នៅដើមទសវត្សរ៍ ២០០០។ ដើម្បីលើកកម្ពស់ការពិនិត្យតាមដានលើការរួមចំណែករបស់ ខ្លួន GPE ត្រូវរាយការណ៍ពីលំហូរជំនួយរបស់ខ្លួនទៅកាន់ OECD-DAC ដូចគ្នានឹងការអនុវត្តរបស់មូលនិធិសកលផ្នែក សុខាភិបាល ដូចជា សម្ព័ន្ធ GAVI និងមូលនិធិសកល ដើម្បីប្រយុទ្ធនឹងជំងឺអេដស៍ របេង និងគ្រុនចាញ់ដែរ។

ពុំមានសញ្ញា ដែលបង្ហាញថាជំនួយជារួមនឹងលែងថយចុះ នៅមុនកាលកំណត់ឆ្នាំ ២០១៥ នោះឡើយ។ ចាប់ពីឆ្នាំ ២០១១ ដល់ ២០១២ ជំនួយសរុបថយចុះ ៤% ដោយសារតែអ្នកផ្តល់ជំនួយ DAC ចំនួន ១៦ បានកាត់បន្ថយជំនួយរបស់ខ្លួន។ អ្នកផ្តល់ជំនួយ DAC ចំនួន ១៣ បានចាត់ទុកជំនួយថាជាអាទិភាពមួយទាប ដោយបានកាត់បន្ថយជំនួយ គិតជា ភាគរយនៃចំណូលជាតិសរុប (GNI)។ ប្រទេសមិនសូវមានការអភិវឌ្ឍ នឹងត្រូវរងបន្ទុក ដោយសារតែការកាត់បន្ថយទាំងនេះ ដោយជំនួយទ្វេភាគីសម្រាប់ប្រទេសទាំងនោះមានការថយចុះ ១២,៨% ពីឆ្នាំ ២០១១ ដល់ ២០១២។ នៅក្នុងឆ្នាំ ២០១៣ គេរំពឹងថា ជំនួយនឹងថយចុះ នៅក្នុងប្រទេសចំណូលទាបចំនួន ៣១ ក្នុងចំណោមប្រទេសចំណូលទាប ៣៦ ដែលប្រទេសភាគច្រើន ស្ថិតនៅក្នុងតំបន់អាហ្វ្រិចសាប់សាហារ៉ា។

លើសពីនេះ មានប្រទេសតែ ៥ ក្នុងចំណោមប្រទេសជាសមាជិករបស់សហភាពអឺរ៉ុបទាំង ១៥ ប៉ុណ្ណោះ ដែលយល់ព្រមបង្កើនជំនួយរបស់ខ្លួនដល់ ០,៧% នៃ GNI ត្រឹមឆ្នាំ ២០១៥ ដែលនឹងបំពេញទៅតាមការសន្យារបស់ខ្លួន។ ប្រសិនបើប្រទេសទាំងនេះបំពេញតាមការសន្យារបស់ខ្លួន ប្រទេសទាំងនេះនឹងអាចរៃអង្គាសថវិកាបាន ៩ ពាន់លានដុល្លារបន្ថែមទៀត សម្រាប់វិស័យអប់រំ នៅក្នុងឆ្នាំ ២០១៥។

វិស័យអប់រំ នៅក្នុងប្រទេសដែលរងផលប៉ះពាល់ដោយសារជម្លោះ គួរតែជាអាទិភាពមួយ សម្រាប់អ្នកផ្តល់ ជំនួយ។ ប្រទេសទាំងនេះមានកុមារក្រៅសាលាពាក់កណ្តាល នៃចំនួនកុមារក្រៅសាលាសរុប នៅក្នុងពិភពលោក។ បច្ចុប្បន្ន នេះការអប់រំទទួលបានថវិកាត្រឹមតែ ១,៤% នៃជំនួយមនុស្សធម៌តែប៉ុណ្ណោះ ពោលគឺទាបឆ្ងាយជាង ៤% ដែលអំពាវនាវ ដោយគំនិតផ្តួចផ្តើមទីមួយផ្នែកការអប់រំសកលរបស់អគ្គលេខាធិការដ្ឋានសហប្រជាជាតិ (រូបភាពទី ១២)។ នៅក្នុងផែនការសម្រាប់ឆ្នាំ ២០១៣ ភាគរយនៃជំនួយសម្រាប់វិស័យអប់រំ ធៀបនឹងជំនួយមនុស្សធម៌សរុប ទំនងជានឹងកើនឡើងមិនលើសពី ២% ឡើយ។

នៅក្នុងប្រទេសម៉ាលី ដែលសាលារៀនភាគច្រើន នៅភាគខាងជើងនៅបន្តបិទទ្វារ ដោយសារតែជម្លោះ ថវិកា សម្រាប់វិស័យអប់រំមានប្រមាណជា ៥% នៃការអំពាវនាវស្នើសុំ សម្រាប់ឆ្នាំ ២០១៣ ប៉ុន្តែមានថវិកាត្រឹមតែ ១៥% នៃ ថវិកាដែលស្នើសុំនេះប៉ុណ្ណោះ ដែលត្រូវបានសន្យាថានឹងផ្តល់ឱ្យ គិតត្រឹមខែ កញ្ញា ឆ្នាំ ២០១៣។ ស្រដៀងគ្នានេះដែរ ធនធានដែលបានស្នើសុំ នៅក្នុងឆ្នាំ ២០១៣ សម្រាប់វិស័យអប់រំនៅក្នុងប្រទេសស៊ីរៀ ទទួលបានការសន្យាផ្តល់ឱ្យតែ ៣៦% ប៉ុណ្ណោះ។ ខណៈពេលដែលប្រទេសទាំងនេះអាចទទួលបានថវិកាដែលស្នើសុំបន្ថែមទៀត នៅពេលក្រោយ នៅក្នុងឆ្នាំ ២០១៣ ថវិកាទាំងនេះអាចធ្លាក់មកយឺតពេកសម្រាប់កុមាររាប់លាននាក់ ដែលត្រូវបោះបង់ចោលការសិក្សា ដោយសារតែជម្លោះ។

មិនត្រឹមតែចំនួនថវិកាជំនួយប៉ុណ្ណោះទេ ដែលសំខាន់ ប៉ុន្តែអ្វីដែលសំខាន់ផងដែរនោះ គឺថាតើថវិកានេះត្រូវបានប្រើប្រាស់ ដើម្បីផ្តោតលើក្រុមដែលជួបប្រទះការលំបាកជាងគេដែរឬទេ។ កុមារទាំងនេះមិនបានទទួលថវិកាជំនួយទាំងអស់ដែលមានសម្រាប់ពួកគេឡើយ។ ជំនួយផ្ទាល់ ១ ភាគ ៤ ដែលផ្តល់សម្រាប់វិស័យអប់រំ ត្រូវបានចំណាយលើសិស្ស ដែលរៀននៅតាមសកលវិទ្យាល័យ នៅតាមបណ្តាប្រទេសអ្នកមាន។ បើទោះបីជាការចំណាយលើអាហារូបករណ៍ និងបន្ទុកចំណាយលើនិស្សិតទាំងនេះ អាចមានសារៈសំខាន់ សម្រាប់ពង្រឹងសមត្ថភាពធនធានមនុស្ស នៅតាមបណ្តាប្រទេសចំណូលទាបយ៉ាងណាក៏ដោយ ជាក់ស្តែង ថវិកាភាគច្រើនបានទៅដល់ប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ដោយប្រទេសចិនជាអ្នកទទួលផលធំជាងគេ ដោយបានទទួល ២១% នៃថវិកាសរុប។

ជាមធ្យម នៅក្នុងរយៈពេល ២០១០-២០១១ អ្នកផ្តល់ជំនួយនានា ជាពិសេស ប្រទេសអាល្លឺម៉ង់ និងជប៉ុន បាន ផ្តល់ថវិកា ៦៥៦ លានដុល្លារ ក្នុងមួយឆ្នាំដល់ប្រទេសចិន សម្រាប់ចំណាយអាហារូបករណ៍ និងបន្ទុកចំណាយផ្សេងៗរបស់និស្សិត ដែលចំនួននេះគឺ ៧៧ ដង ច្រើនជាងជំនួយ ដែលផ្តល់ដល់ប្រទេសឆាដសម្រាប់ការអប់រំថ្នាក់មូលដ្ឋាន នៅក្នុង រយៈពេលដូចគ្នានេះ។ ថវិកាសរុប ក្នុងទម្រង់ជាបន្ទុកចំណាយផ្សេងៗសម្រាប់និស្សិត និងអាហារូបករណ៍ ដែលទទួលបាន ជារៀងរាល់ឆ្នាំ ដោយប្រទេសអាល់ហ្សេរី ចិន ម៉ារ៉ុក ទុយនេស៊ី និងតួគី គឺស្មើនឹងជំនួយផ្ទាល់សរុបសម្រាប់ការអប់រំថ្នាក់ មូលដ្ឋាន ដែលផ្តល់ដល់ប្រទេសចំណូលទាបទាំង ៣៦ គិតជាមធ្យម នៅក្នុងឆ្នាំ ២០១០-២០១១។

ជំនួយ ក៏អាចត្រូវបានផ្ដល់ ដោយមានភ្ជាប់ជាមួយនឹងលក្ខខណ្ឌមិនអំណោយផល សម្រាប់ប្រទេសក្រីក្រផងដែរ ៖ ជំនួយ ១៥% គឺស្ថិតក្នុងទម្រង់ជាប្រាក់កម្ចី ដែលប្រទេសត្រូវសងមកវិញ ក្នុងអត្រាការប្រាក់សម្បទាន។ ប្រសិនបើមិនមានការផ្ដល់ថវិកាពីអ្នកផ្ដល់ជំនួយទ្វេភាគីទេនោះ ប្រទេសក្រីក្រប្រឈមនឹងការពឹងផ្អែកលើកម្ចីទាំងនេះ ដែលនាំឱ្យមានការកើតបំណុល ដែលដាក់កំហិតលើលទ្ធភាពរបស់ពួកគេ ក្នុងការផ្ដល់ថវិកាដល់វិស័យអប់រំ ដោយប្រើប្រាស់ធនធានផ្ទាល់ខ្លួន របស់ពួកគេ។

ប្រសិនបើមានការដកបន្ទុកចំណាយលើនិស្សិត អាហារូបករណ៍ និងកម្ចីចេញ ប្រទេសអាល្លឺម៉ង់នឹងធ្លាក់ពីអ្នកផ្ដល់ ជំនួយធំជាងគេដោយផ្ទាល់ដល់វិស័យអប់រំ មកជាអ្នកផ្ដល់ជំនួយធំជាងគេទី ៥ វិញ។ ធនាគារពិភពលោកនឹងធ្លាក់ពីទី ៣ មកទី ១៤។ ផ្ទុយទៅវិញ ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិច នឹងឡើងពីទី ៦ និងទី ៧ ទៅទី ១ និងទី ២ វិញ។

ព័ត៌មានអំពីវិសាលភាពទាំងមូលនៃការផ្ដល់ហិរញ្ញប្បទានដល់វិស័យអប់រំ ដូចជា ជំនួយធនធានក្នុងស្រុក និងចំណាយតាមគ្រួសារ ជារឿយ មិនមានគ្រប់គ្រាន់ឡើយ ហើយនៅបែកខ្ញែកពីគ្នា ដែលនាំឱ្យគេអាចធ្វើការវិភាគបានតែលើផ្នែកខ្លះអំពីថាតើគេត្រូវការថវិកាប៉ុន្មាន និងត្រូវការនៅកន្លែងណាតែប៉ុណ្ណោះ។ ការវិភាគថ្មីៗ ដែលទទួលបានពីប្រទេស ចំនួន ៧ បង្ហាញថា គ្រួសាររ៉ាប់រងរហូតដល់ ៣៧% នៃចំណាយលើការអប់រំកម្រិតបឋមសិក្សា និងរហូតដល់ ៥៨% នៃចំណាយលើការអប់រំកម្រិតមធ្យមសិក្សា ដែលជាការដាក់បន្ទុកពិសេសលើគ្រួសារដែលមានជីវភាពក្រីក្រជាងគេ។ លើសពីនេះ ការវិភាគនេះបង្ហាញផងដែរពីសារៈសំខាន់នៃជំនួយ សម្រាប់ការផ្ដល់ហិរញ្ញប្បទានដល់វិស័យអប់រំ នៅតាមបណ្ដាប្រទេសក្រីក្រជាងគេមួយចំនួន ៖ ជំនួយរ៉ាប់រងស្មើរតែ ១ ភាគ ៤ នៃចំណាយសម្រាប់ការអប់រំ នៅក្នុងប្រទេសម៉ាឡាវី និង រ៉ាវ៉ាន់ដា។ លទ្ធផលរកឃើញទាំងនេះរំលេចឱ្យឃើញពីសារៈសំខាន់នៃការកសាងប្រព័ន្ធគណនីអប់រំជាតិមួយ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដែលអាចយកគំរូតាមបទពិសោធន៍ ក្នុងវិស័យសុខាភិបាល។

ដើម្បីចៀសវាងកុំឱ្យមានបរាជ័យដល់កុមារមួយជំនាន់ទៀត ដោយសារកង្វះធនធាន ក្រោយឆ្នាំ ២០១៥ រដ្ឋាភិបាល និងអ្នកផ្ដល់ជំនួយនានា ចាំបាច់ត្រូវតែមានការទទួលខុសត្រូវចំពោះការប្ដេជ្ញាចិត្តរបស់ពួកគេ ក្នុងការផ្ដល់នូវធនធាន ដែលចាំបាច់ ដើម្បីសម្រេចគោលដៅនៃការអប់រំ។ ដោយប្រើប្រាស់ការវិភាគ ដែលមាននៅក្នុងរបាយការណ៍ ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា នៅក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ក្រុមតាក់តែងរបាយការណ៍ សូមលើកស្នើឱ្យមានការកំណត់ចំណុចដៅ សម្រាប់ឱ្យរដ្ឋាភិបាលថ្នាក់ជាតិ ធ្វើការបែងចែកយ៉ាងហោចណាស់ ៦% នៃ GNP របស់ខ្លួនសម្រាប់វិស័យអប់រំ។ ចំណុចដៅសម្រាប់រដ្ឋាភិបាល និងអ្នកផ្ដល់ជំនួយ ក៏គួរដាក់បញ្ចូលនូវការសន្យារបស់ពួកគេ ក្នុងការចំណាយយ៉ាងហោចណាស់ ២០% នៃថវិការបស់ខ្លួនលើវិស័យអប់រំផងដែរ។ ការដាក់ចេញនូវចំណុចដៅទាំងនេះ និងការធានាយ៉ាងណាឱ្យរដ្ឋាភិបាល និងអ្នកផ្ដល់ជំនួយខិតខំបំពេញទៅតាមចំណុចដៅទាំងនេះ គឺជាការរួមវិភាគទានដ៏សំខាន់ ដល់ការផ្ដល់ឱកាសអប់រំដល់កុមារ និងយុវជននាពេលអនាគត។

**គេចាំបាច់ត្រូវតែកំណត់ចំណុចដៅនៃការផ្ដល់ហិរញ្ញប្បទានក្រោយឆ្នាំ ២០១៥ ដើម្បីចៀសវាងកុំឱ្យមានបរាជ័យ ដល់កុមារមួយជំនាន់ទៀត**

**រូបភាពទី ១២ ៖ ការថយចុះទ្វេដងនូវជំនួយសម្រាប់ការអប់រំធៀបនឹងជំនួយមនុស្សធម៌ ៖ ការស្នើសុំក្នុងភាគរយមួយតូច និងភាគរយតូចបំផុតនៃការស្នើសុំនេះ ដែលទទួលបានថវិកា**
ការអំពាវនាវស្នើសុំសរុបរួម និងការផ្ដល់ថវិកា បែងចែកទៅតាមវិស័យ ២០១២




*ប្រភព ៖ ការិយាល័យសម្របសម្រួលកិច្ចការមនុស្សធម៌ (២០១៣)*

# ផ្នែកទី ២ ៖ ការអប់រំធ្វើឱ្យជីវិតមានការប្រែប្រួល

សន្ធិសញ្ញា និងច្បាប់ នៅទូទាំងសកលលោកនេះ ទទួលស្គាល់ថា ការអប់រំ គឺជាសិទ្ធិមនុស្សជាមូលដ្ឋានមួយ។ លើសពីនេះ ការអប់រំផ្តល់នូវចំណេះដឹង និងជំនាញ ដែលបង្កលក្ខណៈឱ្យមនុស្សសម្រេចបាននូវសក្តានុពលពេញលេញរបស់ខ្លួន ដូច្នេះការអប់រំ គឺជាកត្តាលីករ សម្រាប់ពន្លឿនការសម្រេចគោលដៅអភិវឌ្ឍន៍ដទៃទៀត។ ការអប់រំកាត់បន្ថយភាពក្រីក្រ បង្កើនឱកាសការងារ និងលើកកម្ពស់វិបុលភាពសេដ្ឋកិច្ច។ ការអប់រំក៏បង្កើនឱកាសរបស់មនុស្ស ក្នុងការរស់នៅ ប្រកបដោយសុខភាពមាំមួន ពង្រឹងមូលដ្ឋានលទ្ធិប្រជាធិបតេយ្យ និងផ្លាស់ប្តូរឥរិយាបថនានា ដើម្បីផ្តល់ការការពារដល់បរិស្ថាន និងផ្តល់ភាពអង់អាចដល់ស្ត្រី។

**ប្រសិនបើសិស្សទាំងអស់ចាកចេញពីសាលារៀនដោយមានជំនាញអំណានជាមូលដ្ឋាន នោះមនុស្សចំនួន ១៧១ លាននាក់អាចចេញផុតពីភាពក្រីក្រ**

ការអប់រំក្មេងស្រី និងស្ត្រី មានអំណាចធ្វើឱ្យជីវិតមានការប្រែប្រួល ដោយគ្មានអ្វីប្រៀបផ្ទឹមបាន។ ដូចគ្នានឹងការបង្កើនឱកាសទទួលបានការងារសម្រាប់ពួកគេ ការរស់នៅដោយមានសុខភាពមាំមួន និងការចូលរួមពេញលេញក្នុងសង្គមដែរ ការអប់រំក្មេងស្រី និងស្ត្រីវ័យក្មេង មានឥទ្ធិពលជាវិជ្ជមានយ៉ាងធំធេងមកលើសុខភាពកូនៗរបស់ពួកគេ ក៏ដូចជាពន្លឿន អន្តរកាលរបស់ប្រទេសរបស់ពួកគេឱ្យមានកំណើនប្រជាជនថេរ។

ដើម្បីទទួលបានប្រយោជន៍ឱ្យបានកាន់តែច្រើនពីការអប់រំ និងសម្រេចគោលដៅអភិវឌ្ឍន៍ក្រោយឆ្នាំ ២០១៥ ការ អប់រំចាំបាច់ត្រូវតែមានសមធម៌ ហើយត្រូវគ្របដណ្តប់ឱ្យបានយ៉ាងហោចណាស់ដល់សាលាមធ្យមសិក្សាបឋមភូមិ។ ហើយ ការរៀនសូត្រដែលកុមារទទួលបាន ត្រូវតែមានគុណភាពល្អប្រសើរ ដើម្បីឱ្យពួកគេអាចរៀនចំណេះដឹងជាមូលដ្ឋានពិតប្រាកដមែន។

## ការអប់រំកាត់បន្ថយភាពក្រីក្រ បង្កើនការងារ និងជម្រុញកំណើន

ការអប់រំ គឺជាមាគ៌ាដ៏សំខាន់មួយ សម្រាប់ជួយបុគ្គលទាំងឡាយ ឱ្យគេចផុតពីភាពក្រីក្រ និងបង្ការភាពក្រីក្រមិនឱ្យ ឆ្លងពីជំនាន់មួយ ទៅជំនាន់មួយទៀត។ ការអប់រំផ្តល់លទ្ធភាពឱ្យអ្នកដែលធ្វើការងារក្នុងវិស័យក្នុងប្រព័ន្ធ ដោយទទួលបានប្រាក់កម្រៃ អាចទទួលបានប្រាក់ឈ្នួលកាន់តែខ្ពស់ជាងមុន និងផ្តល់នូវជីវភាពរស់នៅកាន់តែប្រសើរដល់អ្នកដែលធ្វើការងារ ក្នុងវិស័យកសិកម្ម និងវិស័យក្រៅប្រព័ន្ធ នៅតំបន់ប្រជុំជន។

ការគណនារបស់ក្រុមការងារតាក់តែងរបាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា បង្ហាញថាប្រសិនបើសិស្សទាំងអស់ នៅក្នុងប្រទេសចំណូលទាប ចាកចេញពីសាលារៀនជាមួយនឹងជំនាញអំណានជា មូលដ្ឋាន នោះនឹងមានមនុស្ស ១៧១ លាននាក់ ដែលអាចងើបផុតពីភាពក្រីក្រ ដែលស្មើនឹងការកាត់បន្ថយភាពក្រីក្រក្នុង ពិភពលោកចំនួន ១២%។ វិធីសំខាន់មួយ ដែលការអប់រំកាត់បន្ថយភាពក្រីក្រ គឺតាមរយៈការបង្កើនចំណូលរបស់មនុស្ស។ នៅក្នុងសកលលោកទាំងមូល ការចូលរៀនក្នុងសាលារៀន ១ ឆ្នាំ បង្កើនការរកចំណូល ១០% ជាមធ្យម។

ការអប់រំ អាចជួយមនុស្សឱ្យគេចផុតពីភាពក្រីក្រ បើទោះបីជាពួកគេមានការធ្វើក៏ដោយ។ នៅសាធារណរដ្ឋ តង់ហ្សានៀ កម្មករនិយោជិត ៨២% ដែលមានកម្រិតវប្បធម៌ទាបជាងបឋមសិក្សា រស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ។ ប៉ុន្តែ មនុស្សពេញវ័យមានការងារធ្វើ ហើយមានកម្រិតវប្បធម៌ត្រឹមបឋមសិក្សា កាត់បន្ថយលទ្ធភាពក្លាយជាអ្នកក្របាន ២០% ហើយអ្នកដែលមានកម្រិតវប្បធម៌មធ្យមសិក្សា កាត់បន្ថយលទ្ធភាពក្លាយជាអ្នកក្របានជិត ៦០%។ វាមិនត្រឹមតែ ជារយៈពេលដែលចំណាយក្នុងសាលារៀនប៉ុណ្ណោះទេ ប៉ុន្តែជំនាញដែលទទួលបាន ក៏មានសារៈសំខាន់ផងដែរ។ នៅក្នុងប្រទេសប៉ាគីស្ថាន ស្ត្រីមានការងារធ្វើ ដែលមានជំនាញអក្ខរកម្មល្អប្រសើរ អាចទទួលបានចំណូលច្រើនជាងស្ត្រី ដែលមាន ជំនាញអក្ខរកម្មខ្សោយ ដល់ទៅ ៩៥%។

នៅក្នុងវិស័យក្នុងប្រព័ន្ធ ប្រាក់ឈ្នួលកាន់តែខ្ពស់ ឆ្លុះបញ្ចាំងពីផលិតភាពកាន់តែខ្ពស់ របស់កម្មករនិយោជិត ដែលមានកម្រិតវប្បធម៌កាន់តែខ្ពស់។ ប៉ុន្តែ ប្រជាជនក្រីក្រជាងគេជាច្រើននាក់ នៅកំពុងធ្វើការងារក្នុងវិស័យក្រៅប្រព័ន្ធ ដូចជាប្រកបមុខរបររកស៊ីតូចតាច ជាដើម។ អ្នកដែលទទួលបានការអប់រំ ច្រើនតែចាប់ផ្តើមអាជីវកម្មដោយខ្លួនឯង ហើយ អាជីវកម្មរបស់ពួកគេ ច្រើនតែអាចរកប្រាក់ចំណេញបានច្រើន។ នៅក្នុងប្រទេសអ៊ូហ្គាន់ដា ម្ចាស់សហគ្រាសជាលក្ខណៈគ្រួសារ ដែលរៀនបានកម្រិតបឋមសិក្សា អាចទទួលបានចំណូលច្រើនជាងអ្នកដែលមិនបានរៀន ចំនួន ៣៦% ហើយអ្នកដែលរៀនបានមធ្យមសិក្សាបឋមភូមិអាចរកបានចំណូលច្រើនជាងអ្នកមិនបានរៀន ៥៦%។

នៅតាមតំបន់ជនបទ កសិករដែលចេះអក្សរ និងលេខបានគ្រាន់បើ អាចបកស្រាយ និងឆ្លើយតបចំពោះព័ត៌មានថ្មីៗបាន អាចប្រើប្រាស់ធនធាន និងបច្ចេកវិទ្យាទំនើបបានកាន់តែប្រសើរ ដើម្បីបង្កើនផលិតភាពនៃការប្រកបរបរដាំដុះបែបប្រពៃណីរបស់ពួកគេ និងធ្វើពិពិធកម្មដាំដំណាំ ដែលផ្តល់តម្លៃខ្ពស់។ នៅក្នុងប្រទេសម៉ូហ្សាំប៊ិច កសិករដែលចេះអក្សរ ទំនងជានឹងដាំដំណាំ ដែលអាចលក់បានជាប្រាក់មកវិញ ជាងកសិករមិនចេះអក្សរ ដល់ ទៅ ២៦ ភាគរយចំណុច។

ការអប់រំក៏ជួយប្រជាពលរដ្ឋ តាមតំបន់ជនបទឱ្យធ្វើពិពិធកម្មប្រាក់ចំណូលរបស់ខ្លួន តាមរយៈការបំពេញការងារ មិនមែនស្រែចំការ។ នៅតំបន់ជនបទក្នុងប្រទេសឥណ្ឌូនេស៊ី បុរស ១៥% និងស្ត្រី ១៧% ដែលមិនបានរៀន ធ្វើការងារមិនមែនស្រែចំការ បើធៀបជាមួយនឹង ៦១% នៃបុរស និង ៧២% នៃស្ត្រី ដែលមានកម្រិតវប្បធម៌មធ្យមសិក្សា។

អត្ថប្រយោជន៍មួយ ក្នុងចំណោមអត្ថប្រយោជន៍នានា នៃការបង្កើនការអប់រំ គឺថា មាតាបិតាដែលបានទទួលការអប់រំច្រើនតែមានកូន ដែលទទួលបានការអប់រំបានច្រើន។ ការវិភាគលើការអង្កេតគ្រួសារពីប្រទេសចំនួន ៥៦ រកឃើញថា រៀងរាល់មួយឆ្នាំបន្ថែមនៃការអប់រំរបស់មាតា កុមារធម្មតាទទួលបានការអប់រំ ០,៣២ ឆ្នាំបន្ថែមទៀត ហើយសម្រាប់ក្មេងស្រី អត្ថប្រយោជន៍នេះមានច្រើនជាងនេះបន្តិច។

តាមរយៈការផ្តល់ប្រយោជន៍ដល់ស្ត្រី ការអប់រំអាចជួយកាត់បន្ថយគម្លាតយេនឌ័រ នៅក្នុងឱកាសការងារ និងប្រាក់ឈ្នួល។ ឧទាហរណ៍ នៅក្នុងប្រទេសអាហ្សង់ទីន និងចរដង់ ក្នុងចំណោមមនុស្សដែលមានការអប់រំកម្រិតបឋមសិក្សា ស្ត្រីទទួលបានចំណូលប្រហែលជាពាក់កណ្តាលនៃចំណូលមធ្យមរបស់បុរស ខណៈពេលដែលក្នុងចំណោមអ្នកដែលរៀនបានដល់កម្រិតមធ្យមសិក្សា ស្ត្រីទទួលបានប្រាក់ចំណូលប្រហែលជា ២ ភាគ ៣ នៃចំណូលរបស់បុរស។

ការអប់រំជួយការពារមនុស្សពេញវ័យ ដែលកំពុងបំពេញការងារ ពីការកេងប្រវ័ញ្ច តាមរយៈការបង្កើនឱកាសរបស់ពួកគេឱ្យទទួលបានកិច្ចសន្យាការងារបានជាប់លាប់។ នៅតំបន់ប្រជុំជនរបស់ប្រទេសអេលសាវ៉ាឌ័រ មានមនុស្សពេញវ័យមានការងារធ្វើ និងមានការអប់រំទាបជាងកម្រិតបឋមសិក្សា ត្រឹមតែ ៧% ប៉ុណ្ណោះ ដែលមានកិច្ចសន្យាការងារ បើធៀបជាមួយនឹង ៤៩% នៃអ្នកដែលរៀនបានដល់កម្រិតមធ្យមសិក្សា។

ការអប់រំ មិនត្រឹមតែបង្កលក្ខណៈឱ្យមនុស្សម្នាក់អាចងើបផុតពីភាពក្រីក្រប៉ុណ្ណោះទេ ប៉ុន្តែក៏បង្កើននូវផលិតភាព ដែលជម្រុញកំណើនសេដ្ឋកិច្ចផងដែរ។ ការកើនឡើងនូវការទទួលបានការអប់រំជាមធ្យមរបស់ប្រជាពលរដ្ឋក្នុងប្រទេសមួយ បាន ១ ឆ្នាំ បង្កើនកំណើន GDP សម្រាប់ប្រជាជនម្នាក់ក្នុងមួយឆ្នាំ ពី ២% ទៅ ២,៥%។

ការអប់រំអាចជួយពន្យល់ពីភាពខុសប្លែកគ្នានៃមាគ៌ាកំណើនរបស់តំបន់។ នៅក្នុងឆ្នាំ ១៩៦៥ មនុស្សពេញវ័យ នៅ អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច បានចំណាយពេលក្នុងសាលារៀន ២,៧ ឆ្នាំច្រើនជាងអ្នករស់នៅតំបន់អាហ្វ្រិចសាប់សាហារ៉ា។ នៅក្នុងរយៈពេល ៤៥ ឆ្នាំ បន្ទាប់ អត្រាកំណើនជាមធ្យម នៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច មានល្បឿនលឿនជាង ៤ ដង។

បើធៀបជាមួយនឹងបទពិសោធន៍ក្នុងតំបន់ មានព័ត៌មានកាន់តែច្រើនថែមទៀត ដែលបង្ហាញឱ្យឃើញពីសារៈ-សំខាន់នៃការអប់រំ។ នៅក្នុងប្រទេសគ័រតេម៉ាឡា មនុស្សពេញវ័យទទួលបានការអប់រំ ៣,៦ ឆ្នាំ គិតជាមធ្យម នៅក្នុងឆ្នាំ ២០០៥ ហើយកម្រិតជាមធ្យមនេះកើនឡើងបានតែ ២,៣ ឆ្នាំប៉ុណ្ណោះ ពីឆ្នាំ ១៩៦៥ ដល់ ២០០៥។ ប្រសិនបើប្រទេសនេះ មានចំនួនឆ្នាំនៃការទទួលបានការអប់រំ ដូចគ្នានឹងអាមេរិចឡាទីន និងការីបៀន ដែលចំនួនឆ្នាំជាមធ្យម ដែលមនុស្សពេញ វ័យចំណាយនៅសាលារៀន កើនឡើងពី ៣,៦ នៅក្នុងឆ្នាំ ១៩៦៥ ដល់ ៧,៥ នៅក្នុងឆ្នាំ ២០០៥ ប្រទេសនេះនឹងអាចបង្កើន អត្រាកំណើនប្រចាំឆ្នាំជាមធ្យមរបស់ខ្លួនទ្វេដង ពីឆ្នាំ ២០០៥ ដល់ ២០១០ ស្មើនឹង ៥០០ ដុល្លារបន្ថែមទៀតសម្រាប់ ប្រជាជនម្នាក់។

មានតែការវិនិយោគលើការអប់រំប្រកបដោយសមធម៌ ដោយធានាយ៉ាងណាឱ្យប្រជាជនក្រីក្រជាងគេអាចចូល រៀននៅសាលារៀនឱ្យបានច្រើនឆ្នាំ ទើបប្រទេសនានាអាចសម្រេចបាននូវកំណើន ដែលលុបបំបាត់ភាពក្រីក្រ។ សមភាពក្នុងការអប់រំ អាចវាស់វែងបាន តាមរយៈមេគុណ Gini ដែលមានចាប់ពីសូន្យ មានន័យថាមានសមភាពពេញលេញ រហូតដល់ ១ ដែលមានន័យថាមានវិសមភាពដល់កម្រិតអតិបរមា។ ការកែលំអមេគុណ Gini បាន ០,១ ពន្លឿនកំណើនបាន ០,៥ ភាគរយចំណុច ដែលនាំឱ្យមានការបង្កើនចំណូលសម្រាប់ប្រជាជនម្នាក់ចំនួន ២៣% នៅក្នុងរយៈពេល ៤០ ឆ្នាំ។ ប្រសិនបើមេគុណ Gini នៃការអប់រំនៅអាហ្វ្រិចសាប់សាហារ៉ា ចំនួន ០,៤៩ ត្រូវបានកាត់បន្ថយពាក់កណ្តាលឱ្យនៅត្រឹមកម្រិត នៅអាមេរិចឡាទីន និងការីបៀន អត្រាកំណើនប្រចាំឆ្នាំរបស់ GDP សម្រាប់ប្រជាជនម្នាក់ នៅក្នុងឆ្នាំ ២០០៥-២០១០ អាចកើនឡើង ៤៧% (ពី ២,៤% ដល់ ៣,៥%) ហើយចំណូលអាចកើនឡើង ៨២ ដុល្លារ សម្រាប់ប្រជាជនម្នាក់ នៅក្នុងរយៈពេលនេះ។

ការប្រៀបធៀបប្រទេសប៉ាគីស្ថាន និងវៀតណាម បង្ហាញឱ្យឃើញយ៉ាងច្បាស់លាស់ពីសារៈសំខាន់នៃការអប់រំ ប្រកបដោយសមធម៌។ នៅក្នុងឆ្នាំ ២០០៥ ចំនួនឆ្នាំ គិតជាមធ្យម ដែលមនុស្សពេញវ័យចំណាយនៅសាលារៀនគឺស្រដៀងគ្នា ៖ ៤,៥ ឆ្នាំ ក្នុងប្រទេសប៉ាគីស្ថាន និង ៤,៩ ឆ្នាំ ក្នុងប្រទេសវៀតណាម។ ប៉ុន្តែកម្រិតវប្បធម៌ត្រូវបានបែងចែកដោយ មិនស្មើភាពគ្នាឡើយ នៅក្នុងប្រទេសប៉ាគីស្ថាន។ មេគុណ Gini សម្រាប់វិសមភាពក្នុងការអប់រំរបស់ប្រទេសប៉ាគីស្ថាន ច្រើនជាងកម្រិតមេគុណសម្រាប់ប្រទេសវៀតណាម ២ ដង។ ភាពខុសប្លែកគ្នានៃវិសមភាពក្នុងការអប់រំ របស់ប្រទេសទាំងពីរនេះ នាំឱ្យកំណើនសម្រាប់ប្រជាជនម្នាក់របស់ប្រទេសទាំងពីរ ខុសគ្នា ៦០% ចន្លោះពីឆ្នាំ ២០០៥ ដល់ ២០១០។ ចំណូលសម្រាប់ប្រជាជនម្នាក់របស់ប្រទេសវៀតណាម ដែលទាបជាងប្រទេសប៉ាគីស្ថានប្រហែលជា ៤០% នៅក្នុងទសវត្សរ៍ ១៩៩០ មិនត្រឹមតែតាមទានចំណូលក្នុងប្រទេសប៉ាគីស្ថានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងខ្ពស់ជាងប្រទេសប៉ាគីស្ថាន ២០% ទៅទៀត គិតត្រឹមឆ្នាំ ២០១០។


Photo/ARETE/UNESCO

**សម្រាប់រៀងរាល់មួយឆ្នាំបន្ថែមនៃការអប់រំរបស់មាតា កុមារចំណាយពេល ០,៣២ ឆ្នាំបន្ថែមនៅសាលារៀន**

## ការអប់រំបង្កើនឱកាសឱ្យមនុស្សរស់នៅប្រកបដោយសុខភាពមាំមួនជាងមុន

ការអប់រំ គឺជាមាគ៌ាមួយ ក្នុងចំណោមមាគ៌ាដ៏មានអានុភាពជាងគេ សម្រាប់លើកកម្ពស់សុខភាពរបស់មនុស្ស។ ការអប់រំសង្គ្រោះជីវិតរបស់ម្តាយ និងកុមាររាប់លាននាក់ ជួយបង្ការ និងទប់ស្កាត់ជំងឺ និងជាសមាសភាគដ៏សំខាន់នៃកិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភ។ មនុស្សដែលទទួលបានការអប់រំបានល្អ ដឹងច្រើនពីជំងឺ ចេះចាត់វិធានការបង្ការ ចំណាំរោគសញ្ញារបស់ជំងឺបានទាន់ពេលវេលា និងច្រើនតែប្រើប្រាស់សេវាថែទាំសុខភាពញឹកញាប់។ បើទោះបីជាការអប់រំផ្តល់នូវប្រយោជន៍បែបនេះក៏ដោយ ជារឿយៗ ការអប់រំមិនត្រូវបានគេចាត់ទុកថាជាអន្តរាគមន៍ផ្នែក សុខភាពដ៏សំខាន់ និងជាមធ្យោបាយសម្រាប់ធ្វើឱ្យអន្តរាគមន៍សុខភាពដទៃទៀតកាន់តែមានប្រសិទ្ធភាពនោះឡើយ។

**ប្រសិនបើស្ត្រីទាំងអស់រៀនចប់បឋមសិក្សា នឹងមានការកាត់បន្ថយមរណភាពមាតាបាន ៦៦%**

មានការបង្ហាញគួរឱ្យកត់សម្គាល់មួយចំនួនតូចអំពីអានុភាពនៃការអប់រំ ដែលមានច្រើនជាងការប៉ាន់ស្មានទៅទៀត ដូចជា ជីវិតរបស់កុមារអាយុក្រោម ៥ ឆ្នាំ ចំនួន ២,១ លាននាក់ ត្រូវបានជួយសង្គ្រោះ ចន្លោះពីឆ្នាំ ១៩៩០ ដល់ ២០០៩ ដោយសារតែភាពរីកចម្រើននៃការអប់រំរបស់ស្ត្រីវ័យបន្តពូជ។ ប៉ុន្តែ បញ្ហាប្រឈមនៅមានទំហំធំធេង នៅក្នុងឆ្នាំ ២០១២ កុមារអាយុក្រោម ៥ ឆ្នាំ ៦,៦ លាននាក់ បានបាត់ជីវិត ដែលភាគច្រើន នៅក្នុងប្រទេសចំណូលទាប និងប្រទេសចំណូល មធ្យមកម្រិតទាប។ ប្រសិនបើស្ត្រីទាំងអស់ នៅក្នុងប្រទេសទាំងនេះ រៀនចប់បឋមសិក្សា នោះអត្រាមរណភាពកុមារអាយុ ក្រោម ៥ ឆ្នាំ នឹងថយចុះបាន ១៥%។ ប្រសិនបើស្ត្រីទាំងអស់រៀនចប់មធ្យមសិក្សាបឋមភូមិ នោះអត្រានេះនឹងថយចុះ ៤៩% ស្មើនឹងជីវិត ២,៨ លាននាក់ ក្នុងមួយឆ្នាំ (សូមមើលក្រាហ្វព័ត៌មាន ៖ ជួយសង្គ្រោះជីវិតរបស់កុមារ)។

ប្រមាណជា ៤០% នៃមរណភាពកុមារអាយុក្រោម ៥ ឆ្នាំទាំងអស់ កើតឡើង នៅក្នុងកំឡុង ២៨ ថ្ងៃដំបូងនៃ ជីវិត ដែលភាគច្រើនកើតឡើង ដោយសារការលំបាក ក្នុងពេលសម្រាល។ តែទោះជាយ៉ាងណាក៏ដោយ ការប៉ាន់ប្រមាណ ថ្មីៗចុងក្រោយ បង្ហាញថា ពុំមានវត្តមានរបស់ឆ្មបជំនាញ នៅក្នុងការសម្រាលកូនជាងពាក់កណ្តាល នៅក្នុងតំបន់អាហ្វ្រិចសាប់សាហារ៉ា និងអាស៊ីខាងត្បូង។ នៅក្នុងប្រទេសចំណូលទាប និងមធ្យមចំនួន ៥៧ ម្តាយចេះអក្សរ ច្រើនទៅរកឆ្មបជំនាញឱ្យសម្រាលកូនឱ្យ ច្រើនជាងម្តាយដែលមិនចេះអក្សរ ២៣%។ នៅក្នុងប្រទេសម៉ាលី ភាពចេះអក្សររបស់ម្តាយអាច បង្កើនលទ្ធភាពខាងលើនេះដល់ទៅ ៣ ដង។

ម្តាយ ដែលទទួលបានការអប់រំ ទទួលបានព័ត៌មានច្រើនអំពីជំងឺជាក់លាក់ ដូច្នេះពួកគេអាចចាត់វិធានការ ដើម្បី បង្ការជំងឺទាំងនោះ។ ជំងឺរលាកសួត គឺជាមូលហេតុធំជាងគេ ដែលនាំឱ្យកុមារបាត់បង់ជីវិត ពោលគឺដល់ទៅ ១៧% នៃករណីស្លាប់របស់កុមារទូទាំងសកលលោក។ ការអប់រំរបស់មាតា ១ ឆ្នាំបន្ថែម អាចនាំឱ្យមានការកាត់បន្ថយអត្រាស្លាប់ ដោយសារជំងឺរលាកសួតបាន ១៤% ពោលគឺស្មើនឹងការជួយសង្គ្រោះជីវិតកុមារ ១៦០០០០ នាក់ ជារៀងរាល់ឆ្នាំ។ ជំងឺរាក គឺជាឃាតករធំជាងគេទី ៤ ដែលផ្តាច់ផ្តិលជីវិតរបស់កុមារ ពោលគឺ ៩% នៃករណីស្លាប់របស់កុមារ។ ប្រសិនបើស្ត្រីទាំងអស់រៀនចប់បឋមសិក្សា នោះអាំងស៊ីដង់នៃជំងឺរាកនឹងថយចុះបាន ៨% នៅក្នុងប្រទេសចំណូលទាប និងប្រទេសចំណូលមធ្យមកម្រិតទាប។ ប្រសិនបើស្ត្រីរៀនចប់មធ្យមសិក្សាវិញ វាអាចថយចុះ ៣០%។ លទ្ធភាពដែលកុមារម្នាក់ទទួលបានថ្នាំបង្ការជំងឺខាន់ស្លាក់ តេតាណូស និងក្អកមាន់ នឹងកើនឡើង ១០% ប្រសិនបើស្ត្រីគ្រប់រូប នៅប្រទេសចំណូលទាប និងប្រទេសចំណូលមធ្យមកម្រិតទាប រៀនចប់បឋមសិក្សា និងកើនឡើង ៤៣% ប្រសិនបើពួកគេរៀនចប់មធ្យមសិក្សា។

ការអប់រំរបស់មាតា មានសារៈសំខាន់ចំពោះសុខភាពផ្ទាល់ខ្លួនរបស់គាត់ ដូចសុខភាពរបស់កូនៗរបស់គាត់ផងដែរ។ ជារៀងរាល់ថ្ងៃ មានស្ត្រីជិត ៨០០ នាក់ ដែលបាត់បង់ជីវិត ដោយសារមូលហេតុដែលអាចបង្ការបាន ពាក់ព័ន្ធជាមួយនឹងការមានផ្ទៃពោះ និងការសម្រាលកូន។ ប្រសិនបើស្ត្រីទាំងអស់រៀនចប់បឋមសិក្សា នោះនឹងមានករណីមរណភាពមាតាតិចជាងមុន ៦៦% ពោលគឺអាចជួយសង្គ្រោះជីវិតបាន ១៨៩០០០ នាក់ ក្នុងមួយឆ្នាំ។ នៅតំបន់អាហ្វ្រិចសាប់សាហារ៉ាតែឯង ប្រសិនបើស្ត្រីទាំងអស់បានរៀនចប់ការអប់រំនៅបឋមសិក្សា នឹងមានករណីមរណភាពមាតាតិចជាងមុន ៧០% ដែលអាចជួយសង្គ្រោះជីវិតស្ត្រី ១១៣៤០០ នាក់។

ប្រទេសមួយចំនួនមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ដោយសារកំណែទម្រង់នៃការអប់រំ នៅក្នុងទសវត្សរ៍ ១៩៧០ ចំនួនឆ្នាំនៃការអប់រំ ដែលស្ត្រីវ័យក្មេងបានទទួល បានកើនឡើង ២,២ ឆ្នាំ នៅក្នុងប្រទេសនីហ្សេរីយ៉ា។ នេះនាំឱ្យមានការកាត់បន្ថយអត្រាមរណភាពមាតា ២៩%។

ការលើកកម្ពស់ការអប់រំ គឺជាវិធីដែលមានអានុភាពមួយ ដើម្បីជួយកាត់បន្ថយករណីជំងឺឆ្លង ដូចជា មេរោគ/ ជំងឺអេដស៍ ជាដើម។ ឧទាហរណ៍ ការអប់រំជួយបង្កើនការយល់ដឹងអំពីការបង្ការមេរោគអេដស៍។ នៅអាស៊ីខាងត្បូង និងខាងលិច និងអាហ្វ្រិចសាប់សាហារ៉ា ស្ត្រីចេះអក្សរ ដឹងថាពួកគេមានសិទ្ធិបដិសេធមិនព្រមរួមភេទ ឬស្នើសុំឱ្យមានការប្រើ ប្រាស់ស្រោមអនាម័យ ប្រសិនបើពួកគេដឹងថាដៃគូរបស់ពួកគេមានជំងឺកាមរោគ ច្រើនជាងស្ត្រីដែលមិនចេះអក្សរ ៣០ ភាគរយចំណុច។ ការដឹងពីកន្លែងធ្វើតេស្តមេរោគអេដស៍ គឺជាជំហានទីមួយ ដើម្បីទទួលបានការព្យាបាល ប្រសិនបើចាំបាច់។ ប៉ុន្តែ មានស្ត្រីមិនចេះអក្សរនៅអាហ្វ្រិចសាប់សាហារ៉ា តែ ៥២% ប៉ុណ្ណោះ ដែលដឹងពីកន្លែងទៅធ្វើតេស្តរកមេរោគអេដស៍ បើធៀបជាមួយនឹង ៨៥% នៃស្ត្រីដែលចេះអក្សរ។

ជំងឺគ្រុនចាញ់ គឺជាជំងឺមួយ ក្នុងចំណោមជំងឺ ដែលធ្វើឱ្យមនុស្សស្លាប់ច្រើនជាងគេ នៅក្នុងពិភពលោក ដោយបាន សម្លាប់កុមារម្នាក់ រៀងរាល់នាទី នៅអាហ្វ្រិច។ ការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំ មានសារៈសំខាន់យ៉ាងខ្លាំងនៅក្នុងការធានាប្រសិទ្ធភាពនៃវិធានការបង្ការនានា ដូចជា ការប្រើប្រាស់ឱសថ ឬមុងជ្រលក់ថ្នាំ ជាដើម។ នៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ដែលមានករណីស្លាប់ដោយសារជំងឺគ្រុនចាញ់ ១ ភាគ ៥ នៃករណីសរុបក្នុងពិភពលោកកើតមាននៅទីនោះ ការអប់រំមេគ្រួសារ ឬម្តាយ បង្កើនលទ្ធភាពគេងក្នុងមុងរបស់គ្រួសារ។ ការផ្លាស់ប្តូរទាំងនេះ នាំឱ្យមានការឆ្លងជំងឺតិចជាងមុន ជាពិសេស នៅតាមតំបន់ដែលហានិភ័យនៃការឆ្លងជំងឺមានកម្រិតខ្ពស់។ នៅតាមតំបន់ទាំងនេះ ហានិភ័យ ដែលកុមារមានប៉ារ៉ាស៊ីតបង្កជំងឺគ្រុនចាញ់មានតិចជាងមុន ២២% ប្រសិនបើម្តាយរបស់ពួកគេរៀនបានបឋមសិក្សា បើធៀបជាមួយនឹងម្តាយដែលមិនបានរៀនសោះ ឬតិចជាង ៣៦% ប្រសិនបើម្តាយរបស់ពួកគេរៀនបានមធ្យមសិក្សា។

# ជួយសង្គ្រោះជីវិតរបស់កុមារ

ការអប់រំកម្រិតកាន់តែខ្ពស់ កាត់បន្ថយករណីស្លាប់របស់កុមារដែលអាចបង្ការជាមុនបាន




*ប្រភព ៖ Gakidou (2013); Inter-agency Group for Child Morality Estimation (2013)*



© Amina Sayeed/UNESCO

**ការផ្តល់ឱ្យស្ត្រីទាំងអស់នៅតាមបណ្តាប្រទេសក្រីក្រនូវការអប់រំកម្រិតមធ្យមសិក្សា នឹងកាត់បន្ថយបញ្ហាក្រិនបាន ២៦%**

ការអប់រំ ច្រើនតែដឹងពីការអនុវត្តសមស្របផ្នែកសុខភាព និងអនាម័យនៅផ្ទះ និងមានអំណាចជាងមុន ដើម្បីធានាយ៉ាង ណាឱ្យមានការបែងចែកធនធានក្នុងគ្រួសារ ដើម្បីបំពេញតម្រូវការផ្នែកអាហារូបត្ថម្ភរបស់កុមារ។ នៅតាមប្រទេសដែល មានចំណូលទាប និងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ការផ្តល់ឱ្យស្ត្រីទាំងអស់នូវការអប់រំកម្រិតបឋមសិក្សា នឹងកាត់បន្ថយបញ្ហាក្រិន ដែលជាសញ្ញាបង្ហាញពីបញ្ហាកង្វះអាហារូបត្ថម្ភបាន ៤% ឬអាចជួយដល់កុមារ ១,៧ លាននាក់។ ការផ្តល់ការអប់រំកម្រិតមធ្យមសិក្សានឹងកាត់បន្ថយបញ្ហាក្រិនបាន ២៦% ឬជួយកុមារបាន ១១,៩ លាននាក់។

នៅមុនអាយុបាន ១ ឆ្នាំ ផលប៉ះពាល់ជាអវិជ្ជមាននៃបញ្ហាកង្វះអាហារូបត្ថម្ភមកលើសក្តានុពលក្នុងជីវិតរបស់កុមារ មិនអាចស្រោចស្រង់ឱ្យបានដូចដើមឡើយ។ ទារក នៅក្នុងប្រទេសពេរូ ដែលមានម្តាយរៀនដល់កម្រិតមធ្យមសិក្សាបឋមភូមិ មិនសូវមានបញ្ហាក្រិន ដូចកុមារដែលម្តាយពុំបានរៀនសោះចំនួន ៦០%។

## ការអប់រំលើកកម្ពស់សង្គមដែលមានសុខភាពមាំមួន

ការអប់រំ ជួយមនុស្សឱ្យយល់ពីលទ្ធប្រជាធិបតេយ្យ លើកកម្ពស់ការអត់ឱនយោគយល់គ្នា និងការជឿទុកចិត្តគ្នា និងលើកទឹកចិត្តមនុស្សឱ្យចូលរួមក្នុងការងារនយោបាយ។ ការអប់រំក៏មានតួនាទីសំខាន់ នៅក្នុងការបង្ការការវិចរឹលរបស់បរិស្ថាន និងកាត់បន្ថយមូលហេតុ និងផលប៉ះពាល់របស់ការប្រែប្រួលអាកាសធាតុ។ លើសពីនេះ ការអប់រំអាចផ្តល់ភាពអង់អាចឱ្យស្ត្រីជំនះបាននូវការរើសអើង និងបញ្ជាក់អះអាងពីសិទ្ធិរបស់ខ្លួន។

ការអប់រំបង្កើនការយល់ដឹងរបស់មនុស្សអំពីនយោបាយ និងរបៀបចូលរួមក្នុងការងារនយោបាយ។ នៅក្នុងប្រទេសអាហ្វ្រិចសាប់សាហារ៉ាទាំង ១២ ប្រជាជន ៦៣% ក្នុងចំណោមប្រជាជនដែលមិនបានរៀនផ្លូវការនៅសាលារៀន មានការយល់ដឹងពីលទ្ធិប្រជាធិបតេយ្យ បើធៀបជាមួយនឹង ៧១% នៃអ្នកដែលរៀនបានបឋមសិក្សា និង ៨៥% នៃអ្នកដែលរៀនបានមធ្យមសិក្សា។

អ្នកដែលមានកម្រិតវប្បធម៌កាន់តែខ្ពស់ កាន់តែចាប់អារម្មណ៍ចំពោះការងារនយោបាយ និង ច្រើនស្វែងរកព័ត៌មានអំពីនយោបាយ។ ឧទាហរណ៍ នៅក្នុងប្រទេសតួគី ភាគរយរបស់អ្នកដែលនិយាយថា ពួកគេចាប់ អារម្មណ៍ចំពោះរឿងនយោបាយ បានកើនឡើងពី ៤០% ក្នុងចំណោមអ្នកដែលរៀនបានបឋមសិក្សា ដល់ ៥២% ក្នុង ចំណោមអ្នកដែលរៀនបានមធ្យមសិក្សា។

ការអប់រំបង្កើនការគាំទ្ររបស់ប្រជាពលរដ្ឋចំពោះលទ្ធិប្រជាធិបតេយ្យ ជាពិសេស នៅតាមប្រទេស ដែលទើបនឹងមានការប្ដូរទៅជារបបប្រជាធិបតេយ្យកាលពីពេលថ្មីៗនេះ។ នៅក្នុងប្រទេសសាប់សាហារ៉ាចំនួន ១៨ អ្នកដែលដល់វ័យបោះឆ្នោត និងរៀនបានបឋមសិក្សា ច្រើនសម្ដែងការគាំទ្រដល់លទ្ធិប្រជាធិបតេយ្យ ១,៥ ដង ច្រើនជាងអ្នកដែលមិនបាន រៀន និង ២ ដង ច្រើនជាង ប្រសិនបើពួកគេរៀនចប់មធ្យមសិក្សា។

អ្នកទទួលបានការអប់រំ ច្រើនទៅបោះឆ្នោត។ នៅក្នុងប្រទេសអាមេរិចឡាទីនចំនួន ១៤ ចំនួនប្រជាជនចេញទៅ បោះឆ្នោត គឺមាន ៥ ភាគរយចំណុចច្រើនជាង សម្រាប់អ្នកដែលរៀនបានបឋមសិក្សា និង ៩ ភាគរយចំណុចច្រើនជាង សម្រាប់អ្នកដែលពុំបានទទួលការអប់រំ។ លទ្ធផលនេះកាន់តែមានធំទៅទៀត នៅតាមប្រទេស ដែលកម្រិតវប្បធម៌ជា មធ្យមមានកាន់តែទាប ដូចជា ប្រទេសអេលសាល់វ៉ាឌ័រ គ័រតេម៉ាឡា និងម៉ិកស៊ិក ជាដើម។ ការអប់រំក៏លើកទឹកចិត្តឱ្យមាន ការចូលរួមក្នុងឆាកនយោបាយ ក្នុងទម្រង់ដទៃទៀតផងដែរ។ នៅក្នុងប្រទេសអាហ្សង់ទីន ចិន និងតួគី ប្រជាពលរដ្ឋច្រើន ចុះហត្ថលេខាលើញត្តិ ឬធ្វើពហិការមិនទិញផលិតផលអ្វីមួយ ២ ដងច្រើនជាង ប្រសិនបើពួកគេរៀនបានមធ្យមសិក្សា បើធៀបជាមួយនឹងអ្នកដែលរៀនបានត្រឹមតែបឋមសិក្សា។

ការអប់រំ មានតួនាទីចាំបាច់ ក្នុងការពង្រឹងសាមគ្គីភាពក្នុងសហគមន៍ និងសង្គម។ នៅអាមេរិចឡាទីន អ្នកដែល រៀនបានកម្រិតមធ្យមសិក្សា បង្ហាញពីការមិនអត់ធ្មត់ដល់មនុស្សដែលមានពូជសាសន៍ផ្សេង តិចជាងអ្នករៀនបានត្រឹម បឋមសិក្សា ៤៧%។ នៅក្នុងបណ្ដារដ្ឋអារ៉ាប់ អ្នករៀនបានមធ្យមសិក្សា បង្ហាញពីការមិនអត់ឱនដល់អ្នកមកពីសាសនាផ្សេងតិចជាងអ្នករៀនត្រឹមបឋមសិក្សា ១៤%។ នៅអាហ្វ្រិចសាប់សាហារ៉ា អ្នករៀនបានបឋមសិក្សាបង្ហាញពីភាពមិនអត់ឱនឱ្យអ្នករស់នៅជាមួយមេរោគអេដស៍ តិចជាងអ្នកមិនបានរៀន ១០% និងតិចជាង ២៣% ប្រសិនបើពួកគេរៀនបានមធ្យមសិក្សា។ នៅអឺរ៉ុបភាគកណ្ដាល និងភាគខាងកើត អ្នកដែលរៀនបានមធ្យមសិក្សា បង្ហាញពីការមិនអត់ឱនដល់ជនអន្តោប្រវេសន៍ តិចជាងអ្នកមិនបានបញ្ចប់មធ្យមសិក្សា ១៦%។

ការអប់រំក៏ជួយជំនះនូវភាពលំអៀងយេនឌ័រ នៅក្នុងឥរិយាបថនយោបាយ ដើម្បីជួយពង្រឹងលទ្ធិប្រជាធិបតេយ្យ ផងដែរ។ នៅក្នុងប្រទេសឥណ្ឌា ការកាត់បន្ថយគម្លាតអក្ខរកម្មបាន ៤០% បង្កើនលទ្ធភាពដែលស្ត្រីឈរឈ្មោះសម្រាប់ការបោះឆ្នោតសភាថ្នាក់រដ្ឋចំនួន ១៦% និងភាគរយ នៃសម្លេងឆ្នោតដែលពួកគេទទួលបានចំនួន ១៣%។

ការអប់រំកាត់បន្ថយការយោគយល់ចំពោះអំពើពុករលួយ និងជួយបង្កើនគណនេយ្យភាព។ នៅក្នុងប្រទេសចំនួន ៣១ អ្នកដែលមានការអប់រំកម្រិតមធ្យមសិក្សា ច្រើនតវ៉ាអំពីសេវាមិនមានប្រសិទ្ធភាពរបស់រដ្ឋាភិបាល ច្រើនជាងមនុស្ស ធម្មតា ១ ភាគ ៦។

ជាទូទៅ ការបង្កើនលទ្ធភាពទទួលបានការអប់រំសម្រាប់ទាំងអស់ កាត់បន្ថយអារម្មណ៍ថាខ្លួនទទួលរងភាព អយុត្តិធម៌ ក្នុងសង្គម ដែល ជាដើមចមនាំឱ្យមានជម្លោះជាច្រើន។ ប៉ុន្តែ គេចាំបាច់ត្រូវតែបង្កើនការ អប់រំឱ្យបានស្មើគ្នាសម្រាប់គ្រប់ក្រុមប្រជាជនទាំងអស់ បើមិនដូច្នេះទេ ការយល់ដឹងពីភាពអយុត្តិធម៌អាចរឹតតែបន្ថែមនូវភាពស្រងាកចិត្ត របស់ប្រជាជន។ នៅក្នុងប្រទេសចំណូលទាប និងមធ្យមចំនួន ៥៥ ដែលកម្រិតវិសមភាពអប់រំកើនឡើងទ្វេដង លទ្ធភាពនាំឱ្យមានជម្លោះកើតឡើង កើនឡើងទ្វេដង ពី ៣,៨% ដល់ ៩,៥%។

តាមរយៈការបង្កើនចំណេះដឹង បណ្ដុះនូវគុណតម្លៃ លើកកម្ពស់ជំនឿ និងផ្លាស់ប្ដូរឥរិយាបថ ការអប់រំមាន សក្ដានុពលធំធេង ក្នុងការផ្លាស់ប្ដូរបែបផែននៃការរស់នៅ និងឥរិយាបថ ដែលបង្កគ្រោះថ្នាក់ដល់បរិស្ថាន។ វិធីដ៏សំខាន់ មួយ ដែលការអប់រំអាចបង្កើនការយល់ដឹង និងការគិតគូរពីបរិស្ថាន គឺតាមរយៈការបង្កើនការយល់ដឹងអំពីវិទ្យាសាស្ត្រ ដែលស្ថិតនៅពីក្រោយការប្រែប្រួលអាកាសធាតុ និងបញ្ហាបរិស្ថានដទៃទៀត។ សិស្ស ដែលទទួលបានពិន្ទុវិទ្យាសាស្ត្រខ្ពស់នៅក្នុងប្រទេសចំនួន ៥៧ បានរាយការណ៍ថា មានការយល់ដឹងច្រើនអំពីបញ្ហាបរិស្ថាន ដែលស្មុគស្មាញ។ ស្រដៀងគ្នានេះដែរក្នុង ចំណោមប្រទេស ២៥ ដែលភាគច្រើនជាប្រទេសមានចំណូលខ្ពស់ ប្រជាជន ២៥% ក្នុងចំណោមប្រជាជន ដែលមាន កម្រិតវប្បធម៌ទាបជាងមធ្យមសិក្សា មានការព្រួយបារម្ភពីបរិស្ថាន បើធៀបជាមួយនឹង ៣៧% នៃប្រជាជនដែលមាន ការអប់រំកម្រិតមធ្យមសិក្សា និង ៤៦% នៃប្រជាជន ដែលមានការអប់រំកម្រិតឧត្តមសិក្សា។

ការអប់រំ ក៏មានសារៈសំខាន់ ដើម្បីជួយមនុស្សឱ្យចេះបន្សាំខ្លួនទៅនឹងផលវិបាកនៃការប្រែប្រួលអាកាសធាតុ ជាពិសេស នៅតាមប្រទេសក្រីក្រ ដែលកសិករពឹងអាស្រ័យលើរបរកសិកម្មពឹងទឹកភ្លៀង ទទួលរងការគំរាមកំហែងខ្លាំង ជាងគេចំពោះជីវភាពរស់នៅរបស់ពួកគេ។ នៅក្នុងប្រទេសអេត្យូពី ការ

**នៅក្នុងប្រទេសអាហ្សង់ទីន ចិន និងតួគី ប្រជាពលរដ្ឋ ច្រើនចុះហត្ថលេខាលើញត្តិអ្វីមួយ ក្នុងកម្រិត ២ ដង ច្រើន ជាង ប្រសិនបើពួកគេមានការអប់រំកម្រិតមធ្យមសិក្សា**

# ការរៀនសូត្រកាត់បន្ថយការរៀបការ និងការមានកូននៅវ័យក្មេងពេក

## ស្ត្រី ដែលរៀនបានកាន់តែខ្ពស់ កាន់តែមិនសូវរៀបការ ឬមានកូននៅវ័យក្មេងពេក

### ការរៀបការរបស់កុមារ

14%
រៀបការតិចជាងមុន ១៤% ប្រសិនបើក្មេងស្រីទាំងអស់មានការអប់រំកម្រិតបឋមសិក្សា

64%
រៀបការតិចជាងមុន ៦៤%ប្រសិនបើក្មេងស្រីទាំងអស់មានការអប់រំកម្រិតមធ្យមសិក្សា

ការរៀបការរបស់កុមារ សម្រាប់ក្មេងស្រីទាំងអស់អាយុក្រោម ១៥ ឆ្នាំ នៅអាហ្វ្រិចសាប់សាហារ៉ា និងអាស៊ីខាងត្បូង និងខាងលិច



2,867,000 | 2,459,000 | 1,044,000

### ការឆាប់មានកូន

10%
មានក្មេងស្រីតិចជាងនេះ ១០% នឹងមានផ្ទៃពោះប្រសិនបើក្មេងស្រីទាំងអស់មានការអប់រំកម្រិតបឋមសិក្សា

59%
មានក្មេងស្រីតិចជាងនេះ ៥៩% នឹងមានផ្ទៃពោះប្រសិនបើក្មេងស្រីទាំងអស់មានការអប់រំកម្រិតបឋមសិក្សា

មានក្មេងស្រីតិចជាងនេះ ១០% នឹងមានផ្ទៃពោះប្រសិនបើក្មេងស្រីទាំងអស់មានការអប់រំកម្រិតបឋមសិក្សា



3,397,000 | 3,071,000 | 1,393,000

### អត្រាសាយកូន *

ពុំបានទទួលការអប់រំ | ការអប់រំកម្រិតបឋមសិក្សា | ការអប់រំកម្រិតមធ្យមសិក្សា

ចំនួនសម្រាលកូនជាមធ្យមក្នុងស្ត្រីម្នាក់នៅអាហ្វ្រិចសាប់សាហារ៉ា



6.7 | 5.8 | 3.9

*អត្រាសាយកូន គឺជាចំនួនកូនជាមធ្យម ដែលកើតជាមួយនឹងស្ត្រីម្នាក់ នៅក្នុងពេញមួយជីវិតរបស់នាង

SourcesEFA Global Monitoring Report team calculations (2013), based on Demographic and Health Surveys; UNPD (2011).

អប់រំរយៈពេល ៦ ឆ្នាំបង្កើនឱកាសដែលកសិករនឹង បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈបច្ចេកទេសនានា ដូចជា ការរក្សាការពារដី ការផ្លាស់ប្តូរពេលដាំដុះ និងការផ្លាស់ប្តូរពូជដំណាំបាន ២០%។

ការអប់រំអាចផ្តល់ភាពអង់អាចដល់ស្ត្រី ឱ្យទាមទារសិទ្ធិរបស់ពួកគេ និងជំនះឧបសគ្គនានា ដែលរារាំងពួកគេមិនឱ្យ ទទួលបានចំណែកស្មើភាពពីភាគផលនៃការរីកចម្រើនជារួម។ ការមានសេរីភាព ក្នុងការជ្រើសរើសគូស្រករបស់ខ្លួន គឺជា សិទ្ធិមួយរបស់ស្ត្រី។ ស្ត្រី នៅក្នុងប្រទេសឥណ្ឌា ដែលរៀនបានយ៉ាងហោចណាស់កម្រិតមធ្យមសិក្សា ទំនងជាមានសិទ្ធិក្នុង ការជ្រើសរើសគូស្រករច្រើនជាងស្ត្រីដែលមានការអប់រំតិចជាងនេះ ចំនួន ៣០ ភាគរយចំណុច។

ដូចគ្នានេះដែរ ការធានាយ៉ាងណាឱ្យក្មេងស្រីបន្តរៀនសូត្រក្នុងសាលារៀន គឺជាវិធីសាស្ត្រមួយ ក្នុងចំណោម វិធីសាស្ត្រ ដែលមានប្រសិទ្ធភាពបំផុត ដើម្បីបង្ការមិនឱ្យកុមាររៀបអាពាហ៍ពិពាហ៍។ ប្រសិនបើក្មេងស្រីទាំងអស់បានរៀន ចប់សាលាបឋមសិក្សា នៅអាហ្វ្រិចសាប់សាហារ៉ា និងអាស៊ីខាងត្បូង និងខាងលិច នោះចំនួនក្មេងស្រី ដែលរៀបការមុន អាយុ ១៥ ឆ្នាំ នឹងថយចុះ ១៤%។ ប្រសិនបើពួកគេរៀនបានកម្រិតមធ្យមសិក្សា នឹងមានក្មេងស្រីតិចជាងមុន ៦៤% ដែល រៀបអាពាហ៍ពិពាហ៍ (ក្រាហ្វព័ត៌មាន ៖ ការរៀនសូត្រកាត់បន្ថយការរៀបការ និងការមានកូននៅវ័យក្មេងពេក)។

ការបន្តរៀនសូត្រកាន់តែយូរ ក៏ផ្តល់ឱ្យក្មេងស្រីនូវទំនុកចិត្តកាន់តែច្រើនជាងមុន ក្នុងការជ្រើសរើសនានា ដែលអាច ឱ្យពួកគេចៀសផុតពីហានិភ័យដែលកើតឡើងដោយសារការឆាប់មានកូននៅវ័យក្មេង និងការសម្រាលកូនញឹកញាប់បន្ត បន្ទាប់គ្នា។ បច្ចុប្បន្ននេះ មានក្មេងស្រី ១ នាក់ ក្នុងចំណោម ៧ នាក់ដែលមានកូនមុនដល់អាយុ ១៧ ឆ្នាំ នៅអាហ្វ្រិចសាប់សាហារ៉ា និងអាស៊ីខាងត្បូង និងខាងលិច។ នៅតាមតំបន់ទាំងនេះ មានក្មេងស្រី ដែលអាចមានផ្ទៃពោះ តិចជាង ១០% ប្រសិនបើពួកគេទាំងអស់គ្នាបានរៀនកម្រិតបឋមសិក្សា និងទាបជាងនេះ ៥៩% ប្រសិនបើពួកគេទាំងអស់គ្នាបានរៀន កម្រិតមធ្យមសិក្សា។ នេះនឹងនាំឱ្យមានការសម្រាលកូននៅវ័យក្មេងពេកថយចុះបាន ២ លាននាក់ករណី។

ស្ត្រី ដែលរៀនបានច្រើន ច្រើនតែមានកូនតិច ដែលនេះផ្តល់ប្រយោជន៍ដល់ពួកគេ គ្រួសាររបស់ពួកគេ និងសង្គមទាំងមូល ជាទូទៅ។ មូលហេតុមួយ ដែលនាំឱ្យមានការអះអាងខាងលើ គឺដោយសារតែការអប់រំផ្តល់លទ្ធភាពឱ្យស្ត្រីមានឥទ្ធិពលកាន់តែធំជាងមុនមកលើទំហំគ្រួសារ។ នៅក្នុងប្រទេសប៉ាគីស្ថាន មានស្ត្រីត្រឹមតែ ៣០% ក្នុងចំណោមស្ត្រី ដែលមិនបានទទួលការអប់រំប៉ុណ្ណោះ ដែលជឿថា ពួកគេមានសិទ្ធិនិយាយពីចំនួនកូនដែលពួកគេមាន បើធៀបជាមួយនឹង ៥២% នៃស្ត្រី ដែលរៀនបានបឋមសិក្សា និង ៦៣% នៃស្ត្រី ដែលរៀនបានមធ្យមសិក្សាបឋមភូមិ។

នៅតាមតំបន់មួយចំនួន ការអប់រំ គឺជាកត្តាដ៏សំខាន់មួយ ដើម្បីធ្វើឱ្យមានការបម្រែបម្រួលលក្ខណៈប្រជាសាស្ត្រ។ ប៉ុន្តែ តំបន់ដទៃទៀតនៅក្នុងពិភពលោក នៅមានភាពយឺតយ៉ាវក្រោយគេ ជាពិសេស អាហ្វ្រិចសាប់សាហារ៉ា ដែលស្ត្រី សម្រាលកូនជាមធ្យម ៥,៤ នាក់។ នៅក្នុងតំបន់នេះ ស្ត្រី ដែលមិនបានរៀនសូត្រសោះ សម្រាលកូន ៦,៧ នាក់ ជាមធ្យម។ តួលេខនេះថយចុះមកនៅត្រឹម ៥,៨ នាក់ ចំពោះស្ត្រី ដែលរៀនបានបឋមសិក្សា និងថយចុះជាងពាក់កណ្តាលមកនៅ ៣,៩ ឆ្នាំ ចំពោះស្ត្រី ដែលរៀនបានមធ្យមសិក្សា។

## សេចក្តីសន្និដ្ឋាន

កស្តុតាងគួរភ្ញាក់ផ្អើល ដែលបង្ហាញនៅក្នុងជំពូកនេះ បង្ហាញឱ្យឃើញមិនត្រឹមតែពីលទ្ធភាពរបស់ការអប់រំ ក្នុងការ ពន្លឿនវឌ្ឍនភាព ក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ដទៃទៀតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរបៀបដែលគេអាចទាញប្រយោជន៍ឱ្យបានច្រើនបំផុតពីសក្តានុពលនៃការអប់រំ ជាពិសេសតាមរយៈការធានាឱ្យមនុស្សគ្រប់រូបអាចទទួលបានការ អប់រំប្រកបដោយគុណភាព មិនថាពួកគេស្ថិតក្នុងកាលៈទេសៈបែបណានោះទេ។ អំណាចពិសេសរបស់ការអប់រំ គួរតែធានាឱ្យការអប់រំទទួលបានកន្លែងសំខាន់មួយ នៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ក្រោយឆ្នាំ ២០១៥ ក៏ដូចជានៅក្នុងផែនការរបស់អ្នកតាក់តែងគោលនយោបាយ នៅតាមប្រទេសនានា ទាំងប្រទេសក្រីក្រ និងប្រទេសអ្នកមាន។

**អំណាចនៃការអប់រំ ដើម្បីឱ្យជីវិតមានការប្រែប្រួល គួរធានាឱ្យការអប់រំទទួលបានកន្លែងសំខាន់មួយ នៅក្នុងក្របខ័ណ្ឌក្រោយឆ្នាំ ២០១៥**



© Amina Sayeed/UNESCO

# ផ្នែកទី ៣ ៖ ផ្តល់ការគាំទ្រដល់គ្រូ ដើម្បីបញ្ចប់វិបត្តិនៃការរៀនសូត្រ

កង្វះការយកចិត្តទុកដាក់លើគុណភាពនៃការអប់រំ និងការខកខានមិនបានផ្តល់សេវាឱ្យដល់កុមារហាត់បង់ឱកាស បានរួមចំណែកធ្វើឱ្យវិបត្តិនៃការរៀនសូត្រកើតមានឡើង ដែលទាមទារឱ្យមានការផ្តោតការយកចិត្តទុកដាក់ជាបន្ទាន់។ នៅទូទាំងសកលលោកទាំងមូល កុមារចំនួន ២៥០ លាននាក់ ដែលពួកគេជាច្រើននាក់មកពីគ្រួសារដែលជួបប្រទះការលំបាក មិនបានរៀនជំនាញលេខ និងអក្សរជាមូលដ្ឋានឡើយ ចុះទម្រាំជំនាញផ្សេងទៀត ដែលពួកគេត្រូវការ ដើម្បីបានការងារសមរម្យ និងរស់នៅជីវិត ដែលពួកគេពេញចិត្តនោះ។

ដើម្បីដោះស្រាយបញ្ហានៃការរៀនសូត្រ កុមារគ្រប់រូបត្រូវតែមានគ្រូ ដែលបានទទួលការបណ្តុះបណ្តាល ទទួលបានការលើកទឹកចិត្ត និងពេញចិត្តជាមួយនឹងការងារបង្រៀន ជាអ្នកដែលអាចកំណត់ និងផ្តល់ការគាំទ្រដល់សិស្សដែលរៀនខ្សោយ និងទទួលបានការគាំទ្រពីប្រព័ន្ធអប់រំ ដែលត្រូវបានគ្រប់គ្រងបានល្អ។

ដូចដែលបង្ហាញនៅក្នុងរបាយការណ៍នេះ រដ្ឋាភិបាលអាច បង្កើនលទ្ធភាពទទួលបានការអប់រំ ហើយក្នុងពេលជាមួយគ្នា ធានាឱ្យមានការលើកកម្ពស់ការរៀនសូត្រសម្រាប់ទាំងអស់គ្នា។ ផែនការអប់រំជាតិ ដែលទទួលបានថវិកាក្នុងចំនួនគ្រប់គ្រាន់  ហើយដែលមានគោលបំណងបំពេញតម្រូវការរបស់កុមារជួបប្រទះការលំបាក ក៏ដូចជាធានាឱ្យកុមារទទួលបានគ្រូ ដែលមានការបណ្តុះបណ្តាលត្រឹមត្រូវប្រកបដោយសមធម៌ ត្រូវតែជាអាទិភាពគោលនយោបាយមួយ។ ការទាក់ទាញ និងការរក្សាឱ្យនៅគង់វង្សនូវគ្រូ ដែលមានសមត្ថភាពបំផុតសម្រាប់ជាមធ្យោបាយបញ្ចប់វិបត្តិនៃការរៀនសូត្រ តម្រូវឱ្យមានការធ្វើសកម្មភាពប្រកបដោយភាពប៉ិនប្រសប់ពីសំណាក់អ្នកតាក់តែងគោលនយោបាយ ( សូមមើលរូបភាពបង្ហាញ )។

ដើម្បីធានាយ៉ាងណាឱ្យកុមារគ្រប់រូបទទួលបានការរៀនសូត្រ គ្រូក៏ត្រូវការការគាំទ្រផ្នែកកម្មវិធីសិក្សាសមស្រប និងប្រព័ន្ធវាយតម្លៃ ដែលផ្តោតការយកចិត្តទុកដាក់ជាពិសេសលើតម្រូវការរបស់កុមារ ដែលរៀននៅថ្នាក់ដំបូងៗជាពេល ដែលសិស្សងាយរងគ្រោះបំផុត ច្រើនបោះបង់ចោលការសិក្សា។ ក្រៅពីការបង្រៀនចំណេះដឹងជាមូលដ្ឋាន គ្រូត្រូវជួយឱ្យ សិស្សទទួលបានជំនាញសំខាន់ៗ ដែលអាចផ្ទេរបាន ដើម្បីជួយឱ្យពួកគេក្លាយជាប្រជាពលរដ្ឋសកលប្រកបដោយការទទួលខុសត្រូវ។




អ្នកតាក់តែងគោលនយោបាយ ត្រូវផ្តល់ការគាំទ្រដល់គ្រូ
ដើម្បីបញ្ចប់វិបត្តិនៃការរៀនសូត្រ

© UNESCO/Wild is the Game

## វិបត្តិនៃការរៀនសូត្រមានផលប៉ះពាល់ខ្លាំងជាងគេមកលើកុមារដែលជួបប្រទះការលំបាក

បើទោះបីជាមានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ផ្នែកការទទួលបានការអប់រំ នៅក្នុងទសវត្សរ៍ចុងក្រោយនេះក៏ដោយ ភាពរីកចម្រើនផ្នែកគុណភាព ជានិច្ចកាល មិនបានតាមឱ្យទាន់ភាពរីកចម្រើនផ្នែកការទទួលបានការអប់រំឡើយ។ ប្រទេសជាច្រើន មិនបានផ្ដល់ការធានាឱ្យកុមាររបស់ខ្លួនទទួលបាន សូម្បីតែបំណិនជាមូលដ្ឋានបំផុតផ្នែកអំណាន និងគណិតវិទ្យា។ កុមារជួបប្រទះការលំបាក ច្រើនតែទទួលរងផលប៉ះពាល់ជាងគេ ដោយសារការមានគ្រូដែលឆ្លងកាត់ការ បណ្ដុះបណ្ដាលក្នុងចំនួនគ្រប់គ្រាន់ ហេដ្ឋារចនាសម្ព័ន្ធដែលប្រើហួសកម្រិត និងសម្ភារឯកសារមិនគ្រប់គ្រាន់។ តែទោះជាយ៉ាងណាក៏ដោយ ប្រទេសនានាអាចពង្រីកលទ្ធភាពចូលរៀនរបស់កុមារ ហើយស្របពេលជាមួយគ្នា ក៏អាចលើកកម្ពស់ សមធម៌នៃការរៀនសូត្រផង ដែរ។

## វិបត្តិនៃការរៀនសូត្រជាសកល ៖ វិធានការ គឺជាសកម្មភាពបន្ទាន់ដែលត្រូវធ្វើ

ក្នុងចំណោមកុមារដល់វ័យចូលរៀននៅសាលាបឋមសិក្សាចំនួន ៦៥០ លាននាក់ក្នុងពិភពលោក មានកុមារយ៉ាង ហោចណាស់ ២៥០ លាននាក់ ដែលមិនបានរៀនចំណេះដឹងជាមូលដ្ឋានផ្នែកអំណាន និងគណិតវិទ្យា។ ក្នុងចំណោមកុមារ ទាំងនេះ មានកុមារជាតិ ១២០ លាននាក់ ដែលមានបទពិសោធន៍តិចតួច ឬពុំមានបទពិសោធន៍ទាល់តែសោះជាមួយនឹង សាលាបឋមសិក្សា ដោយមិនទាំងបានរៀនដល់ថ្នាក់ទី ៤ ផង។ កុមារដែលនៅសល់ ១៣០ លាននាក់ទៀត កំពុងរៀននៅសាលាបឋមសិក្សា ប៉ុន្តែមិនហានសម្រេចទៅតាមចំណុចដៅអប្បបរមាសម្រាប់ការរៀនសូត្រឡើយ។ ជារឿយៗ ជាមួយ នឹងការមិនអាចយល់សូម្បីតែពីប្រយោគដ៏សាមញ្ញមួយ កុមារទាំងនេះមិនហានទទួលការបំពាក់បំប៉នឱ្យបានសមស្រប ដើម្បី ឆ្លងភូមិសិក្សាទៅការអប់រំកម្រិតមធ្យមសិក្សាឡើយ។

មានគម្លាតដ៏ធំរវាងតំបន់មួយ និងតំបន់មួយទៀត ផ្នែកលទ្ធផលនៃការរៀនសូត្រ។ នៅអាមេរិចខាងជើង និងអឺរ៉ុបខាងលិច កុមារ ៩៦% បន្តរៀនសូត្រ ក្នុងសាលារៀន រហូតដល់ថ្នាក់ទី ៤ ហើយអាចសម្រេចបាននូវស្តង់ដាអំណាន កម្រិតអប្បបរមា បើធៀបជាមួយនឹងកុមារត្រឹមតែ ១ ភាគ ៣ នៅអាស៊ីខាងត្បូង និងខាងលិច និង ២ ភាគ ៥ នៅ អាហ្វ្រិកសាប់សាហារ៉ា (រូបភាពទី ១៣)។ តំបន់ទាំងពីរនេះ ស្រូបយកដល់ទៅជាង ៣ ភាគ ៤ នៃអ្នកដែលមិនបានឆ្លងកាត់កម្រិតនៃការរៀនសូត្រជាអប្បបរមា។

វិបត្តិនៃការរៀនសូត្រមានទំហំធំធេង។ ការវិភាគថ្មីៗបង្ហាញថា មានកុមារតិចជាងពាក់កណ្ដាល ដែលរៀនចេះ ចំណេះដឹងជាមូលដ្ឋាន នៅក្នុងប្រទេសចំនួន ២១ ក្នុងចំណោម ៨៥ ប្រទេស ដែលមានទិន្នន័យពេញលេញ។ ក្នុងចំណោម ប្រទេសទាំងនេះ មានប្រទេសចំនួន ១៧ ស្ថិតនៅក្នុងតំបន់អាហ្វ្រិកសាប់សាហារ៉ា។ ប្រទេសដទៃទៀត រួមមាន ប្រទេស ឥណ្ឌា ម៉ៅរីតានៀ ម៉ារ៉ុក និងប៉ាគីស្ថាន។

វិបត្តិនៃការរៀនសូត្រនេះ មានការខាតបង់ មិនត្រឹមតែចំពោះមហិច្ឆតារបស់កុមារនាពេលអនាគតប៉ុណ្ណោះទេ ថែមទាំងចំពោះថវិកាបច្ចុប្បន្នរបស់រដ្ឋាភិបាលថែមទៀតផង។ ការខាតបង់ ដោយសារតែកុមារ ២៥០ លាននាក់ មិនបាន រៀនចេះចំណេះដឹងជាមូលដ្ឋាន ស្មើនឹង ១២៩ ពាន់លានដុល្លារ ឬ ១០% នៃការចំណាយជាសកលលើការអប់រំកម្រិតបឋមសិក្សា។

**ការខាតបង់ ដោយសារតែកុមារចំនួន ២៥០ លាននាក់ មិនបានរៀនចេះនូវចំណេះដឹងជាមូលដ្ឋាន ស្មើនឹង ១២៩ ពាន់លានដុល្លារ**



© Nguyen Thanh Tuan/UNESCO

រូបភាពទី ១៣ ៖ កុមារ ២៥០ លាននាក់ មិនបានរៀនចេះចំណេះដឹងជាមូលដ្ឋានផ្នែកអំណានឡើយ
ភាគរយកុមារដែលមានអាយុចូលរៀននៅសាលាបឋមសិក្សា ដែលបានរៀនដល់ថ្នាក់ទី ៤ និងសម្រេចបាននូវស្តង់ដានៃការរៀនសូត្រកម្រិតអប្បបរមាផ្នែកអំណាន បែងចែកតាមតំបន់




សម្គាល់ ៖ និយមន័យកុមារដែលរៀនដល់ថ្នាក់ទី ៤ គឺផ្អែកទៅតាមវិធីសាស្ត្រអត្រាបញ្ចប់ការសិក្សារំពឹងទុករបស់ក្រុមសិស្ស។ និយមន័យនៃការ សម្រេចនូវស្តង់ដារៀនសូត្រកម្រិតអប្បបរមា គឺផ្អែកទៅតាមដំណើរការ ដែលបម្លែងលទ្ធផលនៃការអង្កេតផ្សេងៗ ឱ្យក្លាយជាកម្រិតរួមមួយ
ប្រភព ៖ ការគណនារបស់ក្រុមការងារតាក់តែងរបាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា ផ្អែកទៅតាម (១) អត្រាគង់វង្សរំពឹងទុករបស់ក្រុមសិស្ស ដល់ថ្នាក់ទី ៣ ៖ មូលដ្ឋានទិន្នន័យ UIS, (២) លទ្ធផលនៃការរៀនសូត្រ Altinok (2013a) ៖ ដោយប្រើប្រាស់ ទិន្នន័យដែលបានពី 2011 PIRLS, 2007 SACMEQ, 2004-2008 PASEC, 2006 SERCE; និងការវិភាគដោយក្រុមអង្កេត 2012 ASER របស់ប្រទេសឥណ្ឌា និងរបស់ប្រទេសប៉ាគីស្ថាន

## គម្លាតជាសកល លាក់កំបាំងពីវិសមភាពយ៉ាងធំធេង នៅក្នុងបណ្តាប្រទេសនានា

ខណៈពេលដែលតួលេខជាមធ្យមអំពីលទ្ធផលនៃការរៀនសូត្របង្ហាញនូវរូបភាពជារួមអំពីវិសាលភាពនៃវិបត្តិនៃ ការរៀនសូត្រ តួលេខទាំងនេះលាក់កំបាំងនូវគម្លាតដ៏ធំធេង នៅក្នុងបណ្តាប្រទេសនានា។ ភាពក្រីក្រ យេនឌ័រ ទីតាំង ភាសា ជាតិពន្ធុ ពិការភាព និងកត្តាដទៃទៀត មានន័យថា កុមារមួយចំនួនទំនងជាទទួលបានការគាំទ្រតិចតួចពីសាលារៀន ដើម្បី ឱ្យការរៀនសូត្ររបស់ពួកគេកាន់តែមានភាពល្អប្រសើរ។

ថាតើកុមាររៀនសូត្របានច្រើនប៉ុណ្ណា ទទួលរងឥទ្ធិពលយ៉ាងធំធេងដោយសារទ្រព្យធនរបស់គ្រួសារ។ ការវិភាគ លើប្រទេសនៅអាហ្វ្រិចចំនួន ២០ សម្រាប់របាយការណ៍នៅឆ្នាំនេះ បង្ហាញថា កុមារមកពីគ្រួសារដែលមានជីវភាពធូរធា ច្រើនតែមិនត្រឹមតែបានរៀនចប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចសម្រេចបាននូវការរៀនសូត្រក្នុងកម្រិតអប្បបរមាថែម ទៀតផង។ ផ្ទុយទៅវិញ នៅក្នុងប្រទេសចំនួន ១៥ ក្នុងចំណោមប្រទេសទាំងនេះ ពុំមានកុមារលើសពី ១ នាក់ក្នុងចំណោម កុមារក្រីក្រ ៥ នាក់ អាចរៀនបានដល់ថ្នាក់ចុងក្រោយ និងរៀនចេះចំណេះដឹងជាមូលដ្ឋានឡើយ។

នៅអាមេរិចឡាទីន ដែលលទ្ធផលនៃការរៀនសូត្ររបស់សិស្សមានកម្រិតខ្ពស់ជាទូទៅ កុមារមកពីគ្រួសារជួបប្រទះការលំបាកក៏នៅមានភាពយឺតយ៉ាវឆ្ងាយជាងកុមារមកពីគ្រួសារដែលមានជីវភាពធូរធាដែរ។ នៅក្នុងប្រទេស អេលសាវ៉ាឌ័រ កុមារ ៤២% ក្នុងចំណោមកុមារមកពីគ្រួសារដែលក្រខ្សត់បំផុត រៀនចប់កម្រិតបឋមសិក្សា និងរៀនចេះ ចំណេះដឹងជាមូលដ្ឋាន បើធៀបជាមួយនឹង ៨៤% នៃកុមារមកពីគ្រួសារដែលមានជីវភាពធូរធាបំផុត។

ក្មេងស្រី នៅតាមគ្រួសារក្រីក្រ ជួបប្រទះនឹងការលំបាកជាងគេមួយចំនួន ដែលនេះបង្ហាញថា ចាំបាច់ត្រូវតែមាន ការចាត់វិធានការជាបន្ទាន់មួយ ដើម្បីដោះស្រាយគម្លាតយេនឌ័រ តាមរយៈគោលនយោបាយអប់រំ។ ឧទាហរណ៍ នៅក្នុងប្រទេសបេនីន មានក្មេងប្រុស ៦០% ក្នុងចំណោមមកពីគ្រួសារមានជីវភាពធូរធាបន្តរៀនក្នុងសាលារៀន និងរៀនចេះជំនាញលេខជាមូលដ្ឋានបើធៀបជាមួយនឹង ៦% នៃក្មេងស្រីមកពីគ្រួសារក្រីក្រ។

ការរស់នៅក្នុងតំបន់ជួបប្រទះការលំបាក - ជាពិសេស តំបន់ជនបទដែលជារឿយៗ មានការខ្វះខាតគ្រូ និងធនធានបង្រៀន គឺជាឧបសគ្គដ៏ធំមួយចំពោះការរៀនសូត្រ។ នៅសាធារណរដ្ឋតង់ហ្សានៀ មានកុមារត្រឹមតែ ២៥% ក្នុងចំណោមកុមារមកពីតំបន់ជនបទតែប៉ុណ្ណោះ ដែលរៀនចេះចំណេះដឹងជាមូលដ្ឋានបើធៀបជាមួយនឹងកុមារ ៦៣% ក្នុង ចំណោមកុមារមកពីគ្រួសារមានជីវភាពធូរធា នៅតំបន់ប្រជុំជន។ នៅក្នុងប្រទេសនៅអាមេរិចឡាទីនមួយចំនួន ដូចជាប្រទេសអេលសាវ៉ាឌ័រ គ័រតេម៉ាឡា ប៉ាណាម៉ា និងពេរូ ជាដើម គម្លាតនៃលទ្ធផលសិក្សាផ្នែកគណិតវិទ្យា និងអំណាន រវាងសិស្សនៅតំបន់ជនបទ និងសិស្សនៅតំបន់ប្រជុំជន មានលើសពី ១៥ ភាគរយចំណុចទៅទៀត។

ការលំបាក ពាក់ព័ន្ធជាមួយនឹងទីតាំង ចាប់ផ្តើមមានតាំងពីថ្នាក់ដំបូងៗទៅ ហើយកាន់តែរីកធំឡើងៗ។ នៅក្នុងប្រទេសហ្គាណា សិស្សនៅតំបន់ប្រជុំជន អាចរៀនដល់កម្រិតអប្បបរមានៃភាសាអង់គ្លេសនៅថ្នាក់ទី ៣ ជាងសិស្សនៅ ជនបទដល់ទៅ ២ ដង និងច្រើនជាង ៣ ដង មុនពេលដែលពួកគេរៀនដល់ថ្នាក់ទី ៦។

ការលំបាក ដោយសារតែទីតាំងភូមិសាស្ត្រ ជារឿយៗ រឹតតែធ្ងន់ធ្ងរឡើង ដោយសារតែភាពក្រីក្រ និងយេនឌ័រ។ នៅក្នុងខេត្តបាឡូគីស្ថាន ក្នុងប្រទេសប៉ាគីស្ថាន មានកុមារ ៤៥% ក្នុងចំណោមកុមារដែលមានអាយុរៀនថ្នាក់ទី ៥ ប៉ុណ្ណោះ ដែលអាចដោះស្រាយលំហាត់ប្រមាណវិធីដកលេខពីរខ្ទង់បាន បើធៀបជាមួយនឹងកុមារ ៧៣% នៅក្នុងខេត្តពុនចាប ដែល ប្រជាជនមានជីវភាពធូរធាជាង។ មានក្មេងស្រីប្រមាណជា ១ ភាគ ៤ ក្នុងចំណោមក្មេងស្រីមកពីគ្រួសារមានជីវភាពក្រីក្រ នៅក្នុងខេត្តបាឡូគីស្ថាន ដែលរៀនចេះជំនាញលេខជាមូលដ្ឋាន ខណៈពេលដែលក្មេងប្រុសមកពីគ្រួសារមានជីវភាពធូរធា ក្នុងខេត្តនេះ អាចរៀនបានពូកែជាងនេះឆ្ងាយ ពោលគឺអាចដល់កម្រិតមធ្យម នៅក្នុងខេត្តពុនចាប។

ការរើសអើង ដែលក្រុមជនជាតិដើមភាគតិច ឬក្រុមជនជាតិភាគតិចមួយចំនួន ជួបប្រទះ រឹតតែធ្វើឱ្យពួកគេជួប ប្រទះនឹងការលំបាក ដោយហេតុថា ភាសា ដែលប្រើប្រាស់ក្នុងថ្នាក់រៀន អាចមិនមែនជាភាសា ដែលពួកគេនិយាយនោះឡើយ។ នៅក្នុងប្រទេសពេរូ នៅក្នុងឆ្នាំ ២០១១ អ្នកនិយាយភាសាអេស្ប៉ាញ មានលទ្ធភាព ៧ ដងច្រើនជាងអ្នកនិយាយ ភាសាជនជាតិដើមភាគតិច ក្នុងការឈានទៅដល់ស្តង់ដាជាទីពេញចេញផ្នែកអំណាន។ កម្មវិធីពីរភាសា ដែលរៀបចំបានល្អ ដែលបង្រៀនដោយគ្រូដែលមានសមត្ថភាព អាចជួយកុមារឱ្យជំនះបញ្ហាប្រឈមនេះបាន។

កុមារ ដែលរៀនមិនសូវចេះ ច្រើនតែឆាប់បោះបង់ចោលការសិក្សា។ នៅក្នុងប្រទេសអេត្យូពី ឥណ្ឌា ពេរូ និង វៀតណាម កុមារដែលទទួលបានពិន្ទុទាបមុខវិជ្ជាគណិតវិទ្យានៅអាយុ ១២ ឆ្នាំ ច្រើនបោះបង់ចោលការសិក្សាមុនសិស្ស ផ្សេងទៀត មុនពេលដែលពួកគេដល់អាយុ ១៥ ឆ្នាំ។ ឧទាហរណ៍ នៅក្នុងប្រទេសវៀតណាម សិស្សរៀនខ្សោយនៅអាយុ ១២ ឆ្នាំ ជិតពាក់កណ្តាលបោះបង់ចោលការសិក្សាមុនអាយុ ១៥ ឆ្នាំ បើធៀបជាមួយនឹងសិស្សប្រហែលជា ១ នាក់ ក្នុង ចំណោម ៥ នាក់ ដែលរៀនពូកែជាង។

ការលំបាក ដែលកុមារជួបប្រទះ ក្នុងការចូលរៀននៅសាលារៀន និងបន្តរៀនសូត្រក្នុងសាលារៀន នឹងនៅតែបន្ត មានរហូតដល់ពេល ដែលពួកគេចូលរៀននៅសាលាមធ្យមសិក្សា។ ឧទាហរណ៍ នៅអាហ្វ្រិចខាងត្បូង មានគម្លាតដ៏ធំមួយ នៅក្នុងការរៀនសូត្ររវាងអ្នកមាន និងអ្នកក្រ ដោយមានក្មេងជំទង់ក្រីក្រត្រឹមតែ ១៤% ប៉ុណ្ណោះ ដែលសម្រេចបានស្តង់ដា អប្បបរមាផ្នែកគណិតវិទ្យា ប្រហាក់ប្រហែលនឹងលទ្ធផលនៃការរៀនសូត្ររបស់សិស្សមានជីវភាពក្រីក្រ ក្នុងប្រទេសហ្គាណា ដែលជាប្រទេសមួយមានទ្រព្យធនតិចជាង ១ ភាគ ៥ នៃទ្រព្យធនរបស់ប្រទេសអាហ្វ្រិចខាងត្បូង។ គម្លាតបែប នេះគឺមិនអាចចៀសរួចឡើយ។ ប្រទេសបូស្វាណា មានលទ្ធផលនៃការសិក្សាខ្ពស់ជាងដោយសារតែមានគម្លាតតិចតួចរវាងអ្នកមាន និងអ្នកក្រ។

នៅតាមប្រទេសមួយចំនួន គម្លាតរវាងអ្នកមាន និងអ្នកក្រ កាន់តែស្តែងចេញច្បាស់ នៅថ្នាក់ខ្ពស់ៗ។ ឧទាហរណ៍ នៅក្នុងប្រទេសឈីលី ស្របពេលដែលគម្លាតមានកម្រិតទាបនៅថ្នាក់ទី ៤ សិស្សមកពីគ្រួសារមានជីវភាពធូរធា ៧៧% សម្រេចបានស្តង់ដាអប្បបរមា មុនពេលរៀនដល់ថ្នាក់ទី ៨ បើធៀបជាមួយនឹង ៤៤% នៃសិស្សក្រីក្រ។

## ប្រទេសអ្នកមានក៏ខកខានក្នុងការធានាយ៉ាងណាឱ្យកុមារជួបប្រទះការលំបាកអាចរៀនសូត្របានផងដែរ

ខណៈពេលដែលលទ្ធផលនៃការរៀនសូត្រនៅក្នុងប្រទេសអ្នកមានជាទូទៅ មានកម្រិតខ្ពស់ជាង ប្រព័ន្ធអប់រំរបស់ ប្រទេសទាំងនោះក៏ខកខានមិនបានគិតគូរពីក្រុមភាគតិចផងដែរ។ ឧទាហរណ៍ សិស្សរៀនថ្នាក់ទី ៨ ជាង ១០% នៅប្រទេសណរវ៉េ និងអង់គ្លេស រៀនចេះទាបជាងកម្រិតរៀនសូត្រអប្បបរមាផ្នែកគណិតវិទ្យា នៅក្នុងឆ្នាំ ២០១១។

ខណៈពេលដែលបណ្តាប្រទេសនៅអាស៊ីបូព៌ា ដូចជា ជប៉ុន សាធារណរដ្ឋកូរ៉េ និងសឹង្ហបុរី បានបង្ហាញថា ពួកគេអាចមានលទ្ធភាពដោះស្រាយការលំបាក ដែលប្រឈមដោយប្រជាជនរស់នៅក្នុងភាពក្រីក្រ គេមិនអាចនិយាយបែបនេះបាន សម្រាប់ប្រទេស OECD មួយចំនួន និងសម្រាប់ប្រទេសដែលមានធនធានស្តុកស្តម នៅរដ្ឋអារ៉ាប់នោះទេ។ ឧទាហរណ៍ ឱកាសដែលសិស្សក្រីក្រម្នាក់ នៅក្នុងប្រទេសអូម៉ាន អាចសម្រេចទៅតាមស្តង់ដានៃការរៀនសូត្រកម្រិតអប្បបរមា គឺស្រដៀងគ្នាជាមួយនឹងសិស្ស នៅក្នុងប្រទេសមិនសូវមានធនធាន ដូចជា ប្រទេសហ្គាណា ដែរ។ នៅក្នុងប្រទេសញូហ្សេលេន មានសិស្សក្រីក្រតែ ២ ភាគ ៣ ប៉ុណ្ណោះ ដែលបានសម្រេចស្តង់ដាអប្បរមា បើធៀបជាមួយនឹង ៩៧% នៃសិស្សដែលមកពីគ្រួសារមានជីវភាពធូរធា។

សិស្ស ដែលជាជនអន្តោប្រវេសន៍ ជួបប្រទះនឹងការបាត់បង់ឱកាសក្នុងកម្រិតខ្ពស់ នៅក្នុងការអប់រំ ដែលនាំឱ្យពួកគេមានលទ្ធផលសិក្សាក្នុងកម្រិតទាប។ នៅក្នុងប្រទេសបារាំង អាល្លឺម៉ង់ និងចក្រភពអង់គ្លេស សិស្សអាយុ ១៥ ឆ្នាំ ជាង ៨០% សម្រេចបានទៅតាមចំណុចដៅអប្បបរមាផ្នែកអំណាន។ ប៉ុន្តែសិស្សជាជនអន្តោប្រវេសន៍សម្រេចលទ្ធផលអន់ជាងនេះឆ្ងាយ។ នៅក្នុងចក្រភពអង់គ្លេស ភាគរយនៃសិស្សជាជនអន្តោប្រវេសន៍ ដែលអាចសម្រេចបានលើសពីចំណុចដៅអប្បបរមា គឺមិនខ្ពស់ជាងអត្រាមធ្យម សម្រាប់ប្រទេសតួគីឡើយ ខណៈពេលដែលសិស្សជាជនអន្តោប្រវេសន៍នៅក្នុងប្រទេសអាល្លឺម៉ង់ គឺសម្រេចលទ្ធផលប្រហាក់ប្រហែលគ្នានឹងសិស្ស នៅក្នុងប្រទេសឈីលី។ សិស្សជាជនអន្តោប្រវេសន៍ នៅក្នុងប្រទេសបារាំង ជួបប្រទះនឹងបញ្ហាមួយចំនួន ដោយសារតែពួកគេតិចជាង ៦០% ដែលជាប់ចំណុចដៅអប្បបរមា ស្មើនឹងកម្រិតមធ្យមសម្រាប់សិស្ស នៅប្រទេសម៉ិចស៊ិច។

**សិស្សជាជនអន្តោប្រវេសន៍តិចជាង ៦០% នៅក្នុងប្រទេសបារាំង ជាប់ចំណុចដៅរៀនសូត្រកម្រិតអប្បបរមា**

កុមារជនជាតិដើមភាគតិច នៅតាមប្រទេសដែលមានចំណូលខ្ពស់ជារឿយៗ តែងជួបប្រទះនឹងការលំបាក ហើយ គម្លាតនៅក្នុងលទ្ធផលនៃការរៀនសូត្ររបស់ពួកគេ ធៀបជាមួយនឹងប្រជាជនដទៃទៀត នៅតែបន្តមាន។ នៅក្នុងប្រទេសអូស្ត្រាលី មានសិស្សជនជាតិដើមភាគតិចប្រហែលជា ២ ភាគ ៣ បានសម្រេចទៅតាមចំណុចដៅអប្បបរមា នៅថ្នាក់ទី ៨ ចន្លោះពីឆ្នាំ ១៩៩៤/៥ និង ២០១១ បើធៀបជាមួយនឹង ៩០% នៃកុមារមិនមែនជនជាតិដើមភាគតិច។

## លើកកម្ពស់ការរៀនសូត្រ ហើយក្នុងពេលជាមួយគ្នាពង្រីកលទ្ធភាពទទួលបានការអប់រំ

ជារឿយៗ មានការអះអាងថា ការពង្រីកលទ្ធភាពចូលរៀននៅសាលាបឋមសិក្សា នៅតាមប្រទេសក្រីក្រ ធ្វើឱ្យ មានការថយចុះនូវគុណភាពនៃការអប់រំ។ តែទោះជាយ៉ាងណាក៏ដោយ បើទោះបីជាកុមារជាច្រើននាក់មិនបានរៀនចំណេះដឹងជាមូលដ្ឋានយ៉ាងណាក៏ដោយ ប្រទេសមួយចំនួនអាចប្រមូលកុមារបានកាន់តែច្រើនឱ្យចូលរៀនក្នុងសាលា ហើយក្នុងពេលជាមួយគ្នា ធានាថាពួកគេពិតជាអាចទទួលបានចំណេះដឹង នៅពេលដែលពួកគេរៀននៅទីនោះ។ តុល្យភាពនេះ គឺជាអ្វីដែលគួរឱ្យមានការភ្ញាក់ផ្អើល ដោយសារតែសិស្សដែលចូលរៀនថ្មីៗ ច្រើនតែមកពីគ្រួសារជួបប្រទះការលំបាក។ បើទោះបីជាដូច្នេះយ៉ាងណាក៏ដោយ នៅមានការងារជាច្រើនទៀត ដែលត្រូវធ្វើ ដើម្បីភ្ជាប់គម្លាតនៃការរៀនសូត្រឱ្យបានកាន់តែឆាប់រហ័សជាងនេះ សូម្បីតែនៅតាមប្រទេសអ្នកមាន។

សាធារណរដ្ឋតង់ហ្សានៀ មានការរីកចម្រើនយ៉ាងច្រើន ពាក់ព័ន្ធជាមួយនឹងចំនួនសិស្ស ដែលបានដល់ចប់សាលាបឋមសិក្សា មួយផ្នែកដោយសារតែការបង់ថ្លៃសាលាបឋមសិក្សា ត្រូវបានលុបបំបាត់ចោល នៅក្នុងឆ្នាំ ២០០១។ ចន្លោះពី ឆ្នាំ ២០០០ ដល់ ២០០៧ ភាគរយកុមារ ដែលរៀនចប់សាលាបឋមសិក្សាមានការកើនឡើងពីពាក់កណ្តាល រហូតដល់ពីរភាគបី ខណៈពេលដែលភាគរយកុមារ ដែលទទួលបានចំណេះដឹងមូលដ្ឋានផ្នែកគណិតវិទ្យាមានការកើនឡើងពី ១៩% ដល់ ៣៦%។ នេះគឺស្មើនឹងមានកុមារប្រមាណ ១,៥ លាននាក់បន្ថែមទៀតរៀនចេះចំណេះដឹងជាមូលដ្ឋានទាំងនេះ។ ខណៈពេល ដែលវាមិនមែនជាអ្វីដែលអាចទទួលយកបានឡើយ ដែលមានសិស្ស ២៧% រៀនសូត្រក្នុងសាលារៀន ប៉ុន្តែមិនបានរៀនចេះចំណេះដឹងជាមូលដ្ឋាន ការដែលបញ្ហាគុណភាពត្រូវបានលើកឡើងនៅក្នុងឆ្នាំ ២០០០ បង្ហាញថា បញ្ហាទាំងនេះគឺមាននៅក្នុងប្រព័ន្ធអប់រំផ្ទាល់តែម្តង ជាជាងមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងការពង្រីកវិស័យអប់រំ។

នៅក្នុងប្រទេសម៉ាឡាវី និងអ៊ូហ្គាន់ដា ការចូលរៀន និងគុណភាពនៃការអប់រំ មិនបានកើនឡើងឱ្យបានច្រើនឡើយ ចន្លោះពីឆ្នាំ ២០០០ និង ២០០៧ ហើយគម្លាតនៃការរៀនសូត្ររវាងអ្នកមាន និងអ្នកក្រ កាន់តែរីកធំឡើង។ ប្រទេសទាំងនេះ ជួបប្រទះនឹងបញ្ហាប្រឈមចំនួន ៣ ត្រួត ដែលចាំបាច់ត្រូវតែពង្រឹងលទ្ធភាពទទួលបានការអប់រំគុណភាពនៃការអប់រំ និងសមធម៌ ក្នុងការអប់រំ។

នៅកម្រិតមធ្យមសិក្សាក៏ដូច្នេះដែរ កិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើនលទ្ធភាពទទួលបានការអប់រំ មិនបានទទួល ជោគជ័យជានិច្ចកាល ក្នុងការបង្កើនការរៀនសូត្រ និងការផ្តល់សេវាទៅដល់កុមារដែលជួបប្រទះការលំបាកឡើយ។ នៅ ក្នុងប្រទេសម៉ិចស៊ិច នៅពេលដែលលទ្ធភាពទទួលបានការអប់រំមានការកើនឡើង ភាគរយរបស់សិស្សដែលសម្រេចបាន លទ្ធផលលើពីចំណុចដៅអប្បបរមាក៏មានការកើនឡើងផងដែរ ពី ១ ភាគ ៣ នៅក្នុងឆ្នាំ ២០០៣ ដល់ ១ ភាគ ២ នៅក្នុង ឆ្នាំ ២០០៩។ កម្មវិធីគាំពារសង្គម ដែលផ្តោតគោលដៅលើគ្រួសារជួបប្រទះការលំបាក បានជួយបង្កើនលទ្ធផលនៃការរៀន សូត្រសម្រាប់សិស្សមកពីគ្រួសារមានជីវភាពធូរធាផង និងគ្រួសារក្រីក្រផង។ ផ្ទុយទៅវិញ នៅក្នុងប្រទេសហ្គាណា ខណៈពេលដែលការចូលរៀននៅកម្រិតមធ្យមសិក្សាមានការកើនឡើងពី ៣៥% នៅក្នុងឆ្នាំ ២០០៣ ដល់ ៤៦% នៅក្នុងឆ្នាំ ២០០៩ ហើយលទ្ធផលសិក្សាផ្នែកលេខនព្វន្ធក៏មានការកើនឡើង ១០ ភាគរយចំណុចដែរនោះ គម្លាតយេនឌ័រនៅក្នុងការ រៀនសូត្របានកើនឡើងជាងពីរដង ហើយសិស្សមកពីគ្រួសារក្រីក្របំផុត ស្ទើរតែមិនបានទទួលប្រយោជន៍ទាល់តែសោះ។

ប្រទេសម៉ាឡេស៊ី ជួបប្រទះនឹងនិន្នាការ ដែលគួរឱ្យមានការព្រួយបារម្ភជាពិសេស ដោយសារតែលទ្ធផលនៃការ រៀនសូត្រមានការថយចុះ គួបផ្សំជាមួយនឹងការរីកធំនូវវិសមភាព និងការកើនឡើងនូវចំនួនក្មេងជំទង់ក្រៅសាលារៀន។ នៅក្នុងឆ្នាំ ២០០៣ ក្មេងជំទង់ភាគច្រើនលើសលុប ជាប់ចំណុចដៅអប្បបរមា មិនថាពួកគេមកពីគ្រួសារធូរធា ឬក្រីក្រ នោះទេ។ ប៉ុន្តែ នៅក្នុងឆ្នាំ ២០១១ មានសិស្សប្រុសក្រីក្រជាងគេប្រហែលតែពាក់កណ្តាលប៉ុណ្ណោះ ដែលជាប់ ចំណុចដៅ អប្បបរមា បើធៀបជាមួយនឹងជាង ៩០% នៅក្នុងឆ្នាំ ២០០៣។ កុមារក្រីក្រ នៅក្នុងប្រទេសម៉ាឡេស៊ី បានថយចុះពីការប្រហាក់ប្រហែលនឹងសិស្ស មធ្យមនៅក្នុងសហរដ្ឋអាមេរិច

## ការអប់រំដែលមានគុណភាពទាប នាំឱ្យមានភាពមិនចេះអក្សរ

**នៅប្រទេសដែលមានចំណូលទាប និងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប យុវជន ១ភាគ ៤ មិនចេះអានសូម្បីតែមួយប្រយោគ**

គុណភាពនៃការអប់រំ នៅវ័យកុមារ មានឥទ្ធិពលយ៉ាងសំខាន់លើភាពចេះអក្សររបស់យុវជន។ ការវិភាគថ្មីមួយ ដែលធ្វើឡើង សម្រាប់របាយការណ៍នេះ ផ្អែកទៅតាមការវាយតម្លៃដោយផ្ទាល់លើការអង្កេតអក្ខរកម្មតាមគ្រួសារ បង្ហាញ ថា ភាពមិនចេះអក្សររបស់យុវជន មានការសាយភាយច្រើនជាងកម្រិតដែលគេជឿថាមានកន្លងមក ៖ មានយុវជន ប្រមាណជា ១៧៥ លាននាក់ នៅក្នុងប្រទេសដែលមានចំណូលទាប និងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ពោលគឺស្មើនឹងប្រមាណជា ១ ភាគ ៤ នៃចំនួនយុវជនសរុប មិនចេះអានទាល់តែសោះ ឬចេះអានតែផ្នែកខ្លះរបស់ប្រយោគមួយ តែប៉ុណ្ណោះ។ នៅអាហ្វ្រិចសាប់សាហារ៉ា យុវជន ៤០% មិនចេះអានទាល់តែសោះ (រូបភាពទី ១៤)។

ស្ត្រីវ័យក្មេង ទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរជាងគេ ដោយមានចំនួន ៦១% នៃយុវជនទាំងអស់ ដែលមិនចេះអក្សរ។ នៅអាស៊ីខាងត្បូង និងខាងលិច យុវជន ២ នាក់ ក្នុងចំណោម ៣ នាក់ ដែលមិនចេះអាន គឺជាស្ត្រីវ័យក្មេង។

ការប្រៀបធៀបរវាងប្រទេសមួយ និងប្រទេសមួយទៀត បង្ហាញឱ្យឃើញពីវិសាលភាពដ៏ធំធេងនៃបញ្ហា អនក្ខរកម្ម។ នៅក្នុងប្រទេសចំនួន ៩ ក្នុងចំណោមប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមកម្រិតទាបទាំង ៤១ នៅក្នុងការវិភាគនេះ មានយុវជនអាយុ ១៥-២៤ ឆ្នាំ ជាងពាក់កណ្តាលដែលមិនចេះអក្សរ។ ប្រទេសទាំងនេះស្ថិតនៅក្នុងតំបន់អាហ្វ្រិចសាប់សាហារ៉ា។

ការវិភាគនេះបញ្ជាក់លើការសន្មត់ដែលថា កុមារចាំបាច់ត្រូវចំណាយពេលយ៉ាងហោចណាស់ ៤ ឆ្នាំ នៅក្នុង សាលារៀន ដើម្បីចេះអក្សរ ៖ ក្នុងចំណោមកុមារដែលបានចំណាយពេលតិចជាង ៤ ឆ្នាំ នៅក្នុងសាលារៀន មានប្រហែល ជា ៧៧% មិនចេះអានប្រយោគទាំងមូល ឬផ្នែកខ្លះរបស់ប្រយោគ។ នៅក្នុងប្រទេសចំនួន ៩ ក្នុងចំណោមប្រទេសទាំង ៤១ ដែលត្រូវបានវិភាគ មានយុវជនជាង ២ ពាក់កណ្តាល ដែលចំណាយពេលមិនលើសពី ៤ ឆ្នាំក្នុងសាលារៀន ហើយពួកគេ ស្ទើរតែទាំងអស់ដែលមិនចេះអក្សរ។

ប៉ុន្តែ ការចំណាយពេល ៥ ឬ ៦ ឆ្នាំ នៅក្នុងសាលារៀន ស្មើនឹងប្រព័ន្ធមួយចំនួន ដើម្បីបញ្ចប់ការអប់រំកម្រិតបឋម សិក្សា ឱ្យបានចប់សព្វគ្រប់មិនធានាបាននូវភាពចេះអក្សរនោះទេ។ នៅក្នុងប្រទេសចំនួន ៤១ នៅក្នុងការវិភាគនេះ មានយុវជនប្រហែលជា ២០ លាននាក់ ដែលនៅមិនចេះអានប្រយោគទាំងមូល ឬផ្នែកខ្លះរបស់ប្រយោគមួយ - ស្មើនឹង ១ នាក់ លើ ៣ នាក់ ដែលឈប់រៀន ក្រោយថ្នាក់ទី ៥ ឬទី ៦។

យុវជន មកពីគ្រួសារក្រីក្រ ចេះអក្សរហានតិចតួចបំផុត។ ក្នុងចំណោមប្រទេស ដែលត្រូវបានវិភាគ យុវជនជាង ៨០% មកពីគ្រួសារធូរធាអានប្រយោគមួយដាច់ នៅក្នុង ៣២ ប្រទេស ប៉ុន្តែ ៨០% មកពីគ្រួសារក្រីក្រអាចអានប្រយោគមួយដាច់ តែនៅក្នុង ៤ ប្រទេសតែប៉ុណ្ណោះ។ ដោយឡែកតិចជាងពាក់កណ្តាលនៃយុវជនក្រីក្រអាចអានប្រយោគ

រូបភាពទី ១៤ ៖ មានយុវជនតិចជាង ៣ ភាគ ៤ នៅក្នុងប្រទេសចំណូលទាប និងប្រទេសចំណូលមធ្យមកម្រិតទាប ដែលចេះ អក្សរ
អត្រាអក្ខរកម្មរបស់យុវជន បែងចែកតាមយេនឌ័រ តំបន់មួយចំនួន និងក្រុមចំណូលតាមប្រទេស




ប្រភព ៖ ការវិភាគរបស់ក្រុមតាក់តែងរបាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា (២០១៣) ផ្អែកតាម ទិន្នន័យពីការអង្កេតប្រជាសាស្ត្រ និងសុខភាព

មួយដាច់ នៅក្នុង ២២ ប្រទេស ខណៈពេលដែលយុវជនមានជីវភាពធូរធា ស្ថិតនៅក្រោមកម្រិតនេះ តែនៅក្នុងប្រទេសនីហ្សេ តែប៉ុណ្ណោះ។ នៅក្នុងប្រទេសជាច្រើន ដូចជា កាម៉េរូន ហ្គាណា នីហ្សេរីយ៉ា និងសេរ៉ាលីអូន ភាពខុសប្លែកគ្នានៃអត្រាអក្ខរកម្ម របស់យុវជន រវាងអ្នកមាន និងអ្នកក្រ មានដល់ជាង ៥០ ភាគរយចំណុច។

ការលំបាក នៅក្នុងការទទួលបានជំនាញជាមូលដ្ឋាន រឹតតែមានសភាពធ្ងន់ធ្ងរទៀត ដោយសារកត្តាភាពក្រីក្រ យេនឌ័រ ទីតាំង និងជាតិពន្ធុរួមផ្សំគ្នា។ នៅក្នុងប្រទេសសេណេហ្គាល់ មានស្ត្រីវ័យក្មេងរស់នៅតំបន់ជនបទតែ ២០% ប៉ុណ្ណោះ ដែលចេះអាន នៅក្នុងស្ថានភាពរស់នៅប្រចាំថ្ងៃ នៅក្នុងឆ្នាំ ២០១០ បើធៀបជាមួយនឹង ៦៥% នៃបុរសវ័យក្មេង រស់នៅទីប្រជុំជន។ នៅក្នុងប្រទេសឥណ្ឌូនេស៊ី ស្ត្រីវ័យក្មេង ដែលមានជីវភាពធូរធា នៅក្នុងខេត្តបាលីស្ទើរតែទាំងអស់ ដែលមានជំនាញអក្ខរកម្ម ខណៈពេលដែលមានស្ត្រីក្រីក្រត្រឹមតែ ៦០% នៅក្នុងខេត្តប៉ាពួប៉ុណ្ណោះ ដែលចេះអក្សរ។

លទ្ធផលទាំងនេះ អាចឆ្លុះបញ្ចាំងពីផលប៉ះពាល់រួមគ្នានៃភាពក្រីក្រ ការនៅដោយឡែកពីគេ ការរើសអើង និងការអនុវត្តផ្នែកវប្បធម៌។ ប៉ុន្តែ លទ្ធផលទាំងនេះក៏បង្ហាញផងដែរពីបរាជ័យរបស់គោលនយោបាយអប់រំ ក្នុងការផ្តល់ឱកាស រៀនសូត្រដល់ក្រុមប្រជាជនដែលជួបប្រទះការលំបាកជាងគេ និងបង្ហាញពីតម្រូវការជាបន្ទាន់ ដើម្បីផ្តល់ឱ្យអ្នកទាំងនេះនូវឱកាសទីពីរ។

មានសញ្ញាមួយចំនួនអំពីការរីកចម្រើនផ្នែកអក្ខរកម្មរបស់យុវជន ដែលផ្តល់នូវសេចក្តីសង្ឃឹម។ ដោយសារការពង្រីកការអប់រំកម្រិតបឋមសិក្សា នៅក្នុងទសវត្សរ៍ចុងក្រោយនេះ អត្រាអក្ខរកម្មយុវជនមានការកើនឡើង នៅក្នុងប្រទេសអេត្យូពី ពី ៣៤% នៅក្នុងឆ្នាំ ២០០០ ដល់ ៥២% នៅក្នុងឆ្នាំ ២០១១។ អក្ខរកម្មរបស់យុវជនក៏មានការកើនឡើង ផងដែរ នៅក្នុងប្រទេសនេប៉ាល់ ជាពិសេស នៅក្នុងចំណោមអ្នកដែលជួបប្រទះការលំបាកបំផុត ដែលបានចាប់ផ្តើមពីអក្ខរកម្មក្នុងកម្រិតមួយយ៉ាងទាប។ អក្ខរកម្មក្នុងចំណោមស្ត្រីវ័យក្មេងក្រីក្រ មានការកើនឡើងពី ២០% នៅក្នុងឆ្នាំ ២០០១ ដល់ ៥៥% នៅក្នុងឆ្នាំ ២០១១។

ព័ត៌មានអំពីថាតើកុមារពិការរៀនបានច្រើនប៉ុណ្ណា គឺព័ត៌មានដែលពិបាកនឹងរក ដែលធ្វើឱ្យការវិភាគមានការ លំបាក។ ប្រទេសអ៊ូហ្គាន់ដា គឺជាឧទាហរណ៍កម្រមួយ ដែលមានព័ត៌មានខាងលើនេះគ្រប់គ្រាន់ ដើម្បីធ្វើការប្រៀបធៀប អត្រាអក្ខរកម្មរបស់យុវជន ទៅតាមប្រភេទកម្សោយរបស់ពួកគេ។ នៅក្នុងឆ្នាំ ២០១១ មានយុវជនប្រមាណជា ៦០% ដែលពុំមានកម្សោយអ្វីទាំងអស់ ចេះអក្សរ បើធៀបជាមួយនឹង ៤៧% នៃយុវជនដែលមានកម្សោយរាងកាយ ឬកម្សោយ ផ្នែកការស្តាប់ និង ៣៨% នៃយុវជន ដែលមានកម្សោយផ្នែកស្មារតី។

ការខិតខំឱ្យមានការរៀនសូត្រប្រកបដោយសមភាព រួមទាំងសម្រាប់កុមារ និងយុវជនពិការផង តម្រូវឱ្យមានការ កំណត់ពីការលំបាកជាក់លាក់ ដែលកុមារ និងយុវជន ដែលជួបប្រទះការលំបាកប្រភេទផ្សេងៗ និងការអនុវត្តគោល-នយោបាយ ដើម្បីដោះស្រាយបញ្ហាលំបាកទាំងនេះ។

## ការចាត់ទុកគុណភាពនៃការបង្រៀនជាអាទិភាពមួយរបស់ជាតិ

គោលនយោបាយជាតិ ដែលរឹងមាំ និងផ្តល់អាទិភាពខ្ពស់ដល់ការលើកកម្ពស់ការរៀន និងបង្រៀន មានសារៈ-សំខាន់ ដើម្បីធានាយ៉ាងណាឱ្យកុមារគ្រប់រូប ដែលរៀននៅតាមសាលារៀន អាចទទួលបានជំនាញ និងចំណេះដឹង ដែលពួកគេត្រូវទទួលបាន។ ផែនការវិស័យអប់រំ គួររៀបរាប់ពីគោលដៅនានា និងកំណត់ពីចំណុចដៅ ដែលរដ្ឋាភិបាលត្រូវទទួលខុសត្រូវសម្រេចឱ្យបាន ក៏ដូចជាកំណត់ពីវិធី ដើម្បីសម្រេចគោលដៅទាំងនេះ។ ការលើកកម្ពស់ការរៀនសូត្រ ជាពិសេសក្នុងចំណោមកុមារដែលជួបប្រទះការលំបាកបំផុត ចាំបាច់ត្រូវតែជាគោលដៅជាយុទ្ធសាស្ត្រមួយ។ ផែនការនានាគួរដាក់បញ្ចូលនូវអភិក្រមជាច្រើន ដើម្បីបង្កើនគុណភាពរបស់គ្រូ ដែលផែនការទាំងនេះត្រូវរៀបចំឡើង ដោយមានការពិគ្រោះយោបល់ជាមួយនឹងគ្រូបង្រៀន និងសមាគមគ្រូបង្រៀន។ ផែនការទាំងនេះក៏ចាំបាច់ត្រូវធានាផងដែរថា នឹងមានធនធានគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រនានា។

## គុណភាពត្រូវតែជាគោលដៅជាយុទ្ធសាស្ត្រមួយនៅក្នុងផែនការវិស័យអប់រំ

វិបត្តិនៃការរៀនសូត្រជាសកល មិនអាចដោះស្រាយបានឡើយ លុះត្រាតែគោលនយោបាយនានាផ្តោតគោលដៅ លើការលើកកម្ពស់ការរៀនសូត្រសម្រាប់កុមារដែលជួបប្រទះការលំបាក។ ក្នុងចំណោមផែនការជាតិវិស័យអប់រំចំនួន ៤០ ដែលត្រូវបានយកមកធ្វើការពិនិត្យ សម្រាប់របាយការណ៍នេះ មានផែនការចំនួន ២៦ ចាត់ទុកការកែលំអលទ្ធផលនៃការរៀនសូត្រថាជាគោលដៅជាយុទ្ធសាស្ត្រមួយ។ ខណៈពេលដែលផែនការរបស់ប្រទេសទាំង ៤០ សុទ្ធតែឆ្លើយតបទៅនឹងតម្រូវការរបស់ក្រុមជួបប្រទះការលំបាក ជារឿយៗ ការរៀនសូត្រត្រូវបានគេចាត់ទុកត្រឹមតែជាលទ្ធផលអមជាមួយនឹង ការបង្កើនលទ្ធភាពទទួលបានការអប់រំតែប៉ុណ្ណោះ។

ដើម្បីលើកកម្ពស់លទ្ធផលនៃការរៀនសូត្រសម្រាប់ទាំងអស់គ្នា ផែនការជាតិវិស័យអប់រំ ត្រូវតែលើកកម្ពស់ការ គ្រប់គ្រង និងគុណភាពរបស់គ្រូ។ មានផែនការតែ ១៧ ក្នុងចំណោមផែនការទាំង ៤០ ប៉ុណ្ណោះ ដែលមានដាក់បញ្ចូលយុទ្ធសាស្ត្រ សម្រាប់កែលំអកម្មវិធីអប់រំគ្រូ និងមានផែនការតែ ១៦ ប៉ុណ្ណោះ ដែលមានផែនការផ្តល់ការបណ្តុះបណ្តាល បន្ថែមដល់គ្រូឧទ្ទេស។

វាកាន់តែមិនសូវមានទៀត ដែលផែនការនានាទទួលស្គាល់ថា ការបង្កើនគុណភាពនៃការបង្រៀន អាចលើកកម្ពស់ លទ្ធផលនៃការរៀនសូត្រនោះ។ នៅក្នុងប្រទេសកេនយ៉ា ការបណ្តុះបណ្តាលគ្រូ ផ្តោតចម្បងលើការលើកកម្ពស់ការរៀន សូត្ររបស់អ្នករៀនចប់សាលាបឋមសិក្សា នៅតាមស្រុកដែលបំពេញការងារមិនបានល្អ។ ប្រទេសអាហ្វ្រិចខាងត្បូង និងស្រីលង្កា ផ្សារភ្ជាប់ទំនាក់ទំនងការជ្រើសរើសគ្រូ ជាមួយនឹងការបង្កើនគុណភាពនៃការរៀនសូត្រ។

រដ្ឋាភិបាល ចាំបាច់ត្រូវតែផ្តល់នូវការលើកទឹកចិត្តឱ្យបានសមស្រប ដើម្បីទាក់ទាញ និងរក្សាគ្រូ ដែលមាន សមត្ថភាពជាងគេ។ ក្នុងចំណោមផែនការទាំ ៤០ ដែលត្រូវបានពិនិត្យឡើងវិញនេះ មានផែនការចំនួន ១០ ដែលបានដាក់បញ្ចូលកំណែទម្រង់ ដើម្បីបង្កើនប្រាក់បៀវត្សដល់គ្រូ និងផែនការចំនួន ១៨ គូសបញ្ជាក់ពីមាគ៌ាអាជីព និងលទ្ធភាពដំឡើងឋានៈសម្រាប់គ្រូ។

**អត្រាអក្ខរកម្មយុវជនរបស់ប្រទេសអេត្យូពីមានការកើនឡើងពី ៣៤% នៅក្នុងឆ្នាំ ២០០០ ដល់ ៥២% នៅក្នុងឆ្នាំ ២០១១**

មានផែនការតែមួយចំនួនប៉ុណ្ណោះ ដែលផ្តោតគោលដៅលើកំណែទម្រង់គ្រូ ក្នុងគោលបំណងលើកកម្ពស់ការរៀន សូត្ររបស់សិស្សជួបប្រទះការលំបាក ជាពិសេស តាមរយៈការពង្រាយគ្រូទៅតាមតំបន់ជួបប្រទះការលំបាក។ ក្នុងចំណោមផែនការទាំង ២៨ ដែលមានគោលបំណងបញ្ជូនគ្រូទៅតាមតំបន់ជួបប្រទះការលំបាក មានផែនការចំនួន ២២ ដែលមានគោលបំណងផ្តល់ការលើកទឹកចិត្តនានា ដូចជា ប្រយោជន៍ផ្នែកលំនៅដ្ឋាន និងប្រាក់ឧបត្ថម្ភបន្ថែមជាដើម។ នៅក្នុងប្រទេសចំនួន ១៤ ផែនការអប់រំ មានដាក់បញ្ចូលការលើកទឹកចិត្តដើម្បីជម្រុញឱ្យមានការពង្រាយគ្រូទៅតាមតំបន់ជនបទ ខណៈពេលដែលផែនការចំនួន ៨ រួមទាំងផែនការរបស់ប្រទេសអាហ្វហ្គានីស្ថានផង ផ្តល់ការលើកទឹកចិត្តយ៉ាងសកម្មដល់គ្រូបង្រៀនជាស្ត្រី។ ផែនការរបស់ប្រទេសកម្ពុជា គឺជាផែនការគួរឱ្យកត់សម្គាល់មួយ ដោយសារតែមានយុទ្ធសាស្ត្រជ្រើសរើសគ្រូ ពីតាមតំបន់គោលដៅ និងពីក្រុមជនជាតិភាគតិច ហើយពង្រាយពួកគេ ទៅកន្លែង ដែលមានតម្រូវការគ្រូជាងគេ។ នៅតាមតំបន់ដាច់ស្រយាល ដែលចំនួនសិស្សនៅមានតិចនៅឡើយ គ្រូប្រហែលជាត្រូវបង្រៀនសិស្សលើសពីមួយក្រុមអាយុ ក្នុងពេលជាមួយគ្នា។ នៅក្នុងប្រទេសកម្ពុជា កេនយ៉ា និងប៉ាពួញូហ្គីនី មានផែនការផ្តល់ការបណ្តុះបណ្តាលអំពីការបង្រៀនថ្នាក់គួប។

មានផែនការតែមួយចំនួនតូចប៉ុណ្ណោះ ដែលរំលេចពីភាពចាំបាច់ដើម្បីផ្តល់ការគាំទ្រដល់សិស្សរៀនយឺត។ ផែនការ របស់ប្រទេសហ្គូយ៉ាណា គឺជាករណីលើកលែងមួយ។ ផែនការនេះផ្តល់អាទិភាពខ្ពស់ដល់ការកសាងសមត្ថភាពរបស់គ្រូ ក្នុងការអនុវត្តកម្មវិធី ដែលផ្តោតគោលដៅលើក្រុមសិស្សជាក់លាក់។

ដើម្បីឱ្យផែនការនានាអាចអនុវត្តបានប្រកបដោយជោគជ័យ ផែនការទាំងនេះចាំបាច់ត្រូវតែមានធនធានគាំទ្រឱ្យ បានគ្រប់គ្រាន់ ប៉ុន្តែមានឯកសារគោលនយោបាយតែ ១៦ ក្នុងចំណោមឯកសារគោលនយោបាយ ៤០ ដែលត្រូវបានពិនិត្យឡើងវិញតែប៉ុណ្ណោះ ដែលមានបង្ហាញថវិកាលំអិត។ ប្រទេសនានាផ្តល់សារៈសំខាន់ក្នុងកម្រិតផ្សេងៗគ្នានៅក្នុងថវិការបស់ខ្លួន ដល់គោលនយោបាយដែលមានគោលបំណងបង្កើនគុណភាពនៃការអប់រំ ៖ ឧទាហរណ៍ ថវិកាសម្រាប់គោលបំណង នេះមានដល់ជាង ១ ភាគ ៥ នៅក្នុងថវិការបស់ប្រទេសប៉ាពួញូហ្គីនី ប៉ុន្តែតិចជាង ៥% ប៉ុណ្ណោះ នៅក្នុងប្រទេសប៉ាឡេស្ទីន។ ប៉ុន្តែ មានផែនការមួយចំនួនតូច ដែលមានវិភាជន៍ចំណាយ សម្រាប់ក្រុមដែលជួបប្រទះការលំបាក។

**នៅក្នុងប្រទេសបូលីវៀ សមាគមគ្រូបង្រៀនបានរៀបចំយុទ្ធនាការ ដើម្បីធានាឱ្យមានការដាក់បញ្ចូលសិទ្ធិរបស់ជនជាតិដើមភាគតិច នៅក្នុងរដ្ឋធម្មនុញ្ញ**

គោលនយោបាយនានា អាចមានប្រសិទ្ធភាពទៅបាន តែនៅពេលដែលអ្នកដែលទទួលខុសត្រូវអនុវត្តគោល-នយោបាយទាំងនោះ ចូលរួម នៅក្នុងការតាក់តែងគោលនយោបាយទាំងនោះតែប៉ុណ្ណោះ។ ប៉ុន្តែ ការអង្កេតធ្វើឡើងនៅក្នុង ប្រទេសចំនួន ១០ បានបង្ហាញថា មានគ្រូតែ ២៣% ប៉ុណ្ណោះ ដែលគិតថា ពួកគេមានឥទ្ធិពលលើគោលនយោបាយ និងការ អនុវត្តនានា។ ដោយសារតែការគ្របដណ្តប់សមាជិកភាពរបស់ខ្លួន សមាគមគ្រូបង្រៀន គឺជាដៃគូសំខាន់ៗរបស់រដ្ឋាភិបាល។ នៅតាមប្រទេសមួយចំនួន ការជម្រុញឱ្យមានការចូលរួមពីសមាគមគ្រូបង្រៀនបានធ្វើឱ្យគោលនយោបាយ ដែលមានបំណងជួយដល់ក្រុមជួបប្រទះការលំបាក កាន់តែមានភាពប្រសើរជាងមុន។ ឧទាហរណ៍ នៅក្នុងរដ្ឋពហុជាតិបូលីវៀ សមាគមគ្រូបង្រៀនបានរៀបចំយុទ្ធនាការ ដើម្បីធានាយ៉ាងណាឱ្យសិទ្ធិរបស់ជនជាតិដើមភាគតិច ត្រូវបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញ។

ជារួម គ្រូ និងសមាគមរបស់ពួកគេ អាចជួយធានាយ៉ាងណាឱ្យគោលនយោបាយនានាមានប្រសិទ្ធភាព។ ដូច្នេះ វា គឺជាការសំខាន់ ដែលត្រូវឱ្យពួកគេចូលរួមនៅដំណាក់កាលដំបូងៗ ពេលរៀបចំយុទ្ធសាស្ត្រ ដែលមានគោលបំណង ដោះស្រាយចំណុចខ្វះខាតពាក់ព័ន្ធជាមួយនឹងការរៀនសូត្រ។

## រកគ្រូឱ្យបានគ្រប់គ្រាន់ សម្រាប់ថ្នាក់រៀន

គុណភាពនៃការអប់រំ មានការថយចុះ នៅតាមបណ្តាប្រទេសក្រីក្រជាងគេជាច្រើន ដោយសារតែកង្វះគ្រូបង្រៀន ដែលជារឿយៗ នាំឱ្យថ្នាក់មានចំនួនសិស្សច្រើន នៅថ្នាក់ដំបូងៗ និងនៅតាមតំបន់ក្រីក្រជាងគេ។ ការជ្រើសរើសគ្រូនា ពេលអនាគត ចាំបាច់ត្រូវតែកំណត់ដោយកង្វះគ្រូនាពេលបច្ចុប្បន្ន លក្ខណៈប្រជា សាស្ត្រ និន្នាការនៃការចូលរៀន និងចំនួនកុមារក្រៅសាលា។ ការវិភាគ ដែលធ្វើឡើងដោយវិទ្យាស្ថានស្ថិតិរបស់យូណេស្កូ បង្ហាញថា ចន្លោះពីឆ្នាំ ២០១១ ដល់ ២០១៥ គេចាំបាច់ត្រូវជ្រើសរើសគ្រូចំនួន ៥,២ លាននាក់ ក្នុងនោះមានទាំងគ្រូជំនួយ និងគ្រូបន្ថែមផងដើម្បីធានាយ៉ាងណាឱ្យមានគ្រូក្នុងចំនួនគ្រប់គ្រាន់ ដើម្បីសម្រេចនូវសកលកម្មការអប់រំកម្រិតបឋមសិក្សា។ នេះស្មើនឹងគ្រូជាង ១ លាននាក់ ក្នុង ១ ឆ្នាំ ស្មើនឹងប្រមាណជា ៥% នៃចំនួនបុគ្គលិកបង្រៀនសរុបនៅបឋមសិក្សា នាពេលបច្ចុប្បន្ននេះ។

កម្មវិធីអប់រំគ្រូដំបូងៗភាគច្រើន មានរយៈពេលយ៉ាងហោចណាស់ ២ ឆ្នាំ។ ជាមួយនឹងកុមារក្រៅសាលាចំនួន ៥៧ លាននាក់ ប្រទេសនានា ដែលមានបញ្ហាខ្វះខាតគ្រូ មិនទំនងជាអាចបំពេញទៅតាមកាលបរិច្ឆេទកំណត់នៃការអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ ២០១៥ ដើម្បីសម្រេចឱ្យបាននូវសកលកម្មនៃការអប់រំកម្រិតបឋមសិក្សាឡើយ។ ប៉ុន្តែទោះជាយ៉ាងណាក៏ ដោយ ប្រទេសនានាត្រូវតែចាប់ផ្តើមរៀបចំផែនការពីឥឡូវនេះទៅ ដើម្បីបំពេញកង្វះខាតនេះ។ ប្រសិនបើកាលកំណត់នេះ ត្រូវបានពន្យារដល់ឆ្នាំ ២០២០ បូករួមទាំងកំណើននៃការចុះឈ្មោះចូលរៀន ដែលត្រូវបានព្យាករទុកផងនោះ ចំនួនគ្រូ ដែល ចាំបាច់ត្រូវមាន នឹងកើនឡើងដល់ ១៣,១ លាននាក់ នៅក្នុងរយៈពេល ៩ ឆ្នាំ។ ប្រសិនបើកាលកំណត់នេះត្រូវបានពន្យារ ដល់ ២០៣០ នោះគេត្រូវការគ្រូចំនួន ២០,៦ លាននាក់ នៅក្នុងរយៈពេល ១៩ ឆ្នាំ។

ក្នុងចំណោមគ្រូ ដែលត្រូវមានចន្លោះពីឆ្នាំ ២០១១ ដល់ ២០១៥ គេត្រូវការគ្រូចំនួន ៣,៧ លាននាក់ ដើម្បីជំនួស ឱ្យគ្រូដែលចូលនិវត្តន៍ ផ្លាស់ប្តូរការងារ ឬឈប់ធ្វើការ ដោយសារជំងឺ ឬមរណភាព។ នៅសល់ ១,៦ លាននាក់ គឺជាគ្រូ បន្ថែមទៀត ដែលចាំបាច់ត្រូវមាន ដើម្បីបំពេញចំនួនគ្រូដែលខ្វះ ឆ្លើយតបទៅនឹងចំនួនសិស្សដែលបានចុះឈ្មោះចូលរៀន បន្ថែម និងដោះស្រាយបញ្ហាគុណភាព តាមរយៈការធានាយ៉ាងណាមិនឱ្យមានសិស្សលើសពី ៤០ នាក់ សម្រាប់គ្រូម្នាក់ ឡើយ (រូបភាពទី ១៥)។ ដូច្នេះ ចាំបាច់ត្រូវមានការជ្រើសរើសគ្រូប្រមាណជា ៤០០០០០ នាក់បន្ថែមទៀត ជារៀងរាល់ ឆ្នាំ ប្រសិនបើគេចង់ឱ្យមានចំនួនគ្រូឱ្យបានគ្រប់គ្រាន់ នៅមុនឆ្នាំ ២០១៥។

តំបន់អាហ្វ្រិចសាប់សាហារ៉ា ស្រូបយក ៥៨% នៃគ្រូបឋមសិក្សា ដែលចាំបាច់ត្រូវជ្រើសរើសបន្ថែមនេះ ពោលគឺ ត្រូវការប្រមាណជា ២២៥០០០ នាក់បន្ថែមក្នុងមួយឆ្នាំ ចន្លោះពីឆ្នាំ ២០១១ ដល់ ២០១៥។ ប៉ុន្តែ នៅក្នុងទសវត្សរ៍ចុង ក្រោយនេះ ការកើនឡើងនូវចំនួនគ្រូជាមធ្យមប្រចាំឆ្នាំក្នុងតំបន់នេះមានត្រឹមតែ ១០២០០០ នាក់តែប៉ុណ្ណោះ។

ប្រទេសនីហ្សេរីយ៉ា កន្លងមក មានកង្វះគ្រូច្រើនជាងគេ ដែលត្រូវបំពេញ។ ពីឆ្នាំ ២០១១ ដល់ ២០១៥ ប្រទេស នេះត្រូវការគ្រូបឋមសិក្សាចំនួន ២១២០០០ នាក់ ស្មើនឹង ១៣% នៃចំនួនគ្រូបន្ថែមសរុបក្នុងសកលលោកទាំងមូល។ ក្នុង ចំណោមប្រទេសចំនួន ១០ ដែលត្រូវការគ្រូបឋមសិក្សាបន្ថែមច្រើនជាងគេ ប្រទេសទាំងអស់សុទ្ធតែជាប្រទេសនៅក្នុង តំបន់អាហ្វ្រិចសាប់សាហារ៉ា លើកលែងតែប្រទេសប៉ាគីស្ថានមួយចេញ។

រូបភាពទី ១៥ ៖ នៅក្នុងសកលលោកទាំងមូល គេត្រូវការគ្រូចំនួន ១,៦ លាននាក់ បន្ថែមទៀត មុនឆ្នាំ ២០១៥

ចំនួនគ្រូសរុប ដែលចាំបាច់ត្រូវមាន ដើម្បីសម្រេចនូវសកលកម្មនៃការអប់រំកម្រិតបឋមសិក្សា មុនឆ្នាំ ២០១៥




ប្រភព ៖ UIS (2013)

បញ្ហាប្រឈមក្នុងការជ្រើសរើសគ្រូ កាន់តែមានទំហំធំធេងទៅទៀត នៅពេលដែលគេគិតបញ្ចូលទាំងការអប់រំ នៅកម្រិតមធ្យមសិក្សាបឋមភូមិ។ ដើម្បីសម្រេចឱ្យបាននូវសកលកម្មនៃការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ ឱ្យបាន នៅឆ្នាំ ២០៣០ ជាមួយនឹងសិស្ស ៣២ នាក់ ក្នុងគ្រូម្នាក់ គេត្រូវការគ្រូ ៥,១ លាន នាក់បន្ថែមទៀត ឬ ២៦៨០០០ នាក់ ក្នុងមួយឆ្នាំ។ តំបន់អាហ្វ្រិចសាប់សាហារ៉ា ស្រូបយកពាក់កណ្តាលនៃចំនួនគ្រូមធ្យមសិក្សាបឋមភូមិ ដែលត្រូវការបន្ថែមនៅ ក្នុងរយៈពេលនេះ។

ប្រទេស ដែលនៅខ្វះគ្រូច្រើន មិនទំនងជាអាចជ្រើសរើសគ្រូក្នុងចំនួន ដែលចាំបាច់ខាងលើ ឱ្យបានមុនឆ្នាំ ២០១៥ ឡើយ។ ក្នុងចំណោមប្រទេសចំនួន ៩៣ ដែលត្រូវការជ្រើសរើសគ្រូបឋមសិក្សាបន្ថែមទៀត នៅមុនឆ្នាំ ២០១៥ មាន ប្រទេសត្រឹមតែ ៣៧ ប៉ុណ្ណោះ ដែលនឹងអាចបំពេញគម្លាតនេះបាន។ ប្រទេស ចំនួន ២៩ មិនទាំងអាចបំពេញគម្លាតនេះ នៅ មុនឆ្នាំ ២០៣០ ផង។ ស្របពេល ជាមួយគ្នា ប្រទេសចំនួន ១៤៨ ត្រូវការគ្រូបន្ថែមទៀត សម្រាប់សាលារៀនមធ្យម សិក្សាបឋមភូមិ នៅមុនឆ្នាំ ២០១៥។ ប្រទេសចំនួន ២៩ នឹងមិនអាចបំពេញ គម្លាតនេះ នៅមុនឆ្នាំ ២០៣០ ឡើយ។

ដើម្បីបំពេញកង្វះគ្រូបង្រៀន នៅមុនឆ្នាំ ២០១៥ ប្រទេសមួយចំនួនចាំ បាច់ត្រូវតែពន្លឿនការពង្រីកចំនួនបុគ្គលិកជាគ្រូបង្រៀនរបស់ខ្លួន។ ប្រទេស រវ៉ាន់ដា និងអ៊ូហ្គាន់ដា ចាំបាច់ត្រូវពង្រីកការជ្រើសរើសគ្រូចំនួន ៦% ជាមធ្យម បើធៀប ជាមួយនឹងការបង្កើនបច្ចុប្បន្នជាមធ្យម ៣% ក្នុងមួយឆ្នាំ។ នៅក្នុងប្រទេស ម៉ាឡាវី ចំនួនបុគ្គលិកបង្រៀនកើនឡើងត្រឹមតែ ១% ប៉ុណ្ណោះ ក្នុងមួយឆ្នាំ ដែល នៅទាបឆ្ងាយពីចំនួនគ្រប់គ្រាន់ ដើម្បីកាត់បន្ថយផលធៀបសិស្ស-គ្រូ ពី ៧៦ ៖ ១ មកនៅ ៤០ ៖ ១។ ដើម្បីឱ្យប្រទេសម៉ាឡាវីសម្រេចនូវគោលដៅសកលកម្មនៃ ការអប់រំកម្រិតបឋមសិក្សា ត្រឹមឆ្នាំ ២០១៥ ប្រទេសនេះចាំបាច់ត្រូវបង្កើនចំនួន បុគ្គលិកបង្រៀនរបស់ខ្លួនឱ្យបាន ១៥% ជារៀងរាល់ឆ្នាំ ពីឆ្នាំ ២០១១ ដល់ ២០១៥។

ប្រទេសក្រីក្រជាច្រើន នឹងមិនអាចបំពេញកង្វះចំនួនគ្រូបង្រៀន របស់ខ្លួនឡើយ ដោយហេតុថាប្រទេសទាំងនេះពុំ មានអ្នករៀនចប់សាលាមធ្យម សិក្សាទុតិយភូមិ - ដែលជាលក្ខណៈសម្បត្តិកម្រិតអប្បបរមាសម្រាប់គរុសិស្ស ដែល នឹងបម្រើការងារជាគ្រូបឋមសិក្សា - ក្នុងចំនួនគ្រប់គ្រាន់។ នៅក្នុងប្រទេសចំនួន ៨ ក្នុងចំណោម ១៤ ប្រទេស នៅតំបន់អាហ្វ្រិចសាប់សាហារ៉ា នៅក្នុងឆ្នាំ ២០២០ គេត្រូវទាញសិស្សបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិយ៉ាងហោច ណាស់ ៥% ឱ្យបម្រើការងារជាគ្រូបង្រៀន ទើបអាចបំពេញកង្វះចំនួនគ្រូនេះបាន ដែលតួលេខនេះកើនឡើងរហូតដល់ជិត ២៥% នៅក្នុងប្រទេសនីហ្សេ។ បើតាម ការប្រៀបធៀប មានកម្លាំងពលកម្មតែជាង ៣% នៃចំនួនកម្លាំងពលកម្មសរុប ដែលមានកម្រិតវប្បធម៌តិចបំផុតមធ្យមសិក្សាប៉ុណ្ណោះ ដែលបម្រើការងារជាគ្រូ បឋមសិក្សា នៅតាមបណ្តាប្រទេសមានចំណូលមធ្យម។

គ្រូ មិនមែនគ្រាន់តែជ្រើសរើសប៉ុណ្ណោះទេ គេក៏ត្រូវការបណ្តុះបណ្តាល ពួកគេផងដែរ។ ប្រទេសជាច្រើន ជាពិសេស ប្រទេសនៅ អាហ្វ្រិចសាប់សាហារ៉ា តែម្តង ក៏ចាំបាច់ត្រូវបណ្តុះបណ្តាលគ្រូ ដែលមានស្រាប់ផងដែរ។ ឧទាហរណ៍ ប្រទេសម៉ាលី បានជ្រើសរើសគ្រូក្នុងអត្រា ៩% ក្នុងមួយឆ្នាំ នៅក្នុងទសវត្សរ៍ចុង ក្រោយនេះ ដែលបានជួយកាត់បន្ថយចំនួនសិស្សក្នុងគ្រូម្នាក់ពី ៦២ នាក់ នៅក្នុង ឆ្នាំ ១៩៩៩ មកនៅ ៤៨ នាក់ នៅក្នុងឆ្នាំ ២០១១។ ប៉ុន្តែ គ្រូជាច្រើននាក់ ក្នុង ចំណោមគ្រូទាំងនេះ គឺជាគ្រូដែលមិនបានឆ្លងកាត់ការបណ្តុះបណ្តាល។ លទ្ធផល គឺថា ផលធៀបសិស្សក្នុងគ្រូដែលបានទទួលការបណ្តុះបណ្តាលម្នាក់ក្នុងប្រទេស ម៉ាលី គឺ ៩២ ៖ ១ ដែលជាអត្រាមួយខ្ពស់ជាងគេ ក្នុងពិភពលោក។ បើមើលតាម និន្នាការកន្លងមក នៃការជ្រើសរើសគ្រូដែលបានទទួលការបណ្តុះបណ្តាល ម៉ាលី នឹងមិនអាចសម្រេចបាននូវផលធៀបសិស្ស ៤០ នាក់ ក្នុងគ្រូ ដែលបានទទួលការ បណ្តុះបណ្តាលម្នាក់បានឡើយ រហូតដល់ឆ្នាំ ២០៣០។ ប្រទេសចំនួន ២៩ នឹង មិនអាចបំពេញកង្វះចំនួនគ្រូបឋមសិក្សាបានឡើយ នៅមុនឆ្នាំ ២០៣០។

**ប្រទេសចំនួន ២៩ នឹងមិនអាចបំពេញកង្វះចំនួនគ្រូបឋមសិក្សាបានឡើយ នៅមុនឆ្នាំ ២០៣០**

ប្រទេស នានា ដែលមានគ្រូមិនបានទទួលការបណ្តុះបណ្តាលច្រើន នាក់ ចាំបាច់ត្រូវតែរិះរកវិធី ដើម្បីផ្តល់ការបណ្តុះបណ្តាលដល់ពួកគេ។ នៅក្នុង ប្រទេសចំនួន ១០ ក្នុងចំណោម ២៧ ប្រទេស ដែលមានទិន្នន័យ បញ្ហាប្រឈម នេះមានទំហំធំ ធេងជាងការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូថ្មីៗទៅទៀត។ នៅក្នុងប្រទេសបេនីន គ្រូចំនួន ៤៧% បានទទួលការបណ្តុះបណ្តាល នៅក្នុងឆ្នាំ ២០១១។ ប្រទេសនេះចាំបាច់ត្រូវពង្រីកការជ្រើសរើសគ្រូឱ្យបានត្រឹម ១,៤% ក្នុង មួយឆ្នាំ ដើម្បីសម្រេចសកលកម្មនៃការអប់រំបឋមសិក្សា នៅមុនឆ្នាំ ២០២០ ប៉ុន្តែចំនួនគ្រូដែលមានស្រាប់ ដែលចាំបាច់ត្រូវបណ្តុះបណ្តាល នឹងមានការកើន ឡើងជិត ៩% ក្នុងមួយឆ្នាំ ច្រើនជាងអត្រាកំណើនប្រចាំឆ្នាំគិតជាមធ្យម ៦% សម្រាប់គ្រូដែលបានទទួលការបណ្តុះបណ្តាល ក្នុងប្រទេសបេនីន ចាប់តាំងពីឆ្នាំ ១៩៩៩ មក។

កង្វះចំនួនគ្រូ ដែលបានទទួលការបណ្តុះបណ្តាល ទំនងជានឹងមាន ផលប៉ះពាល់លើតំបន់ជួបប្រទះការលំបាកជាងគេ។ នៅរដ្ឋកានូភាគខាងជើង ដែល ជាតំបន់ក្រីក្រមួយរបស់ប្រទេសនីហ្សេរីយ៉ា ផលធៀបសិស្ស/គ្រូបានទទួលការ បណ្តុះ បណ្តាលមានលើសពី ១០០ នាក់ នៅក្នុងឆ្នាំ ២០០៩/១០ ពោលគឺមាន សិស្សយ៉ាងហោចណាស់ ១៥០ នាក់ ក្នុងគ្រូដែលបានទទួលការបណ្តុះបណ្តាល ម្នាក់ នៅក្នុងសាលារៀន ២៥% ដែលជួបប្រទះការលំបាកជាងគេ។

កុមាររៀនថ្នាក់ដំបូងៗ ដែលរស់នៅតាមតំបន់ដាច់ស្រយាល តែង ជួបប្រទះនឹងការលំបាក ២ ត្រួត។ ឧទាហរណ៍ នៅក្នុងប្រទេសអេត្យូពី ដែលគ្រូ ចំនួន ៤៨% បានទទួលការបណ្តុះបណ្តាល មានគ្រូប្រហែលជា ២០% ដែលបាន ទទួលការបណ្តុះបណ្តាលនៅថ្នាក់ទី ១ ដល់ទី ៤ ក្នុងឆ្នាំ ២០១០ ធៀបជាមួយ នឹង ៨៣% នៅក្នុងថ្នាក់ទី ៥ ដល់ទី ៨។

**អ្នកផ្តល់ជំនួយ ចំណាយត្រឹមតែ ១៨៩ លានដុល្លារ តែប៉ុណ្ណោះ ក្នុងមួយឆ្នាំ លើការអប់រំគ្រូបង្រៀន**

ប្រទេស ដែលត្រូវការគ្រូបន្ថែមទៀត ចាំបាច់ត្រូវបង្កើនថវិការួមរបស់ខ្លួន សម្រាប់បៀវត្សរបស់គ្រូ។ ការវិភាគថ្មីៗ ដែលធ្វើឡើងដោយវិទ្យាស្ថានស្ថិតិរបស់យូណេស្កូ សម្រាប់របាយការណ៍នេះ រកឃើញថា គេត្រូវការថវិកា ៤ ពាន់លានដុល្លារជារៀងរាល់ឆ្នាំ នៅតំបន់អាហ្វ្រិចសាប់សាហារ៉ា ដើម្បីផ្តល់បៀវត្សដល់គ្រូបឋមសិក្សា ដែលចាំបាច់ត្រូវជ្រើសរើសបន្ថែម ដើម្បីសម្រេចនូវសកលកម្មនៃការអប់រំកម្រិតបឋមសិក្សា នៅមុនឆ្នាំ ២០២០ ក្រោយពេលបានធ្វើការពិចារណាលើកំណើនសេដ្ឋកិច្ច ដែលត្រូវបានព្យាករហើយ។ នេះស្មើនឹង ១៩% នៃថវិកាអប់រំសរុបរបស់តំបន់នេះ នៅក្នុងឆ្នាំ ២០១១។ ប្រទេសនីហ្សេរីយ៉ាតែឯង ស្រូបយក ២ ភាគ ៥ នៃកង្វះខាតនេះ។

ខណៈពេលដែលការបង្កើនថវិកាដែលចាំបាច់ ហាក់បីដូចជាមានចំនួនច្រើន ប្រទេសភាគច្រើនគួរអាចបំពេញតាម តម្រូវការនេះ ប្រសិនបើសេដ្ឋកិច្ចរបស់ប្រទេសពួកគេមានការរីកចម្រើន ដូចការព្យាករទុក ហើយប្រសិនបើពួកគេប្តេជ្ញា វិភាជន៍ថវិកាក្នុងភាគរយច្រើនជាងមុនធៀបនឹង GDP ដល់វិស័យអប់រំ ហើយក្នុងពេលជាមួយគ្នា នៅតែបែងចែករង្វង់ ៣% ដល់ការអប់រំកម្រិតបឋមសិក្សា។ ជាមធ្យម ប្រទេសនៅអាហ្វ្រិចសាប់សាហារ៉ាត្រូវបង្កើនភាគរយថវិកា ដែលពួកគេបែងចែកទៅឱ្យវិស័យអប់រំពី ១២% ដល់ ១៤% នៅក្នុងឆ្នាំ ២០១១ ដើម្បីបិទគម្លាតគ្រូ នៅមុនឆ្នាំ ២០២០។

បញ្ហាប្រឈមផ្នែកហិរញ្ញប្បទាន កាន់តែមានទំហំធំទៅទៀត សម្រាប់សាលាមធ្យមសិក្សាបឋមភូមិ។ នៅអាហ្វ្រិចសាប់សាហារ៉ា ការជ្រើសរើសគ្រូក្នុងចំនួនឱ្យបានគ្រប់គ្រាន់ ដើម្បីសម្រេចនូវសកលកម្មនៃការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ ត្រឹមឆ្នាំ ២០៣០ ទាមទារឱ្យមានការបន្ថែមថវិកា ៩,៥ ពាន់លានដុល្លារលើថវិកាអប់រំប្រចាំឆ្នាំ។

ខណៈពេលដែលប្រទេសជាច្រើនគួរអាចរ៉ាប់រងលើចំណាយសម្រាប់ជ្រើសរើស និងផ្តល់បៀវត្សដល់គ្រូបឋមសិក្សា ដែលត្រូវការបន្ថែមទាំងនេះ ដោយប្រើប្រាស់ថវិកាជាតិរបស់ខ្លួន ប្រទេសទាំងនោះក៏ចាំបាច់ត្រូវរ៉ាប់រងលើចំណាយបណ្តុះបណ្តាលគ្រូ ក៏ដូចជាលើការសាងសង់សាលារៀន និងសម្ភារសិក្សាផងដែរ ដើម្បីធានាយ៉ាងណាឱ្យកុមារអាចទទួលបាននូវការអប់រំប្រកបដោយគុណភាព។ ការបង្កើនចំនួនគ្រូមធ្យមសិក្សាបឋមភូមិ គឺជាបន្ទុកបន្ថែមទៀតលើថវិកាជាតិ។ ដូច្នេះ ប្រទេសក្រីក្រជាងគេមួយចំនួនទំនងជានឹងប្រឈមនឹងកង្វះខាតថវិកាធ្ងន់ធ្ងរ ហើយត្រូវការការគាំទ្រពីអ្នកផ្តល់ជំនួយ។ តម្រូវការនេះទំនងជានឹងកាន់តែមានធំជាងនេះទៅទៀត នៅពេលដែលគេគិតរួមទាំងចំណាយសម្រាប់ពង្រីកកម្មវិធីអប់រំគ្រូផង។

យ៉ាងណាមិញ ពីឆ្នាំ ២០០៨ ដល់ ២០១១ អ្នកផ្តល់ជំនួយ ចំណាយថវិកាជាមធ្យមត្រឹមតែ ១៨៩ លានដុល្លារ ប៉ុណ្ណោះក្នុងមួយឆ្នាំ លើកម្មវិធីបណ្តុះ - បណ្តាល និងវិក្រឹតការគ្រូ ពោលគឺស្មើនឹង ២% នៃថវិកាជំនួយសម្រាប់វិស័យអប់រំ។ ខណៈពេលដែលប្រទេសដែលត្រូវការជំនួយច្រើនជាងគេ គឺប្រទេសនៅអាហ្វ្រិចសាប់សាហារ៉ា ប្រទេសដែលជាអ្នកទទួល បានជំនួយនេះច្រើនជាងគេរួមមានប្រទេសដែលមានចំណូលមធ្យម ដែលសម្បូរធនធានច្រើន ដូចជា ប្រទេសប្រេស៊ីល ចិន និងឥណ្ឌូនេស៊ី ជាដើម។

## យុទ្ធសាស្ត្រចំនួន ៤ ដើម្បីផ្តល់គ្រូដែលល្អបំផុត

អ្នកតាក់តែងគោលនយោបាយ ចាំបាច់ត្រូវតែផ្តល់គ្រប់ឱកាសទាំងអស់ដល់គ្រូ ដើម្បីឱ្យពួកគេមានទឹកចិត្ត ថាមពល ប្រើប្រាស់ចំណេះដឹង និងជំនាញរបស់ពួកគេ ដើម្បីធ្វើឱ្យការរៀនសូត្រកាន់តែមានភាពប្រសើរឡើងសម្រាប់កុមារគ្រប់រូប។ របាយការណ៍នេះរៀបរាប់ពីយុទ្ធសាស្ត្រចំនួន ៤ ដែលរដ្ឋាភិបាលចាំបាច់ត្រូវយកមកអនុវត្ត ដើម្បីទាក់ទាញ និងរក្សាគ្រូដែល មានសមត្ថភាពបំផុត លើកកម្ពស់ការអប់រំគ្រូ ពង្រាយគ្រូឱ្យកាន់តែស្មើភាពគ្នា និងផ្តល់ការលើកទឹកចិត្តក្នុងទម្រង់ជាបៀវត្សសមស្រប និងមាគ៌ាអាជីព ដែលមានភាពទាក់ទាញ។ បន្ទាប់មករបាយការណ៍នេះនឹងបង្ហាញពីផ្នែក ដែលចាំបាច់ ត្រូវមានការពង្រឹងអភិបាលកិច្ចគ្រូ ដើម្បីធានាឱ្យមានការសម្រេចនូវប្រយោជន៍ចេញពីយុទ្ធសាស្ត្រទាំង ៤ នេះ។

## យុទ្ធសាស្ត្រទី ១ ៖ ទាក់ទាញគ្រូដែលមានសមត្ថភាពបំផុត

*ខ្ញុំសម្រេចចិត្តធ្វើជាគ្រូបង្រៀន ដោយសារតែខ្ញុំជឿថា ការអប់រំមានអំណាចធ្វើឱ្យមានការផ្លាស់ប្តូរក្នុងសង្គម ដែលយើងកំពុងរស់នៅ។ កត្តាដែលលើកទឹកចិត្តឱ្យខ្ញុំធ្វើជាគ្រូឱ្យបានល្អម្នាក់ គឺខ្ញុំអាចក្លាយជាភ្នាក់ងារជំរុញ ដើម្បីជម្រុញឱ្យ មានការផ្លាស់ប្តូរ ដែលចាំបាច់បំផុតសម្រាប់ ប្រទេសរបស់ខ្ញុំ ក្នុងការប្រយុទ្ធប្រឆាំងនឹងការរើសអើង ភាពអយុត្តិធម៌ ការរើសអើងពូជសាសន៍ អំពើពុករលួយ ភាពក្រីក្រ។*

- Ana ជាគ្រូ នៅទីក្រុងលីម៉ា ប្រទេសពេរូ

ជំហានទី ១ ដើម្បីបានគ្រូល្អៗ គឺត្រូវទាក់ទាញបេក្ខជនដែលមានសមត្ថភាពបំផុត និងមានទឹកចិត្តជាងគេ ឱ្យបំពេញ ការងារនេះ។ មនុស្សជាច្រើនដែលសម្រេចចិត្តធ្វើជាគ្រូ ត្រូវបានលើកទឹកចិត្តដោយសារការពេញចិត្តនឹងជួយឱ្យសិស្សបានរៀនសូត្រ បំពេញសក្តានុពលរបស់ពួកគេ និងអភិវឌ្ឍខ្លួនឱ្យក្លាយជាប្រជាជនប្រកបដោយទំនុកចិត្ត និងការទទួលខុសត្រូវ។

ការគ្រាន់តែចង់បង្រៀន គឺមិនគ្រប់គ្រាន់ឡើយ។ គេគួរចូលបំពេញការងារនេះ បន្ទាប់ពីបានទទួលការអប់រំល្អ ដោយខ្លួនឯងរួចមក។ ពួកគេចាំបាច់ត្រូវបញ្ចប់យ៉ាងហោចណាស់ការសិក្សាកម្រិតមធ្យមសិក្សា ដែលមានគុណភាពនិង ភាពពាក់ព័ន្ធសមស្រប ដើម្បីឱ្យពួកគេមានចំណេះដឹងបានល្អអំពីមុខវិជ្ជាដែលពួកគេនឹងបង្រៀន ក៏ដូចជាមានសមត្ថភាព ទទួលបានជំនាញ ដែលចាំបាច់សម្រាប់ការបង្រៀន។

ប៉ុន្តែ ការងារបង្រៀន មិនមែនជានិច្ចកាល សុទ្ធតែអាចទាក់ទាញបេក្ខជនដែលល្អបំផុតនោះទេ។ នៅតាមប្រទេសមួយចំនួន ការងារបង្រៀនត្រូវបានគេចាត់ទុកថាជាការងារថ្នាក់ទី ២ សម្រាប់អ្នកដែលរៀនមិនពូកែ ដើម្បីចាប់យកអាជីព ដែលល្អជាងនេះ ដូចជា អាជីពជាគ្រូពេទ្យ ឬវិស្វករ ជាដើម។ កម្រិតគុណវឌ្ឍិ ដែលចាំបាច់ ដើម្បីចូលបម្រើការងារជាគ្រូ បង្រៀន គឺជាសញ្ញា ដែលបង្ហាញពីឋានៈវិជ្ជាជីវៈរបស់ការងារនេះ។ ឧទាហរណ៍ ដើម្បីបង្កើនឋានៈការងារបង្រៀន និងទាក់ទាញបេក្ខជនដែលមានទេពកោសល្យ ប្រទេសអេហ្ស៊ីបបានដាក់ឱ្យអនុវត្តនូវលក្ខខណ្ឌយ៉ាងតឹងរ៉ឹងសម្រាប់ចូលបម្រើការងារនេះ ដែលតម្រូវឱ្យបេក្ខជនទទួលបានពិន្ទុខ្ពស់នៅសាលាមធ្យមសិក្សា និងទទួលបានលទ្ធផលគាប់ប្រសើរពេលសម្ភាស។ បន្ទាប់ពីបានជ្រើសរើសរួច បេក្ខជនក៏ត្រូវជាប់ការប្រឡងចូលផងដែរ ដើម្បីកំណត់ឱ្យដឹងថាតើពួកគេស័ក្តិសមជាគ្រូល្អម្នាក់ដែរឬទេ។

ការធានាយ៉ាងណាឱ្យមានគ្រូស្រីក្នុងចំនួនគ្រប់គ្រាន់ និងការជ្រើសរើសគ្រូ ដែលមានសាវតារចម្រុះឱ្យបានច្រើននាក់ គឺជាកត្តាសំខាន់ ដើម្បីផ្តល់ការអប់រំបញ្ចូលគ្នាប្រកបដោយគុណភាព។ ប្រហែលជាចាំបាច់ត្រូវមានគោលនយោបាយ ដែលមានភាពបត់បែន អំពីលក្ខណៈសម្បត្តិ ដើម្បីធ្វើជាគ្រូបង្រៀន ដើម្បីបង្កើនភាពចម្រុះនៃបុគ្គលិកបង្រៀន។ នៅស៊ូដង់ភាគខាងត្បូង ស្ត្រីមានប្រមាណជា ៦៥% នៃចំនួនប្រជាជនក្រោយសង្គ្រាម ប៉ុន្តែមានគ្រូតិចជាង ១០ % ប៉ុណ្ណោះ ជាស្ត្រី។ ដើម្បីបង្កើនចំនួនគ្រូស្រី ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងសម្ភារ ត្រូវបានផ្តល់ដល់ក្មេងស្រីជាង ៤៥០០ នាក់ ដើម្បីឱ្យពួកគេ បញ្ចប់ការអប់រំនៅកម្រិតមធ្យមសិក្សា និងចាប់អាជីពជាគ្រូបង្រៀន។

ការជ្រើសរើសគ្រូពីក្រុម ដែលមិនសូវមានតំណាង ដើម្បីឱ្យទៅធ្វើការងារតាមសហគមន៍របស់ពួកគេវិញ អាចធានាថាកុមារទទួលបានគ្រូ ដែលដឹងពីវប្បធម៌ និងភាសារបស់ពួកគេ។ គោលនយោបាយប្រកបដោយភាពបត់បែនអំពីលក្ខខណ្ឌសម្រាប់ចូលបម្រើការងារជាគ្រូបង្រៀន អាចជួយបង្កើនចំនួនបេក្ខជន ដែលត្រូវបានជ្រើសរើសចេញពីក្រុមជន ជាតិភាគតិច។ នៅក្នុងប្រទេសកម្ពុជា ដែលធម្មតា គរុសិស្សត្រូវបញ្ចប់ថ្នាក់ទី ១២ លក្ខខណ្ឌមួយនេះត្រូវបានលើកលែងសម្រាប់តំបន់ដាច់ស្រយាល ដែលពុំមានផ្តល់ការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ដែលនាំឱ្យមានការកើនឡើងនូវចំនួន គ្រូមកពីសហគមន៍ជនជាតិភាគតិច។

## យុទ្ធសាស្ត្រទី ២ ៖ កែលំអការអប់រំរបស់គ្រូ ដើម្បីឱ្យកុមារទាំងអស់អាចរៀនចេះ

ការបណ្តុះបណ្តាលគ្រូដំបូង គួរផ្តល់ជំនាញ ដែលចាំបាច់សម្រាប់ធ្វើការបង្រៀន ជាពិសេស សម្រាប់បង្រៀនកុមារជួបប្រទះការលំបាក និងកុមារដែលរៀនថ្នាក់ដំបូងៗ និងដាក់ចេញនូវមូលដ្ឋាន សម្រាប់ការបណ្តុះបណ្តាលបន្ត។ ប៉ុន្តែ ការបណ្តុះបណ្តាលគ្រូដំបូងៗ ជានិច្ចកាល មិនមានប្រសិទ្ធភាព នៅក្នុងការរៀបចំគ្រូឱ្យផ្តល់ការអប់រំប្រកបដែលមានគុណភាព និងប្រកបដោយសមធម៌នោះទេ។

គរុសិស្សត្រូវការការយល់ដឹងឱ្យបានល្អអំពីមុខវិជ្ជា ដែលពួកគេនឹងបង្រៀន។ ប៉ុន្តែ នៅតាមបណ្តាប្រទេសដែល មានចំណូលទាប ជារឿយៗ គ្រូចាប់ផ្តើមអាជីពបង្រៀន ដោយខ្វះចំណេះដឹងអំពីមុខវិជ្ជាស្នូល ដោយសារតែការអប់រំរបស់ពួកគេខ្លួនឯងមានកម្រិតខ្សោយ។ នៅក្នុងការអង្កេតឆ្នាំ ២០១០ លើសាលាបឋមសិក្សា នៅក្នុងប្រទេកេនយ៉ា គ្រូថ្នាក់ទី ៦ ទទួលពិន្ទុបានត្រឹមតែ ៦០% លើតេស្ត ដែលរៀបចំឡើង សម្រាប់សិស្សរបស់ពួកគេតែប៉ុណ្ណោះ។ នៅក្នុងកាលៈទេសៈបែប នេះ កម្មវិធីអប់រំគ្រូ ចាំបាច់ត្រូវចាប់ផ្តើម ដោយធានាយ៉ាងណាឱ្យគរុសិស្សទទួលបានការយល់ដឹងឱ្យបានល្អអំពីមុខវិជ្ជា ដែលពួកគេនឹងបង្រៀន។

ស្ថាប័នអប់រំគ្រូ ជារឿយៗ មិនមានពេលវេលា ដើម្បីកែលំអចំណេះដឹងអំពីមុខវិជ្ជា ដែលនៅខ្សោយនោះទេ មួយ ផ្នែកដោយសារតែកម្មវិធីសិក្សាតម្រូវឱ្យមានការបំពេញការងារជាច្រើន។ នៅក្នុងប្រទេសកេនយ៉ា គរុសិស្សត្រូវបង្រៀនត្រូវរៀន ១០ មុខវិជ្ជា ហើយត្រូវចូលរួមក្នុងកម្មសិក្សា នៅឆ្នាំដំបូង។ នេះធ្វើឱ្យគេមានពេលវេលាតិចតួច ដើម្បីបំពេញគម្លាតចំណេះដឹងអំពីមុខវិជ្ជា។ ប្រទេសហ្គាណា បានដោះស្រាយបញ្ហានេះ ដោយតម្រូវឱ្យគរុសិស្សប្រឡងឱ្យជាប់តេស្តចំណេះដឹងអំពីមុខវិជ្ជារបស់ពួកគេ នៅឆ្នាំទីមួយ។

គ្រូត្រូវការមិនត្រឹមតែចំណេះដឹងឱ្យបានល្អអំពីមុខវិជ្ជាប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ត្រូវការចំណេះដឹងអំពីរបៀប បង្រៀនផងដែរ។ ប៉ុន្តែ គ្រូកម្រទទួលបានការបណ្តុះបណ្តាលអំពីជំនាញទាំងនេះណាស់។ នៅក្នុងប្រទេសម៉ាលី មានគ្រូតែមួយចំនួនតូចប៉ុណ្ណោះ ដែលអាចបង្រៀនសិស្សរបស់ពួកគេពីរបៀបអានបាន។ គ្រូ មិនត្រូវបានគេរៀបចំឱ្យបានគ្រប់គ្រាន់ ដើម្បីអនុវត្តវិធីសាស្ត្របង្រៀនដែលចាំបាច់ និងមិនបានផ្តោតការយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់លើការអានរបស់សិស្ស ម្នាក់ៗឡើយ។ នេះគឺជាមូលហេតុសំខាន់មួយ ដែលនាំឱ្យសិស្សជិតពាក់កណ្តាល នៅក្នុងប្រទេសម៉ាលី មិនចេះអានសូម្បីតែ ពាក្យមួយម៉ាត់ ក្នុងភាសារបស់របស់ពួកគេ នៅពេលចុងថ្នាក់ទី ២។ គ្រូ ក៏កម្រត្រូវបានគេរៀបចំ ដើម្បីឆ្លើយតបទៅនឹងតថភាពនៃថ្នាក់រៀនពហុភាសាផងដែរ។ ឧទាហរណ៍ នៅក្នុងប្រទេសសេណេហ្គាល់ មានគរុសិស្សត្រឹមតែ ៨% ប៉ុណ្ណោះ ដែលមានទំនុកចិត្តលើការបង្រៀនអំណាន ដោយប្រើប្រាស់ភាសាក្នុងស្រុក។

ដោយសារការបណ្តុះបណ្តាលមិនបានគ្រប់គ្រាន់ រាប់បញ្ចូលទាំងការ ផ្តោតខ្លាំងពេកលើទ្រឹស្តី ជាជាងលើការអនុវត្ត គ្រូ ដែលមានសមត្ថភាពថ្មីៗជាច្រើននាក់ ពុំមានទំនុកចិត្តថា ពួកគេមានជំនាញ ដែលចាំបាច់ ដើម្បីផ្តល់ការគាំទ្រដល់កុមារ ដែលមានតម្រូវការរៀនសូត្រពិបាកៗ នៅក្នុងសាលាធម្មតានោះឡើយ ដូចជា កុមារដែលមានពិការភាពធ្ងន់ធ្ងរផ្លូវកាយ ឬ បញ្ញា ជាដើម។ ដើម្បីដោះស្រាយបញ្ហានេះ គ្រូ នៅក្នុងប្រទេសវៀតណាម បង្កើតនូវផែនការអប់រំកុមារម្នាក់ៗ សម្រាប់កុមារទាំងអស់ ដោយបានរៀបចំ និងកែសម្រួលសកម្មភាព ឱ្យស្របទៅតាមតម្រូវការនៃការរៀនសូត្រផ្សេងៗគ្នារបស់កុមារ និងធ្វើការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ដែលមានតម្រូវការពិសេស។

ការអប់រំគ្រូ ក៏គួររៀបចំគ្រូ សម្រាប់សាលារៀននៅតាមតំបន់ដាច់ស្រយាល ឬសាលារៀនដែលខ្វះខាតធនធានផង ដែរ ពោលគឺគ្រូមួយចំនួនត្រូវបង្រៀនថ្នាក់គួប ដែលមានសិស្សក្នុងក្រុមអាយុផ្សេងៗគ្នា និងមានសមត្ថភាពខុសៗគ្នា ក្នុងថ្នាក់តែមួយ។ នៅតាមប្រទេសមួយចំនួន នៅអាហ្វ្រិចសាប់សាហារ៉ា ដូចជា បើគីណាហ្វាសូ ម៉ាលី នីហ្សេ សេណេហ្គាល់ និង តូហ្គោ ជាដើម មានសិស្សយ៉ាងហោចណាស់ ១០% រៀនសូត្រ នៅតាមថ្នាក់រៀនទាំងនេះ។ គម្រោងតូចមួយ នៅក្នុង ប្រទេសស្រីលង្កា បានបណ្តុះបណ្តាលគ្រូ ឱ្យចេះរៀបចំកិច្ចតែងការបង្រៀន និងរៀបចំកិច្ចការសមស្របតាមកម្រិតថ្នាក់ សម្រាប់ថ្នាក់រៀន ដែលមានសិស្សរៀនថ្នាក់ទី ៤ និងទី ៥ ជាមួយគ្នា។ លទ្ធផលបានបង្ហាញថា វិធីសាស្ត្របែបនេះមានផលជាវិជ្ជមានលើលទ្ធផលសិក្សាផ្នែកគណិតវិទ្យារបស់សិស្ស។

**នៅក្នុងប្រទេសកេនយ៉ា គ្រូបង្រៀនថ្នាក់ទី ៦ ទទួលពិន្ទុបានត្រឹមតែ ៦០% លើតេស្ត ដែលរៀបចំឡើងសម្រាប់សិស្សរបស់ពួកគេប៉ុណ្ណោះ**

ប្រទេស ដែលមានសិស្សមានលទ្ធផលសិក្សាខ្ពស់តម្រូវឱ្យគរុសិស្សទទួលបានការបណ្តុះបណ្តាលអំពីការអនុវត្តក្នុងថ្នាក់រៀន មុនពេលចេញបង្រៀន។ ការបណ្តុះបណ្តាលនេះមានសារៈសំខាន់ជាពិសេស សម្រាប់គ្រូ ដែលបង្រៀន នៅតាមថ្នាក់ ដែលខ្វះធនធាន និងមានសិស្សចម្រុះ ប៉ុន្តែកម្រនឹងមានការផ្តល់ការបណ្តុះបណ្តាលបែបនេះណាស់។ នៅក្នុងប្រទេសប៉ាគីស្ថាន

គរុសិស្សចំណាយពេលត្រឹមតែ ១០% នៃពេលបណ្តុះបណ្តាលរបស់ពួកគេតែប៉ុណ្ណោះ នៅក្នុងថ្នាក់រៀន។ ដើម្បីឆ្លើយតបនឹងតម្រូវការនេះ កម្មវិធីបណ្តុះបណ្តាលគ្រូ របស់អង្គការមិនមែនរដ្ឋាភិបាលមួយ នៅក្នុងប្រទេសម៉ាឡាវី ដាក់បញ្ចូលនូវការហ្វឹកហាត់ការបង្រៀនពេញមួយឆ្នាំ នៅតាមតំបន់ជនបទ។ អ្នកចូលរួមប្រមាណជា ៧២% បាននិយាយថា សមាសភាគហ្វឹកហាត់បង្រៀន នៅក្នុងថ្នាក់រៀន គឺជាមុខវិជ្ជាសិក្សាមួយ ដែលបានផ្តល់ការរៀបចំដល់ពួកគេច្រើនជាងគេ សម្រាប់ចុះទៅបង្រៀននៅតាមតំបន់ជនបទ។ លើសពីនេះ ពួកគេ ៨០% បានទទួលបទពិសោធន៍អំពីការផ្តល់ការគាំទ្របន្ថែមដល់សិស្ស បើធៀបជាមួយនឹង ១៤% នៃគរុសិស្ស ដែលរៀននៅតាមសាលាគរុកោសល្យរបស់រដ្ឋ។

**នៅក្នុងប្រទេសតួគី វគ្គបណ្តុះបណ្តាលគ្រូ មុនពេលចេញបម្រើការងារ អំពីសមធម៌យេនឌ័រ មានផលប៉ះពាល់យ៉ាងធំធេងមកលើឥរិយាបថយេនឌ័ររបស់គ្រូស្រី**

គ្រូក៏ត្រូវការការបណ្តុះបណ្តាលពីរបៀបដែលឥរិយាបថចំពោះយេនឌ័រ អាចមានផលប៉ះពាល់លើលទ្ធផលនៃការ រៀនសូត្រផងដែរ។ នៅក្នុងប្រទេសតួគី វគ្គបណ្តុះបណ្តាលគ្រូរយៈពេលមួយត្រីមាសអំពីសមធម៌យេនឌ័រ មានឥទ្ធិពលយ៉ាង ធំធេងមកលើឥរិយាបថ និងការយល់ដឹងអំពីយេនឌ័ររបស់គ្រូបង្រៀនជាស្ត្រី។

គ្រូបង្រៀនទាំងអស់ ត្រូវការការផ្តល់ការគាំទ្រជាបន្តទៀត នៅពេលដែលពួកគេទៅបង្រៀនតាមថ្នាក់រៀន ដើម្បី ផ្តល់លទ្ធភាពឱ្យពួកគេអាចឆ្លុះបញ្ចាំងលើរបៀបបង្រៀនរបស់ពួកគេ ជម្រុញលើកទឹកចិត្ត និងជួយឱ្យពួកគេសម្របទៅតាមការផ្លាស់ប្តូរនានា ដូចជា ការប្រើប្រាស់កម្មវិធីសិក្សាថ្មី ឬភាសាថ្មីសម្រាប់បង្រៀន ជាដើម។ ការបណ្តុះបណ្តាលបន្តក៏អាចផ្តល់ឱ្យគ្រូនូវគំនិតថ្មីៗអំពីរបៀបផ្តល់ការគាំទ្រដល់សិស្សខ្សោយផងដែរ។ គ្រូ ដែលបានទទួលការបណ្តុះបណ្តាលមួយចំនួន ជាទូទៅ ត្រូវបានគេរកឃើញថាអាចបង្រៀនបានល្អជាងគ្រូ ដែលមិនបានទទួលការបណ្តុះបណ្តាល បើទោះបីជាវាអាស្រ័យទៅតាមគោលបំណង និងគុណភាពនៃការបណ្តុះបណ្តាលយ៉ាងណាក៏ដោយ។

ការបណ្តុះបណ្តាលបន្ត រឹតតែសំខាន់ទៅទៀត សម្រាប់គ្រូ ដែលចូលមកបង្រៀន ដោយមានការអប់រំមុនចេញ បម្រើការងារតិចតួច ឬពុំមានឆ្លងកាត់ការអប់រំបែបនេះសោះ ឬដែលការបណ្តុះបណ្តាល ដែលពួកគេបានទទួលមិនបានផ្តល់ពិសោធន៍គ្រប់គ្រាន់ដល់ពួកគេអំពីអ្វីដែលកើតមានជាក់ស្តែង ក្នុងថ្នាក់រៀន។ នៅក្នុងប្រទេសបេនីន គ្រូបង្រៀនជាច្រើននាក់ ត្រូវបានជួលឱ្យធ្វើជាគ្រូសហគមន៍ ឬគ្រូកិច្ចសន្យា ដោយមិនបានទទួលការបណ្តុះបណ្តាលគ្រូអ្វីទាំងអស់។ មានកម្មវិធីមួយ ដែលរៀបចំឡើង នៅក្នុងឆ្នាំ ២០០៧ ផ្តល់ការបណ្តុះបណ្តាលរយៈពេល ៣ ឆ្នាំដល់ពួកគេ ដើម្បីផ្តល់ឱ្យពួកគេនូវគុណវឌ្ឍិស្មើនឹងគ្រូពេញសិទ្ធិរបស់រដ្ឋ។

គ្រូ នៅតាមតំបន់ដែលមានជម្លោះ គឺជាគ្រូ ដែលមានតម្រូវការជាងគេនូវយុទ្ធសាស្ត្រស៊ីសង្វាក់មួយ ដើម្បីលើក កម្ពស់ជំនាញរបស់ពួកគេ។ នៅជំរុំភៀសខ្លួន Dadaab នៅភាគខាងជើងប្រទេសកេនយ៉ា មានគ្រូ ៩០% ត្រូវបានជួលចេញ ពីសហគមន៍ជនភៀសខ្លួន ប៉ុន្តែមានគ្រូត្រឹមតែ ២% ប៉ុណ្ណោះ ដែលមានសមត្ថភាព។ គ្រូបង្រៀន ដែលជាជនភៀសខ្លួន ពុំមានសិទ្ធិចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា នៅក្នុងប្រទេសកេនយ៉ាឡើយ ដូច្នេះពួកគេត្រូវការជម្រើសបន្ថែមទៀត ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ យុទ្ធសាស្ត្រពីការគ្រប់គ្រង និងអភិវឌ្ឍគ្រូមួយ សម្រាប់ឆ្នាំ ២០១៣-២០១៥ ត្រូវ បានរៀបចំឡើង ដើម្បីផ្តល់ឱ្យពួកគេនូវការបណ្តុះបណ្តាល ក្នុងនោះមានទាំងការហ្វឹកហាត់បង្រៀនតាមសាលារៀនផង ដែរ។ យុទ្ធសាស្ត្រនេះ ក៏ផ្តល់ជាអនុសាសន៍ឱ្យមានជម្រើសផ្តល់គុណវឌ្ឍិ និងវិញ្ញាបនបត្របញ្ជាក់ដល់គ្រូ ដែលអាចបំពេញ បាននូវលក្ខខណ្ឌអប្បបរមាសម្រាប់ចូលរៀននៅកម្រិតឧត្តមសិក្សា ក៏ដូចជាជម្រើសសម្រាប់គ្រូ ភាគច្រើន ដែលមិនអាចបំពេញតាមលក្ខខណ្ឌនេះបាន។ ការបណ្តុះបណ្តាលបន្ត អាចភ្ជាប់គម្លាតពាក់ព័ន្ធនឹងគុណភាព និងភាពពាក់ព័ន្ធនៃការអប់រំគ្រូ ប៉ុន្តែជារឿយៗ មិនបានផ្តល់ជំនាញ ដែលគ្រូត្រូវការ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរៀនសូត្រជាក់លាក់ឡើយ ជាពិសេសនៅថ្នាក់ដំបូងៗ។ ការវាយតម្លៃអំណានសម្រាប់ថ្នាក់ដំបូង នៅក្នុងប្រទេសលីបេរី រកឃើញថា មានសិស្សថ្នាក់ទី ២ ប្រមាណជា ១ ភាគ ៣ មិនអាចអានពាក្យមួយម៉ាត់ដាច់ឡើយ។ ជាលទ្ធផល នៅក្នុងឆ្នាំ ២០០៨ ក្រសួងអប់រំបានដាក់ឱ្យអនុវត្តនូវកម្មវិធីថ្មីមួយ ដែលរួមមានការអប់រំ និងគាំទ្រដល់គ្រូ កិច្ចតែងការបង្រៀន ធនធានសម្ភារសម្រាប់ការបង្រៀន និងសៀវភៅ សម្រាប់ឱ្យកុមារយកទៅផ្ទះ ជាដើម។ គ្រូបានចូលរួម នៅក្នុងវគ្គបណ្តុះបណ្តាលរយៈពេល ១ សប្តាហ៍ អំពីការបង្រៀនអំណានសម្រាប់ថ្នាក់ដំបូង និងរបៀបប្រើប្រាស់ការវាយតម្លៃវិភាគ ដើម្បីកំណត់រកសិស្សរៀនខ្សោយ និងផ្តល់ការគាំទ្រដល់ពួកគេ។ បន្ទាប់មកមានការចុះផ្តល់ការគាំទ្រ ដោយគ្រូឧទ្ទេស រយៈពេល ២ ឆ្នាំ។ សិស្សដែលចូលរួមនៅក្នុងកម្មវិធីនេះ បានបង្កើនពិន្ទុអំណានរបស់ពួកគេ ១៣០% បើធៀបជាមួយនឹង ៣៣% សម្រាប់សិស្សដែលមិនបានចូលរួមក្នុង កម្មវិធីនេះ។

នៅតាមប្រទេស ដែលមានចំណូលទាបជាច្រើន ការបង្រៀនពឹងអាស្រ័យលើគោលវិធីបង្រៀនបែបប្រពៃណី ដូចជា ការសូត្រមេរៀនឱ្យសិស្សស្តាប់ការរៀនតាមមេរៀន និងការថាតាម ជាជាងប្រើប្រាស់ជំនាញ ដែលនាំឱ្យមានការផ្ទេរចំណេះដឹង ដូចជា ការពិចារណាល្អិតល្អន់ ជាដើម។ កម្មវិធីអភិវឌ្ឍគ្រូ តាមសាលារៀន នៅក្នុងប្រទេសកេនយ៉ា បានបង្ហាញថា ការបណ្តុះបណ្តាលអាចមានប្រសិទ្ធភាព ក្នុងការជួយគ្រូឱ្យប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌលបាន។ កម្មវិធីនេះ ដែលមានប្រើប្រាស់ស្វ័យសិក្សា ដោយប្រើប្រាស់ឯកសាររៀនសូត្រពីចម្ងាយ និងកិច្ចប្រជុំជាមួយគ្រូ នៅតាមមណ្ឌល ធនធានកម្រង ធ្វើឱ្យការបង្រៀនកាន់តែមានអន្តរកម្ម ដោយមានការប្រើប្រាស់កិច្ចតែងការបង្រៀន និងធនធានបង្រៀន កាន់តែប្រសើរជាងមុន។

តួនាទីសំខាន់មួយ ដែលគ្រូឧទ្ទេសបំពេញ ក្នុងការផ្តល់ជំនាញដល់គ្រូ ជារឿយៗ គឺជាអ្វីដែលគេមិនសូវយកចិត្តទុក ដាក់ជាងគេ នៅក្នុងប្រព័ន្ធសម្រាប់រៀបចំគ្រូ ជាពិសេស នៅតាមប្រទេសកំពុងអភិវឌ្ឍ។ គ្រូឧទ្ទេសជាច្រើនកម្រមកមើល តាមសាលានៅមូលដ្ឋាន ដើម្បីដឹងពីបញ្ហាប្រឈម ដែលគរុសិស្សរបស់ពួកគេនឹងជួបប្រទះណាស់។ ការវិភាគលើប្រទេស ចំនួន ២ នៅអាហ្វ្រិចសាប់សាហារ៉ា បានរកឃើញថា គ្រូឧទ្ទេស ដែលជួយបណ្តុះបណ្តាលគ្រូអំពីរបៀបបង្រៀនជំនាញ អំណានកម្រជាអ្នកដែលមានជំនាញខាងគោលវិធី ដែលប្រើប្រាស់សម្រាប់មុខវិជ្ជាមួយនេះណាស់។

កំណែទម្រង់ ដែលមានគោលបំណងជួយដល់សិស្សជួបប្រទះការលំបាក ចាំបាច់ត្រូវតែធានាយ៉ាងណាឱ្យគ្រូឧទ្ទេសទទួលបានការបណ្តុះបណ្តាល ដើម្បីផ្តល់ការគាំទ្រឱ្យបានសមស្របដល់គ្រូ។ នៅក្នុងប្រទេសវៀតណាម គ្រូឧទ្ទេសជាច្រើននាក់ មានចំណេះដឹងតិចតួចអំពីរបៀបបំពេញតម្រូវការចម្រុះរបស់សិស្ស ទាល់តែមានការផ្តល់ការបណ្តុះបណ្តាលដល់គ្រូឧទ្ទេស មកពីតាមសកលវិទ្យាល័យ និងសាលានានា ឱ្យពួកគេក្លាយជាអ្នកជំនាញផ្នែកការអប់រំបញ្ចូលគ្នា នៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូរបស់ពួកគេ។

មិនត្រឹមតែគុណភាពនៃការអប់រំគ្រូប៉ុណ្ណោះទេ ដែលមិនគ្រប់គ្រាន់ គ្រឹះស្ថានផ្តល់ការអប់រំគ្រូជាច្រើន ក៏ខ្វះ សមត្ថភាព ដើម្បីទទួលយកអ្នក ដែលចាំបាច់ត្រូវទទួលការបណ្តុះបណ្តាល ក្នុងចំនួនដ៏ច្រើនបែបនេះផងដែរហើយការ


© Karel Prinsloo/ARETE/UNESCO

ពង្រីកសមត្ថភាពនេះត្រូវការចំណាយយ៉ាងច្រើន។ ការប្រើប្រាស់ បច្ចេកវិទ្យាដើម្បីផ្ដល់ការបណ្ដុះបណ្ដាលពីចំងាយគឺ ជាវិធីមួយ ដើម្បីអាចផ្ដល់ ការបណ្ដុះ-បណ្ដាលដល់គរុសិស្សឱ្យបានកាន់ត ច្រើននាក់។ កម្មវិធីបណ្ដុះបណ្ដាលពីចំងាយ ត្រូវតែមានគុណភាពគ្រប់គ្រាន់ ហើយគួរបំពេញបន្ថែមដោយការណែនាំ និងការគាំទ្រដោយផ្ទាល់នៅ ដំណាក់កាលសំខាន់ៗ។

វិសាលភាព ដែលបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) ត្រូវបានគេយកមកប្រើប្រាស់ នៅក្នុងការរៀនសូត្រពីចំងាយ សម្រាប់អប់រំគ្រូគឺអាស្រ័យទៅតាមហេដ្ឋារចនាសម្ព័ន្ធ និងធនធាន ICT និងតម្រូវការរបស់ក្រុមគោលដៅ។ នៅអាហ្វ្រិចខាងត្បូង ដែលការអង្កេតបានបង្ហាញថា មានគ្រូត្រឹមតែ ១% ប៉ុណ្ណោះ ដែលមានអ៉ីនធឺណិតប្រើប្រាស់ ប៉ុន្តែ មនុស្សភាគច្រើនមានទូរស័ព្ទដៃប្រើប្រាស់ កម្មវិធីអប់រំគ្រូមួយ បានបំពេញបន្ថែមពីលើការរៀនសូត្រពីចំងាយដោយប្រើ ឯកសារជាក្រដាស ជាមួយនឹងការផ្ញើសារជាអក្សរ។ នៅក្នុងប្រទេសម៉ាឡាវី ម៉ាស៊ីនចាក់ឌីវីឌី ដោយប្រើអាគុយ និងឌីវីឌី បង្រៀនបែបអន្តរកម្មត្រូវបានប្រើប្រាស់ ដើម្បីជួយដល់ការបណ្ដុះបណ្ដាលនេះ។

កម្មវិធីអប់រំគ្រូពីចំងាយ អាចគ្របដណ្ដប់ដល់គ្រូបន្ថែមទៀតនាពេលអនាគត ដោយអស់ចំណាយតិចជាងកម្មវិធី ដែលអនុវត្តនៅតាមគ្រឹះស្ថានអប់រំគ្រូ។ ការចំណាយក្នុងសិស្សម្នាក់ ដែលរៀនចប់ពីកម្មវិធីពីចំងាយ ត្រូវបានគេប៉ាន់ស្មានថា នៅចន្លោះ ១ ភាគ ៣ ទៅ ២ ភាគ ៣ នៃកម្មវិធីធម្មតា។

## យុទ្ធសាស្ត្រទី ៣ ៖ រកគ្រូពីកន្លែង ដែលត្រូវការគ្រូជាងគេ

គេអាចយល់បានថា គ្រូមានការស្ទាក់ស្ទើរ ក្នុងការចុះទៅបម្រើការងារ នៅតំបន់ជួបប្រទះការលំបាក ដែលមានការខ្វះខាតសម្ភាររូបវន្តនានា ដូចជា អគ្គិសនី លំនៅដ្ឋានសមរម្យ និងការថែទាំសុខភាពជាដើម។ ប្រសិនបើគ្រូល្អៗ កម្រចុះទៅធ្វើការងារ នៅតាមតំបន់ដាច់ស្រយាល ជនបទ ក្រីក្រ ឬតំបន់ដែលមានគ្រោះថ្នាក់ ឱកាសរៀនសូត្ររបស់កុមារ ដែលជួបប្រទះការលំបាកទៅហើយនោះ នឹងរឹតតែស្ដួចស្ដើងទៅទៀត ដោយសារតែមានសិស្សច្រើននាក់ក្នុងថ្នាក់ អត្រាផ្លាស់ប្ដូរគ្រូខ្ពស់ និងភាពកម្រនៃគ្រូដែលបានទទួលការបណ្ដុះបណ្ដាល។

រដ្ឋាភិបាល ចាំបាច់ត្រូវតែបង្កើតយុទ្ធសាស្ត្រ ដើម្បីធានាឱ្យមានការពង្រាយគ្រូឱ្យបានស្មើភាពគ្នា ប៉ុន្តែរដ្ឋាភិបាល កម្រនឹងធ្វើបែបនេះណាស់។ នៅក្នុងប្រទេសយេមែន សាលារៀន ដែលមានសិស្ស ៥០០ នាក់ ត្រូវបានរកឃើញថាមានគ្រូ ពី ៤ ទៅ ២៧ នាក់។ នៅប្រទេសស៊ូដង់ភាគខាងត្បូង ផលធៀបសិស្ស-គ្រូ ប្រែប្រួលពី ៥១ ៖ ១ នៅ Equatoria ភាគកណ្ដាល ដល់ ១៤៥ ៖ ១ នៅ Jonglei។

**នៅក្នុងប្រទេសស៊ូដង់ខាងត្បូង ផលធៀបសិស្ស-គ្រូ ឡើងដល់ ១៤៥ ៖ ១ នៅតំបន់ Jonglei**

ការបែងចែកសិស្សមិនស្មើគ្នា គឺជាមូលហេតុមួយ ដែលកុមារជាច្រើននាក់ បោះបង់ចោលការសិក្សា មុនពេលដែលពួកគេរៀនចេះចំណេះដឹងជាមូលដ្ឋាន។ នៅក្នុងប្រទេសបង់ក្លាដេស មានសិស្សត្រឹមតែ ៦០% ប៉ុណ្ណោះ ដែលបានរៀនដល់ថ្នាក់ចុងក្រោយនៅបឋមសិក្សា នៅតាមអនុស្រុក ដែលមានសិស្ស ៧៥ នាក់ ក្នុងគ្រូ ១ នាក់ បើធៀបជាមួយនឹង ៣ ភាគ ៤ ដែលមានសិស្ស ៣០ នាក់។

ការបែងចែកគ្រូមិនស្មើភាពគ្នា ទទួលរងផលប៉ះពាល់ដោយសារកត្តាសំខាន់ៗចំនួន ៤ ៖

ភាពលំអៀងទៅកេទីប្រជុំជន ៖ ហេដ្ឋារចនាសម្ព័ន្ធខ្សត់ខ្សោយនៅតាមតំបន់ជនបទ មានន័យថា គ្រូមិនសូវជាចង់ ទៅបង្រៀននៅទីនោះឡើយ។ ឧទាហរណ៍ នៅក្នុងប្រទេសស្វាហ្ស៊ីលេន សាលារៀននៅតាមតំបន់ជនបទដាច់ស្រយាល មានបុគ្គលិកភាគច្រើនជាគ្រូបង្រៀន ដែលត្រូវបានជ្រើសរើសថ្មី ពុំមានបទពិសោធន៍ និងគ្រូ ដែលមានសមត្ថភាពទាប។

ជាតិពន្ធុ និងភាសា ៖ ដោយសារកម្រិតវប្បធម៌របស់ជនជាតិភាគតិច ជារឿយៗ មានកម្រិតទាប មានពួកគេតែ មួយចំនួនតូចប៉ុណ្ណោះ ដែលអាចដាក់ពាក្យធ្វើជាគ្រូបង្រៀន។ នៅក្នុងប្រទេសឥណ្ឌា រដ្ឋមិនអាចបំពេញកូតាតាមវណ្ណៈ សម្រាប់ធ្វើការជ្រើសរើសគ្រូបានឡើយ លុះត្រាតែមានការជួលគ្រូ ដែលមានលក្ខណៈសម្បត្តិទាបជាងនេះ។

យេនឌ័រ ៖ ស្ត្រី មិនសូវទៅធ្វើការងារនៅតាមតំបន់ជួបប្រទះការលំបាក ដូចបុរសឡើយ។ នៅក្នុងប្រទេសរវ៉ាន់ដា មានគ្រូបឋមសិក្សាត្រឹមតែ ១០% ប៉ុណ្ណោះ ដែលជាស្ត្រី នៅក្នុងស្រុក Burera បើធៀបជាមួយនឹង ៦៧% នៅក្នុងស្រុក Gisagara ដែលមានជីវភាពធូរជាជាង។

មុខវិជ្ជា ៖ ជាពិសេស នៅតាមសាលាមធ្យមសិក្សា ជារឿយៗ មានកង្វះចំនួនគ្រូ នៅតាមមុខវិជ្ជាជាក់លាក់។ ឧទាហរណ៍ នៅក្នុងប្រទេសឥណ្ឌូនេស៊ី នៅសាលាមធ្យមសិក្សាបឋមភូមិ មានគ្រូលើសពីចំនួនត្រូវការសម្រាប់មុខវិជ្ជាសាសនា ប៉ុន្តែខ្វះគ្រូ សម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រកុំព្យូទ័រ។

**ប្រាក់ខែគ្រូជាមធ្យម មានកម្រិតទាបជាង ១០ ដុល្លារ ក្នុងមួយថ្ងៃ នៅក្នុងប្រទេសចំនួន ៨**

ដើម្បីឱ្យមានតុល្យភាពគ្រូ នៅទូទាំងប្រទេស រដ្ឋាភិបាលមួយចំនួនបានពង្រាយគ្រូ ទៅតាមតំបន់ជួបប្រទះការលំបាក។ មូលហេតុមួយ ដែលធ្វើឱ្យសាធារណរដ្ឋកូរ៉េមានលទ្ធផលសិក្សារឹងមាំ និងមានសមធម៌ គឺដោយសារតែក្រុមជួប ប្រទះការលំបាក មានលទ្ធភាពរៀនសូត្រជាមួយនឹងគ្រូដែលមានសមត្ថភាព និងមានបទពិសោធន៍។ គ្រូបង្រៀនជាង ៣ ភាគ ៤ នៅក្នុងភូមិ មានយ៉ាងហោចណាស់កម្រិតវប្បធម៌ត្រឹមបរិញ្ញាបត្រ បើធៀបជាមួយនឹង ៣២% នៅតាមទីក្រុងធំៗ ហើយ ៤៥% មានបទពិសោធន៍បង្រៀនជាង ២០ ឆ្នាំ បើធៀបជាមួយនឹង ៣០% នៅតាមទីក្រុងធំៗ។ គ្រូបង្រៀន ដែលធ្វើ ការងារនៅតាមសាលាជួបប្រទះការលំបាកទទួលបានប្រយោជន៍ពីការលើកទឹកចិត្តនានា ដូចជា ប្រាក់ឧបត្ថម្ភបន្ថែម ចំនួនសិស្សតិចក្នុងមួយថ្នាក់ ម៉ោងបង្រៀនតិចជាងឱកាសជ្រើសរើសសាលារៀនបន្ទាប់ក្រោយពេលដែលពួកគេបានបង្រៀន នៅក្នុងតំបន់ជួបប្រទះការលំបាកមួយហើយ និងឱកាសឡើងឋានៈ។

ការផ្តល់ការលើកទឹកចិត្ត គឺជាវិធីសាស្ត្រមួយ ដើម្បីលើកទឹកចិត្តគ្រូឱ្យទទួលយកប៉ុស្តិ៍បង្រៀន ដែលពិបាកៗ។ ការ ផ្តល់កន្លែងស្នាក់នៅប្រកបដោយសុវត្ថិភាព មានសារៈសំខាន់ជាពិសេស ដើម្បីលើកទឹកចិត្តស្ត្រីឱ្យទៅបង្រៀនតាមទីជនបទ ដូចជា នៅក្នុងប្រទេសបង់ក្លាដេស ជាដើម។ ប្រទេសហ្គាំបៀ បានដាក់ឱ្យប្រើប្រាស់នូវប្រាក់ឧបត្ថម្ភបន្ថែម ៣០% ទៅ ៤០% ពីលើប្រាក់ខែគោលរបស់គ្រូសម្រាប់ការបង្រៀននៅតាមតំបន់ដាច់ស្រយាល។ គិតត្រឹមឆ្នាំ ២០០៧ មានគ្រូ ២៤% បានស្នើសុំផ្ទេរទៅធ្វើការងារ នៅតាមសាលារៀន ដែលជួបប្រទះការលំបាក។

ជម្រើសមួយទៀត ប្រទេសទាំងឡាយអាចជ្រើសរើសគ្រូចេញពីក្នុងសហគមន៍ដោយផ្ទាល់តែម្តង។ នៅក្នុងប្រទេសឡេសូតូ ប្រព័ន្ធជ្រើសរើសគ្រូនៅនឹងមូលដ្ឋាន ផ្តល់លទ្ធភាពឱ្យ គណៈកម្មាធិការគ្រប់គ្រងសាលារៀនជួលគ្រូ ដែលដាក់ពាក្យធ្វើការងារទៅកាន់ សាលារៀនដោយផ្ទាល់តែម្តង។ ដូច្នេះហើយបានជានៅក្នុងប្រទេសនេះ មាន ភាពខុសគ្នាបន្តិចបន្តួចតែប៉ុណ្ណោះនៃផលធៀបសិស្ស-គ្រូ រវាងតំបន់ជនបទ និង តំបន់ប្រជុំជន។

ប្រទេសមួយចំនួន កំពុងផ្តល់ច្រកផ្សេងទៀតសម្រាប់ការងារបង្រៀន ដើម្បីទាក់ទាញអ្នកជំនាញ ដែលមានសមត្ថភាពខ្ពស់ ដែលមានចំណេះដឹងខ្លាំងអំពីមុខវិជ្ជាអ្វីមួយ។ វិធីសាស្ត្រមួយ គឺជាវិធីសាស្ត្រ ដែលប្រើប្រាស់ដោយកម្មវិធីបង្រៀនសម្រាប់ទាំងអស់គ្នា (Teach for All) នៅក្នុងប្រទេសជាច្រើន ដែលធ្វើការជ្រើសរើសនិស្សិតបញ្ចប់ការសិក្សា ដែលបញ្ចប់ការសិក្សា ដោយទទួលបានពិន្ទុខ្ពស់ខាងមុខវិជ្ជាអ្វីមួយ ឱ្យទៅបង្រៀនតាមសាលារៀន ដែលផ្តល់សេវាភាគច្រើនដល់សិស្សជួបប្រទះការលំបាក។ ភស្តុតាង ទទួលបានការវាយតម្លៃលើកម្មវិធីបង្រៀនសម្រាប់អាមេរិច (Teach for America) បង្ហាញថា នៅពេលដែលពួកគេបានទទួលបទពិសោធន៍មួយចំនួនរួចហើយ គ្រូទាំងនេះជួយកែលំអការរៀនសូត្ររបស់សិស្ស ដោយសារតែពួកគេបានផ្តល់នូវការបណ្តុះបណ្តាលមួយចំនួន។

## យុទ្ធសាស្ត្រទី ៤ ៖ ផ្តល់ការលើកទឹកចិត្តឱ្យបានសមស្រប ដើម្បីរក្សាទុកគ្រូដែលមានសមត្ថភាពបំផុត

បៀវត្ស គ្រាន់តែជាកត្តាមួយ ក្នុងចំណោមកត្តានានាជាច្រើន ដែលផ្តល់ការលើកទឹកចិត្តដល់គ្រូតែប៉ុណ្ណោះ ប៉ុន្តែ បៀវត្ស គឺជាកត្តាគន្លឹះ នៅក្នុងការទាក់ទាញបេក្ខជនដែលមានលក្ខណៈសម្បត្តិល្អបំផុត និងរក្សាទុកគ្រូដែលមានសមត្ថភាពបំផុត។ បៀវត្សទាប ទំនងជាធ្វើប៉ះពាល់ដល់ទឹកចិត្ត និងអាចនាំឱ្យគ្រូផ្លាស់ទៅបម្រើការងារផ្សេងទៀតវិញ។ ក្នុងពេលជាមួយគ្នា បៀវត្សរបស់គ្រូស្រូបយកចំណែកធំជាងគេនៃថវិកាអប់រំរបស់ប្រទេសភាគច្រើន ដូច្នេះគេត្រូវកំណត់បៀវត្សនៅត្រឹមកម្រិតដែលមានលក្ខណៈប្រាកដនិយម ដើម្បីឱ្យគេអាចជ្រើសរើសគ្រូឱ្យបានគ្រប់គ្រាន់។

កម្រិតបៀវត្សរបស់គ្រូ មានឥទ្ធិពលលើគុណភាពនៃការអប់រំ។ នៅក្នុងប្រទេសចំនួន ៣៩ ការបង្កើនបៀវត្សរបស់គ្រូចំនួន ១៥% បង្កើនលទ្ធផលសិក្សារបស់សិស្សពី ៦ ដល់ ៨%។ ប៉ុន្តែ គ្រូនៅតាមប្រទេសមួយចំនួន មិនទាំងអាចទទួល បានបៀវត្សគ្រប់គ្រាន់ ដើម្បីជួយឱ្យគ្រួសាររបស់ពួកគេងើបផុតពីភាពក្រីក្រផង។ គ្រូម្នាក់ ដែលជាអ្នករកចំណូលបង្គោល ក្នុងគ្រួសារ និងមានសមាជិកក្នុងគ្រួសារយ៉ាងហោចណាស់ ៤ នាក់ ដើម្បីគាំទ្រ ត្រូវការរកចំណូលឱ្យបានយ៉ាងហោចណាស់ ១០ ដុល្លារ ក្នុងមួយថ្ងៃ ដើម្បីឱ្យគ្រួសាររបស់ខ្លួនស្ថិតនៅលើបន្ទាត់នៃភាពក្រីក្រ ២ ដុល្លារ ក្នុងមួយថ្ងៃ សម្រាប់មនុស្សម្នាក់។ យ៉ាងណាក៏ដោយ បៀវត្សជាមធ្យមរបស់គ្រូ គឺស្ថិតនៅក្រោមកម្រិតនេះ នៅក្នុងប្រទេសចំនួន ៨។ នៅសាធារណរដ្ឋអាហ្វ្រិចកណ្តាល ហ្គីនីប៊ីសាវ និងលីបេរីយ៉ា គ្រូទទួលបានបៀវត្សមិនលើសពី ៥ ដុល្លារ ក្នុងមួយថ្ងៃឡើយ គិតជាមធ្យម។ បៀវត្សរបស់គ្រូ គឺទាបប្រហាក់ប្រហែលគ្នានេះ នៅសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ដែលជារឿយៗសហគមន៍ត្រូវតែផ្តល់ប្រាក់បន្ថែមពីលើបៀវត្សរបស់ពួកគេ។ សហគមន៍ ដែលមានជីវភាពក្រីក្រពេក ត្រូវជួបប្រទះនឹងការលំបាកបន្ថែម ដូចជាត្រូវបាត់បង់គ្រូល្អៗ ជាដើម។

នៅតាមប្រទេសមួយចំនួន មានគ្រូមួយចំនួនតូចប៉ុណ្ណោះ ដែលមានលទ្ធភាពរ៉ាប់រងចំណាយលើរបស់របរចាំបាច់ជាមូលដ្ឋាន ដោយមិនធ្វើការងារទី ២។ នៅក្នុងប្រទេសកម្ពុជា ដែលបៀវត្សរបស់គ្រូមិនអាចរ៉ាប់រងចំណាយលើទំនិញស្បៀងអាហារជាមូលដ្ឋានបាន នៅក្នុងឆ្នាំ ២០០៨ មានគ្រូជាង ២ ភាគ ៣ ដែលមានការងារទី ២។

ទិន្នន័យថ្នាក់ជាតិអំពីបៀវត្សជាមធ្យមរបស់គ្រូលាក់កំបាំងភាពខុសប្លែកគ្នានៃបៀវត្សរវាងប្រភេទគ្រូផ្សេងៗគ្នា ៖ ជារឿយៗ បៀវត្សមានចំនួនតិចជាងកម្រិតមធ្យម សម្រាប់គ្រូ នៅពេលចាប់ផ្ដើមអាជីពការងាររបស់ខ្លួន សម្រាប់គ្រូដែលមិនសូវមានសមត្ថភាព និងគ្រូ ដែលមានកិច្ចសន្យាបណ្ដោះអាសន្ន។ នៅក្នុងប្រទេសម៉ាឡាវី គ្រូ ដែលចូលបម្រើការងារនេះ ឬដែលខ្វះលក្ខណៈសម្បត្តិផ្នែកការអប់រំ ដែលចាំបាច់សម្រាប់ឡើងឋានៈ ទទួលបានបៀវត្សតិចជាគ្រូ ១ ភាគ ៣ ដែលស្ថិតនៅក្នុងប្រភេទកាំប្រាក់ ដែលខ្ពស់ជាងគេ។ បៀវត្សរបស់ពួកគេ គឺស្មើនឹងត្រឹមតែ ៤ ដុល្លារ ក្នុងមួយថ្ងៃប៉ុណ្ណោះ នៅក្នុងឆ្នាំ ២០០៧-២០០៨។

នៅពេលដែលគ្រូទទួលបានបៀវត្សតិចជាងអ្នក ដែលធ្វើការងារប្រហាក់ប្រហែលពួកគេ សិស្សដែលពូកែបំផុត មិនទំនងជាចង់ធ្វើជាគ្រូឡើយ ហើយគ្រូច្រើនតែបាត់បង់ការលើកទឹកចិត្ត ឬចង់ចាកចេញពីអាជីពនេះតែម្ដង។ នៅអាមេរិច ឡាទីន ជាទូទៅ គ្រូទទួលបានបៀវត្សលើកម្រិតនៃភាពក្រីក្រ ប៉ុន្តែបៀវត្សរបស់ពួកគេមិនអាចប្រៀបធៀបជាមួយនឹងអ្នក ធ្វើការងារផ្សេងទៀត ដែលត្រូវការគុណវឌ្ឍិប្រហាក់ប្រហែលគ្នាឡើយ។ នៅក្នុងឆ្នាំ២០០៧ អ្នកជំនាញ និងអ្នកបច្ចេកទេស ដែលមានសមត្ថភាពប្រហាក់ប្រហែលគ្នា ទទួលបានចំណូលច្រើនជាងគ្រូមត្តេយ្យ និងគ្រូបឋម ៤៣% នៅក្នុងប្រទេសប្រេស៊ីល និង ៥០% ជាងនៅក្នុងប្រទេសពេរូ។

នៅអាហ្វ្រិចសាប់សាហារ៉ា និងអាស៊ីខាងត្បូង និងខាងលិចអ្នកតាក់តែងគោលនយោបាយបានធ្វើការឆ្លើយតប ចំពោះតម្រូវការពង្រីកប្រព័ន្ធអប់រំយ៉ាងឆាប់រហ័ស ដោយធ្វើការជ្រើសរើសគ្រូ ដោយប្រើប្រាស់កិច្ចសន្យាបណ្ដោះអាសន្ន ដោយផ្ដល់ឱ្យពួកគេនូវការបណ្ដុះបណ្ដាលផ្លូវការតិចតួច។ ជាធម្មតា គ្រូជាប់កិច្ចសន្យាទទួលបៀវត្សតិចជាងគ្រូពេញសិទ្ធិ យ៉ាងច្រើន។ គ្រូមួយចំនួនត្រូវបានសហគមន៍ ឬសាលារៀនជួលឱ្យធ្វើការងារ ដោយផ្ទាល់តែម្ដង។

នៅអាហ្វ្រិចខាងលិច គ្រូជាប់កិច្ចសន្យា មានចំនួនស្មើនឹងពាក់កណ្ដាលនៃបុគ្គលិកបង្រៀន គិតត្រឹមពាក់កណ្ដាល ទសវត្សរ៍ ២០០០។ នៅចុងទសវត្សរ៍នេះ គ្រូ ដែលមានកិច្ចសន្យាបណ្ដោះអាសន្ន មានចំនួនច្រើនឆ្ងាយជាងគ្រូពេញសិទ្ធិនៅតាមប្រទេសមួយចំនួន ក្នុងចំណោមប្រទេសទាំងនេះ ៖ ភាគរយនេះកើនឡើងជិត ៨០% នៅក្នុងប្រទេសម៉ាលី និងនីហ្សេ និងជាង ៦០% នៅប្រទេសបេនីន និងកាម៉េរូន។ នៅក្នុងប្រទេសនីហ្សេ គ្រូជាប់កិច្ចសន្យាទទួលបៀវត្សត្រឹមពាក់កណ្ដាល គ្រូពេញសិទ្ធិតែប៉ុណ្ណោះ។

ទីបំផុត រដ្ឋាភិបាល នៅក្នុងប្រទេសមួយចំនួន ជួលគ្រូកិច្ចសន្យាឱ្យធ្វើជាគ្រូពេញសិទ្ធិ។ ឧទាហរណ៍ នៅក្នុងប្រទេសបេនីន គ្រូកិច្ចសន្យា ដោយមានការជួយគាំទ្រពីសមាគមគ្រូបង្រៀន បានរៀបចំយុទ្ធនាការ ដើម្បីទទួលបានលក្ខខណ្ឌការងារឱ្យកាន់តែមានស្ថិរភាព និងទទួលបានបៀវត្សឱ្យបានកាន់តែច្រើនជាងមុន។ នៅក្នុងឆ្នាំ ២០០៧ រដ្ឋាភិបាលបានចេញបទបញ្ជាមួយ ស្រូបយកគ្រូ ដែលអាចបំពេញទៅតាមលក្ខណៈសម្បត្តិដែលចាំបាច់ ឱ្យធ្វើជាគ្រូពេញសិទ្ធិទាំងអស់។

នៅក្នុងប្រទេសឥណ្ឌូនេស៊ី ដែលគ្រូកិច្ចសន្យាមានជាង ១ ភាគ ៣ នៃចំនួនបុគ្គលិកបង្រៀនសរុបនៅបឋមសិក្សា នៅក្នុងឆ្នាំ ២០១០ គ្រូពេញសិទ្ធិទទួលបានបៀវត្សដល់ទៅ ៤០ ដងនៃបៀវត្សរបស់គ្រូកិច្ចសន្យា។ រដ្ឋាភិបាលបានធានាថា គ្រូកិច្ចសន្យានឹងក្លាយជាគ្រូពេញសិទ្ធិ ដោយមានភាពពាក់ព័ន្ធជាមួយនឹងថវិកាអប់រំ ៖ ការផ្ដល់កិច្ចសន្យាពេញសិទ្ធិ ដល់គ្រូ កិច្ចសន្យាទាំងអស់ នឹងធ្វើឱ្យថវិកាសម្រាប់ចាយលើបៀវត្ស សម្រាប់ការអប់រំថ្នាក់មូលដ្ឋាន មានការកើនឡើង ៣៥% ដល់ ប្រហែលជា ៩ ពាន់លានដុល្លារ។

នៅពេលដែលគ្រូកិច្ចសន្យាទទួលបានបៀវត្សពីសហគមន៍ ការរក្សានិរន្តរភាពសេវារបស់ពួកគេ ពឹងអាស្រ័យលើ លទ្ធភាពរបស់មាតាបិតាក្នុងការកៀងគរថវិកា ដែលជាការដាក់បន្ទុកហិរញ្ញវត្ថុយ៉ាងច្រើនមកលើសហគមន៍ក្រីក្រ។ នៅក្នុងករណីមួយចំនួន នេះអាចនាំឱ្យរដ្ឋាភិបាលទទួលយកការទទួលខុសត្រូវមួយចំនួន ដោយចុងក្រោយរដ្ឋាភិបាលត្រូវផ្ដល់ ថវិកាបន្ថែម។ នៅក្នុងប្រទេសម៉ាដាកាស្កា គ្រូសហគមន៍ ដែលមានចំនួនស្មើនឹងប្រហែលជាពាក់កណ្ដាលនៃចំនួនគ្រូសរុប នៅក្នុងឆ្នាំ ២០០៥-២០០៦ ត្រូវបានជួលឱ្យបម្រើការងារដោយផ្ទាល់ដោយសមាគមមាតាបិតាសិស្ស ហើយជាទូទៅ ទទួលបានបៀវត្សទាបជាគ្រូពេញសិទ្ធិពាក់កណ្ដាល។ ចាប់តាំងពីឆ្នាំ ២០០៦ មក រដ្ឋាភិបាលបានទទួលរ៉ាប់រងច្រើនជាងមុន ក្នុងការផ្ដល់បៀវត្សដល់គ្រូសហគមន៍។

នៅពេលដែលការជួលគ្រូកិច្ចសន្យា ដើម្បីកាត់បន្ថយបញ្ហាកង្វះគ្រូ អាចជួយបាន នៅក្នុងរយៈពេលខ្លី យុទ្ធសាស្ត្រ បែបនេះមិនទំនងជាអាចបំពេញតម្រូវការរយៈពេលវែង ដើម្បីពង្រីកការអប់រំប្រកបដោយគុណភាពនោះទេ។ ប្រទេសនានា ដែលពឹងផ្អែកខ្លាំងលើគ្រូកិច្ចសន្យា ជាពិសេស នៅអាហ្វ្រិចខាងលិច ជាប់ចំណាត់ថ្នាក់ជិតបាតគេ ផ្នែកខាងលទ្ធភាព ទទួលបានការអប់រំ និងការរៀនសូត្រ។

**នៅក្នុងប្រទេសពេរូ អ្នកជំនាញ ដែលមានលក្ខណៈសម្បត្តិប្រហាក់ប្រហែលនឹងគ្រូ អាចរកចំណូលបានច្រើនជាងគ្រូ ៥០%**

បៀវត្សរបស់គ្រូ និងអត្រាកំណើននៃបៀវត្សរបស់គ្រូ បច្ចុប្បន្ននេះ ត្រូវបានកំណត់ដោយគុណវឌ្ឍិផ្លូវការ ចំនួនការបណ្ដុះបណ្ដាល និងចំនួនឆ្នាំនៃបទពិសោធន៍របស់ពួកគេ។ ប៉ុន្តែ រចនាសម្ព័ន្ធសម្រាប់ផ្ដល់បៀវត្ស ដែលផ្អែកទៅតាមលក្ខណៈវិនិច្ឆ័យបែបនេះ មិនអាចនាំឱ្យលទ្ធផលនៃការរៀនសូត្រមានភាពប្រសើរឡើងនោះទេ។ ការភ្ជាប់ទំនាក់ទំនងបៀវត្សរបស់គ្រូ ជាមួយនឹងលទ្ធផលសិក្សារបស់សិស្ស គឺជាគោលវិធីជាជម្រើសមួយទៀត ដែលអាចមានភាពទាក់ទាញផងដែរ។ ភាពទាក់ទាញនេះ ទទួលបានការគាំទ្រពីទិន្នន័យ PISA ដែលទទួលបានពីប្រទេស OECD ចំនួន ២៨ ៖ ប្រទេស ដែលបៀវត្សរបស់គ្រូ ត្រូវបានកែសម្រួលទៅតាមលទ្ធផលសិក្សារបស់សិស្ស ដែលទទួលបានពិន្ទុខ្ពស់ផ្នែកអំណានគណិតវិទ្យា និងវិទ្យាសាស្ត្រ។ ប៉ុន្តែ ការពិនិត្យឱ្យបានជិតស្និទលើភស្តុតាងអំពីបៀវត្ស ដែលមានទំនាក់ទំនងជាមួយលទ្ធផលសិក្សា ទទួលបានពីប្រទេសនានាជុំវិញពិភពលោក ពុំមានបានបង្ហាញឱ្យឃើញពីអត្ថប្រយោជន៍ឱ្យបានច្បាស់លាស់នោះទេ។

គេមានការលំបាក ដើម្បីស្វែងរកវិធី ដែលអាចជឿទុកចិត្តបានសម្រាប់ធ្វើការវាយតម្លៃថាតើគ្រូណា ដែលល្អជាងគេ និងដែលបន្ថែមគុណតម្លៃជាងគេ ដូចដែលបង្ហាញដោយបទពិសោធន៍របស់សហរដ្ឋអាមេរិច។ ការផ្ដល់បៀវត្ស ទៅតាមលទ្ធផលការងារ ក៏អាចមានផលប៉ះពាល់ជាអវិជ្ជមានដោយអចេតនា លើការបង្រៀន និងរៀនផងដែរ។ នៅក្នុងប្រទេសពេរូ ការផ្ដល់បៀវត្សបែបនេះ នាំឱ្យមានការប្រកួតប្រជែងរវាងគ្រូ និងគ្រូ ដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដល់សិស្សដែលរៀនខ្សោយជាងគេ។




នៅក្នុងប្រទេសម៉ិចស៊ិច គ្រូបង្រៀនជាច្រើននាក់ ត្រូវបានគេផាត់ចេញមិនឱ្យចូលរួមក្នុងកម្មវិធីបែបនេះ ដោយគ្រូដែលបង្រៀនតាមសាលារៀន ដែលសិស្សមានលទ្ធផលសិក្សាទាប ត្រូវចេញប្រៀបគេ។ បទពិសោធន៍ នៅក្នុងប្រទេសប្រេស៊ីល បង្ហាញថា ការផ្តល់ឱ្យសាលារៀននូវប្រាក់រង្វាន់រួមគ្នា អាចជាវិធីសាស្ត្រ ដែលមានប្រសិទ្ធភាព ជាង ក្នុងការលើកកម្ពស់លទ្ធផលនៃការរៀនសូត្រ។

នៅតាមប្រទេសក្រីក្រ ការផ្តល់បៀវត្សទៅតាមលទ្ធផលការងារកម្រ ត្រូវបានគេយកមកសាកល្បងក្នុងទ្រង់ទ្រាយ ធំណាស់ ប៉ុន្តែបទពិសោធន៍បង្ហាញថា ការផ្តល់បៀវត្សបែបនេះមានហានិភ័យ ដោយវាលើកទឹកចិត្តឱ្យគ្រូបង្រៀនសិស្សឱ្យ ត្រូវនឹងតេស្តដែលសិស្សធ្វើ ជាជាងជម្រុញឱ្យសិស្សរៀនសូត្រទូទៅ។ នៅក្នុងការពិសោធន៍មួយ នៅតាមសាលារៀនបឋមសិក្សាក្នុងប្រទេសកេនយ៉ា គ្រូទទួលបានរង្វាន់ ប្រសិនបើសិស្សរបស់ពួកគេទទួលបានពិន្ទុល្អសម្រាប់ការធ្វើតេស្ត និងទទួលការពិន័យ ប្រសិនបើសិស្សមិនចូលរួមក្នុងការប្រឡងចុងឆ្នាំ។ ពិន្ទុតេស្ត និងការចូលរួមក្នុងការប្រឡងមានការកើនឡើង ប៉ុន្តែពិន្ទុតេស្ត មិនបានកើនឡើងសម្រាប់មុខវិជ្ជា ដែលមិនត្រូវបានគេរាប់ចូលទៅក្នុងរូបមន្តសម្រាប់គណនាបៀវត្សរបស់គ្រូឡើយ។

**នៅសាធារណរដ្ឋកូរ៉េ គ្រូដែលមានបទពិសោធន៍ អាចទទួលបានបៀវត្សច្រើនជាងគ្រូថ្មី ២ ដង**

វិធីសាស្ត្រសមស្របជាងនេះ សម្រាប់ធ្វើការលើកទឹកចិត្តគ្រូ គឺត្រូវផ្តល់នូវមាគ៌ាអាជីពដែលមានភាពទាក់ទាញដល់ ពួកគេ។ នៅតាមប្រទេស OECD មួយចំនួន ភាពខុសប្លែកគ្នានៃបៀវត្សរវាងគ្រូដែលមានបទពិសោធន៍ និងគ្រូថ្មីមានកម្រិតតិចតួច ហើយឱកាសឡើងឋានៈមានតិចតួចបំផុត។ ឧទាហរណ៍ នៅក្នុងប្រទេសអង់គ្លេស គ្រូចាប់ផ្តើមដំបូងទទួល បានបៀវត្ស ៣២០០០ ដុល្លារ ខណៈពេលដែលគ្រូដែលមានបទពិសោធន៍បំផុត អាចទទួលបានច្រើនបំផុត ១៥០០០ ច្រើនជាងនេះ។ ផ្ទុយទៅវិញសាធារណរដ្ឋកូរ៉េមានរចនាសម្ព័ន្ធបៀវត្ស ខុសគ្នាពីនេះ ៖ គ្រូថ្មីម្នាក់ទទួលបានបៀវត្សប្រហាក់ ប្រហែលគ្នានឹងគ្រូថ្មី នៅអង់គ្លេសដែរ ប៉ុន្តែគ្រូដែលមានបទពិសោធន៍ អាចទទួលបានបៀវត្សច្រើនជាងនេះ ២ ដង។ នៅក្នុងប្រទេសបារាំង ការគ្រប់គ្រងអាជីពមិនគ្រប់គ្រាន់ និងគោលនយោបាយគ្រូមិនគ្រប់ជ្រុងជ្រោយផ្សេងទៀត រួមចំណែកធ្វើឲការរៀនសូត្ររបស់សិស្សមានកម្រិតខ្សោយ។

នៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍជាច្រើន រចនាសម្ព័ន្ធអាជីពរបស់គ្រូ ពុំមានទំនាក់ទំនងឱ្យបានគ្រប់គ្រាន់ជាមួយ នឹងលទ្ធភាពដំឡើងឋានៈ ដែលទទួលស្គាល់ និងផ្តល់រង្វាន់ដល់គ្រូ ដែលធ្វើការងារប្រកបដោយប្រសិទ្ធភាពឡើយ។ នៅក្នុង ឆ្នាំ ២០១០ ប្រទេសហ្គាណាបានចាប់ផ្តើមធ្វើការពិនិត្យឡើងវិញលើគោលនយោបាយគ្រប់គ្រង និងអភិវឌ្ឍន៍គ្រូរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាទាំងនេះ។

## ពង្រឹងការគ្រប់គ្រងគ្រូ

ការគ្រប់គ្រងគ្រូឱ្យបានល្អប្រសើរជាងមុន មានសារៈសំខាន់សម្រាប់ធ្វើការកាត់បន្ថយការលំបាក នៅក្នុងការរៀនសូត្រ។ ឧទាហរណ៍ ប្រសិនបើចំនួន ថ្ងៃដែលបាត់បង់ ដោយសារគ្រូអវត្តមាន ឬផ្តោតការយកចិត្តទុកដាក់ខ្លាំងជាងលើការបង្រៀនគួរឯកជន ជាជាងលើការបង្រៀនក្នុងថ្នាក់រៀន ការរៀនសូត្ររបស់កុមារមកពីគ្រួសារដែលមានជីវភាពក្រីក្រ ជាងគេ អាចទទួលរងផលប៉ះពាល់។ ការស្វែងយល់ពីមូលហេតុនៅពីក្រោយបញ្ហាទាំងនេះ មានសារៈសំខាន់ សម្រាប់រៀបចំយុទ្ធសាស្ត្រ ដែលមានប្រសិទ្ធភាព ដើម្បីដោះស្រាយបញ្ហាទាំងនេះ។ ចាំបាច់ ត្រូវតែមានការដឹកនាំឱ្យបានរឹងមាំតាមសាលារៀន ដើម្បីធានាយ៉ាងណាឱ្យគ្រូ បង្ហាញមុខធ្វើការងារទាន់ពេលវេលាធ្វើការងារពេញមួយសប្តាហ៍ និងផ្តល់ការគាំទ្រ ស្មើភាពគ្នាដល់គ្រប់សិស្សទាំងអស់។ អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ដែល ពេលខ្លះបង្កឡើងដោយគ្រូ ធ្វើឱ្យប៉ះពាល់ដល់ឱកាសរៀនសូត្ររបស់ក្មេងស្រី។ យុទ្ធសាស្ត្រ ដើម្បីបង្ការ និងឆ្លើយតបចំពោះការប្រព្រឹត្តផ្តាំឆ្គងរបស់គ្រូ និងការចាត់វិធានការប្រឆាំងនឹងជនប្រព្រឹត្តល្មើស តម្រូវឱ្យមានការតស៊ូមតិ និងការគាំទ្រពី នាយកសាលា គ្រូ និងសមាគមគ្រូ ក៏ដូចជា សហគមន៍ ប្រសិនបើចង់ឱ្យក្មេងស្រី ទទួលបានការការពារ។

កម្រិតអវត្តមានរបស់គ្រូ ត្រូវបានបង្ហាញនៅក្នុងការអង្កេតនានា ដែលធ្វើឡើងនៅតាមបណ្តាប្រទេសក្រីក្រជាច្រើន នៅក្នុងទសវត្សរ៍ចុងក្រោយនេះ ៖ នៅពាក់កណ្តាលទសវត្សរ៍ ២០០០ អវត្តមានរបស់គ្រូមានចាប់ពី ១១% នៅក្នុង ប្រទេសពេរូ ដល់ ២៧% នៅក្នុងប្រទេសអ៊ូហ្គាន់ដា។ បញ្ហាអវត្តមានធ្វើឱ្យបញ្ហាកង្វះចំនួនគ្រូកាន់តែធ្ងន់ធ្ងរឡើង។ នៅ ក្នុងប្រទេសកេនយ៉ា ដែលសាលាបឋម សិក្សាជម្មតាមានការខ្វះគ្រូជាមធ្យម ៤ នាក់ គ្រូបង្រៀនចំនួន ១៣% អវត្តមាន នៅ ក្នុងពេលដែលក្រុមការងារស្រាវជ្រាវចុះទៅតាមសាលារៀន។ បញ្ហាអវត្តមាន ក៏អាចមានផលប៉ះពាល់ដល់សិស្សជួបប្រទះ ការលំបាកជាពិសេសផងដែរ។ នៅ ក្នុងប្រទេសឥណ្ឌាទាំងមូល បញ្ហាអវត្តមានមានចាប់ពី ១៥% នៅក្នុងរដ្ឋ Maharashtra និង ១៧% នៅក្នុងរដ្ឋ Gujarat ជារដ្ឋមានជាងគេ រហូតដល់ ៣៨% នៅក្នុងរដ្ឋ Bihar និង ៤២% នៅក្នុងរដ្ឋ Jharkhand ដែលជារដ្ឋ ២ ក្នុង ចំណោមរដ្ឋក្រីក្រជាងគេ។

អវត្តមានរបស់គ្រូ ធ្វើឱ្យប៉ះពាល់ដល់ការរៀនសូត្រ។ នៅក្នុងប្រទេសឥណ្ឌូនេស៊ី ការកើនឡើងនូវអវត្តមានរបស់គ្រូ ១០% ត្រូវបានគេប៉ាន់ស្មានថា នាំឱ្យមានការថយចុះពិន្ទុគណិតវិទ្យារបស់សិស្ស ៧% គិតជាមធ្យម ហើយអវត្តមានរបស់គ្រូ ទំនងជាមានផលប៉ះពាល់លើសិស្សដែល រៀនខ្សោយជាងគេ ៖ អត្រាអវត្តមានរបស់គ្រូមាន ១៩% សម្រាប់បញ្ចូភាគសិស្ស ដែលមានពិន្ទុគណិតវិទ្យាខ្ពស់ជាងគេ និង ២២% សម្រាប់បញ្ចូភាគ ដែលមានពិន្ទុទាបជាងគេ។

ពេលខ្លះ នាយកសាលាខ្លួនឯងក៏អវត្តមានផងដែរ ដែលធ្វើឱ្យប៉ះពាល់ដល់ការពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាពលើវត្តមានរបស់គ្រូ និងជាការបង្ហាញពីភាពជាអ្នកដឹកនាំមិនគ្រប់គ្រាន់ ពាក់ព័ន្ធជាមួយនឹងបញ្ហានេះ។ ការអង្កេតឆ្នាំ ២០១១ លើសាលារៀននានា នៅក្នុងប្រទេសអ៊ូហ្គាន់ដា បានរកឃើញថា ជាមធ្យមមាននាយកសាលា ២១% ដែលអវត្តមាន នៅថ្ងៃដែលក្រុមការងារចុះទៅតាមសាលារៀនរបស់ពួកគេ។

អ្នកតាក់តែងគោលនយោបាយ ចាំបាច់ត្រូវតែស្វែងយល់ពីមូលហេតុ ដែលគ្រូអវត្តមានពីសាលារៀន។ នៅតាម ប្រទេសមួយចំនួន គ្រូអវត្តមាន ដោយសារតែបៀវត្សរបស់ពួកគេទាបពេក និងនៅតាមប្រទេសផ្សេងទៀត គឺដោយសារតែ លក្ខខណ្ឌការងារមានកម្រិតទាប។ នៅក្នុងប្រទេស ម៉ាឡាវី ដែលបៀវត្សរបស់គ្រូមានកម្រិតទាប ហើយការបើកបៀវត្សទៀតសោតធ្វើឡើងមិនទៀងទាត់ គ្រូ ១ នាក់ ក្នុងចំណោម ១០ នាក់លើក ឡើងថា ពួកគេឧស្សាហ៍អវត្តមានពីសាលារៀន ដោយសារតែបញ្ហា ហិរញ្ញវត្ថុ ដូចជា ត្រូវធ្វើដំណើរទៅបើកប្រាក់ខែ ឬត្រូវដោះស្រាយបំណុល ជាដើម។ អត្រាមេរោគ/ជំងឺ អេដស៍ខ្ពស់ អាចមានផលប៉ះពាល់មកលើវត្ត មានរបស់គ្រូផងដែរ។ ប្រទេសហ្សាំបៀ បានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់គ្រូ ដែលផ្ទុកមេរោគអេដស៍ ដូចជា ផ្តល់ការព្យាបាល ផ្តល់អាហារូបត្ថម្ភបន្ថែម និង ផ្តល់កម្ចីជាដើម។

អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ នៅតាមសាលារៀន គឺជាឧបសគ្គចម្បង មួយចំពោះគុណភាព និងសមភាព នៅក្នុង ការអប់រំ។ ការអង្កេតមួយ ដែលធ្វើឡើងនៅក្នុងប្រទេសម៉ាឡាវី បានរកឃើញថា មានគ្រូប្រហែលជា ១ ភាគ ៥ បាន និយាយថា ពួកគេដឹងថាមានគ្រូដែលបង្ខិតបង្ខំសិស្ស ស្រីឱ្យមានទំនាក់ទំនងផ្លូវភេទជាមួយពួកគេ។

កម្មវិធី និងគោលនយោបាយនានា ដែលផ្តោតការយកចិត្តទុកដាក់លើការរើសអើងយេនឌ័រ និងអំពើហិង្សាពាក់ព័ន្ធ នឹងយេនឌ័រ ចាំបាច់ត្រូវតែផ្តល់ការការពារ និងភាពអង់អាចដល់ក្មេងស្រី ជំទាស់នឹងការអនុវត្តផ្តាំផ្គងដែលត្រូវបានគេ ការពារ នាំយកជនប្រព្រឹត្តល្មើសឱ្យអ្នកផងបានដឹង និងចាត់វិធានការលើពួកគេ។ ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ដែលផ្តល់ការការពារជាទូទៅដល់កុមារ ចាំបាច់ត្រូវតែពង្រឹង និងផ្សព្វផ្សាយជាសាធារណៈ ហើយគ្រូចាំបាច់ត្រូវដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេ។ ឧទាហរណ៍ នៅក្នុងប្រទេសកេនយ៉ា មានការដាក់ទោសទណ្ឌជាច្រើន ដើម្បីដាក់ពិន័យ ដល់គ្រូដែលប្រព្រឹត្តបំពានក្រមសីលធម៌វិជ្ជាជីវៈ ដូចជា ព្យួរការងារ និងដកសិទ្ធិមិនឱ្យ បង្រៀន ជាដើម។ បទបញ្ញាថ្មីៗ ចែងថា គ្រូម្នាក់ ដែល ជាប់ចោទពីបទល្មើស ផ្លូវភេទលើកុមារ នឹងត្រូវដកឈ្មោះចេញពីបញ្ជីគ្រូប ង្រៀន។

ការតស៊ូមតិ និងការបញ្ចុះបញ្ចូល គឺជាជំហានសំខាន់ទី ១ ដើម្បីឱ្យមានការរៀបចំ និងអនុវត្តគោលនយោបាយ ដែលដោះស្រាយបញ្ហា អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ។ នៅក្នុងប្រទេសម៉ាឡាវី គម្រោងមួយ ទទួលបានជោគជ័យក្នុងការបញ្ចុះបញ្ចូលឱ្យមានការកែសម្រួលក្រមសីលធម៌ និងពង្រឹងយន្តការរាយការណ៍ឱ្យបានកាន់តែប្រសើរជាងមុន។ នៅពេលដែលគម្រោងនេះរៀបចំជាយុទ្ធនាការបង្កើនការយល់ដឹង ចំនួនគ្រូ ដែលនិយាយថា ពួកគេដឹងពីរបៀបរាយការណ៍អំពី ការបំពានក្រមសីលធម៌ មានការកើនឡើងជាង ១ ភាគ ៣។

ការធ្វើការងារដោយផ្ទាល់ជាមួយនឹងសមាគមគ្រូបង្រៀន គឺជាវិធីមួយដើម្បីប្រមូលការគាំទ្រដល់ការចាត់ វិធានការចំពោះគ្រូ ដែលបំពានក្រមសីលធម៌។ នៅក្នុងប្រទេសកេនយ៉ា សមាគមគ្រូបង្រៀនថ្នាក់ជាតិ បានសហការជាមួយនឹងគណៈកម្មការសេវាគ្រូបង្រៀន ក្រសួងអប់រំ និងនាយកដ្ឋានកុមារ ដើម្បីជួយរៀបចំសេចក្តីព្រាងច្បាប់មួយ ដែលនឹង ពង្រឹងការអនុវត្តវិធានការ សម្រាប់រាយការណ៍ពីការរំលោភបំពាន ឬអំពើហិង្សា ដែលប្រព្រឹត្តដោយគ្រូ និងទប់ស្កាត់មិនឱ្យមានការផ្ទេរគ្រូដែលជាប់ចោទ ទៅសាលារៀនដទៃទៀត។

ការបង្រៀនគួរ គឺជាលទ្ធផលមួយទៀតនៃការគ្រប់គ្រងគ្រូមិនបានល្អ។ ប្រសិនបើមិនមានការពិនិត្យ ឬត្រួតពិនិត្យទេនោះ វាអាចមានផលប៉ះពាល់លើលទ្ធផលនៃការរៀនសូត្រ ជាពិសេស សម្រាប់សិស្សក្រីក្រ ដែលមិនអាចបង់ថ្លៃសម្រាប់ការរៀនគួរបាន។ ការបង្រៀនគួរបស់គ្រូ ជារឿយៗ គឺជាសញ្ញា ដែលបង្ហាញ ពីដំណើរការមិនល្អរបស់ប្រព័ន្ធសាលារៀន និងបៀវត្សទាប ដែលបង្ខំឱ្យគ្រូត្រូវរកប្រាក់ ដើម្បីបន្ថែមពីលើចំណូលរបស់ពួកគេ។ នៅក្នុងប្រទេសកម្ពុជា បៀវត្សរបស់គ្រូ មានចំនួនតិចតួច ហើយជារឿយៗ បើកយឺតយ៉ាវ។ ផលវិបាកមួយ គឺថា គ្រូបឋមសិក្សា ១៣% និងគ្រូមធ្យមសិក្សា ៨៧% ត្រូវបង្រៀនគួរ។ នេះធ្វើឱ្យគម្លាតរវាងអ្នកដែលមានលទ្ធភាពបង់ថ្លៃរៀនគួរ និងអ្នកដែលមិនមានលទ្ធភាពបង់ថ្លៃរីកកាន់តែធំ។ នៅតំបន់ប្រជុំជន សិស្សរៀនថ្នាក់ទី ៩ ដែលរៀនគួរ ទទួលបានពិន្ទុ ៨,៣ លើ ១០ សម្រាប់មុខវិជ្ជាភាសាខ្មែរ បើធៀបជាមួយនឹងពិន្ទុ ៣,៨ សម្រាប់អ្នកដែលមិនបានរៀន។

នៅក្នុងប្រទេសអេហ្ស៊ីព ស្ថានភាពកាន់តែមានកម្រិតធ្ងន់ធ្ងរមួយផ្នែកដោយសារតែមានការថយចុះនូវគុណភាពនៃ ការអប់រំ និងមួយផ្នែកទៀតដោយសារតែគ្រូត្រូវការប្រាក់បន្ថែមពីលើចំណូលដ៏ទាបរបស់ពួកគេ។ ថវិកាដែលចំណាយ ប្រចាំឆ្នាំលើការរៀនគួរ ត្រូវបានគេរាយការណ៍ថាមានចំនួន ២,៤ ពាន់លានដុល្លារ ស្មើនឹង ២៧% នៃការចំណាយរបស់រដ្ឋាភិបាលលើការអប់រំ នៅក្នុងឆ្នាំ ២០១១។ ការរៀនគួរ គឺជាផ្នែកដ៏ធំមួយនៃការចំណាយលើការអប់រំរបស់គ្រួសារ គិតជា មធ្យម ៤៧% សម្រាប់គ្រួសារនៅជនបទ និង ៤០% សម្រាប់គ្រួសារនៅតំបន់ប្រជុំជន។ កុមារមកពីគ្រួសារធូរធា ច្រើន ចូលរៀនគួរជាងកុមារក្រីក្រជិត ២ ដង។ គ្រូអាចជាគ្រូដែលបង្រៀនគួរឱ្យសិស្សខ្លួនឯង ដូច្នេះ គឺជាអ្នកទទួលខុសត្រូវលើការដាក់ពិន្ទុសិស្សរបស់ខ្លួន។ សិស្សតវ៉ាថា គ្រូមិនបានរៀនតាមកម្មវិធីសិក្សាឡើយ នៅពេលបង្រៀនធម្មតា ដែលត្រូវបង្ខំឱ្យពួកគេទៅរៀនគួរ ដើម្បីរៀនតាមកម្មវិធី ទើបអាចប្រឡងជាប់។

**នៅក្នុងប្រទេសអេហ្ស៊ីប សិស្សដែលមានជីវភាពធូរធាច្រើនទទួលបានការបង្រៀនគួរច្រើនជាងសិស្សក្រីក្រជិត ២ ដង**

យ៉ាងហោចណាស់ គួរតែមានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រនានា ដើម្បីបង្ការមិនឱ្យគ្រូដែលទទួលខុសត្រូវបង្រៀន សិស្សប្រចាំថ្ងៃ ឱ្យបង្រៀនគួរដល់ពួកគេ។ ការធ្វើបែបនេះនឹងធានាថា សិស្សទាំងអស់នឹងអាចរៀនចប់កម្មវិធីសិក្សាពេញលេញ សូម្បីតែសិស្សដែលមិនអាចមានលទ្ធភាពបង់ថ្លៃរៀនគួរបាន។

**នៅក្នុងប្រទេសប៉ាគីស្ថាន សិស្សរៀនថ្នាក់ទី ៥ នៅសាលាឯកជន ៣៦% មិនចេះអានប្រយោគជាភាសាអង់គ្លេស សូម្បីតែមួយប្រយោគ**

សាលាឯកជន ដែលយកថ្លៃទាប ត្រូវហានមនុស្សមួយចំនួនយល់ថាជាវិធីសាស្ត្រ សម្រាប់ពង្រីកលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាពល្អជាងមុន សម្រាប់កុមារជួបប្រទះការលំបាក ដែលសាលារដ្ឋខកខានមិនបានផ្តល់សេវាដល់ពួកគេ។ នៅក្នុងប្រទេសប៉ាគីស្ថាន កុមារ ដែលរៀននៅតាមសាលាឯកជន ដែលយកថ្លៃទាប រៀនហានពូកែជាងកុមារជម្មតា នៅក្នុងចំណោមកុមារ ១ ភាគ ៣ ដែលរៀនពូកែជាងគេ នៅតាមសាលារដ្ឋ។ ប៉ុន្តែ សូម្បីតែនៅតាមសាលាឯកជនក៏ដោយ សិស្សជាច្រើននាក់ កម្រនឹងរៀនបានដល់កម្រិតសមត្ថភាពរំពឹងទុកណាស់។ បើតាមការវិភាគ ដែលធ្វើឡើងដោយក្រុមតាក់តែងរបាយការណ៍ប្រចាំឆ្នាំស្តីពីស្ថានភាពនៃការអប់រំ នៅក្នុងប្រទេសប៉ាគីស្ថាន សិស្សថ្នាក់ទី ៥ ដែលនៅសាលាឯកជន ៣៦% មិនអាចអានប្រយោគជាភាសាអង់គ្លេសជាច់សូម្បីតែមួយប្រយោគ ដែលពួកគេគួរតែចេះតាំងពីថ្នាក់ទី ២ មកម្ល៉េះ។

លទ្ធផលនៃ ការរៀនសូត្រ អាចកាន់តែប្រសើរ នៅតាមសាលាឯកជន ដែលយកថ្លៃទាប មួយផ្នែក គឺដោយសារតែ បៀវត្សទាបផ្តល់លទ្ធភាពឱ្យសាលារៀនទាំងនេះ អាចជួលគ្រូកាន់តែច្រើននាក់ និងរក្សាផលធៀបសិស្ស-គ្រូឱ្យនៅទាប។ នៅតាមសាលាឯកជន នៅតំបន់មួយចំនួនក្នុងទីក្រុងណៃរ៉ូប៊ី មានសិស្ស ១៥ នាក់ ក្នុងគ្រូ ១ នាក់ បើធៀបជាមួយនឹងសិស្ស ៨០ នាក់ នៅតាមសាលារដ្ឋ។ ចំនួនសិស្សតិចក្នុងថ្នាក់រៀនបែបនេះ ក៏ផ្តល់លទ្ធភាពឱ្យគ្រូ នៅតាមសាលាឯកជនអាចមាន អន្តរកម្មកាន់តែច្រើនជាមួយនឹងសិស្សរបស់ពួកគេ។ នៅរដ្ឋ Andhra Pradesh ប្រទេសឥណ្ឌា គ្រូ ៨២% ធ្វើការកែ លំហាត់ ដែលដាក់ឱ្យកុមារធ្វើបានទៀងទាត់ បើធៀបជាមួយនឹង ៤០% នៅតាមសាលារដ្ឋ។

ជាទូទៅ គ្រូ ដែលបង្រៀនតាមសាលាឯកជន ត្រូវបានគេគិតថាជាអ្នកបម្រើការងារក្រោមលក្ខខណ្ឌ ដែលនាំឱ្យ ពួកគេមានការទទួលខុសត្រូវកាន់តែច្រើន។ នៅក្នុងប្រទេសឥណ្ឌា មានតែនាយកសាលាម្នាក់ប៉ុណ្ណោះ នៅក្នុងសាលារដ្ឋ ចំនួន ៣០០០ កន្លែង ដែលបានរាយការណ៍ថា បានបញ្ឈប់គ្រូម្នាក់ដែលតែងអវត្តមានជាបន្តបន្ទាប់ ពីការងារ។ ផ្ទុយទៅ វិញ នាយកសាលាឯកជនចំនួន ៣៥ នាក់ ក្នុងចំណោម ៦០០ នាក់ ដែលបានអង្កេត បានរាយការណ៍ថាបានបណ្តេញគ្រូចេញពីការងារ ដោយសារមូលហេតុនេះ។

អត្ថប្រយោជន៍ របស់សាលាឯកជន ដែលយកថ្លៃទាប មិនមានន័យថាសាលារៀនទាំងនោះល្អជាងគេសាលាដទៃ នោះទេ។ ជារឿយៗ សិស្សរបស់ពួកគេជួបប្រទះការលំបាកតិចតួចជាងសិស្ស ដែលរៀនតាមសាលារដ្ឋ។ នៅរដ្ឋ Andhra Pradesh សិស្សដែលរៀននៅសាលារដ្ឋជាង ៧០% មកពីគ្រួសារក្រីក្រជាងគេ ៤០% បើធៀបជាមួយនឹង ២៦% នៅ សាលាឯកជន។ មានគ្រូប្រមាណជា ១ ភាគ ៣ នៅសាលារដ្ឋ កំពុងបង្រៀនសិស្សអាយុខុសៗគ្នា នៅក្នុងថ្នាក់គួប បើធៀប ជាមួយនឹង ៣% នៅសាលាឯកជន។

ពុំមានលេស សម្រាប់សិស្ស ថាមិនមានលក្ខខណ្ឌសមស្របសម្រាប់ការរៀនសូត្រនោះទេ ៖ ចុងក្រោយ ជាការ សំខាន់ ដែលសិស្សទាំងអស់មិនថាពួកគេមានប្រវត្តិបែបណា និងរៀននៅសាលាប្រភេទណានោះទេ ត្រូវមានគ្រូដែលល្អបំផុត ដើម្បីផ្តល់ឱ្យពួកគេនូវឱកាសរៀនសូត្របែបនេះ។

## កម្មវិធីសិក្សា និងយុទ្ធសាស្ត្រវាយតម្លៃ ដែលធ្វើឱ្យការរៀនសូត្រកាន់តែមានភាពល្អប្រសើរឡើង

ដើម្បីធ្វើឱ្យការរៀនសូត្រសម្រាប់កុមារទាំងអស់កាន់តែមានល្អប្រសើរឡើង គ្រូត្រូវការការគាំទ្រជាកម្មវិធីសិក្សា និងយុទ្ធសាស្ត្រវាយតម្លៃ ដែលអាចកាត់បន្ថយគម្លាតនៃលទ្ធផលសិក្សា និងផ្តល់ឱ្យកុមារ និងយុវជនទាំងអស់នូវឱកាស ទទួលបានជំនាញអាចផ្ទេរបាន ដែលមានសារៈសំខាន់។ យុទ្ធសាស្ត្របែបនេះ ចាំបាច់ត្រូវតែកសាងនូវជំនាញមូលដ្ឋានឱ្យបានរឹងមាំ ដោយចាប់ផ្តើមឱ្យបានឆាប់រហ័ស ផ្លាស់ប្តូរក្នុងល្បឿនសមស្រប ផ្តល់លទ្ធភាពឱ្យសិស្សជួបប្រទះការលំបាករៀនទាន់គេ បំពេញតម្រូវការភាសារបស់សហគមន៍ជនជាតិភាគតិច និងកសាងនូវវប្បធម៌អំណានមួយ។

## ធានាយ៉ាងណាឱ្យកុមារគ្រប់រូបទទួលបានជំនាញជាមូលដ្ឋាន

គន្លឹះសំខាន់ ដើម្បីធានាយ៉ាងណាឱ្យកុមារទទួលបានជោគជ័យក្នុងសាលារៀន គឺត្រូវផ្តល់លទ្ធភាពឱ្យពួកគេទទួល បានជំនាញជាមូលដ្ឋានសំខាន់ៗ ដូចជា អំណាន និងគណិតវិទ្យាជាមូលដ្ឋាន។ ប្រសិនបើមិនមានជំនាញជាមូលដ្ឋានទាំងនេះនោះទេ កុមារជាច្រើននឹងមានការលំបាក ដើម្បីតាមឱ្យទាន់កម្មវិធីសិក្សា ដែលបានកំណត់ ហើយគម្លាតនៃការរៀនសូត្រនឹងរីកកាន់តែធំ សម្រាប់កុមារដែលជួបប្រទះការលំបាក។

គុណភាពនៃការ អប់រំកម្រិតមត្តេយ្យសិក្សា ធ្វើឱ្យមានភាពខុសប្លែកគ្នាយ៉ាងសំខាន់ចំពោះការរៀនសូត្ររបស់កុមារនៅថ្នាក់ដំបូងៗនៅបឋមសិក្សា។ នៅក្នុងប្រទេសបង់ក្លាដេស សិស្សបឋមសិក្សា ដែលបានឆ្លងកាត់មត្តេយ្យសិក្សា រៀនពូកែជាងកុមារ ដែលមិនបានឆ្លងកាត់មត្តេយ្យសិក្សាខាងជំនាញពាក់ព័ន្ធជាមួយនឹងអំណាន សំណេរនិងគណិតវិទ្យាផ្ទាល់មាត់។

ជាការសំខាន់ណាស់ ដែលសិស្សរៀននៅសាលាបឋមសិក្សាចេះជំនាញជាមូលដ្ឋានលេខ និងអក្សរ នៅថ្នាក់ដំបូងៗ ដើម្បីឱ្យពួកគេអាចយល់ពីអ្វី ដែលពួកគេរៀននៅថ្នាក់ក្រោយៗ ប៉ុន្តែពេលខ្លះ ពួកគេមិនបានរៀនបែបនេះនោះទេ ដោយសារតែកម្មវិធីសិក្សាមានមហិច្ឆតាធំពេក។ កម្មវិធីសិក្សារបស់ប្រទេសវៀតណាម ផ្តោតលើជំនាញជាមូលដ្ឋាន ផ្សារភ្ជាប់យ៉ាងជិតស្និទជាមួយនឹងអ្វីដែលកុមារអាចរៀនបាន និងផ្តោតការយកចិត្តទុកដាក់ពិសេសលើសិស្ស ដែលជួបប្រទះការលំបាក។ ផ្ទុយទៅវិញ កម្មវិធីសិក្សារបស់ប្រទេសឥណ្ឌា ដែលមានល្បឿនលឿនជាងអ្វីដែលសិស្សអាចរៀនបានជាក់ស្តែង និងសម្រេចបានក្នុងពេលណាមួយនោះ គឺជាកត្តាដែលធ្វើឱ្យគម្លាតនៃការរៀនសូត្ររីកធំជាងមុន។ នៅក្នុងប្រទេស វៀតណាម កុមារអាយុ ៨ ឆ្នាំ ៨៦% ឆ្លើយលំហាត់ក្នុងតេស្តតាមកម្រិតថ្នាក់បានត្រឹមត្រូវ។ ស្រដៀងគ្នានេះដែរ កុមារ អាយុ ៨ ឆ្នាំ នៅប្រទេសឥណ្ឌា ក៏ឆ្លើយត្រូវបែបនេះដែរ។ ប៉ុន្តែនៅ ពេលដែលកុមារអាយុ ១៤-១៥ ឆ្នាំ ត្រូវបានឱ្យ ដោះស្រាយចំណោទ ២ ដំណាក់កាល ដែលត្រូវប្រើប្រាស់ប្រមាណវិធីគុណ និងបូក កុមារ ៧១% នៅក្នុងប្រទេសវៀតណាម ឆ្លើយបានត្រឹមត្រូវខណៈ ពេលដែលប្រទេសឥណ្ឌា មានតែ ៣៣% ប៉ុណ្ណោះ។

ដើម្បីឱ្យកុមារមកពីសហគមន៍ជនជាតិភាគតិច និងនិយាយភាសាភាគតិច អាចទទួលបានជំនាញមូលដ្ឋានឱ្យបាន រឹងមាំ សាលារៀនចាំបាច់ត្រូវបង្រៀនកម្មវិធីសិក្សា ដោយប្រើប្រាស់ភាសា ដែលកុមារអាចយល់បាន។ គោលវិធី ២ ភាសា ដែលដាក់បញ្ចូលការបង្រៀនបន្តដោយប្រើប្រាស់ភាសាកំណើតរបស់កុមារ រួមជាមួយនឹងភាសាទី ២ អាចបង្កើន

លទ្ធផលសិក្សារបស់សិស្សផ្នែកមុខវិជ្ជា ភាសាទី ២ និងមុខវិជ្ជាដទៃទៀត។ ដើម្បីកាត់បន្ថយគម្លាតនៃការរៀនសូត្រនៅក្នុងរយៈពេលវែង កម្មវិធីពីរភាសា គួរមាននិរន្តរភាព នៅក្នុងរយៈពេលជា ច្រើនឆ្នាំ។ នៅក្នុងប្រទេសកាម៉េរូន កុមារដែលត្រូវបានបង្រៀនដោយប្រើប្រាស់ ភាសាក្នុងមូលដ្ឋានរបស់ខ្លួន ដែលមានឈ្មោះថាភាសា Kom សម្រេចបាន លទ្ធផលសិក្សា ផ្នែកអំណាន និងការយល់ច្រើនជាង បើធៀបជាមួយនឹងកុមារដែលត្រូវបានបង្រៀន ដោយប្រើតែភាសាអង់គ្លេស។ កុមារដែលទទួលបានការអប់រំជាភាសា Kom ក៏ទទួលបានពិន្ទុសម្រាប់តេស្តគណិតវិទ្យាខ្ពស់ជាង ២ ដងនៅចុងថ្នាក់ទី ៣ ផងដែរ។ ប៉ុន្តែ ការសម្រេចបានលទ្ធផលនៃការរៀនសូត្រទាំងនេះមិនមាននិរន្តរភាពឡើយ នៅពេលដែលសិស្សប្តូរទៅរៀនតែភាសាអង់គ្លេសនៅថ្នាក់ទី ៤។ ផ្ទុយទៅវិញ នៅក្នុងប្រទេសអេត្យូពីវិញ កុមារ នៅតាមតំបន់នានា ដែលការបង្រៀនដោយប្រើ ប្រាស់ភាសានៅមូលដ្ឋាន ត្រូវបានពង្រីកដល់សាលាមធ្យមសិក្សាទុតិយភូមិ សម្រេចលទ្ធផលបានល្អប្រសើរជាងសម្រាប់មុខវិជ្ជាថ្នាក់ទី ៨ ជាកុមារ ដែលត្រូវបានបង្រៀន ដោយប្រើតែភាសាអង់គ្លេស។

គោលនយោបាយផ្នែកភាសា អាចមានការលំបាក ក្នុងការ អនុវត្តជាពិសេស នៅពេលដែលមានក្រុមនិយាយភាសាលើសពី ១ នៅក្នុងថ្នាក់រៀនតែមួយ ហើយគ្រូពុំចេះភាសាក្នុងមូលដ្ឋានឱ្យបានស្ទាត់ជំនាញ។ ដើម្បីឱ្យការអប់រំពីរភាសាមានប្រសិទ្ធភាព រដ្ឋាភិបាលចាំបាច់ត្រូវធ្វើការជ្រើសរើស និងពង្រាយគ្រូ ដែលមកពីតាមក្រុមនិយាយភាសាជនជាតិភាគតិច។ ចាំបាច់ត្រូវមានកម្មវិធីបណ្តុះបណ្តាលដំបូងៗ និងកម្មវិធីបំប៉នបន្ថែមជាបន្តបន្ទាប់ ដើម្បីបណ្តុះបណ្តាលគ្រូអំពីរបៀបបង្រៀន ដោយប្រើប្រាស់ ២ ភាសា និងដើម្បីយល់ពីតម្រូវការរបស់សិស្ស ដែលប្រើប្រាស់ភាសាទី ២។

ដើម្បីឱ្យថ្នាក់អក្ខរកម្មដំបូង និងការអប់រំពីរភាសាទទួលបានជោគជ័យ សិស្សចាំបាច់ត្រូវទទួលបានសម្ភាររៀនសូត្របញ្ចូលគ្នា ដែលមានភាពពាក់ព័ន្ធទៅនឹងស្ថានភាពរបស់ពួកគេ និងដែលប្រើប្រាស់ភាសា ដែលពួកគេងាយស្រួលយល់។ អាជ្ញាប័ណ្ណបើកចំហ និងបច្ចេកវិទ្យាថ្មីៗ អាចធ្វើឱ្យសម្ភាររៀនសូត្រកាន់តែងាយស្រួលរកបាន។ នៅអាហ្វ្រិចខាងត្បូង សម្ភាររៀនសូត្រដោយប្រើប្រាស់ប្រភពបើកចំហ កំពុងត្រូវបានរៀបចំឡើង និងដាក់ឱ្យមានជាភាសាអាហ្វ្រិចជាច្រើន។ ការចែកចាយតាមប្រព័ន្ធឌីជីថល កំពុងបង្កើនចំនួនស្រុកសាលារៀន និងគ្រូ ដែលមានលទ្ធភាពទទួលបានធនធានក្នុងកម្មវិធីសិក្សា។

ប៉ុន្តែ ការផ្តល់ឯកសារអំណានដែលសមស្រប អាចមិនទាន់គ្រប់គ្រាន់នោះទេ ដើម្បីធ្វើឱ្យការរៀនសូត្ររបស់កុមារ កាន់តែមានភាពល្អប្រសើរឡើងនោះ។ កុមារ និងគ្រួសារ ក៏ត្រូវទទួលបានការលើកទឹកចិត្តឱ្យប្រើប្រាស់ឯកសារទាំងនោះផងដែរ។ នៅតាមសហគមន៍ក្រីក្រ និងដាច់ស្រយាល ដែលប្រជាពលរដ្ឋមានលទ្ធភាពតិចតួច ក្នុងការទទួលបានសារព័ត៌មាន បោះពុម្ពការផ្តល់ឯកសារអាន និងការគាំទ្រដល់សកម្មភាព ដើម្បីឱ្យសិស្សអាចហ្វឹកហាត់ការអានអាចធ្វើឱ្យការរៀនសូត្រ របស់សិស្សកាន់តែមានភាពប្រសើរឡើង។ កម្មវិធីជម្រុញអក្ខរកម្មរបស់អង្គការសង្គ្រោះកុមារ មានគោលបំណងលើកកម្ពស់បំណិនអំណាននៅថ្នាក់ដំបូងៗ នៅតាមសាលារដ្ឋ តាមរយៈអន្តរាគមន៍នានា ដូចជា ការបណ្តុះបណ្តាលគ្រូឱ្យចេះ បង្រៀនបំណិនអំណានសំខាន់ៗ និងពិនិត្យតាមដានភាពស្ទាត់ជំនាញរបស់សិស្សក្នុងបំណិនទាំងនោះ។ លើសពីនេះ សហគមន៍ត្រូវបានលើកទឹកចិត្តឱ្យផ្តល់ការគាំទ្រដល់អំណានរបស់កុមារ។

ការវាយតម្លៃ នៅក្នុងប្រទេសម៉ាឡាវី មូហ្សំប៊ិច នេប៉ាល់ និងប៉ាគីស្ថាន សុទ្ធតែបានបង្ហាញពីការទទួលបានការរៀនសូត្រកាន់តែច្រើនជាងមុនរបស់សិស្ស ដែលរៀននៅតាមសាលារៀន ដែលចូលរួមក្នុង កម្មវិធីជម្រុញអក្ខរកម្ម បើធៀបជាមួយនឹងកុមារផ្សេងទៀត ដូចជា ការកាត់បន្ថយចំនួន កុមារដែលទទួលបានពិន្ទុសូន្យជាដើម ដែលនេះបង្ហាញថា កម្មវិធីនេះបានផ្តល់ប្រយោជន៍ដល់សិស្សរៀនខ្សោយផងដែរ។ នផងដែរ។

ការគាំទ្រក្រៅម៉ោសិក្សា គឺជាមូលហេតុមួយ ដែលនាំឱ្យមានជោគជ័យបែបនេះ។ នៅក្នុងប្រទេសប៉ាគីស្ថាន កុមារ ដែលបានចូលរួមក្នុងជំរុំអានក្រោយសាលារៀន ដែលសម្របសម្រួលដោយអ្នកស្ម័គ្រចិត្តក្នុងសហគមន៍ បានបង្ហាញពីការរីកចម្រើនផ្នែកភាពស្ទាត់ជំនាញ និងសុក្រឹតភាពផ្នែកអំណាន ទាំងក្នុងភាសា Pashito និងភាសា Urdu បើធៀបជាមួយនឹងមិត្តរួមថ្នាក់របស់ពួកគេ នៅក្នុងសាលារៀនតែមួយ។ នៅក្នុងប្រទេសម៉ាឡាវី សិស្ស ដែលមាតាបិតាបានទទួលការបណ្តុះបណ្តាល ដើម្បីគាំទ្រដល់អំណានរបស់កូនខ្លួនឯង រៀនចេះវាក្យស័ព្ទជាងសិស្ស ដែលមាតាបិតាមិនបានទទួលការគាំទ្របែបនេះ។និងពិន្ទុតេស្តខ្ពស់ជាងមុនផងដែរ។

**ប្រទេសហ្វីលីពីនបានដាក់បញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ នៅក្នុងការអប់រំ**

កម្មវិធីសិក្សា ចាំបាច់ត្រូវតែដោះស្រាយបញ្ហាពាក់ព័ន្ធជាមួយនឹងការអប់រំបញ្ចូលគ្នា ដើម្បីលើកកម្ពស់ឱកាសឱ្យ សិស្សដែលមានប្រវត្តិជួបប្រទះការលំបាក អាចធ្វើការរៀនសូត្រប្រកបដោយប្រសិទ្ធភាព។ នៅតាមកន្លែង ដែលកម្មវិធី សិក្សាឆ្លើយតបនឹងយេនឌ័រ ត្រូវបានរៀបចំឡើង ដូចជានៅតាមគម្រោងនៅក្នុងទីក្រុងម៉ុមបៃ ប្រទេសឥណ្ឌា និងនៅក្នុង ប្រទេសហុងឌុយរ៉ាស់ ជាដើម ពិន្ទុតេស្តសម្រាប់វាស់វែងឥរិយាបថពាក់ព័ន្ធនឹងបញ្ហាយេនឌ័រជាច្រើនមានការកើនឡើង។ នៅក្នុងប្រទេសហុងឌុយរ៉ាស់ ក្មេងជំទង់ ដែលបានចូលរួមនៅក្នុងគម្រោងនេះ ក៏បានបង្ហាញពីជំនាញដោះស្រាយបញ្ហា ប្រសើរជាងមុន និងពិន្ទុតេស្តខ្ពស់ជាងមុនផងដែរ។

មានការងារបន្ថែមទៀត ដែលចាំបាច់ត្រូវធ្វើឡើង ដើម្បីរៀបចំកម្មវិធីសិក្សា ដែលផ្តោតការយកចិត្តទុកដាក់លើ តម្រូវការរបស់សិស្សពិការ។ នៅទីក្រុងកង់បេរ៉ា ប្រទេសអូស្ត្រាលី កំណែទម្រង់កម្មវិធីសិក្សាមានគោលបំណងកែលំអ ឥរិយាបថរបស់សិស្ស ចំពោះសិស្សពិការ បង្កើនគុណភាពនៃអន្តរកម្មរវាងសិស្សពិការ និងសិស្សមិនពិការ និងលើកកម្ពស់ សុខុមាលភាពនិងលទ្ធផលសិក្សារបស់សិស្សពិការ។

ឧបករណ៍ សម្រាប់ធ្វើការវាយតម្លៃតាមថ្នាក់រៀន បានជួយឱ្យគ្រូចេះកំណត់ ពិនិត្យតាមដាន និងផ្តល់ការគាំទ្រដល់ សិស្ស ដែលរៀនខ្សោយ។ នៅក្នុងប្រទេសលីបេរី គម្រោង EGRA Plus ដែលបានផ្តល់ការបណ្តុះបណ្តាលដល់គ្រូអំពីការ ប្រើប្រាស់ឧបករណ៍វាយតម្លៃតាមថ្នាក់រៀន និងផ្តល់ធនធានអំណាន និងកិច្ចតែងការបង្រៀន សម្រាប់តំរាយផ្លូវដល់ការបង្រៀន បានបង្កើនលទ្ធផលផ្នែកអំណាន ដែលធ្លាប់តែមានកម្រិតទាបកន្លងមករបស់សិស្សថ្នាក់ទី ២ និងទី ៣។

ការវាយតម្លៃ ចាំបាច់ត្រូវតែតម្រឹមឱ្យស្របតាមកម្មវិធីសិក្សា ដើម្បីឱ្យការវាយតម្លៃទាំងនេះមិនបន្ថែមបន្ទុក ការងារច្រើនដល់គ្រូឡើយ។ នៅអាហ្វ្រិចខាងត្បូង ការវាយតម្លៃដែលត្រូវបានរៀបចំបានល្អ ដោយមានការណែនាំច្បាស់ លាស់អំពីរបៀបបកស្រាយលទ្ធផល បានជួយគ្រូ ដែលទទួលបានការបណ្តុះបណ្តាលតិចតួច និងដែលធ្វើការងារក្រោមស្ថានភាពពិបាក ៖ គ្រូ ៨០% អាចប្រើប្រាស់ការវាយតម្លៃទាំងនេះ នៅតាមថ្នាក់របស់ពួកគេ។

សិស្សអាចសម្រេចលទ្ធផលប្រសើរជាងមុនច្រើន ប្រសិនបើពួកគេមានឱកាសពិនិត្យតាមដានការរៀនសូត្រផ្ទាល់ ខ្លួនរបស់ពួកគេ។ នៅរដ្ឋ Tamil Nadu ប្រទេសឥណ្ឌា សិស្សបឋមសិក្សារៀនដោយខ្លួនឯងដោយប្រើប្រាស់ប័ណ្ណស្វ័យវាយតម្លៃ ដែលអាចប្រើប្រាស់តែឯង ឬដោយមាន ជំនួយពីកុមារម្នាក់ទៀត។ គ្រូរៀបចំបង្កើតដៃគូក្នុងលក្ខណៈជាយុទ្ធសាស្ត្រ ដោយឱ្យកុមារដែលរៀនពូកែ ចាប់គូជាមួយនឹងសិស្សដែលរៀនមិនសូវពូកែ សម្រាប់លំហាត់មួយចំនួន។ ជារួម ស្វ័យទំនុកចិត្តរបស់កុមារមានការកើនឡើង ក្រោយពេលប្រើប្រាស់គោលវិធីនេះ ហើយលទ្ធផលសិក្សារបស់សិស្សនៅក្នុងរដ្ឋនេះមានកម្រិតខ្ពស់។

**នៅក្នុងប្រទេសឥណ្ឌា សាលារៀនដែលមានអ្នកស្ម័គ្រចិត្តទទួលបានការបណ្តុះបណ្តាលជាស្ត្រីបានជួយលើកកម្ពស់ ការរៀនសូត្ររបស់កុមារ**

ការផ្តល់ការគាំទ្របន្ថែម ដោយផ្តោតគោលដៅលើសិស្សតាមរយៈជំនួយការបង្រៀនដែលបានឆ្លងកាត់ការបណ្តុះ បណ្តាល គឺជាមធ្យោបាយមួយទៀត ដើម្បីលើកកម្ពស់ការរៀនសូត្ររបស់សិស្ស ដែលរៀនមិនទាន់គេ។ អន្តរាគមន៍អំណាន នៅថ្នាក់ដំបូងៗ ដែលផ្តល់ដោយជំនួយការបង្រៀននៅតាមសាលារៀនក្នុងទីក្រុងឡុង នៅចក្រភពអង់គ្លេស ត្រូវបានគេរក ឃើញថាបានបង្កើនបំណិនអំណាន និងមានផលវិជ្ជមានរយៈពេលវែង សម្រាប់កុមារដែលខ្សោយខាងបំណិនអក្សរ។ នៅក្នុងប្រទេសឥណ្ឌា សាលារៀន ដែលមានអ្នកស្ម័គ្រចិត្តទទួលបានការបណ្តុះបណ្តាលជាស្ត្រី បានជួយបង្កើនភាគរយកុមារ ដែល អាចធ្វើប្រមាណវិធីលេខ ២ ខ្ទង់។ ខណៈពេលដែលមានសិស្សត្រឹមតែ ៥% ប៉ុណ្ណោះ ដែលអាចធ្វើប្រមាណវិធីដកងាយៗ នៅពេលចាប់ផ្តើមសិក្សា ៥២% អាចធ្វើប្រមាណវិធីនេះ នៅមុនចុងឆ្នាំ បើធៀបជាមួយនឹង ៣៩% នៅថ្នាក់ផ្សេងទៀត។

ការបង្រៀនតាមវិទ្យុ បែបអន្តរកម្ម អាចជួយបង្កើនលទ្ធផលនៃការរៀនសូត្រ សម្រាប់ក្រុមដែលជួបប្រទះការលំបាកតាមរយៈការដោះ ស្រាយឧបសគ្គនានា ដូចជា ចម្ងាយ និងការទទួលបានធនធាន និងគ្រូដែលមានគុណភាពក្នុងចំនួនតិចតួច ដូចដែលបានរកឃើញ នៅក្នុងការពិនិត្យឡើងវិញលើគម្រោងចំនួន ១៥។ ការប្រើប្រាស់វិទ្យុបែបអន្តរកម្ម អាចមានប្រយោជន៍ជាពិសេស នៅក្នុងបរិបទនៃការមានជម្លោះ។ ចន្លោះពីឆ្នាំ ២០០៦ ដល់ ២០១១ គម្រោងបង្រៀនបែប អន្តរកម្មតាមវិទ្យុ ក្នុងប្រទេសស៊ូដង់ភាគខាងត្បូង បានចុះឈ្មោះសិស្សបានជាង ៤៧៣០០០ នាក់ ដោយបានផ្តល់នូវមេរៀន រយៈពេលកន្លះម៉ោង ភ្ជាប់ជាមួយនឹងកម្មវិធីសិក្សារបស់ជាតិ និងមានដាក់បញ្ចូលការបង្រៀនជាភាសាអង់គ្លេស ការរៀន ភាសាក្នុងមូលដ្ឋាន គណិតវិទ្យា និងបំណិនជីវិត ដូចជា មេរោគ/ជំងឺអេដស៍ និងការយល់ដឹងពីហានិភ័យគ្រាប់មីនជាដើម។ នៅតាមទីតាំង ដែលមិនអាចចាប់សញ្ញាវិទ្យុបាន គម្រោងនេះបានចែកម៉ាស៊ីនចាក់ MP3 ដើម្បីឱ្យគ្រូដែលបានឆ្លងកាត់ការបណ្តុះបណ្តាលប្រើប្រាស់។

ថ្នាក់រៀនបែបឌីជីថល អាចបំពេញបន្ថែមថ្នាក់រៀនធម្មតា ដែលបង្ហាត់ដោយគ្រូមិនសូវមានសមត្ថភាពបាន។ នៅក្នុងប្រទេសឥណ្ឌា គម្រោង Digital Study Hall ផ្តល់ឌីសវីដេអូឌីជីថល ដែលថតការបង្រៀន ដែលធ្វើឡើងគ្រូជំនាញ ហើយយកទៅបង្ហាញ តាមរយៈការចាក់ DVD នៅតាមសាលារៀនជនបទ និងសាលារៀនក្នុងតំបន់ក្រីក្រ។ ការវាយតម្លៃ លើសាលារៀនចំនួន ៤ នៅរដ្ឋ Uttar Pradesh បានរកឃើញថា ៨ ខែក្រោយមក សិស្ស ៧២% ទទួលបានពិន្ទុតេស្តខ្ពស់ជាងមុន។

ការច្នៃប្រឌិតថ្មី ដោយប្រើប្រាស់បច្ចេកវិទ្យា អាចជួយលើកកម្ពស់ការរៀនសូត្រ តាមរយៈការធ្វើឱ្យការអនុវត្ត កម្មវិធីសិក្សារបស់គ្រូមានភាពសម្បូរបែប និងលើកទឹកចិត្តឱ្យមានភាពបត់បែន នៅក្នុងការរៀនសូត្ររបស់សិស្ស។ ការមានលទ្ធភាពប្រើប្រាស់កុំព្យូទ័រជាងមុន នៅតាមសាលារៀននានា ក៏អាចជួយកាត់បន្ថយគម្លាតឌីជីថល រវាងក្រុមដែល មានចំណូលទាប និងក្រុមដែលមានចំណូលខ្ពស់ផងដែរ។ ប៉ុន្តែបច្ចេកវិទ្យាថ្មី មិនមែនជំនួសឱ្យការបង្រៀនដែលល្អនោះទេ។

សមត្ថភាពរបស់គ្រូ ក្នុងការប្រើប្រាស់ ICT ជាធនធានសម្រាប់ការអប់រំ បំពេញតួនាទីយ៉ាងសំខាន់ នៅក្នុងការលើកកម្ពស់ការរៀនសូត្រ។ ការសិក្សាមួយ ដែលធ្វើឡើងនៅក្នុងប្រទេសប្រេស៊ីល បានរកឃើញថា ការបង្កើតបន្ទប់កុំព្យូទ័រ តាមសាលារៀន មានផលប៉ះពាល់ជាអវិជ្ជមានមកលើលទ្ធផលសិក្សារបស់សិស្ស ប៉ុន្តែការប្រើប្រាស់អ៊ីនធឺណិតរបស់គ្រូជាធនធានគរុកោសល្យ បានគាំទ្រដល់ការបង្រៀន និងរៀនក្នុងថ្នាក់រៀនបែបច្នៃប្រឌិតថ្មី ដែលជាលទ្ធផលនាំឱ្យមានការកែ លំអពិន្ទុតេស្តរបស់សិស្ស។

កុមារមក ពីតាមក្រុមចំណូលទាប មិនសូវមានបទពិសោធន៍ជាមួយនឹង ICT ខាងក្រៅសាលារៀនឡើយ ដូច្នេះ ពួកគេអាចត្រូវការពេលយូរ ដើម្បីបន្សាំខ្លួនទៅនឹង ICT និងត្រូវការការគាំទ្របន្ថែមទៀត។ នៅក្នុងប្រទេសរ៉ាន់ដា សិស្ស ៧៩% ដែលប្រើប្រាស់កុំព្យូទ័រនៅតាមសាលាមធ្យមសិក្សា ធ្លាប់ប្រើ ICT និងអ៊ីនធឺណិតពីមុនមក នៅខាងក្រៅសាលា (ជាពិសេសនៅតាមអ៊ីនធឺណិតកាហ្វេ)។ ប៉ុន្តែ ក្មេងស្រី និងកុមារតាមជនបទចាញ់ ប្រៀបកុមារដទៃទៀត ដោយសារតែ ពួកគេមិនសូវបានចូលទៅអ៊ីនធឺណិតកាហ្វេ ឬមានធនធាន ICT ដទៃទៀត សម្រាប់ប្រើប្រាស់ នៅក្នុងសហគមន៍របស់ពួកគេឡើយ។

ចំណុចល្អមួយ សម្រាប់បង្កើនលទ្ធភាពប្រើប្រាស់ ICT សម្រាប់ការបង្រៀន និងរៀន គឺ "ការរៀនចល័ត" ពោលគឺ ការប្រើប្រាស់ទូរស័ព្ទដៃ និងឧបករណ៍អេឡិចត្រូនិចចល័តដទៃទៀត ដូចជា ម៉ាស៊ីនចាក់ MP3 ជាដើម។ នៅតាមជនបទ ក្នុងប្រទេសឥណ្ឌ កម្មវិធីក្រោយសាលា សម្រាប់កុមារមកពីគ្រួសារ ដែលមានចំណូលទាប បានប្រើប្រាស់ល្បែងតាមទូរស័ព្ទដៃ ដើម្បីជួយឱ្យកុមាររៀនភាសាអង់គ្លេស។ នេះនាំឱ្យមានការទទួលបានលទ្ធផលល្អប្រសើរនៅក្នុងការធ្វើតេស្តប្រកបនាមជាភាសាអង់គ្លេស ដែលគេប្រើប្រាស់ញឹកញាប់ជាពិសេស សម្រាប់កុមាររៀននៅថ្នាក់ខ្ពស់ៗ ដែលមានជំនាញជាមូលដ្ឋានរឹងមាំ។

នៅតាមកន្លែងដែលកុមាររៀនសូត្របានតិចតួចនិងឆាប់បោះបង់ចោលការសិក្សា កម្មវិធីឱកាសទី ២ អាចបង្រៀន ជំនាញជាមូលដ្ឋានដល់ពួកគេតាមរយៈការរៀនសូត្រជាវគ្គខ្លីៗ ដែលជាមធ្យោបាយមួយ សម្រាប់ពន្លឿនការរីកចម្រើន របស់កុមារ និងបង្កើនលទ្ធផលសិក្សាសម្រាប់ក្រុមដែលជួបប្រទះការលំបាក។ កម្មវិធីពន្លឿនការសិក្សាបែបនេះជាច្រើនបានបង្កើនលទ្ធផលសិក្សារបស់ក្រុមជួបប្រទះការលំបាក ដោយចំណាយពេលវេលាតិចជាងសាលារដ្ឋ ដែលផ្តល់ឱកាសឱ្យ ពួកគេអាចរៀនទាន់កុមារផ្សេងទៀត និងអាចចូលរៀនសារជាថ្មីនៅតាមសាលារដ្ឋ។ ជាធម្មតា ពួកគេទទួលបានប្រយោជន៍ ពីថ្នាក់រៀនដែលមានចំនួនសិស្សតិច និងពីគ្រូដែលនិយាយភាសាក្នុងមូលដ្ឋាន ដែលត្រូវបានជ្រើសរើសចេញពីក្នុងសហគមន៍ជុំវិញ។ ឧទាហរណ៍ នៅភាគខាងជើងប្រទេសហ្គាណា សិស្ស ៤៤% ក្នុងចំណោមសិស្សដែលបានចូល រៀនក្នុងកម្មវិធីពន្លឿនការសិក្សា និងបានចូលរៀននៅសាលាបឋមសិក្សាឡើងវិញបានទទួលពិន្ទុស្របតាមកម្រិតថ្នាក់របស់ពួកគេ នៅពេលដែលពួកគេរៀនថ្នាក់ទី ៤ បើធៀបជាមួយនឹង ៣៤% នៃសិស្សដទៃទៀត។

សាលាបឋមសិក្សារបស់រដ្ឋ ក៏អាចប្រើប្រាស់កម្មវិធីពន្លឿនការសិក្សា នៅក្នុងស្ថានភាព ដែលសិស្សភាគច្រើនហួសអាយុ សម្រាប់កម្រិតថ្នាក់របស់ពួកគេផងដែរ។ នៅក្នុងប្រទេសប្រេស៊ីល សិស្សលើសអាយុពីថ្នាក់ទី ៥ ដល់ទី ៨ ទទួលបានការបង្រៀន តាមកម្មវិធីសិក្សា ដែលមានការកែប្រែជាច្រើន ដោយគ្របដណ្តប់លើសពីមួយថ្នាក់ នៅក្នុងរយៈពេល ១ ឆ្នាំ។ ជារួម ភាគរយសិស្សតាមសាលារៀន ដែលមានគម្លាតអាយុ ២ ឆ្នាំ ពីថ្នាក់របស់ពួកគេត្រូវបានកាត់បន្ថយពី ៤៦% នៅក្នុងឆ្នាំ ១៩៩៨ មក ៣០% នៅក្នុងឆ្នាំ ២០០៣។ នៅពេលដែលសិស្សត្រូវបានស្តារឱ្យរៀននៅកម្រិតថ្នាក់ត្រូវនឹងអាយុរបស់ពួកគេ ពួកគេអាចរក្សាបាននូវលទ្ធផលសិក្សារបស់ខ្លួន ហើយអត្រាឡើងថ្នាក់របស់ពួកគេ នៅសាលាមធ្យម គឺប្រហាក់ប្រហែលជាមួយនឹងសិស្សដទៃទៀតដែរ។


© Hugo Infante/UNESCO

## លើសពីចំណេះដឹងជាមូលដ្ឋាន ៖ ជំនាញដែលអាចផ្ទេរបានសម្រាប់ប្រជាពលរដ្ឋសកល

កម្មវិធីសិក្សា ចាំបាច់ត្រូវតែធានាថា កុមារ និងយុវជនទាំងអស់រៀនសូត្របាន មិនត្រឹមតែជំនាញជាមូលដ្ឋាន ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជំនាញដែលអាចផ្ទេរបាន ដូចជា ការគិតល្អិតល្អន់ការដោះស្រាយ បញ្ហា ការតស៊ូមតិ និងការដោះស្រាយវិវាទ ជាដើម ដើម្បីជួយឱ្យពួកគេក្លាយជាប្រជាពលរដ្ឋសកលប្រកបដោយការទទួលខុសត្រូវ។ គោលវិធីពហុ-ជំនាញ ដែលមានប្រើប្រាស់សកម្មភាពអប់រំ ដែលមានការអនុវត្តដោយផ្ទាល់ និងមានភាពពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន ក៏អាចអភិវឌ្ឍការយល់ដឹងរបស់សិស្សអំពីបរិស្ថាន និងកសាងនូវជំនាញ ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពផងដែរ។

ចន្លោះពីឆ្នាំ ១៩៩៩ ដល់ ២០០៤ ប្រទេសអាល្លឺម៉ង់បានដាក់ឱ្យអនុវត្តនូវកម្មវិធីពហុជំនាញមួយ ដែលបានជម្រុញ លើកកម្ពស់ឱ្យមានការរៀនសូត្រដោយមានការចូលរួម និងបានផ្តល់ឱកាសឱ្យសិស្សអាចធ្វើការងារជាមួយគ្នា នៅក្នុងគម្រោងដែលមានលក្ខណៈច្នៃប្រឌិតថ្មី ដើម្បីធានានិរន្តរភាពការរស់នៅរបស់ពួកគេ។ ការវាយតម្លៃមួយបានរកឃើញថា អ្នកចូលរួមមានការយល់ដឹងច្រើនជាងមុនអំពីការអភិវឌ្ឍប្រកបដោយនិរន្តរភាពបើធៀបជាមួយនឹងអ្នកដែលមិនបានចូល រួម ហើយមានសិស្សរហូតដល់ ៨០% បាននិយាយថាពួកគេបានទទួលជំនាញដែលអាចផ្ទេរបាន។ នៅអាហ្វ្រិចខាងត្បូង គំនិតផ្តួចផ្តើមមួយ ដែលផ្សារភ្ជាប់ទំនាក់ទំនងកម្មវិធីសិក្សា ជាមួយនឹងសកម្មភាព ដែលអាចអនុវត្តបាន ដូចជា ការប្រើប្រាស់ប្រព័ន្ធកែច្នៃសម្រាមសម្រាប់ប្រើប្រាស់ឡើងវិញ និងការប្រមូលទឹកទុកតាមសាលារៀនដោយប្រើប្រាស់ប្រភពថាមពលដទៃទៀត សម្រាប់ចំអិនអាហារ សំអាតទីសាធារណៈ បង្កើនសួនសម្រាប់ជនជាតិដើមភាគតិច និងដាំដើមឈើ។ សាលារៀន ដែលចូលរួមក្នុងគំនិតផ្តួចផ្តើមនេះបានរាយការណ៍ពីការកើនឡើងនូវការយល់ដឹងអំពីបរិស្ថាន និងការកែលំអសកម្មភាព ដែលនាំឱ្យមាននិរន្តរភាព នៅតាមសាលារៀន និងផ្ទះ។

**ប្រទេសហ្វីលីពីនបានដាក់បញ្ចូលការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ នៅក្នុងការអប់រំ**

ការផ្តល់ភាពអង់អាចដល់កុមារ តាមរយៈការប្រាស្រ័យទាក់ទង និងការតស៊ូមតិ អាចជួយពួកគេកាត់បន្ថយភាព ងាយរងគ្រោះរបស់ពួកគេចំពោះហានិភ័យបរិស្ថាន។ នៅក្នុងប្រទេសហ្វីលីពីន ដែលងាយទទួលរងគ្រោះមហន្តរាយបរិស្ថាន ការប្តេជ្ញាចិត្តយ៉ាងរឹងមាំមួយ ដើម្បីដាក់បញ្ចូលការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ទៅក្នុងការអប់រំ បានធ្វើឱ្យកុមារបំពេញតួនាទីយ៉ាងសកម្ម ក្នុងការធ្វើឱ្យសហគមន៍របស់ពួកគេមានសមត្ថភាពជាងមុន។

កម្មវិធីនានា ដែលផ្តោតសំខាន់លើការចូលរួម និងការដោះស្រាយវិវាទ ក៏អាចជួយលើកកម្ពស់សិទ្ធិរបស់បុគ្គល និង កសាងសន្តិភាពផងដែរ។ នៅក្នុងប្រទេសប៊ូរុនឌី នៅក្នុងឆ្នាំ ២០០៩ សាលាមធ្យមសិក្សាបានបង្រៀនជំនាញប្រាស្រ័យទាក់ទង និងជំនាញផ្សះផ្សារវិវាទ ដើម្បីជួយដល់ជនភៀសខ្លួន ដែលវិលត្រឡប់មកវិញ។ ២ ឆ្នាំក្រោយមក គ្រូ ដែលបាន ឆ្លងកាត់ការបណ្តុះបណ្តាល បានលះបង់ការធ្វើទារុណកម្មរាងកាយលើសិស្ស បញ្ហារំលោភបំពានផ្លូវភេទ និងអំពើពុករលួយ ត្រូវបានគេងាយលើកយកមកពិភាក្សាជាងមុន ទំនាក់ទំនងកាន់តែមានភាពប្រសើរជាងមុនរវាងសិស្ស និងសិស្ស និងគ្រូរបស់ពួកគេ ហើយសិស្សបំពេញនាទីជាអ្នកផ្សះផ្សារនៅក្នុងការដោះស្រាយវិវាទតូចតាច ដែលកើតឡើងនៅក្នុង សាលារៀន និងសហគមន៍របស់ពួកគេ។

# ប្រើប្រាស់សក្ដានុពលរបស់គ្រូ ដើម្បីដោះស្រាយវិបត្តិនៃការរៀនសូត្រ

របាយការណ៍នេះបង្ហាញពីកំណែទម្រង់នៃការបង្រៀនសំខាន់ៗជាងគេចំនួន ១០ ដែលអ្នកតាក់តែងគោលនយោបាយ គួរអនុវត្ត ដើម្បីសម្រេចឱ្យបាននូវការរៀនសូត្រប្រកបដោយសមធម៌ សម្រាប់ទាំងអស់គ្នា។

## 1 បំពេញកង្វះចំនួនគ្រូបង្រៀន

បើតាមនិន្នាការបច្ចុប្បន្ននេះ ប្រទេសមួយចំនួន នឹងមិនអាចបំពេញតម្រូវការចំនួនគ្រូបឋមសិក្សារបស់ខ្លួន នៅមុនឆ្នាំ២០៣០ ឡើយ។ បញ្ហាប្រឈមនេះរឹតតែមានទំហំធំធេងទៅទៀត សម្រាប់ការអប់រំ នៅកម្រិតផ្សេងទៀត។ ដូច្នេះ ប្រទេសទាំងឡាយ ចាំបាច់ត្រូវតែអនុវត្តគោលនយោបាយ ដែលចាប់ផ្ដើមដោះស្រាយចំណុចខ្វះខាត ដែលមានទំហំធំធេងនេះ។

## 2 ទាក់ទាញបេក្ខជនល្អបំផុតឱ្យបំពេញការងារបង្រៀន

ជាការសំខាន់ណាស់ ដែលកុមារគ្រប់រូបត្រូវមានគ្រូ ដែលមានគុណវឌ្ឍិយ៉ាងហោចណាស់ត្រឹមមធ្យមសិក្សា។ ដូច្នេះ រដ្ឋាភិបាលគួរវិនិយោគលើការបង្កើនលទ្ធភាពទទួលបានការអប់រំកម្រិតមធ្យមសិក្សាប្រកបដោយគុណភាព ដើម្បីពង្រីកចំនួនបេក្ខជនគ្រូបង្រៀន ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ កំណែទម្រង់នេះមានសារៈសំខាន់ជាពិសេស ប្រសិនបើគេ ចង់បង្កើនចំនួនគ្រូបង្រៀនជាស្ត្រី ដែលទទួលបានការអប់រំបានល្អ ឱ្យទៅបម្រើការងារតាមតំបន់ជួបប្រទះការលំបាក។ នៅតាមប្រទេសមួយចំនួននេះមានន័យថា គេត្រូវដាក់ឱ្យអនុវត្តនូវវិធានការជាវិជ្ជមាន ដើម្បីទាក់ទាញស្ត្រីឱ្យបានកាន់តែច្រើននាក់បន្ថែមទៀតចំពោះការងារ បង្រៀន។

អ្នកតាក់តែងគោលនយោបាយ ក៏ចាំបាច់ត្រូវផ្ដោតការយកចិត្តទុកដាក់លើការជ្រើស និងការបណ្ដុះបណ្ដាលគ្រូពីក្រុម ដែលមិនសូវមានតំណាង ដូចជា សហគមន៍ជនជាតិភាគតិច ជាដើម ដើម្បីឱ្យពួកគេទៅបម្រើការងារ នៅតាមសហគមន៍ របស់ពួកគេវិញ។ គ្រូបង្រៀនមួយចំនួន ដែលដឹងពីបរិបទវប្បធម៌ និងភាសាក្នុងមូលដ្ឋាន អាចបង្កើនឱកាសរៀនសូត្រដល់កុមារជួបប្រទះការលំបាកបាន។

## 3 បណ្ដុះបណ្ដាលគ្រូឱ្យបំពេញតម្រូវការរបស់កុមារទាំងអស់

គ្រូទាំងអស់ ចាំបាច់ត្រូវទទួលបានការបណ្ដុះបណ្ដាល ដើម្បីផ្ដល់លទ្ធភាពឱ្យពួកគេអាចបំពេញតម្រូវការនៃការរៀនសូត្ររបស់កុមារទាំងអស់។ មុនពេលដែលគ្រូចូលដល់ថ្នាក់រៀន ពួកគេគួរឆ្លងកាត់កម្មវិធីអប់រំគ្រូប្រកបដោយគុណភាពដែលបង្កើតនូវតុល្យភាពរវាងចំណេះដឹងមុខវិជ្ជាដែលត្រូវបង្រៀន និងចំណេះដឹងអំពីវិធីសាស្ត្របង្រៀន។

ការអប់រំគ្រូមុនចេញបម្រើការងារ ក៏គួរចាត់ទុកបទពិសោធន៍បង្រៀនក្នុងថ្នាក់ដែលមានកម្រិតគ្រប់គ្រាន់ ថាជាផ្នែកដ៏សំខាន់មួយនៃការបណ្ដុះបណ្ដាល ដើម្បីក្លាយជាគ្រូ ដែលមានសមត្ថភាពផងដែរ។ ការអប់រំប្រភេទនេះគួរផ្ដល់ឱ្យគ្រូនូវជំនាញអនុវត្ត ដើម្បីបង្រៀនកុមារឱ្យចេះអាន និងយល់ពីគណិតវិទ្យាជាមូលដ្ឋាន។ នៅក្នុងសង្គមដែលមានជនជាតិចម្រុះ គ្រូគួររៀនបង្រៀនភាសាលើសពីមួយ។ កម្មវិធីអប់រំគ្រូ ក៏គួររៀបចំគ្រូឱ្យចេះបង្រៀនថ្នាក់គួប និងកុមារមកពីច្រើនក្រុមអាយុ នៅក្នុងថ្នាក់រៀនតែមួយ និងយល់ពីរបៀបដែលឥរិយាបថរបស់គ្រូចំពោះយេនឌ័រផ្សេងៗគ្នា អាចមានផលប៉ះពាល់ លើលទ្ធផលនៃការរៀនសូត្រ។

ការបណ្ដុះបណ្ដាលបន្ត មានសារៈសំខាន់ ដើម្បីឱ្យគ្រូទាំងអស់អាចអភិវឌ្ឍ និងពង្រឹងជំនាញបង្រៀនរបស់ខ្លួនបាន។ ការបណ្ដុះបណ្ដាលបែបនេះក៏អាចផ្ដល់នូវគំនិតថ្មីៗ ដើម្បីគាំទ្រដល់សិស្សរៀនខ្សោយ ជាពិសេស នៅថ្នាក់ដំបូងៗ និងជួយឱ្យគ្រូសម្របទៅតាមការផ្លាស់ប្ដូរនានា ដូចជា កម្មវិធីសិក្សាថ្មី ជាដើម។

គោលវិធីថ្មីៗ ដូចជា ការអប់រំគ្រូពីចម្ងាយ ជាដើម គួបផ្សំនឹងការបណ្ដុះបណ្ដាល និងការជួយណែនាំផ្ទាល់ ក៏គួរលើកទឹកចិត្តឱ្យមានផងដែរ ដើម្បីពង្រីកការបណ្ដុះបណ្ដាលផង និងវិក្រឹតការផង ដល់គ្រូឱ្យបានកាន់តែច្រើននាក់។

## 4 រៀបចំគ្រូឧទ្ទេស និងអ្នកជួយណែនាំ ឱ្យចេះផ្ដល់ការគាំទ្រដល់គ្រូ

ដើម្បីធានាយ៉ាងណាឱ្យគ្រូអាចទទួលបានការបណ្ដុះបណ្ដាល ដែលល្អបំផុត ដើម្បីលើកកម្ពស់ការរៀនសូត្រសម្រាប់សិស្សទាំងអស់ជាការសំខាន់ណាស់ ដែលអ្នកផ្ដល់ការបណ្ដុះបណ្ដាលដល់គ្រូ មានចំណេះដឹង និងបទពិសោធន៍ជាមួយនឹង បញ្ហាប្រឈមក្នុងការបង្រៀននៅក្នុងថ្នាក់ពិតប្រាកដ និងរបៀបដោះស្រាយបញ្ហាទាំងនោះ។ ដូច្នេះ អ្នកតាក់តែងគោលនយោបាយគួរធានាយ៉ាងណាឱ្យគ្រូឧទ្ទេសទទួលបានការបណ្ដុះបណ្ដាល និងមានពិសោធន៍គ្រប់គ្រាន់ ជាមួយនឹងតម្រូវការនៃការរៀនសូត្រ ដែលជួបប្រទះដោយគ្រូ ដែលបង្រៀននៅក្នុងកាលៈទេសៈដែលមានការលំបាក។

ដើម្បីផ្តល់លទ្ធភាពឱ្យគ្រូ ដែលមានសមត្ថភាពថ្មីៗ អាចបម្លែងចំណេះដឹងបង្រៀន ទៅជាសកម្មភាព ដែលលើកកម្ពស់ការរៀនសូត្រសម្រាប់កុមារទាំងអស់ អ្នកតាក់តែងគោលនយោបាយគួររៀបចំឱ្យមានអ្នកចុះជួយណែនាំ ដែលបានឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវ ជួយឱ្យពួកគេសម្រេចលទ្ធផលនៅក្នុងរយៈពេលដំបូងនេះ។

## 5 ពង្រាយគ្រូទៅកាន់កន្លែង ដែលមានតម្រូវការគ្រូច្រើនបំផុត

រដ្ឋាភិបាល ចាំបាច់ត្រូវតែធានាយ៉ាងណាមិនត្រឹមតែឱ្យមានការជ្រើសរើស និងបណ្តុះបណ្តាល គ្រូដែលមាន សមត្ថភាពបំផុតប៉ុណ្ណោះទេ ថែមទាំងធានាឱ្យមានការពង្រាយគ្រូទៅតាមតំបន់ ដែលមានតម្រូវការគ្រូច្រើនបំផុតផងដែរ។ ការផ្តល់បៀវត្សឱ្យបានគ្រប់គ្រាន់ ប្រាក់ឧបត្ថម្ភ លំនៅដ្ឋានបានល្អ និងការគាំទ្រ ក្នុងទម្រង់ជាឱកាសអភិវឌ្ឍន៍វិជ្ជាជីវៈ គួរប្រើប្រាស់ ដើម្បីលើកទឹកចិត្តឱ្យគ្រូ ដែលឆ្លងកាត់ការបណ្តុះបណ្តាល ទទួលយកប៉ុស្តិ៍បង្រៀន នៅតាមតំបន់ជនបទ ឬតំបន់ជួបប្រទះការលំបាក។ លើសពីនេះរដ្ឋាភិបាលគួរជ្រើសរើសគ្រូពីក្នុងមូលដ្ឋានតែម្តង ហើយត្រូវផ្តល់ឱ្យពួកគេនូវការបំប៉នបន្ត ដើម្បីឱ្យកុមារគ្រប់រូប មិនថាពួកគេនៅទីណានោះទេ អាចរៀនជាមួយគ្រូ ដែលយល់ពីភាសា និងវប្បធម៌របស់ពួកគេ និងអាចជួយធ្វើឱ្យការរៀនសូត្ររបស់ពួកគេកាន់តែមានភាពល្អប្រសើរឡើង។

## 6 ប្រើប្រាស់រចនាសម្ព័ន្ធអាជីព និងបៀវត្សដែលមានការប្រកួតប្រជែង ដើម្បីរក្សាទុកគ្រូដែលមានសមត្ថភាពបំផុត

រដ្ឋាភិបាលគួរធានាយ៉ាងណាឱ្យគ្រូទទួលបានចំណូលយ៉ាងហោចណាស់ឱ្យបានគ្រប់គ្រាន់ ដើម្បីជួយគ្រួសាររបស់ ពួកគេឱ្យរួចផុតពីបន្ទាត់នៃភាពក្រីក្រ និងត្រូវធ្វើយ៉ាងណាឱ្យបៀវត្សរបស់ពួកគេ អាចប្រកួតប្រជែងបានជាមួយនឹងអាជីព ប្រហាក់ប្រហែលគ្នានេះ។ ការផ្តល់បៀវត្ស ទៅតាមលទ្ធផលការងារ គឺជាមធ្យោបាយ ដែលមានភាពទាក់ទាញ សម្រាប់ លើកទឹកចិត្តគ្រូឱ្យធ្វើការកែលំអការរៀនសូត្ររបស់សិស្ស។ ប៉ុន្តែ វាអាចជាការមិនលើកទឹកចិត្ត ដើម្បីឱ្យគ្រូយល់ព្រមបង្រៀនសិស្សដែលរៀនមិនសូវពូកែ សិស្សដែលជួបប្រទះការលំបាកក្នុងការរៀនសូត្រ ឬសិស្សដែលរស់នៅតាមសហគមន៍ក្រីក្រ នោះឡើយ។ ផ្ទុយទៅវិញ គេគួរប្រើប្រាស់រចនាសម្ព័ន្ធអាជីព និងបៀវត្ស ដែលមានភាពទាក់ទាញជាការលើកទឹកចិត្ត ឱ្យគ្រូទាំងអស់ធ្វើការកែលំអលទ្ធផលការងាររបស់ខ្លួន។ រចនាសម្ព័ន្ធបែបនេះ ក៏អាចប្រើប្រាស់ ដើម្បីផ្តល់ការទទួលស្គាល់ និងរង្វាន់ដល់គ្រូនៅតាមតំបន់ដាច់ស្រយាល និងគ្រូ ដែលផ្តល់ការគាំទ្រដល់ការរៀនសូត្ររបស់កុមារជួបប្រទះការលំបាកផងដែរ។

## 7 លើកកម្ពស់ការគ្រប់គ្រងគ្រូ ដើម្បីផ្តល់ប្រយោជន៍វិជ្ជមានដល់កម្រិតអតិបរមា

រដ្ឋាភិបាល គួរធ្វើការកែលំអគោលនយោបាយអភិបាលកិច្ច ដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងកំហុសឆ្គងរបស់គ្រូ ដូចជា អវត្តមាន ការបង្រៀនគួរសិស្ស និងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ។ រដ្ឋាភិបាលក៏អាចធ្វើការងារបន្ថែមទៀត ដើម្បី ដោះស្រាយបញ្ហាអវត្តមានគ្រូ តាមរយៈការកែលំអលក្ខខណ្ឌការងាររបស់គ្រូ ធានាយ៉ាងណាកុំឱ្យពួកគេមានបន្ទុកការងារច្រើនពេកជាមួយ នឹងការងារមិនបង្រៀននិងផ្តល់ឱ្យពួកគេនូវលទ្ធភាពទទួលបានការថែទាំសុខភាពឱ្យបានល្អ។ ចាំបាច់ត្រូវមានការដឹកនាំរឹងមាំក្នុងសាលារៀន ដើម្បីធានាយ៉ាងណាឱ្យគ្រូមានវត្តមានទាន់ពេលវេលា ធ្វើការងារពេញម៉ោង និងផ្តល់ ការគាំទ្រស្មើភាពគ្នាដល់កុមារគ្រប់រូប។ អ្នកដឹកនាំសាលារៀន ក៏ត្រូវការការបណ្តុះបណ្តាល ដើម្បីអាចផ្តល់ការគាំទ្រកម្រិតវិជ្ជាជីវៈដល់គ្រូបង្រៀនផងដែរ។

រដ្ឋាភិបាលចាំបាច់ត្រូវធ្វើការងារជាមួយគ្នាឱ្យបានជិតស្និទជាមួយនឹងសមាគមគ្រូ និងគ្រូ ដើម្បីតាក់តែងគោល-នយោបាយ និងអនុម័តលើក្រមសីលធម៌ ដើម្បីដោះស្រាយបញ្ហាឥរិយាបថមិនស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ដូចជា អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ជាដើម។ ក្រមសីលធម៌គួរលើកឡើងឱ្យ បានច្បាស់លាស់ពីអំពើហិង្សា និងការរំលោភបំពាននានា ដែលធ្វើឱ្យការដាក់ទោសវិន័យ មានសង្គតភាពស្របជាមួយនឹងក្របខ័ណ្ឌច្បាប់ស្តីពីសិទ្ធិកុមារ និងការការពារកុមារ។ នៅតាមកន្លែង ដែលមានករណីគ្រូបង្រៀនគួរច្រើន ចាំបាច់ត្រូវមានសេចក្តីណែនាំ ដែលមានភាពច្បាស់លាស់ ដោយមានការគាំទ្រពីច្បាប់ដើម្បីកុំឱ្យគ្រូលះបង់ពេលវេលាក្នុងថ្នាក់រៀន ដើម្បីបង្រៀនគួរជាលក្ខណៈឯកជនអំពីកម្មវិធីសិក្សាតាមសាលារៀន។

## 8 ផ្តល់ឱ្យគ្រូនូវកម្មវិធីសិក្សា ដែលមានលក្ខណៈច្នៃប្រឌិតថ្មី ដើម្បីឱ្យការរៀនសូត្រកាន់តែមានភាពល្អប្រសើរជាងមុន

គ្រូ ត្រូវការការគាំទ្រផ្នែកខាងយុទ្ធវិធីបង្រៀនក្នុងកម្មវិធីសិក្សាបែបបញ្ចូលគ្នា និងមានភាពបត់បែន ដែលរៀបចំឡើង ដើម្បីបំពេញតម្រូវការនៃការរៀនសូត្ររបស់កុមារ មកពីក្រុមជួបប្រទះការលំបាក។ ជាមួយនឹងការបំពាក់បំប៉នអំពីខ្លឹមសាររបស់កម្មវិធីសិក្សា និងវិធីសាស្រ្តសម្រាប់អនុវត្តកម្មវិធីសិក្សាគ្រូអាចកាត់បន្ថយគម្លាតនៃការរៀនសូត្របាន ដែលផ្តល់លទ្ធភាពឱ្យសិស្សរៀនខ្សោយអាចរៀនទាន់សិស្សដទៃទៀតបាន។

អ្នកតាក់តែងគោលនយោបាយគួរធានាយ៉ាងណាឱ្យកម្មវិធីសិក្សាសម្រាប់ឆ្នាំដំបូងៗ ផ្តោតការយកចិត្តទុកដាក់លើការធានាបាននូវជំនាញជាមូលដ្ឋានរឹងមាំសម្រាប់កុមារទាំងអស់ ហើយជំនាញទាំងនេះត្រូវបានបង្រៀនដោយប្រើប្រាស់ភាសា ដែលកុមារអាចយល់បាន។ ជាការសំខាន់ណាស់ដែលការរំពឹងទុកក្នុងកម្មវិធីសិក្សាអាចមានភាពសមស្របទៅតាមសមត្ថភាពរបស់អ្នករៀនសូត្រ ដោយសារតែកម្មវិធីសិក្សា ដែលមានមហិច្ឆតាខ្លាំងពេកអាចកំហិតនូវអ្វីដែលគ្រូអាចសម្រេចបាន ដើម្បីជួយកុមារឱ្យមានភាព ជឿនលឿន នៅក្នុងការសិក្សារបស់ពួកគេ។

ការធ្វើយ៉ាងណាឱ្យកុមារ ក្រៅសាលា ត្រឡប់មកសាលារៀន និងរៀនសូត្រដូចដើមវិញ គឺជាការងារមួយដ៏សំខាន់។ រដ្ឋាភិបាល និងទីភ្នាក់ងារផ្តល់ជំនួយ គួរផ្តល់ការគាំទ្រដល់កម្មវិធីពន្លឿនការសិក្សាឱកាសទី ២ ដើម្បីសម្រេចគោលដៅនេះ។

នៅតាមប្រទេសជាច្រើន វិទ្យុ ទូរទស្សន៍ កុំព្យូទ័រ និង បច្ចេកវិទ្យាចល័តកំពុងត្រូវបានប្រើប្រាស់ ដើម្បីបំពេញបន្ថែម និងកែលំអការរៀនសូត្ររបស់កុមារ។ គ្រូ នៅក្នុងការអប់រំទាំងក្នុងប្រព័ន្ធ ទាំងក្រៅប្រព័ន្ធ ចាំបាច់ត្រូវតែទទួលបានជំនាញ ដើម្បីបង្កើនជាអតិបរមានូវអត្ថប្រយោជន៍ដែលទទួលបានពីបច្ចេកវិទ្យា តាមបែបផែន ដែលជួយកាត់បន្ថយគម្លាត ឌីជីថល។

## 9 រៀបចំការវាយតម្លៃក្នុងថ្នាក់រៀន ដើម្បីជួយគ្រូចេះកំណត់រក និងផ្តល់ការគាំទ្រដល់សិស្សដែលប្រឈមនឹងការរៀនមិន ចេះ

ការវាយតម្លៃតាមថ្នាក់រៀន គឺជាឧបករណ៍សំខាន់ ដើម្បីកំណត់រក និងជួយដល់អ្នករៀនសូត្រ ដែលមានការ លំបាក។ គ្រូ ចាំបាច់ត្រូវទទួលបានការបណ្តុះបណ្តាលអំពីរបៀបប្រើប្រាស់ឧបករណ៍ទាំងនេះ ដើម្បីឱ្យពួកគេអាចកំណត់រក ឃើញការលំបាកក្នុងការរៀនសូត្រឱ្យបានឆាប់ និងប្រើប្រាស់យុទ្ធសាស្ត្រសមស្រប ដើម្បីដោះស្រាយការលំបាកទាំងនេះ។

ការផ្តល់សម្ភាររៀនសូត្រដល់កុមារ ដើម្បីឱ្យពួកគេចេះវាយតម្លៃភាពជឿនលឿនក្នុងការរៀនសូត្ររបស់ពួកគេ ដោយខ្លួនឯង និងការបណ្តុះបណ្តាលឱ្យគ្រូ ចេះគាំទ្រដល់ការប្រើប្រាស់ឧបករណ៍ទាំងនេះ អាចជួយឱ្យកុមារមានការរីក ចម្រើនបានយ៉ាងច្រើន នៅក្នុងការរៀនសូត្រ។ ការគាំទ្របន្ថែមដោយមានផ្តោតគោលដៅជាក់លាក់ តាមរយៈជំនួយការ បង្រៀន ឬអ្នកស្ម័គ្រចិត្តសហគមន៍ គឺជាមធ្យោបាយយ៉ាងសំខាន់មួយទៀតសម្រាប់លើកកម្ពស់ការរៀនសូត្ររបស់សិស្ស ដែលប្រឈមនឹងការរៀនមិនទាន់គេ។

## 10 ផ្តល់នូវទិន្នន័យកាន់តែប្រសើរអំពីគ្រូ ដែលបានឆ្លងកាត់ការបណ្តុះបណ្តាល

ប្រទេសនានា គួរវិនិយោគលើការប្រមូល និងការវិភាគទិន្នន័យប្រចាំឆ្នាំអំពីចំនួនគ្រូឆ្លងកាត់ការបណ្តុះបណ្តាល ដែលមាននៅទូទាំងប្រទេសរួមទាំងលក្ខណៈផ្សេងទៀតៗ ដូចជា យេនឌ័រ ជាតិពន្ធុ និងពិការភាព នៅគ្រប់ភូមិសិក្សាទាំងអស់។ ទិន្នន័យទាំងនេះគួរបំពេញបន្ថែម ដោយព័ត៌មានអំពីសមត្ថភាពរបស់កម្មវិធីអប់រំគ្រូ ដោយត្រូវមានការវាយតម្លៃលើ សមត្ថភាព ដែលគ្រូនឹងត្រូវទទួលបាន។ គេចាំបាច់ត្រូវបង្កើតនូវស្តង់ដា ដែលមានការឯកភាពជាអន្តរជាតិ សម្រាប់កម្មវិធី អប់រំគ្រូ ដើម្បីឱ្យមានការធានាភាពសមស្របជាមួយនឹងកម្មវិធីនៅប្រទេសដទៃទៀត។

ចាំបាច់ត្រូវមានការប្រមូលទិន្នន័យបន្ថែមទៀត និងកាន់តែប្រសើរជាងមុន នៅតាមប្រទេសដែលមានចំណូលទាប និងចំណូលមធ្យម ដើម្បីផ្តល់លទ្ធភាពឱ្យរដ្ឋាភិបាលនៅថ្នាក់ជាតិ និងសហគមន៍អន្តរជាតិ អាចធ្វើការតាមដានថាតើគ្រូទទួលបានបៀវត្សល្មមកម្រិតណា និងដើម្បីបង្កើនការយល់ ដឹងជាសកលអំពីភាពចាំបាច់ ដើម្បីផ្តល់បៀវត្សដល់ពួកគេឱ្យបាន ប្រសើរ។ ដើម្បីឱ្យមានការធានាភាពសមស្របជាមួយនឹងកម្មវិធីនៅប្រទេសដទៃទៀត។

## សេចក្តីសន្និដ្ឋាន

ដើម្បីបញ្ចប់វិបត្តិនៃការរៀនសូត្រ គ្រប់ប្រទេសទាំងអស់ ទាំងប្រទេសអ្នកមាន ទាំងប្រទេសអ្នកក្រ ត្រូវតែខិតខំធានាយ៉ាងណាឱ្យកុមារគ្រប់រូបមានឱកាសរៀនសូត្រជាមួយគ្រូ ដែលទទួលបានការបណ្តុះបណ្តាល និងការលើកទឹកចិត្តបានល្អ។ យុទ្ធសាស្ត្រទាំង ១០ ដែលបង្ហាញនៅទីនេះ គឺផ្អែកទៅតាមភស្តុតា អំពីគោលនយោបាយ កម្មវិធី យុទ្ធសាស្ត្រនានា ដែលទទួលបានជោគជ័យ នៅតាមបណ្តាប្រទេស និងបរិបទនៃការអប់រំជាច្រើន។ តាមរយៈការអនុវត្តកំណែទម្រង់ទាំង នេះ ប្រទេសនានាអាចផ្តល់ការធានាឱ្យកុមារ និងយុវជនទាំងអស់ ជាពិសេស កុមារ និងយុវជន ដែលជួបប្រទះការលំបាក ទទួលបានការអប់រំប្រកបដោយគុណភាពដែលពួកគេត្រូវការ ដើម្បីសម្រេចឱ្យបាននូវសក្តានុពលរបស់ពួកគេ និងមានជីវិតគួរជាទីគាប់ចិត្ត។



© Eva-Lotta Jansson/UNESCO

# ការបង្រៀន និងរៀន ៖
## សម្រេចឱ្យបាននូវគុណភាពសម្រាប់ទាំងអស់គ្នា

របាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ ២០១៣-២០១៤ បង្ហាញថា កង្វះការយកចិត្តទុកដាក់លើគុណភាពនៃការអប់រំ និងការខកខានមិនបានផ្តល់សេវាដល់កុមារដែលបាត់បង់ឱកាស បានរួមចំណែក នាំឱ្យមានវិបត្តិនៃការរៀនសូត្រ ដែលត្រូវការការយកចិត្តទុកដាក់ជាបន្ទាន់។ នៅទូទាំងសកលលោកទាំងមូល មានកុមារ ២៥០ លាននាក់ ដែលពួកគេជាច្រើននាក់មានប្រវត្តិជួបប្រទះការលំបាក មិនបានរៀនចេះចំណេះដឹងជាមូលដ្ឋាន ចុះទម្រាំជំនាញផ្សេងទៀត ដែលពួកគេត្រូវការ ដើម្បីទទួលបានការងារធ្វើសមរម្យ និងមានជីវិតរស់នៅជាទីគាប់ចិត្តនោះ។

របាយការណ៍ក្រោមចំណងជើងថា ការបង្រៀន និងរៀន ៖ សម្រេចឱ្យបាននូវគុណភាពសម្រាប់ទាំងអស់គ្នា រៀបរាប់ពីរបៀបដែលអ្នកតាក់តែងគោលនយោបាយ អាចផ្តល់ការគាំទ្រ និងធានានូវនិរន្តរភាពនៃប្រព័ន្ធអប់រំប្រកបដោយ គុណភាពសម្រាប់កុមារគ្រប់រូប មិនថាពួកគេមានប្រវត្តិបែបណានេះនោះឡើយ តាមរយៈការផ្តល់ឱ្យពួកគេនូវគ្រូ ដែល មានសមត្ថភាពបំផុត។ របាយការណ៍នេះក៏បង្ហាញផងដែរពីការថមថយនូវការផ្តល់ជំនួយ ដែលនាំឱ្យដើរថយក្រោយនូវ វឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅអប់រំ និងបង្ហាញពីរបៀបដែលបណ្តាប្រទេសនានាអាចបង្កើនថវិកាអប់រំ តាមរយៈការ កៀងគរធនធានក្នុងស្រុកឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

ខណៈពេលដែលសហគមន៍អន្តរជាតិត្រៀមរៀបចំគោលដៅអភិវឌ្ឍន៍ក្រោយឆ្នាំ ២០១៥ របាយការណ៍នេះបង្ហាញ ពីទល្លីករណ៍យ៉ាងសំខាន់ដើម្បីផ្តល់កន្លែងសំខាន់មួយដល់ការអប់រំ នៅក្នុងក្របខ័ណ្ឌសកល។ របាយការណ៍នេះបង្ហាញពី ភស្តុតាងទទួលបានពីជុំវិញពិភពលោកអំពីអានុភាពនៃការអប់រំជាពិសេស ការអប់រំក្មេងស្រី ដើម្បីជួយលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ កាត់បន្ថយភាពក្រីក្រ ជម្រុញកំណើនសេដ្ឋកិច្ច និងការពារបរិស្ថាន។

របាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា ត្រូវបានរៀបចំឡើង ដើម្បីផ្តល់ព័ត៌មាន មានឥទ្ធិពល និងធានានិរន្តរភាពនៃការប្តេជ្ញាចិត្តពិតប្រាកដ ក្នុងការសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នាឱ្យបានមុន ឆ្នាំ ២០១៥។ របាយការណ៍នេះពិនិត្យតាមដានវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅ នៅក្នុងប្រទេស និងដែនដីប្រមាណជា ២០០ និងជាឯកសារយោងយ៉ាងសំខាន់ សម្រាប់អ្នកតាក់តែងគោលនយោបាយអប់រំ អ្នកឯកទេសផ្នែកការអភិវឌ្ឍ អ្នកស្រាវជ្រាវ និងប្រព័ន្ធផ្សព្វផ្សាយ។

ខ្ញុំសម្រេចចិត្តធ្វើជាគ្រូ ដោយសារតែខ្ញុំជឿថាការអប់រំមានអំណាចធ្វើឱ្យមានការប្រែប្រួលនៅក្នុងសង្គម ដែលយើងរស់នៅ។ កត្តាដែលលើកទឹកចិត្តខ្ញុំឱ្យធ្វើជាគ្រូល្អម្នាក់ គឺខ្ញុំអាចក្លាយជាភ្នាក់ងារជំរុញសកម្មម្នាក់ នៅក្នុងបម្លាស់ប្តូរនេះដែលចាំបាច់បំផុតសម្រាប់ប្រទេសរបស់ខ្ញុំក្នុងការប្រយុទ្ធប្រឆាំងនឹងការរើសអើងភាពអយុត្តិធម៌ការរើសអើងពូជសាសន៍ អំពើពុករលួយ និងភាពក្រីក្រ។ ការទទួលខុសត្រូវរបស់យើងក្នុងនាមជាគ្រូមានទំហំធំធេង ហើយការប្តេជ្ញាចិត្តរបស់យើងដើម្បីផ្តល់នូវការអប់រំប្រកបដោយគុណភាព ត្រូវតែបន្តមានជារៀងរាល់ថ្ងៃ

- Ana ជាគ្រូបង្រៀន នៅប្រទេសពេរូ

កត្តា ដែលលើកទឹកចិត្តខ្ញុំឱ្យក្លាយជាគ្រូល្អម្នាក់ គឺការអាចប្រើប្រាស់ទេពកោសល្យរបស់ ខ្ញុំដើម្បីធ្វើឱ្យមានភាពខុសប្លែកគ្នាក្នុងជីវិតរបស់មនុស្សម្នាក់ទៀត។ វាគឺជាការបំពេញទៅតាមបំណងប្រាថ្នាក់ក្នុងការជម្រុញលើកទឹកចិត្តអ្នកដទៃឱ្យចេះកំណត់ពីអត្តសញ្ញាណផ្ទាល់ខ្លួនរបស់ពួកគេ និងក្លាយជាមនុស្សល្អបំផុត ដែលពួកគេអាចធ្វើបាន។

- Lea ជាគ្រូបង្រៀន នៅប្រទេសហ្វីលីពីន

កត្តា ដែលលើកទឹកចិត្តខ្ញុំ គឺការដឹងថាខ្ញុំមានអំណាចដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរអ្វីដែលបានកំណត់ទុកជាមុននូវជីវិតរបស់ប្រជាពលរដ្ឋក្រីក្របំផុតនៅក្នុងប្រទេសរបស់ខ្ញុំ។ ខ្ញុំចាត់ទុកការអប់រំថាជាឧបករណ៍តែមួយគត់ដើម្បីជួយដល់ពួកគេទាំងអស់គ្នា និងជាវិធីសាស្ត្រដែលមានសុពលភាពតែមួយគត់ដើម្បីសម្រេចនូវ “ជីវិតដែលគាប់ប្រសើរ”។

- Lea ជាគ្រូបង្រៀន Ecuador

កត្តា ដែលលើកទឹកចិត្តខ្ញុំ គឺការដឹងថាខ្ញុំមានអំណាចដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរអ្វីដែលបាន កំណត់ទុកជាមុននូវ ជីវិតរបស់ប្រជាពលរដ្ឋក្រីក្របំផុត នៅក្នុងប្រទេសរបស់ខ្ញុំ។ ខ្ញុំចាត់ទុកការអប់រំថាជាឧបករណ៍ តែមួយគត់ ដើម្បីជួយដល់ ពួកគេទាំងអស់គ្នា និងជាវិធីសាស្ត្រដែលមានសុពលភាពតែមួយគត់ ដើម្បីសម្រេច នូវ “ជីវិតដែលគាប់ប្រសើរ”។ ខ្ញុំជឿជាក់ថាមនុស្សគ្រប់រូបមានសិទ្ធិទទួលបានការអប់រំចេះអក្សរ ចេះលេខ និងចេះគិតល្អិតល្អន់។ ដើម្បីរៀនឱ្យបានចេះពិតប្រាកដខ្ញុំជឿថាមនុស្សគ្រប់រូបមានសិទ្ធិទទួលបានការងារធ្វើ និងបំពេញតម្រូវការខ្លួនឯងឱ្យបានគ្រប់គ្រាន់។ ខ្ញុំជឿថាប្រសិនបើខ្ញុំធ្វើអ្វីមិនបានល្អបំផុតដែលខ្ញុំអាចធ្វើបានមានន័យថាអ្វីនៅខាងលើមិនអាចកើតមានឡើងឡើយ។

- Laura ជាគ្រូបង្រៀន នៅចក្រភពអង់គ្លេស

ខ្ញុំចាត់ទុកខ្លួនខ្ញុំថាជាគ្រូល្អម្នាក់ដោយហេតុថាខ្ញុំមានគ្រូដែលល្អ ហើយខ្ញុំទទួលបានជោគជ័យនៅក្នុងការសិក្សា និងអាជីពការងាររបស់ខ្ញុំ។ ខ្ញុំដឹងថា ប្រសិនបើអ្នកណាម្នាក់បានបង្រៀនខ្ញុំឱ្យទទួលបានជោគជ័យបែបនេះ ខ្ញុំអាចប្រើប្រាស់បំណងប្រាថ្នាក់ និងជំនាញដូចគ្នានេះដើម្បីជួយដល់អ្នកដទៃទៀត។

- Fwanshishak ជាគ្រូបង្រៀន នៅប្រទេសនីហ្សេរីយ៉ា

UNESCO
United Nations
Educational, Scientific and
Cultural Organization

UNESCO
Publishing

EFA GMR
EDUCATION FOR ALL GLOBAL MONITORING REPORT

www.unesco.org/publishing
www.efareport.unesco.org